**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# សេរីភាពបញ្ចេញមតិ

# (ករណីសិក្សាប្រៀបធៀបកម្ពុជា-ជប៉ុន)

ស្រាវជ្រាវពីថ្ងៃទី ៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក.ឆួន ពុទ្ធារ៉េខ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី២១ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ធូន ពុទ្ធារ៉ង** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ថ្នាក់អាហារូបករណ៍ ជំនាន់ទី២១ ថ្នាក់L4A5 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០១២-២០១៧។

នាងខ្ញុំបានសម្រេចនូវសមិទ្ធិផល នៃការសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ "**សេរីភាពបញ្ចេញមតិ (ករណីសិក្សាប្រៀបធៀបកម្ពុជា-ជប៉ុន)**" បានដោយជោគជ័យ។ ការសម្រេចបានជាសមិទ្ធិផលមួយនេះ គឺដោយសារតែមាននូវកត្តាជម្រុញ និងគាំទ្រជាច្រើន។

ជាបឋម នាងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ**អ្នកមានគុណទាំងពីរ** ដែលលោកបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត មិនថាត្រូវជួបការនឿយហត់លំបាកយ៉ាងណា ក៏លោកនៅតែអត់ធ្មត់តស៊ូ ចិញ្ចឹមបីបាច់ថែរក្សាកូន អប់រំប្រៀនប្រដៅ ជាពិសេសគឺផ្តល់ឱកាសឱ្យកូនបានទទួលនូវការសិក្សាជាចំណេះដឹង រហូតបានសម្រេចនូវសមិទ្ធិផលបញ្ចប់ថ្នាក់បរិញ្ញាប័ត្រមួយនេះ។

ជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមគោរពថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ រួមទាំងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំបំពេញការងារ ទាំងការបង្រៀន អប់រំផ្តល់ចំណេះដឹងសព្វគ្រប់បែបយ៉ាង។ ជាពិសេស នាងខ្ញុំសូមសម្តែងនូវសេចក្តីដឹងគុណជូនចំពោះ លោកសាស្ត្រាចារ្យ **បណ្ឌិត ឈុន ណារ៉េត** ដែលជាសាស្ត្រាចារ្យដឹកនាំ ដោយលោកបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្តល់ជាដំបូន្មាន គំនិតពិចារណា ក៏ដូចជា តម្រែតម្រង់ ត្រួសត្រាយផ្លូវដើម្បីសម្រេចបាននូវសមិទ្ធិផលមួយនេះ។

នាងខ្ញុំក៏សូមអរគុណយ៉ាងក្រៃលែងចំពោះ **សាស្ត្រាចារ្យ បុគ្គលិកទាំងអស់នៃមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន (CJL)** ដែលបានបង្ហាត់បង្រៀន ផ្តល់ដំបូន្មានដល់នាងខ្ញុំនូវចំនេះដឹង និងបទពិសោធន៍ជាច្រើន ប្រកបដោយគុណប្រយោជន៍ ជាពិសេសទាក់ទងនឹងការសិក្សាស្រាវជ្រាវដែលនាងខ្ញុំមិនធ្លាប់បានសិក្សាពីមុនមក។

នៅទីបញ្ចប់ នាងខ្ញុំសូមជូនពរដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ ទទួលបាននូវសេចក្តីសុខ សេចក្តីចម្រើន ប្រកបដោយភាពជោគជ័យនូវរាល់គ្រប់ភារកិច្ចការងារ និងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

សារណានេះ អាចសម្រេចបានដោយជោគជ័យ គឺដោយសារការសិក្សាទៅលើផ្នែកនីតិសាស្ត្ររយៈពេល៤ឆ្នាំ នៅសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាមួយនឹងមជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន (CJL)។

សារណានេះ ត្រូវបានតាក់តែងឡើងក្នុងគោលបំណងចែករំលែកនូវចំណេះដឹង ការសិក្សាស្រាវជ្រាវ គំនិតវិភាគ ត្រិះរិះពិចារណា ដែលទទួលបានពីការសិក្សាកន្លងមក។ ជាពិសេស គឺដើម្បីចែករំលែកដល់អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ដែលមានបំណងស្វែងយល់បន្ថែមអំពីប្រធានបទសិទ្ធិមនុស្ស ដោយផ្តោតសំខាន់លើសេរីភាពបញ្ចេញមតិ។ តាមរយៈសារណាមួយនេះ អ្នកសិក្សាស្រាវជ្រាវ អាចទទួលបានជាគំនិតបន្ថែម ច្បាស់លាស់ និងស៊ីជម្រៅលើអ្វីដែលបានដឹងពីមុន ទាក់ទិននឹងអត្ថន័យ បទដ្ឋានគតិយុត្ត បញ្ហាប្រឈមផ្សេងៗនៃសេរីភាពបញ្ចេញមតិដែលមានក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន។ សារណានេះ ត្រូវបានសម្រិតសម្រាំងឡើងដោយផ្តោតសំខាន់ជាពិសេសលើការវិភាគអំពីបញ្ហា ដែលក្នុងនោះមានបញ្ហានៃការអនុវត្តជាក់ស្តែង និងជាពិសេសបញ្ហាគតិយុត្តដែលជាអ្វីដែលអ្នកសិក្សាច្បាប់គួរស្វែងយល់។

ការស្រាវជ្រាវទៅលើប្រធានបទមួយនេះ មិនមានបំណងអ្វីក្រៅពីការចង់ចែករំលែកទៅកាន់អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ឱ្យទទួលបាននូវចំណេះដឹង និងជាឯកសារស្រាវជ្រាវលើកៗក្រោយទៀត ក៏ដូចជាចូលរួមបង្កើន និងអភិវឌ្ឍនូវការស្រាវជ្រាវក្នុងប្រទេសកម្ពុជា ជាពិសេស គឺការស្រាវជ្រាវផ្នែកនីតិសាស្ត្រនេះតែម្តង។ ព្រោះថា ដើម្បីជាបច្ច័យក្នុងការបង្កើនគុណភាពអប់រំតាមរយៈការស្រាវជ្រាវដ៏សម្បូរបែបមួយ និងផ្តល់ជាឱកាសក្នុងការស្វែងរកនូវចំនុចខ្លាំង និងចំនុចខ្សោយដែលកម្ពុជាមាន ឈានទៅរកនូវដំណោះស្រាយដើម្បីកែតម្រូវ និងធ្វើឱ្យមានការអភិវឌ្ឍ រីកចម្រើន ក្នុងនាមជាប្រទេសនីតិរដ្ឋ។

ទោះបីជាខិតខំ និងយកចិត្តទុកដាក់ក្នុងការសម្រេចឱ្យបានយ៉ាងណាក៏ដោយ នាងខ្ញុំជឿជាក់ថា សារណាមួយនេះមិនមានភាពល្អឥតខ្ចោះទាំងស្រុងដោយគ្មានភាពខ្វះចន្លោះ និងកំហុសឆ្គងនោះទេ។ ហេតុនេះ នាងខ្ញុំសូមអភ័យទោសទុកជាមុនចំពោះកំហុសដែលបានកើតឡើងដោយប្រការណាមួយ និងព្រមទទួលយកនូវរាល់ការរិះគន់ក្នុងន័យស្ថាបនា កែលម្អ ទៅលើអត្ថន័យខ្លឹមសារនៃសារណាមួយនេះ ដើម្បីជាគុណប្រយោជន៍ឱ្យសារណាមួយនេះ កាន់តែមាននូវភាពល្អប្រសើរច្បាស់លាស់និងត្រឹមត្រូវបន្ថែមទៀត៕

## មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី ១ អំពី សេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា** .................... ៧

**១.១. ប្រវត្តិ និងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា**.............៧

១.១.១. ប្រវត្តិនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា ...................... ៧

១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ (១៩៤៧~១៩៧០) ......... ៧

១.១.១.២. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ (១៩៧២~១៩៧៥) ................. ៨

១.១.១.៣. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ (១៩៧៥~១៩៧៩)................. ៩

១.១.១.៤. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩~១៩៨១)...... ១០

១.១.១.៥. រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា (១៩៨៩~១៩៩២).......................... ១០

១.១.២. សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា .................១១

១.១.២.១. និយមន័យ ..................................................១១

១.១.២.២. ប្រភេទ ......................................................១២

**១.២. បទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា** ........................១៣

១.២.១. បទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិ.......................... ១៤

១.២.១.១. ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ................................. ១៤

១.២.១.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ........................... ១៥

១.២.១.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ......... ១៥

១.២.២. បទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិ..............................១៧

១.២.២.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន .......................១៧

១.២.២.២. ច្បាប់ស្តីពីរបបសារព័ត៌មាន ........................................១៨

១.២.២.៣. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី..............................២០

១.២.២.៤. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា..............................២១

១.២.២.៥. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ........................ ២២
**១.៣. បញ្ហាប្រឈម និងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា** ២៣
១.៣.១. បញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិ ........................................ ២៤
១.៣.១.១. បញ្ហាគតិយុត្តនៃកង្វះស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការកាត់ក្តីបញ្ហារំលោភសេរីភាពបញ្ចេញមតិ .................................................. ២៥
១.៣.១.២. បញ្ហាគតិយុត្តមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាន.............. ២៧
ក. និយមន័យពាក្យ "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ"............ ២៧
ខ. ធម្មនុញ្ញភាពនៃមាត្រា១២ច្បាប់ស្តីពីរបបសារព័ត៌មាន ................ ២៨
១.៣.១.៣. បញ្ហាអនុវត្តជាក់ស្តែងនៃអ្នកសារព័ត៌មាន ........................ ៣១
ក. បញ្ហាឯករាជភាពនៃអ្នកសារព័ត៌មាន ........................................ ៣២
ខ. បញ្ហាវិជ្ជាជីវៈអ្នកសារព័ត៌មាន .................................................. ៣៣
១.៣.២. ដំណោះស្រាយបញ្ហាសេរីភាពបញ្ចេញមតិ ................................ ៣៣
១.៣.២.១. ការពិចារណាលើស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការកាត់ក្តីបញ្ហាសេរីភាពបញ្ចេញមតិ ...................................................................... ៣៣
១.៣.២.២. មាត្រា១២ច្បាប់ស្តីពីរបបសារព័ត៌មាន ................................ ៣៤
ក. និយមន័យវាក្យសព្ទគតិយុត្ត "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ".. ៣៤
ខ. ធម្មនុញ្ញភាពនៃមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាន ................ ៣៥
១.៣.២.៣. បញ្ហាអនុវត្តជាក់ស្តែងនៃអ្នកសារព័ត៌មាន ........................ ៣៦
ក. ឯករាជភាពនៃអ្នកសារព័ត៌មាន .................................................. ៣៦
ខ. វិជ្ជាជីវៈអ្នកសារព័ត៌មាន ........................................................ ៣៦
**ជំពូកទី ២ អំពី សេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន**................................ ៣៨
**២.១. ប្រវត្តិ និងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន**........... ៣៨
២.១.១. ប្រវត្តិនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន ........................ ៣៨
២.១.១.១. រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន ................................................ ៣៨
២.១.១.២. រដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្ន .................................................. ៤០

២.១.២. សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន .................. ៤២
២.១.២.១. និយមន័យ ........................................................ ៤២
២.១.២.២. អត្ថន័យ ......................................................... ៤២
២.១.២.៣. ប្រភេទ .......................................................... ៤៣
ក. សិទ្ធិទទួលបានព័ត៌មាន ............................................. ៤៤
ខ. សេរីភាពខាងសារព័ត៌មាន ............................................ ៤៥
គ. សេរីភាពបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត ......................... ៤៦
ឃ. សេរីភាពបញ្ចេញមតិទាក់ទងទៅនឹងសិទ្ធិបុគ្គល និងរូបភាពអាសអាភាស ៤៦
ង. សេរីភាពបញ្ចេញមតិលើវិស័យជំនួញ ................................. ៤៧
ច. សេរីភាពក្នុងការជួបជុំ ការបង្កើតសមាគម ............................. ៤៧
**២.២. បទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន** ........................... ៤៨
២.២.១. បទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិ ........................ ៤៨
២.២.២. បទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន .............. ៤៨
២.២.២.១. ច្បាប់ស្តីការបើកចំហរព័ត៌មាននៃស្ថាប័នរដ្ឋបាល ................... ៤៩
២.២.២.២. ច្បាប់ស្តីពីការផ្សព្វផ្សាយ ........................................ ៤៩
២.២.២.៣. ក្រមព្រហ្មទណ្ឌ .................................................. ៥០
២.២.២.៤. ច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋ ................ ៥១
២.២.២.៥. ច្បាប់ស្តីពីការការពារសកម្មភាពដែលបង្កឱ្យមានការបំផ្លាញ .......... ៥២
២.២.២.៦. ច្បាប់ស្តីពីការលុបបំបាត់សកម្មភាពរើសអើងទៅនឹងជនជាតិបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន ........................................ ៥៣
**២.៣. បញ្ហាប្រឈម និងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន** ៥៣
២.៣.១. បញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិ ........................................ ៥៤
២.៣.១.១. បញ្ហាគតិយុត្តនៃច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋ. ៥៤
២.៣.១.២. បញ្ហាគតិយុត្ត និងបញ្ហាជាក់ស្តែងនៃឯករាជភាពស្ថាប័នសារព័ត៌មាន.... ៥៥

២.៣.១.៣. បញ្ហាជាក់ស្តែងនៃការប្រើពាក្យរិះគន់ក្នុងន័យរើសអើងពូជសាសន៍ ... ៥៧

២.៣.១.៤. បញ្ហាជាក់ស្តែងនៃការកម្រិតសេរីភាពក្នុងការធ្វើបាតុកម្ម ............ ៥៨

២.៣.១.៥. បញ្ហាជាក់ស្តែងនៃការបង្កើតសមាគម.............................. ៥៨

២.៣.២. ដំណោះស្រាយបញ្ហាសេរីភាពបញ្ចេញមតិ ................................ ៥៩

២.៣.២.១. ច្បាប់ស្តីពីការរក្សាអាថ៌កំបាំងពិសេសរបស់រដ្ឋ ........................ ៥៩

២.៣.២.២. ឯករាជភាពស្ថាប័នសារព័ត៌មាន ..................................... ៥៩

២.៣.២.៣. ការប្រើពាក្យរិះគន់ក្នុងន័យរើសអើងពូជសាសន៍.................... ៦០

២.៣.២.៤. ការធ្វើបាតុកម្ម និងការបង្កើតសមាគម ............................ ៦០

២.៣.២.៥. ការបង្កើតសមាគម ................................................ ៦១

**សេចក្តីសន្និដ្ឋាន** .............................................................. ៦២

**អនុសាសន៍** ................................................................. ៦៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១** សេចក្តីព្រាងបឋម ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

**ឧបសម្ព័ន្ធទី២** កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពីសេរីភាព បញ្ចេញមតិ

**ឧបសម្ព័ន្ធទី៣** របាយការណ៍របស់អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិទាក់ទងនឹង ការព្រួយបារម្ភណ៍ចំពោះបញ្ហាឯករាជភាពស្ថាប័នសារព័ត៌មានប្រទេស ជប៉ុន

# សេចក្តីផ្តើម

# សេចក្តីផ្តើម

សេរីភាពបញ្ចេញមតិ គឺជាសិទ្ធិមនុស្សមូលដ្ឋានដែលមានសារៈសំខាន់ខ្លាំងបំផុត។ សេរីភាពនេះ គឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សដទៃទៀត មានន័យថាប្រសិនបើគ្មានសេរីភាពបញ្ចេញមតិនេះទេ សិទ្ធិមនុស្សសំខាន់ៗដទៃទៀតក៏មិនអាចមានដែរ។ គណៈកម្មាធិការសិទ្ធិមនុស្សដែលជាអ្នកឃ្លាំមើលកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានថ្លែងថា សេរីភាពបញ្ចេញមតិ គឺជាលក្ខខណ្ឌសំខាន់ចាំបាច់មួយក្នុងការទទួលស្គាល់គោលនយោបាយតម្លាភាព និងគណនេយ្យភាពដែលជាលទ្ធផលមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស[1]។ សារៈសំខាន់ និងតម្លៃនៃសេរីភាពមួយនេះ ជាតម្រូវការមិនអាចខ្វះបានសម្រាប់ប្រជាពលរដ្ឋទូទៅ ជាពិសេសសម្រាប់ប្រជាពលរដ្ឋនៃប្រទេសសេរី ដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងឱ្យតម្លៃទៅលើសិទ្ធិមនុស្សជាធំ។ តម្រូវការមួយនេះពិតជាចាំបាច់ណាស់ ព្រោះថាក្នុងការរស់នៅក្នុងសង្គមមួយ មនុស្សត្រូវការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក។ តាមរយៈការធ្វើប្រាស្រ័យទាក់ទងគ្នា មនុស្សធ្វើការបញ្ចេញនូវការយល់ឃើញ អារម្មណ៍ផ្សេងៗដែលមាននៅក្នុងចិត្តរបស់គេ ចេញមកខាងក្រៅបង្ហាញទៅកាន់អ្នកដទៃទៅតាមអ្វីដែលគេចង់បញ្ចេញ។ ក្នុងសង្គមប្រជាធិបតេយ្យមួយ មាននូវរឿងជាច្រើនមិនថាជារឿងនយោបាយ សេដ្ឋកិច្ច សង្គមកិច្ចជាដើមនោះទេ ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្គមមួយនោះ ធ្វើការបញ្ចេញការយល់ឃើញ ចំណាប់អារម្មណ៍ ការពេញចិត្ត មិនពេញចិត្ត ការគាំទ្រឬប្រឆាំងផ្សេងៗ។ មិនត្រឹមតែការបញ្ចេញនូវអ្វីដែលមនុស្សយល់ឃើញប៉ុណ្ណោះទេ អ្វីដែលសំខាន់ជាងនេះទៅទៀតនោះ គឺការបញ្ចេញនូវអ្វីដែលជាការទាមទារជាសេចក្តីត្រូវការ ការស្នើសុំ ទៅលើរឿងអ្វីមួយដែលគេយល់ថាជាតម្រូវការរបស់ពួកគេទៅកាន់សង្គម។ សកម្មភាពទាំងនេះហើយជាសេរីភាពបញ្ចេញមតិ និងជាអ្វីដែលត្រូវតែមានក្នុងសង្គមប្រជាធិបតេយ្យមួយ ហើយដែលរដ្ឋនៃសង្គមប្រជាធិបតេយ្យមួយត្រូវតែផ្តល់ឱ្យទៅប្រជាពលរដ្ឋរបស់ពួកគេនូវសេរីភាពមួយនេះ។ គួរបន្ថែមផងដែរថា ក្នុងការផ្តល់ឱ្យប្រជាពលរដ្ឋនូវសេរីភាពបញ្ចេញមតិនេះ គឺមាននូវទំនាក់ទំនងសំខាន់ជាច្រើន។ ទំនាក់ទំនងនោះគឺ ទាក់ទងទៅនឹងការផ្តល់ឱ្យនូវ សេវាព័ត៌មានសាធារណៈ និងសេរីភាពសារព័ត៌មាន។ ដើម្បីអាចដឹង និងទទួលបាននូវអ្វីថ្មីៗ ឬអ្វីដែលមានក្នុងសង្គមមុននឹងធ្វើការបញ្ចេញមតិ ប្រជាពលរដ្ឋចាំបាច់ត្រូវទទួលបាននូវព័ត៌មាន ហើយព័ត៌មាននោះជាព័ត៌មានដែលរដ្ឋផ្តល់ឱ្យពួកគេ។ ក្នុងនោះដែរ មិនមែនតែជាព័ត៌មានដែលជាការផ្សាយពីស្ថានីយវិទ្យុ ទូរទស្សន៍ជាដើមមួយមុខនោះទេ ព័ត៌មានដែលរដ្ឋ ពោលគឺ

[1] កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, សេរីភាពបញ្ចេញមតិ, (ខែកុម្ភៈ ឆ្នាំ២០១៣), ទំព័រ២

ស្ថាប័នរដ្ឋខ្លួនឯងផ្ទាល់ត្រូវផ្តល់ទៅប្រជាពលរដ្ឋ។ រដ្ឋមានតួនាទីបង្ហាញព័ត៌មានជូនប្រជាពលរដ្ឋនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងការងារ ដំណើរការរបស់រដ្ឋដែលប្រជាពលរដ្ឋមានសិទ្ធិដឹង។ ជារួម ភ្ជាប់ជាមួយនឹងសេរីភាពបញ្ចេញមតិ មាននូវសិទ្ធិសេរីភាពសំខាន់ចំនួន២ទៀតដែលទាក់ទង គឺ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។

បើក្រឡេកមើលទៅលើប្រវត្តិសាស្ត្រ ការកើតឡើងដំបូងនៃសេរីភាពបញ្ចេញមតិនេះវិញ ឃើញថាមានទំនាក់ទំនងជាមួយនឹងកំណាក់ំណើតនៃសិទ្ធិមនុស្ស។ ពាក្យថាសិទ្ធិមនុស្ស ត្រូវបានលេចចេញដំបូងគេក្នុងក្រមនៃសិទ្ធិវ៉ាជីនា (Virginia Code) របស់អាមេរិកខាងជើង ក្នុងឆ្នាំ១៧៧៦[2]។ ប៉ុន្តែ ការលេចចេញជារូបរាងពិតប្រាកដនៃសិទ្ធិរបស់មនុស្សនោះ គឺចាប់កកើតឡើងក្នុងប្រទេសអង់គ្លេសដែលពេលនោះ ប្រទេសអង់គ្លេសបានទទួលស្គាល់នូវសិទ្ធិមនុស្ស ដោយផ្តាច់ចេញពីការស្ថិតក្រោមការគ្រប់គ្រងរបស់ស្តេចតទៅទៀត ពោលគឺ មនុស្សកើតមកមានសិទ្ធិរបស់ពួកគេស្មើគ្នាៗតាំងពីកំណើត។ ឆ្លងកាត់ប្រវត្តិសាស្ត្រជាច្រើនឆ្នាំមក ការវិវត្តនៃការផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋអង់គ្លេសកាន់តែមានការផ្លាស់ប្តូរទូលាយទៅៗ ហើយការវិវត្តនៃសិទ្ធិនេះ សង្កេតឃើញមាន ការហាមឃាត់មិនឱ្យយកពន្ធពីប្រជាពលរដ្ឋដោយមិនមានការសម្រេចពីសភា ការហាមឃាត់មិនឱ្យមានការចាប់ខ្លួន ឬឃុំខ្លួនដោយមិនមានការសម្រេចពីតុលាការជាដើម រហូតដល់មាននូវការផ្តល់សិទ្ធិអរូបីដែលមានដូចជាសិទ្ធិមានទ្រព្យសម្បត្តិ និងសេរីភាពបញ្ចេញមតិនេះជាដើម។ ក្រោយៗមក មានការទាមទារនូវសិទ្ធិសេរីភាពរបស់មនុស្សកាន់តែច្រើនឡើងៗ ដែលគេឃើញមាននូវការធ្វើបដិវត្តដើម្បីសេរីភាពនៅប្រទេសអង់គ្លេស សហរដ្ឋអាមេរិក និងប្រទេសបារាំងជាដើម។ តាមរយៈការទាមទារទាំងអស់នេះ បានធ្វើឱ្យមនុស្សទទួលបាននូវសិទ្ធិសេរីភាពរបស់ពួកគេបន្តិចម្តងៗ ហើយការទាមទារទាំងអស់នេះត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ និងត្រូវបានធានា ដោយចាត់ទុកថាជាសេរីភាពបញ្ចេញមតិដែលជាសិទ្ធិមូលដ្ឋានមួយរបស់មនុស្ស។

ដោយឡែក បើយើងក្រឡេកមើលនាពេលបច្ចុប្បន្ននេះ ការឱ្យតម្លៃទៅលើសិទ្ធិមនុស្សត្រូវបានយកចិត្តទុកដាក់ខ្លាំងពីបណ្តាប្រទេសសេរីជាច្រើននៅលើសកលលោក។ ព្រមជាមួយគ្នានេះដែរ មិនថាប្រទេសកម្ពុជា ឬក៏ប្រទេសជប៉ុន គឺសុទ្ធសឹងតែជាប្រទេសដែលប្រកាន់យករបបនយោបាយសេរី ឱ្យតម្លៃលើការគោរពសិទ្ធមនុស្សជាធំ។ ប៉ុន្តែទោះជាយ៉ាងណា ប្រទេសទាំងពីរ

---

[2] 高橋和之『立憲主義と日本国憲法　第 2 版』（有斐閣、2010 年）、66 頁
ថាកាហាស៊ិ កាហ្ស៊ុយឹគី, របបអាស្រ័យរដ្ឋធម្មនុញ្ញនិងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន បោះពុម្ពលើកទី២, (រោងពុម្ពយឺហ៊ិកាគឺ ,២០១០), ទំព័រ៦៦

ស្ថិតក្នុងលំដាប់ពីរផ្សេងគ្នា បើប្រៀបធៀបលើការគោរពសិទ្ធិមនុស្ស។ ប្រទេសកម្ពុជា តាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានប្រែក្លាយមុខមាត់ និងការដឹកនាំប្រទេសតាមរបបលទ្ធិប្រជាធិបតេយ្យ ធានាឱ្យបាននូវការការពារសិទ្ធិមនុស្សជាមូលដ្ឋាន។ ចំពោះការការពារលើសិទ្ធិសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា គឺស្ថិតក្នុងដំណើរការវិវត្តមួយដ៏គួរឱ្យកត់សម្គាល់។ ដោយគិតចាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមានវត្តមានមក សេរីភាពបញ្ចេញមតិត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាថ្មី។ ការចែងឱ្យមានការធានាដោយរដ្ឋធម្មនុញ្ញនេះ គឺជាប្រការដ៏ល្អប្រសើរមួយដែលប្រទេសប្រជាធិបតេយ្យមួយត្រូវធ្វើ។ ប៉ុន្តែ ការចែងឱ្យមានតែក្នុងច្បាប់ គឺមិនគ្រប់គ្រាន់នោះទេ ទន្ទឹមនឹងនេះអ្វីដែលសំខាន់មិនអាចខ្វះបានដែរនោះគឺ ការអនុវត្តជាក់ស្តែងពិតប្រាកដ។ បើនិយាយពីការអនុវត្តជាក់ស្តែងនៃការការពារនូវសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋកម្ពុជាដោយរាជរដ្ឋាភិបាលកម្ពុជា គឺហាក់ដូចជានៅមានកម្រិតនៅឡើយ។ ថ្វីត្បិតតែ ប្រទេសកម្ពុជាបានសន្យាធានានូវកិច្ចការពារសិទ្ធិមនុស្សតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ក៏ដូចជាការចូលជាសមាជិកនៃអង្គការសហប្រជាជាតិ រួមជាមួយនឹងការដែលខ្លួនបានទទួលស្គាល់នូវលិខិតបទដ្ឋានគតិយុត្តអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលក្នុងនោះ មានពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិនេះយ៉ាងណាក៏ដោយ តែបញ្ហាដែលកើតឡើងជុំវិញសេរីភាពបញ្ចេញមតិត្រូវបានគេមើលឃើញគួរឱ្យកត់សម្គាល់។ យ៉ាងណាក៏ដោយ មកទល់នឹងពេលបច្ចុប្បន្ននេះ ស្ថានភាពនៃសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជាត្រូវបានគេមើលឃើញថាមានភាពល្អប្រសើរជាងមុន ដោយមានជាអាទិ៍ការផ្តល់ឱ្យមាននូវការបញ្ចេញមតិផ្សេងៗ តាមបណ្តាញទំនាក់ទំនងសង្គម ការធ្វើបាតុកម្មទូលំទូលាយ។ យ៉ាងនេះក្តី បញ្ហាដែលកើតចេញពីសេរីភាពបញ្ចេញមតិនៅបន្តមានក្នុងសង្គមកម្ពុជានៅឡើយដោយ បញ្ហាដែលកើតមានកន្លងមក ទាក់ទងទៅនឹងការហាមមិនឱ្យផ្សាយនូវស្ថានីយផ្សាយមួយចំនួន ការសម្តែងមតិរិះគន់រាជរដ្ឋាភិបាល ការវិភាគបញ្ហាសង្គមជាដើម ដែលជាបញ្ហាសង្គមគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ។

ដូច្នេះហើយ មិនមែនមានន័យថាមានតែប្រទេសកម្ពុជាទេដែលមាននូវបញ្ហានៃការរំលោភបំពានសេរីភាពបញ្ចេញមតិនោះ ប្រទេសជប៉ុនដែលជាប្រទេសលទ្ធិប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្សមួយក្នុងតំបន់អាស៊ី ក៏មាននូវបញ្ហានេះដែរ។ រដ្ឋធម្មនុញ្ញប្រទេសជប៉ុន ជារដ្ឋធម្មនុញ្ញដែលមានប្រភពពីសហរដ្ឋអាមេរិក ជាប្រទេសដែលត្រូវបានគេទទួលស្គាល់ថា មានការគោរពសិទ្ធិមនុស្សទូលំទូលាយ និងដោយសេរីបំផុត។ ដោយមានការទទួលឥទ្ធិពលបែបនេះហើយ ទើបធ្វើឱ្យរដ្ឋធម្មនុញ្ញប្រទេសជប៉ុន ត្រូវបានទទួលស្គាល់ថា មាននូវគោលការណ៍គោរពសិទ្ធិមនុស្សបានល្អ។

ជាក់ស្តែង តាមរយៈបញ្ញត្តិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ បង្ហាញឱ្យឃើញពីចេតនានៃការគោរពសិទ្ធិមនុស្សយ៉ាងម៉ត់ចត់ និងទូលំទូលាយ។ ដោយឡែក ក្នុងសង្គមជាក់ស្តែងនៃប្រទេសជប៉ុន សេរីភាពបញ្ចេញមតិត្រូវបានចាត់ទុកថាជាសិទ្ធិមនុស្សដ៏សំខាន់សម្រាប់ប្រជាពលរដ្ឋជប៉ុន ដោយមាននូវការការពារ និងការផ្តល់នូវសិទ្ធិសេរីភាពនេះយ៉ាងទូលំទូលាយខ្លាំង។ ក៏ប៉ុន្តែ ក្នុងរយៈពេលថ្មីៗនេះប្រទេសជប៉ុនក៏មាននូវបញ្ហាជុំវិញសេរីភាពបញ្ចេញមតិដែរ ជាក់ស្តែងដូចជាមាននូវការលើកឡើងមិនពេញចិត្តនឹងសេរីភាពបញ្ចេញមតិពីសំណាក់ក្រុមមេធាវីជប៉ុន ក្រុមអ្នកសារព័ត៌មាន ប្រជាពលរដ្ឋជប៉ុន និងមាននូវការរិះគន់ពីសំណាក់អន្តរជាតិផងដែរ។

ក្នុងការស្រាវជ្រាវសារណានេះផងដែរ នាងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាសំខាន់ៗចំនួន៥ ដូចខាងក្រោម ៖

- តើសេរីភាពបញ្ចេញមតិ ត្រូវបានធានាយ៉ាងដូចម្តេច ជាពិសេសក្នុងប្រវត្តិនៃរដ្ឋធម្មនុញ្ញក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន?
- តើសញ្ញាណនៃសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុនមានអ្វីខ្លះ? ហើយវាមានភាពដូចគ្នា និងខុសគ្នាដូចម្តេចខ្លះ?
- តើមានបទដ្ឋានគតិយុត្តអ្វីខ្លះ ទាក់ទងនឹងសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន?
- តើមានបញ្ហាអ្វីខ្លះទាក់ទងនឹងសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន?
- ឆ្លើយតបទៅនឹងបញ្ហាដែលកំពុងប្រឈម ប្រទេសកម្ពុជា និងប្រទេសជប៉ុន មាននូវដំណោះស្រាយដែរ ឬយ៉ាងណា? បើមាន តើមានដំណោះស្រាយដូចម្តេច?

សារណានេះត្រូវបានធ្វើឡើងក្នុងគោលបំណង ដើម្បីសិក្សាពីសេរីភាពបញ្ចេញមតិ ជាពិសេស គឺការបង្ហាញឱ្យឃើញពីបញ្ហាដែលកើតមានក្នុងប្រទេសកម្ពុជា ក្នុងការស្វែងរកនូវដំណោះស្រាយល្អប្រសើរមួយ តាមរយៈការសិក្សាប្រៀបធៀបជាមួយនឹងប្រទេសជប៉ុន។ ការសិក្សាប្រៀបធៀបនេះក្នុងគោលបំណងស្វែងយល់ឱ្យកាន់តែទូលំទូលាយពីសញ្ញាណនៃសេរីភាពបញ្ចេញមតិ ក៏ដូចជាស្វែងយល់ពីចំណុចវិជ្ជមាន និងអវិជ្ជមានដែលមានក្នុងប្រទេសទាំងពីរ ជាពិសេសប្រទេសកម្ពុជា។

ចំពោះការកំណត់ទំហំ និងដែនកំណត់នៃការស្រាវជ្រាវនេះផងដែរ គឺផ្ដោតសំខាន់ទៅលើសេរីភាពបញ្ចេញមតិដែលពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាន សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋជាសំខាន់ និងជាបន្ទាប់មានការសិក្សា រួមនឹងការលើកឡើងទាក់ទងទៅនឹងសេរីភាពនៃការជួបប្រជុំ សេរីភាពធ្វើបាតុកម្មជាដើម។ ក្នុងនោះដែរ នឹងធ្វើការសិក្សាទៅលើសារតារនៃសេរីភាពបញ្ចេញមតិដែលមានក្នុងរដ្ឋធម្មនុញ្ញមុនៗមកបង្ហាញខ្លះៗ ហើយធ្វើការសិក្សាទៅលើបទដ្ឋានគតិយុត្តដែលមានក្នុងពេលបច្ចុប្បន្ន។ ចំណុចដែលផ្ដោតសំខាន់មួយទៀតនោះ គឺបញ្ហាប្រឈមដែលមានក្នុងប្រទេសទាំងពីរ ដោយមាននូវការវិភាគខ្លះៗទៅលើបញ្ហាទាំងនោះ រួមជាមួយនឹងការបង្ហាញពីដំណោះស្រាយចំពោះបញ្ហាទាំងនោះ។

សារណានេះ មានសារៈសំខាន់ជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវផ្នែកនីតិរដ្ឋធម្មនុញ្ញជាពិសេសផ្នែកសិទ្ធិមនុស្ស ក្នុងការស្វែងយល់ឱ្យបានកាន់តែច្បាស់ និងស៊ីជម្រៅទៅលើសញ្ញាណទូទៅ បទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិ ជាពិសេសគឺការសិក្សាវិភាគទៅលើបញ្ហាដែលកំពុងកើតមាន។ ជាមួយគ្នានេះដែរ អ្នកសិក្សាស្រាវជ្រាវនឹងអាចស្វែងយល់តាមរយៈការសិក្សាប្រៀបធៀបគ្នារវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនពីភាពដូចគ្នា និងភាពខុសគ្នា ក៏ដូចជាចំនុចវិជ្ជមាន និងអវិជ្ជមាន។

ទាក់ទងនឹងការប្រមូលឯកសារក្នុងការស្រាវជ្រាវនូវសារណាមួយនេះ នាងខ្ញុំបានធ្វើតាមវិធីពីរយ៉ាង។ វិធីទីមួយ គឺការប្រមូលឯកសារតាមរយៈបណ្ណាល័យ។ ឯកសារដែលបានប្រមូលនោះមានដូចជាលិខិតបទដ្ឋានគតិយុត្ត សៀវភៅនានាដែលទាក់ទងទៅនឹងនីតិរដ្ឋធម្មនុញ្ញ និងនីតិសិទ្ធិមនុស្សដែលមានក្នុងបណ្ណាល័យច្បាប់ និងសៀវភៅទ្រឹស្ដីនីតិរដ្ឋធម្មនុញ្ញ សិទ្ធិមនុស្សរបស់ប្រទេសជប៉ុន ដែលមានក្នុងបណ្ណាល័យរបស់មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុន។ វិធីទីពីរ គឺតាមប្រព័ន្ធអ៊ីនធើណេត។ ដោយចូលទៅមើលតាមគេហទំព័រនានារបស់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការសង្គមស៊ីវិលនានារបស់ប្រទេសកម្ពុជា និងគេហទំព័រច្បាប់ផ្លូវការរបស់ប្រទេសជប៉ុន រួមជាមួយនឹង សារណាស្រាវជ្រាវរបស់អ្នកស្រាវជ្រាវជប៉ុនទាក់ទងនឹងសេរីភាពបញ្ចេញមតិ ក៏ដូចជា គេហទំព័ររបស់សារព័ត៌មានផ្សេងៗដែលចុះផ្សាយអំពីបញ្ហាសេរីភាពបញ្ចេញមតិទាំងរបស់ប្រទេសកម្ពុជា និងប្រទេសជប៉ុន។

សារណានេះ ត្រូវបានចែកចេញជា២ជំពូកធំៗគឺ **ជំពូកទី១** សិក្សាអំពី**សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា** ដោយធ្វើការបែងចែកជាបីផ្នែក រួមមាន អំពីប្រវត្តិ និងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិ(១.១) សិក្សាអំពីបទដ្ឋានគតិយុត្តិនៃសេរីភាពបញ្ចេញមតិ(១.២) និងសិក្សាអំពី

បញ្ហានិងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា(១.៣)។ រីឯ**ជំពូកទី២** សិក្សាអំពី**សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសជប៉ុន** ដោយធ្វើការសិក្សាទៅលើបីផ្នែកដូចគ្នា គឺអំពីប្រវត្តិនិងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិ(២.១) សិក្សាអំពីបទដ្ឋានគតិយុត្តិនៃសេរីភាពបញ្ចេញមតិ(២.២) និងសិក្សាអំពីបញ្ហានិងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅក្នុងប្រទេសជប៉ុន(២.៣)។

# ជំពូកទី១
# អំពី
# សេរីភាពបញ្ចេញមតិនៅ
# ប្រទេសកម្ពុជា

# ជំពូកទី ១ អំពី សេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

## ១.១. ប្រវត្តិ និងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

### ១.១.១. ប្រវត្តិនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

នៅក្នុងចំណុចនេះ នឹងធ្វើការសិក្សាអំពីប្រវត្តិនៃការកកើតឡើងនៃសេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។ ដើម្បីស្វែងយល់បានអំពីប្រវត្តិនេះ នឹងធ្វើការសិក្សាតាមរយៈបទដ្ឋានគតិយុត្តិដែលប្រទេសកម្ពុជាមាននៅក្នុងប្រវត្តិសាស្ត្រតាមសម័យកាលនីមួយៗ។ បទដ្ឋានគតិយុត្តិដែលនឹងលើកយកមកសិក្សានេះ គឺរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។ តាមរយៈការលើកឡើងនូវរដ្ឋធម្មនុញ្ញទាំងឡាយទៅតាមសម័យកាលនីមួយៗនេះ នឹងអាចស្វែងយល់បានអំពីការរៀបចំការអនុវត្តរបស់រដ្ឋាភិបាលនីមួយៗ លើការគោរពសិទ្ធិមនុស្ស ជាពិសេសសេរីភាពបញ្ចេញមតិ ថាតើត្រូវបានផ្តល់នូវការគោរពលើសេរីភាពជាមូលដ្ឋាននេះដែរឬទេ?

#### ១.១.១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ (១៩៤៧-១៩៧០)

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ គឺជារដ្ឋធម្មនុញ្ញដំបូងគេរបស់ប្រទេសកម្ពុជាដែលត្រូវបានអនុម័តនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ មាន១២២មាត្រា ចែកចេញជា១២ជំពូក។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១នេះ គឺជារដ្ឋធម្មនុញ្ញដែលត្រូវបានបង្កើតឡើងនៅសម័យសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះនរោត្តមសីហនុជាព្រះប្រមុខរដ្ឋ។

តាមរយៈបញ្ញត្តិដែលមានក្នុងរដ្ឋធម្មនុញ្ញនេះ សង្កេតឃើញថាមានចែងអំពីការទទួលស្គាល់នូវសិទ្ធិ សេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋនាសម័យនោះ[3] ហើយក៏ក្នុងនោះផងដែរ ក៏សង្កេតឃើញមាននូវបញ្ញត្តិដែលមានចែងអំពីសេរីភាពបញ្ចេញមតិ នៅក្នុងមាត្រា៩នៃរដ្ឋធម្មនុញ្ញនេះផងដែរ។

មាត្រា៩ នៃរដ្ឋធម្មនុញ្ញនេះបានចែងអំពីសេរីភាពបញ្ចេញមតិដែលត្រូវផ្តល់ដល់ប្រជាពលរដ្ឋដែលមានអត្ថន័យខ្លឹមសារដូចខាងក្រោម :

" ខេមរជនមានសិទ្ធិសេរីភាពក្នុងការនិយាយ-សរសេរ បោះពុម្ព និងការផ្សាយដល់មហាជន។ ខេមរជនអាចសំដែង ផ្សាយឬការពារមតិគ្រប់យ៉ាង តាមផ្លូវកាសែតក្តី តាមវិធីណាងទៀតក្តី កុំឲ្យតែប្រើសិទ្ធិនេះដោយរំលោភ ហើយកុំឱ្យតែញ៉ាំងឲ្យខូចសេចក្តីស្ងប់រៀបរយដល់មហាជន។

[3] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១, ជំពូកទី២ " សេរីភាព សិទ្ធិ និងករណីយកិច្ចរបស់ខេមរជន" មាន១៩មាត្រា

មិនត្រូវបង្ខំ ឬបង្គាប់នរណាឱ្យសំដែងមតិថាដូច្នេះឬដូច្នោះបានឡើយ។"

តាមអត្ថន័យខ្លឹមសារដែលមានចែងក្នុងមាត្រា៩នេះ អាចបង្ហាញបានថា រដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានទទួលស្គាល់នូវសិទ្ធិសេរីភាពបញ្ចេញមតិ ដោយមានការអនុញ្ញាតឲ្យមាននូវការនិយាយស្តី សម្តែងមតិយោបល់ ការយល់ឃើញរបស់ប្រជាពលរដ្ឋគ្រប់រូប ទោះតាមវិធីណាមួយក្តី។ ព្រមជាមួយគ្នានេះផងដែរ ក៏មាននូវការផ្តល់នូវព័ត៌មានជូនប្រជាពលរដ្ឋ អាចនិយាយម៉្យាងទៀតថា សេរីភាពទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋពីសំណាក់រដ្ឋ ដោយការដាក់ឲ្យមាននូវការផ្សាយជូនប្រជាពលរដ្ឋ តាមការបោះពុម្ព ក៏ដូចជាការផ្សាយផ្សេងៗ។ សិទ្ធិសេរីភាពទាំងនេះប្រើប្រាស់ទៅបានគ្រប់យ៉ាង វៀរលែងតែមានការប៉ះពាល់ដល់របៀបរបប សណ្តាប់ធ្នាប់ សន្តិសុខរបស់ប្រជាពលរដ្ឋ។

បន្ថែមលើចំណុចដែលមានខាងលើ វាក្យខណ្ឌទី២នៃមាត្រាដដែលនេះ បានបញ្ជាក់ឲ្យដឹងថា មិនមាននូវការញុះញង់ ការបង្ខិតបង្ខំឲ្យនិយាយស្តី សម្តែងមតិណាមួយដែលមិនមានចេញពីឆន្ទៈរបស់បុគ្គលនោះពិតប្រាកដឡើយ។

ជាសរុបមក នៅក្នុងសម័យសង្គមរាស្ត្រនិយម ចំពោះសេរីភាពបញ្ចេញមតិត្រូវបានធានាពីសំណាក់រដ្ឋនាសម័យនោះ ដែលទាក់ទងនឹងការសម្តែងមតិ ការទទួលបាននូវព័ត៌មាន ការផ្សាយចេញទៅវិញនូវព័ត៌មានជាដើម។

### ១.១.១.២. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ (១៩៧២-១៩៧៥)

រដ្ឋធម្មនុញ្ញនៃសាធាណរដ្ឋខ្មែរ គឺជារដ្ឋធម្មនុញ្ញដែលត្រូវបានបង្កើតឡើងក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៧០ ហើយរដ្ឋធម្មនុញ្ញនេះត្រូវបានដាក់ឲ្យធ្វើប្រជាមតិនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២ដោយសេនាប្រមុខ លន់ នល់[4]។ រដ្ឋធម្មនុញ្ញត្រូវបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការនៅទី១០ ខែឧសភា ឆ្នាំ១៩៧២ ដែលមាន១២១មាត្រា និងចែកចេញជា១១ជំពូក។

ថ្វីត្បិតតែមាននូវព្រឹត្តិការណ៍រដ្ឋប្រហារយ៉ាងណាក៏ដោយក៏រដ្ឋធម្មនុញ្ញនេះ មិនសូវជាខុសគ្នាពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ប៉ុន្មានដែរ ទាក់ទិននឹងការផ្តល់នូវសេរីភាពបញ្ចេញមតិជូនប្រជាពលរដ្ឋ។ មិនសូវខុសគ្នានោះ គឺត្រង់ថាមាននូវការបញ្ញត្តិមាត្រាស្តីអំពីសេរីភាព

[4] កៅ មុយថង កែសម្រួលដោយ ម៉ី វិចិត្រ, រដ្ឋធម្មនុញ្ញកម្ពុជា (ភ្នំពេញ៖ បណ្ណាគារអង្គរ, បោះពុម្ពលើកទី១, ២០០៦), ទំព័រ ២៦

បញ្ចេញមតិ ដែលមានខ្លឹមសារ គោលគំនិតស្រដៀងនឹងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។ ដើម្បីបន្ថែមឲ្យកាន់តែច្បាស់ ខាងក្រោមនេះជាខ្លឹមសារនៃមាត្រា៧រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋខ្មែរ។

" ពលរដ្ឋរាល់រូបមានសេរីភាពសំដែងគំនិតរបស់ខ្លួនតាមវាចា តាមលាយលក្ខណអក្សរ ឬតាមមធ្យោបាយសំរាប់ផ្សាយដទៃទៀត។ ក៏ប៉ុន្តែ ពលរដ្ឋត្រូវចៀសវាងកុំប្រើសិទ្ធិនេះ ដោយរំលោភហើយនិងកុំធ្វើឲ្យខូចរបៀបរៀបរយសាធារណៈ។

ការប្រើសេរីភាពសារព័ត៌មានមិនត្រូវប៉ះពាល់កិត្តិយសបុគ្គល សន្តិសុខជាតិ ឬទំនៀមទំលាប់ល្អទេ។ របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់មួយ។ "

### **១.១.១.៣. រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ** (**១៩៧៥-១៩៧៩**)

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ គឺជារដ្ឋធម្មនុញ្ញដែលត្រូវបានបង្កើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្ថិតក្រោមការដឹកនាំផ្តាច់ការ ដែលត្រូវបានអនុម័តនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ មានមាត្រាសរុបត្រឹមតែ២១មាត្រា និង១៦ជំពូកតែប៉ុណ្ណោះ។

ដោយហេតុថា នាសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាត្រូវស្ថិតក្រោមការគ្រប់គ្រងផ្តាច់ការ មិនមាននូវការគោរពសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដូចនឹងគោលការណ៍សិទ្ធិមនុស្សក្នុងលទ្ធិប្រជាធិបតេយ្យនោះទេ។ យ៉ាងនេះហើយ ទើបក្នុងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យ មិនមានចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋ។ ដោយមិនមានបញ្ញត្តិចែងអំពីសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងរដ្ឋធម្មនុញ្ញបែបនេះ ចំពោះសេរីភាពបញ្ចេញមតិដែលជាសិទ្ធិសេរីភាពជាមូលដ្ឋានមួយមិនអាចខ្វះបានរបស់មនុស្សនោះក៏មិនមានដែរ។ បើក្រឡេកមើលទៅតថភាពជាក់ស្តែងនៃប្រវត្តិសាស្ត្រ ពិតណាស់ថារដ្ឋាភិបាលសម័យកម្ពុជាប្រជាធិបតេយ្យ មិនអនុញ្ញាតឡើយចំពោះការនិយាយស្តី ការបញ្ចេញមតិយោបល់ដោយសេរីអ្វីទាំងអស់ គឺត្រូវស្ថិតក្រោមការគាបសង្កត់សិទ្ធិសេរីភាព។ ប្រាកដណាស់ថា រដ្ឋាភិបាលសម័យនោះយល់ច្បាស់អំពីសារៈសំខាន់នៃសេរីភាពបញ្ចេញមតិមួយនេះចំពោះប្រជាពលរដ្ឋ ដូចនេះហើយប្រសិនបើអនុញ្ញាតឲ្យមានការសម្តែងមតិយោបល់ផ្សេងៗ ពោលគឺគោរពនូវសេរីភាពបញ្ចេញមតិ នោះការដឹកនាំតាមបែបផ្តាច់ការនឹងមិនអាចមានវត្តមានបាននោះទេ។

### ១.១.១.៤. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨១)

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺជារដ្ឋធម្មនុញ្ញទី៤របស់ប្រទេសកម្ពុជា។ រដ្ឋធម្មនុញ្ញនេះ ត្រូវបានអនុម័តជាឯកច្ឆ័ន្ទ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ និងត្រូវបានប្រកាសឲ្យប្រើតាមក្រឹត្យលេខ០១ក្រ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ មាន៩៣មាត្រា និងចែកជា១០ជំពូក។

គួរបញ្ជាក់ផងដែរថា រដ្ឋាភិបាលនាសម័យនោះប្រកាន់យករបបលទ្ធិសង្គមនិយម ហើយរដ្ឋធម្មនុញ្ញនេះបានយកគំរូតាមរដ្ឋធម្មនុញ្ញវៀតណាមភាគច្រើន[5]។ ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញនេះចែងអំពី "សិទ្ធិ និងករណីយកិច្ចរបស់ពលរដ្ឋ" ដែលមាន១៥មាត្រា ក្នុងនោះមាត្រា៣៧ បានចែងអំពីសេរីភាពបញ្ចេញមតិថា :

> " ពលរដ្ឋមានសេរីភាពខាងការនិយាយ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទន្លាប់ល្អរបស់សង្គម ដល់របៀបរៀបរយសាធារណៈ និងដល់សន្តិសុខជាតិ។ "

ខ្លឹមសារដែលមានក្នុងមាត្រា៣៧នេះ បង្ហាញឲ្យឃើញអំពីការទទួលស្គាល់របស់រដ្ឋលើការគោរពចំពោះសេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មានជាដើម។ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការប្រើប្រាស់នូវសិទ្ធិនេះដោយសេរី លុះត្រាណាមិនប៉ះពាល់ដល់សិទ្ធិ កិត្តិយស សេចក្តីថ្លៃថ្នូរអ្នកដទៃ ឬប៉ះពាល់ដល់ទំនៀមទន្លាប់ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ។

### ១.១.១.៥. រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា (១៩៨៩-១៩៩២)

រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា គឺជារដ្ឋធម្មនុញ្ញ ដែលត្រូវបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១។ គួររំលឹកផងដែរថា ក្នុងអំឡុងពេលនោះ ជាសម័យនៃសង្គ្រាមត្រជាក់មានការបែងចែករវាងលោកខាងលិច និងលោកខាងកើត។ ប៉ុន្តែ ក្រោយមកពេលដែលជញ្ជាំងប៊ែរឡាំងត្រូវបានរលំ ជាសញ្ញាប្រាប់ពិភពលោកថាការបែងចែកនេះត្រូវបានបញ្ចប់។ ពេលនោះដែរ ប្រទេសកម្ពុជាដែលប្រកាន់យកលទ្ធិសង្គមនិយមនោះ ក៏បានផ្លាស់ប្តូរមកប្រកាន់យករបបសេរី ដោយការប្តូរឈ្មោះពី "**សាធារណរដ្ឋប្រជាមានិតកម្ពុជា**" មកជា "**រដ្ឋកម្ពុជា**" វិញ។ តាមរយៈការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ បានធ្វើឲ្យប្រទេសកម្ពុជាទទួលស្គាល់នូវលទ្ធិប្រជា

[5] ដូច៤, ទំព័រ៣៩

ធិបតេយ្យ និងសិទ្ធិសេរីភាពផ្សេងៗ។ រដ្ឋធម្មនុញ្ញនេះ មាន១០ជំពូក និង៩៣មាត្រា ហើយសង្កេតឃើញមានមាត្រាស្ទួនគ្នាចំនួន៨។

ដូចគ្នាទៅនឹងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាដែរ ទាក់ទងនឹងការទទួលស្គាល់សេរីភាពបញ្ចេញមតិក្នុងរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា។ មាត្រា៣៧នៃរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាចែងថា :

" ពលរដ្ឋមានសេរីភាពខាងការនិយាយ សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ដល់ទំនៀមទន្លាប់ល្អរបស់សង្គម ដល់របៀបរៀបរយសាធារណៈ និងដល់សន្តិសុខជាតិ។
របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់។ "

មាត្រានេះ គឺមិនមានការលុបពាក្យពេចន៍ណាមួយចេញពីមាត្រាចាស់នោះទេ តែមានការបន្ថែមនូវការបង្កើតច្បាប់ទាក់ទងនឹងសេរីភាពសារព័ត៌មាននៅក្នុងច្បាប់ដោយឡែក។

ចំពោះស្ថានភាពនៃសេរីភាពបញ្ចេញមតិដែលមានក្នុងប្រវត្តិសាស្ត្រ តាមរយៈការលើកយកនូវរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋមកធ្វើការសិក្សាជាគោលនេះ អាចសន្និដ្ឋានបានថា ក្នុងសម័យកាលនៃរបបនីមួយៗ លើកលែងតែរបបផ្តាច់ការកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជាបានទទួលស្គាល់នូវការគោរពនូវសេរីភាពបញ្ចេញមតិ។ ទោះជាយ៉ាងណាក្តី ចំពោះស្ថានភាពជាក់ស្តែងអាចនឹងមាននូវការរំលោភបំពាន ការអនុវត្តនូវសេរីភាពនេះមិនបានពេញលេញគ្រប់ប្រការណាមួយជាក់ជាមិនខាន ព្រោះថា ការអនុវត្តជាក់ស្តែងមិនទាន់មានភាពស្របគ្នាទាំងស្រុងទៅជាមួយនឹងបញ្ញត្តិច្បាប់ចែងនៅឡើយទេ។

### ១.១.២. សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

#### ១.១.២.១. និយមន័យ

សេរីភាពបញ្ចេញមតិ បានមកពីពាក្យ "សេរីភាព" ពាក្យ"បញ្ចេញ" និង ពាក្យ"មតិ" បូកបញ្ចូលគ្នា។

ដោយយោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត [6] ពាក្យ **"សេរីភាព"** គឺជាអំណាចដែលអាចធ្វើអ្វីបានតាមអំពើចិត្ត ប៉ុន្តែក្រោមច្បាប់ អំណាចពេញទី។ មួយវិញទៀត សេរីភាពជាប្រភពដ៏សំខាន់នៃសិទ្ធិពលរដ្ឋ និងនយោបាយ និងជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ដែលត្រូវបានគេស្គាល់ថាជាសេចក្តីត្រូវការសំខាន់បំផុតសម្រាប់មនុស្សគ្រប់ៗរូប[7]។ ដោយហេតុថា សេរីភាព គឺជាអ្វីដែលមនុស្សត្រូវការក្នុងការធ្វើអ្វីៗគ្រប់យ៉ាង ដោយមិនទទួលរងនូវការគម្រាមកំហែង ការឃាយឃី ការរឹតត្បិត ការបង្ខិតបង្ខំ ឬការជ្រៀតជ្រៀកបែបណាមួយនោះទេ[8]។ ម្យ៉ាងវិញទៀត សេរីភាព គឺជាអ្វីដែលមិនចាំបាច់សុំការអនុញ្ញាតជាមុននោះទេ[9]។ មានន័យថា សេរីភាពជាអ្វីៗដែលមនុស្សអាចមាន ឬត្រូវមាន ដោយសេរី ពីធម្មជាតិ មិនចាំបាច់ត្រូវមានការអនុញ្ញាតមុននឹងយកមកប្រើប្រាស់នោះទេ។ សេរីភាពអាចត្រូវបានប្រើដោយសេរី ដរាបណាមិនប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃ[10] ឬ លើកលែងតែមិនត្រូវបានហាមឃាត់យ៉ាងច្បាស់ដោយច្បាប់[11]។

ឯពាក្យ **"បញ្ចេញ"** យោងតាមវចនានុក្រមសម្តេចព្រះសង្ឃរាជជួន ណាត[12] មានន័យថាធ្វើឱ្យចេញ បញ្ចេញវាចា និយាយបញ្ចេញ បញ្ចេញយោបល់ជាដើម។

និងពាក្យ **"មតិ"** គឺជាប្រាជ្ញា ការឈ្វេងយល់ គំនិត យោបល់[13]។

ជាសរុបមក សេរីភាពបញ្ចេញមតិ គឺជា សេរីភាពដែលមានសារៈសំខាន់ ជាមូលដ្ឋានក្នុងការជជែកវែកញែកជាសាធារណៈ ការសម្រេចចិត្តជាជំហារ និងការដោះដូរដោយសេរីនូវគំនិតយោបល់ និងព័ត៌មាន[14]។

### ១.១.២.២. ប្រភេទ

ទាក់ទងនឹងសញ្ញាណនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា នៅមិនទាន់មានឯកសារនៃការស្រាវជ្រាវធ្វើការកំណត់ពីប្រភេទនៃសេរីភាពបញ្ចេញមតិនេះច្បាស់លាស់នៅឡើយទេ។

---

[6] វចនានុក្រមខ្មែរ ភាគទី១, ភាគទី២ (ពុទ្ធសាសនិកបណ្ឌិត, ១៩៦៨), ទំព័រ ១៩០៥

[7] បណ្ឌិត ឈុន ណារ៉េត, សេចក្តីផ្តើម នីតិរដ្ឋធម្មនុញ្ញ, (រោងពុម្ពដារ៉ា, ២០១២), ទំព័រ ៣៩០

[8] ដូច៧

[9] Dr. Wilhelm Treiber/ Andrea Behm/ Hout Sotheary, ការពិចារណាពិស្តារផ្នែកគតិយុត្តិ សៀវភៅសិក្សាផ្នែកទី១ សិទ្ធិមនុស្ស, វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ, ទំព័រ២៦

[10] ដូច៩, ទំព័រ២៥

[11] ដូច៩, ទំព័រ២៦

[12] ដូច៦, ទំព័រ៥៣៦

[13] ដូច៦, ទំព័រ៨៥៨

[14] ដូច៩, ទំព័រ៣៧

ដោយឯកសារស្រាវជ្រាវភាគច្រើន លើកឡើងតែពី សារៈសំខាន់នៃសេរីភាពបញ្ចេញមតិតែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងនោះឃើញមានឯកសារមួយ[15]ដែលធ្វើការកំណត់ពីសមាសភាពរបស់សេរីភាពបញ្ចេញមតិ។

តាមឯកសារនោះ[16] សេរីភាពបញ្ចេញមតិមិនត្រឹមតែសំដៅទៅលើ ការពិត ទិន្នន័យ និងព័ត៌មាននោះទេ ប៉ុន្តែក៏រួមទាំងគំនិតយោបល់ និងទស្សនៈ។ សេរីភាពនេះ រួមបញ្ចូលផងដែរនូវសេរីភាពនៃព័ត៌មានដែលមានន័យថាការទទួលបានព័ត៌មានដោយសេរី។ រួមជាមួយនឹង ការបញ្ចេញមតិ និងការទទួលបានព័ត៌មានតាមរយៈប្រព័ន្ធឃោសនាអេឡិចត្រូនិក ដូចជាវិទ្យុ ទូរទស្សន៍ ផ្ទាយរណប ខ្សែកាប ឬអ៊ីនធើណេត។ ក្រៅពីសេរីភាពទាំងនេះ សេរីភាពក្នុងការប្រជុំក៏ត្រូវបានចាត់ចូលជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិដែរ[17]។

ទាំងអស់នេះ ជាសញ្ញាណដែលមានទាក់ទងនឹងការបែងចែកប្រភេទនៃសេរីភាពបញ្ចេញមតិដែលមានក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ពោលគឺមាន សេរីភាពក្នុងការបញ្ចេញគំនិតយោបល់ សេរីភាពទទួលបានព័ត៌មាន សេរីភាពផ្សព្វផ្សាយព័ត៌មាន និងសេរីភាពនៃការប្រជុំ។

## ១.២. បទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

ដើម្បីសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់ ទៅលើសេរីភាពបញ្ចេញមតិដែលមាននៅក្នុងប្រទេសកម្ពុជា ចាំបាច់ណាស់ត្រូវយល់ដឹងអំពីបទដ្ឋានគតិយុត្តទាំងឡាយដែលទាក់ទងទៅនឹងសេរីភាពនេះ។ ដោយហេតុថា ការសិក្សាអំពីបទដ្ឋានគតិយុត្តនេះ នឹងអាចបង្ហាញឲ្យឃើញអំពីស្ថានភាពដែលរដ្ឋបានចាត់ទុក ផ្តល់តម្លៃ គោរពទៅលើសិទ្ធិសេរីភាពនេះបានដល់កម្រិតណា។ ព្រមជាមួយគ្នានេះដែរ ក៏ដើម្បីធ្វើការពិនិត្យមើលទៅលើចំណុចដែលជាចន្លោះខ្វះខាត បញ្ហាប្រឈមដែលមាន ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិនេះ (ដែលនឹងលើកយកមកសិក្សានៅក្នុងចំណុច១.៣) បានផងដែរ។

ក្នុងផ្នែកនេះនឹងធ្វើការបែងចែកជា២ចំណុចធំៗគឺ បទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា(១.២.១) និង បទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា(១.២.២)។

---

[15] ឯកសាររបស់ Dr. Wilhelm Treiber/ Andrea Behm/ Hout Sotheary, ការពិចារណាពិស្តារផ្នែកគតិយុត្តិ សៀវភៅសិក្សាផ្នែកទី១ សិទ្ធិមនុស្ស, វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ

[16] ដូច៩, ទំព័រ៣៩

[17] ដូច៩, ទំព័រ៦២

### ១.២.១. បទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិ

ប្រទេសកម្ពុជា គឺជាប្រទេសមួយនៃសមាជិកអង្គការសហប្រជាជាតិ។ ហេតុនេះ មិនថាជាសកម្មភាព កិច្ចការងារ ការរៀបចំផ្សេងៗ ជាពិសេសលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមានក្នុងប្រទេសស្តីអំពីសិទ្ធិមនុស្ស ត្រូវមានការគោរពទៅតាមគោលការណ៍ជារួមរបស់លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលស្គាល់។

មាត្រា៣១វាក្យខណ្ឌទី១នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានបញ្ញត្តិអំពីការទទួលស្គាល់ការគោរពសិទ្ធិមនុស្សដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ ដូចជាធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ក៏ដូចជាអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស។

បទដ្ឋានគតិយុត្តអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់បច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងសេរីភាពបញ្ចេញមតិ សរុបមានចំនួន៣ ដូចជា ធម្មនុញ្ញានៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីពលរដ្ឋ និងសិទ្ធិនយោបាយ ។

#### ១.២.១.១. ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ

ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ជាលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលប្រទេសនៅលើពិភពលោកជាសមាជិកនៃអង្គការសហប្រជាជាតិអនុម័តយល់ព្រម។ ស្របតាមស្មារតីនៃមាត្រា៣១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ក៏បានទទួលស្គាល់នូវការគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិនេះដែរ។

ប្រការ១ ចំណុចទី៣នៃធម្មនុញ្ញសហប្រជាជាតិ ដែលស្តីពីវត្ថុបំណងនៃសហប្រជាជាតិចែងថា ត្រូវបង្កើតឱ្យមានពិតប្រាកដនូវសហប្រតិបត្តិការអន្តរជាតិ ដោយដោះស្រាយនូវបញ្ហាអន្តរជាតិខាងសេដ្ឋកិច្ច សង្គមកិច្ច ឬមនុស្សធម៌ ដោយពង្រីក និងលើកទឹកចិត្តក្នុងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាសាធារណៈសម្រាប់មនុស្សទូទៅឥតសម្គាល់ជាតិសាសន៍ ភេទ ភាសា ឬសាសនាឡើយ[18]។

ប្រការនេះ បង្ហាញឱ្យឃើញពីការងារសំខាន់មួយដែលអង្គការសហប្រជាជាតិត្រូវបំពេញក្នុងចំណោមការងារសំខាន់ដទៃផ្សេងទៀត ពោលគឺការធានាឱ្យបាននូវការគោរពសិទ្ធិមនុស្សរបស់

[18] ការបកប្រែជាភាសាខ្មែររបស់គេហទំព័របណ្ណាល័យច្បាប់។

មនុស្សគ្រប់ៗគ្នានៅលើសកលលោកដោយមិនមាននូវការប្រកាន់ ឬបែងចែកពូជសាសន៍ ភេទ សាសនាជាដើមឡើយ។

### ១.២.១.២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សត្រូវបានអនុម័ត និងប្រកាសដោយសេចក្តីសម្រេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ២១៧ A(III) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨[19]។

មាត្រា១៩នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានចែងអំពីការការពារសេរីភាពបញ្ចេញមតិថា :

> " មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួលនិងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយគ្មានព្រំដែនទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។ "

តាមរយៈមាត្រា១៩នេះ សេរីភាពបញ្ចេញមតិត្រូវបានធានាការពារស្របតាមលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ដោយសង្កេតឃើញថា ការផ្តល់ឲ្យនូវការមាននូវសេរីភាពមួយនេះ គឺមិនមានការប្រកាន់ទៅលើមនុស្សប្រភេទណាមួយឡើយ ពោលគឺមនុស្សគ្រប់រូបសុទ្ធតែមានសិទ្ធិមួយនេះ។ រួមជាមួយគ្នានេះផងដែរ មិនត្រឹមតែសេរីភាពក្នុងការសម្តែងមតិប៉ុណ្ណោះទេ សេរីភាពក្នុងការផ្សព្វផ្សាយ និងទទួលបានព័ត៌មានក៏ត្រូវបានទទួលស្គាល់ចំពោះមនុស្សគ្រប់រូបផងដែរ។

### ១.២.១.៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនេះ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ និងចូលជាធរមាននៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៧៦។ ប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២[20]។

[19] ច្បាប់សិទ្ធិមនុស្សកម្ពុជា, ចងក្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, ខែកញ្ញា ឆ្នាំ២០១២, ទំព័រ២៩

[20] ដូច១៩, ទំព័រ៦៧

ស្រដៀងគ្នាទៅនឹងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែរ ទាក់ទងនឹងការការពារសេរីភាពបញ្ចេញមតិ មាត្រា១៩វាក្យខណ្ឌទី១និងទី២ នៃកតិកាសញ្ញាអន្តរជាតិនេះ បានចែងថា :

" ១. ជនគ្រប់រូប មានសិទ្ធិប្រកាន់យកមតិយោបល់ ដោយគ្មានការជ្រៀតជ្រែក។
២. ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មាន ទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តីតាមការជ្រើសរើសរបស់ខ្លួន។ "

តាមអត្ថន័យដែលមានក្នុងបញ្ញត្តិនេះ គឺស្ថិតក្នុងគោលគំនិតតែមួយក្នុងការធានាឱ្យបាននូវការការពារសេរីភាពជាមូលដ្ឋានមួយនេះ ដោយមិនឲ្យមាននូវការជ្រៀតជ្រែក ការបំបិទសេរីភាពមួយនេះឡើយ។ ដោយត្រូវអនុញ្ញាតយ៉ាងទូលំទូលាយ ចំពោះការប្រើប្រាស់សេរីភាពបញ្ចេញមតិ សិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិក្នុងការផ្សព្វផ្សាយព័ត៌មានផ្សេងៗគ្រប់ទម្រង់ និងគ្រប់រូបភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ទោះតាមវិធី ឬមធ្យោបាយណាមួយក៏ដោយ។

ភ្ជាប់ជាមួយគ្នានេះដែរ ជាការកម្រិតមួយចំពោះការប្រើប្រាស់សេរីភាពបញ្ចេញមតិនេះ វាក្យខណ្ឌទី៣នៃមាត្រាដដែលនេះបានបញ្ញត្តិបន្ថែមថា :

" ៣. ការប្រើប្រាស់សិទ្ធិដែលមានចែងក្នុងវាក្យខណ្ឌ២នៃមាត្រានេះ តម្រូវឱ្យមានករណីយកិច្ច និងការទទួលខុសត្រូវពិសេស។ ដូច្នេះ ការប្រើប្រាស់សិទ្ធិនេះអាចមានការរិតត្បិតមួយចំនួនដែលត្រូវកំណត់ដាច់ខាតដោយច្បាប់ និងដែលចាំបាច់ដើម្បី:
(ក) គោរពសិទ្ធិ និងកិត្តិសព្ទរបស់អ្នកដទៃ។
(ខ) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាព ឬសីលធម៌សាធារណៈ។ "

វាក្យខណ្ឌទី៣នេះ ចែងអំពីការដាក់កម្រិតមួយទៅលើសេរីភាពបញ្ចេញមតិដែលត្រូវបានទទួលស្គាល់ និងត្រូវបានការពារនៅវាក្យខណ្ឌទី១និងទី២។ ការដាក់កម្រិតសិទ្ធិដែលមាននេះ មិនមែនជាការរំលោភទៅលើសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋនោះទេ។ ជាការពិតណាស់ មនុស្សម្នាក់អាចប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយសេរីបាន ហើយសិទ្ធិនោះត្រូវបានធានាដោយរដ្ឋ ប៉ុន្តែទន្ទឹមគ្នានេះដែរ គេមិនអាចប្រើសិទ្ធិនោះដោយគ្មានព្រំដែននោះទេ។ ហេតុនេះហើយ វាក្យ

ខណ្ឌទី៣នេះ ធ្វើការកំណត់ពីទំហំនៃសេរីភាពដែលអាចប្រើប្រាស់បាន ដោយមិនឱ្យមានការប្រើប្រាស់ដោយសេរីជ្រុល ទៅតាមតែអំពើចិត្ត ដែលជាហេតុធ្វើឱ្យការប្រើប្រាស់សេរីភាពមួយនេះក្លាយជាខុសទៅវិញ។ ពោលគឺ សេរីភាពបញ្ចេញមតិត្រូវបានប្រើប្រាស់ដោយសេរី ត្រឹមត្រូវទៅតាមតម្រូវការរបស់មនុស្សម្នាក់ៗ លុះត្រាណាមិនមានការប៉ះពាល់ដល់សិទ្ធិឯកជនរបស់អ្នកដទៃ ឬសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សីលធម៌សាធារណៈ។ ករណីការប្រើប្រាស់បណ្តាលឱ្យមានការប៉ះពាល់បែបនេះ សេរីភាពនេះមិនអាចអនុញ្ញាតឱ្យបន្ត ឬធានាបានឡើយ។

### ១.២.២. បទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិ

តាមរយៈការសិក្សាស្រាវជ្រាវ ទាក់ទងនឹងបទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិដែលមានក្នុងប្រទេសកម្ពុជា គិតមកត្រឹមពេលបច្ចុប្បន្ននេះ(ឆ្នាំ២០១៧) សង្កេតឃើញថាមានបទដ្ឋានគតិយុត្តជាធរមានចំនួន៤ និងនៅជាសេចក្តីព្រាងច្បាប់ចំនួនមួយដែលពាក់ព័ន្ធ។ បទដ្ឋានគតិយុត្តជាធរមាន គឺមានដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ បទដ្ឋានគតិយុត្តដែលនៅជាសេចក្តីព្រាងច្បាប់នៅឡើយ នោះគឺ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។

#### ១.២.២.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺជាច្បាប់កំពូលរបស់ប្រទេស ដែលរដ្ឋធម្មនុញ្ញនេះត្រូវបានប្រសូតឡើងបន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ រដ្ឋធម្មនុញ្ញនេះត្រូវបានសភាធម្មនុញ្ញអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន បានធានាទទួលស្គាល់នូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប[21] ដែលក្នុងនោះសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញមួយនេះផងដែរ។

មាត្រា៤១រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា :

[21] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន, មាត្រា៣១

" ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់។ "

មាត្រា៤១នេះ បានចែងធានាទទួលស្គាល់ពីសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរ ដោយរួមបញ្ចូលនូវសិទ្ធិដទៃទៀត ដែលត្រូវបានទទួលស្គាល់ផងដែរថាជាប្រភេទនៃសេរីភាពបញ្ចេញមតិ។ រួមមានដូចជាសេរីភាពសារព័ត៌មាន សេរីភាពបោះពុម្ពផ្សាយ និងសេរីភាពជួបជុំ។ ដូចគ្នាដែរទៅនឹងលិខិតបទដ្ឋានអន្តរជាតិដែលប្រទេសកម្ពុជាបានទទួលស្គាល់ ការទទួលស្គាល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋជារឿងសំខាន់ចាំបាច់បំផុតដែលរដ្ឋត្រូវធ្វើ ប៉ុន្តែឆ្លើយតបមកវិញ ប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ ក៏មិនអាចសំអាងថាជាសិទ្ធិរបស់ខ្លួន ប្រើប្រាស់សិទ្ធិដោយរំលោភលើច្បាប់ ហួសដែនកំណត់បាននោះដែរ។ ហេតុនេះហើយ ទើបឃើញមានការកម្រិតនូវសេរីភាពបញ្ចេញមតិនេះស្របតាមគោលការណ៍រួមនៃលិខិតបទដ្ឋានអន្តរជាតិ ថាមិនត្រូវឱ្យមានការរំលោភបំពានទៅដល់កិត្តិយសរបស់បុគ្គលដទៃទៀត ឬទៅដល់ទំនៀមទម្លាប់ សណ្តាប់ធ្នាប់សង្គម និងសន្តិសុខជាតិជាដើមបាននោះទេ។

ក្រៅពីមាត្រា៤១ ដែលជាមាត្រាគោលនៃសេរីភាពបញ្ចេញមតិនេះ គឺមាននូវមាត្រា៣៧មួយទៀត។ មាត្រា៣៧ ចែងអំពីសិទ្ធិក្នុងការធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី[22]។ ដូចដែលបានសិក្សានៅក្នុងជំពូកទី១ អំពីសញ្ញាណនៃសេរីភាពបញ្ចេញមតិ សិទ្ធិដែលត្រូវបានរាប់បញ្ចូលក្នុងសេរីភាពបញ្ចេញមតិនោះ មិនមានត្រឹមតែការសម្តែងមតិ ការផ្សព្វផ្សាយសារព័ត៌មាន ការទទួលបានព័ត៌មាន ការបោះពុម្ពផ្សាយប៉ុណ្ណោះទេ តែក៏រួមបញ្ចូលផងដែរនូវការចូលរួមជួបជុំ ការធ្វើកូដកម្ម ឬបាតុកម្មក្តី។

### ១.២.២.២. ច្បាប់ស្តីពីរបបសារព័ត៌មាន

គួររំលឹកផងដែរថា មាត្រា៤១វាក្យខណ្ឌទី២នៃរដ្ឋធម្មនុញ្ញបានចង្អុលបង្ហាញថា ត្រូវមានការបង្កើតឡើងនូវច្បាប់ដែលគ្រប់គ្រងនូវរបបសារព័ត៌មាន។ ច្បាប់ស្តីពីរបបសារព័ត៌មាន ត្រូវបាន

[22] មាត្រា៣៧នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នចែងថា: "សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់"។

អនុម័តនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងធានាការពារសេរីភាពសារព័ត៌មាន និងសេរីភាពខាងការបោះពុម្ពផ្សាយឱ្យស្របទៅតាមមាត្រា៣១ និងមាត្រា៤១នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន[23]។

ច្បាប់ស្តីពីរបបសារព័ត៌មាននេះ បានធ្វើការកំណត់ចែងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកសារព័ត៌មាន អ្នកបោះពុម្ពផ្សាយ។ សិទ្ធិរបស់អ្នកសារព័ត៌មាន និងអ្នកបោះពុម្ពផ្សាយដែលត្រូវមានក្នុងច្បាប់ស្តីពីរបបសារព័ត៌មាននេះ មានដូចជា សិទ្ធិក្នុងការទទួលបានព័ត៌មាន និងបោះពុម្ពនូវសេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយរបស់អង្គនីតិបញ្ញត្តិ (រដ្ឋសភា) អង្គនីតិប្រតិបត្តិ(រាជរដ្ឋាភិបាល) អង្គតុលាការ[24]។ មួយទៀត គឺសិទ្ធិក្នុងការបង្កើតនូវសមាគមអ្នកសារព័ត៌មានរបស់អ្នកសារព័ត៌មាន[25]។

ចំណែកឯ កាតព្វកិច្ចរបស់អ្នកសារព័ត៌មាន ក៏ដូចជាអ្នកបោះពុម្ពមានដូចជា កាតព្វកិច្ចក្នុងការផ្សាយ និងបោះពុម្ពផ្សាយនូវសេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗរបស់អង្គស្ថាប័នទាំងបី ដោយគោរពទៅតាមការចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

- អាចផ្សាយ ឬបោះពុម្ពផ្សាយនូវគ្រប់សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗរបស់រដ្ឋសភា រួមទាំងគណៈកម្មាធិការ ឬគណៈកម្មការនានារបស់រដ្ឋសភាបាន លើកលែងតែករណីរដ្ឋសភាធ្វើការប្រជុំសម្ងាត់ដូចមានចែងក្នុងមាត្រា៨៨នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[26]។
- អាចផ្សាយ ឬបោះពុម្ពផ្សាយនូវគ្រប់សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ផ្សេងៗនូវគ្រប់ទិដ្ឋភាពនៃដំណើរការរបស់តុលាការ រាប់ទាំងនីតិវិធីទាំងឡាយផង លើកលែងតែ ៖
  - តុលាការហាមមិនឱ្យបើកចំហរដល់សាធារណជន
  - ប៉ះពាល់អាថ៌កំបាំងរបស់បុគ្គលម្នាក់ៗនៅក្នុងដំណើរការជំនុំជម្រះក្តី
  - សំណុំរឿងដែលនៅក្នុងការស៊ើបអង្កេតរបស់តុលាការនៅឡើយ[27]។

[23] ច្បាប់ស្តីពីរបបសារព័ត៌មាន, មាត្រា១

[24] ដូច២៣, មាត្រា៥

[25] ដូច២៣, មាត្រា៦

[26] ដូច២៣, មាត្រា៥ ចំណុច១

[27] ដូច២៣, មាត្រា៥ ចំណុច៣

ក្រៅពីនេះ នៅមានកាតព្វកិច្ចរបស់អ្នកសារព័ត៌មាន នៅពេលបង្កើតនូវសមាគមអ្នកសារព័ត៌មាន ដែលមាន១១ចំណុច[28]។ ដោយលើកជាគ្រួសៗ មានដូចជា ការគោរពសច្ចធម៌របស់សាធារណជន ការផ្សាយដោយសុចរិត ការរិះគន់ដោយត្រឹមត្រូវស្របតាមគតិយុត្តិធម៌ ប្រើវិធីសុចរិតក្នុងការស្វែងរកដំណឹង ជៀសវាងការផ្សាយព័ត៌មានដែលមានលក្ខណៈញុះញង់ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ជំនឿ សាសនាផ្សេងៗ ការបោះពុម្ពផ្សាយអត្ថបទ ឬរូបភាពអាសអាភាស រូបភាពនៃអំពើហិង្សា ការទទួលសំណូកដើម្បីជាថ្នូរក្នុងការបោះពុម្ពផ្សាយជាដើម។

បន្ថែមពីនេះទៀត ច្បាប់ស្តីពីរបបសារព័ត៌មាននេះ មានចែងអំពីនីតិវិធីសុំក្នុងការផ្សព្វផ្សាយព័ត៌មាន ឬបោះពុម្ព ការដាក់កម្រិតមួយចំនួនទៅលើការផ្សាយព័ត៌មាន ឬការបោះពុម្ពផ្សាយ និងមាននូវទោសបញ្ញត្តិ ចំពោះការប្រព្រឹត្តខុសទៅនឹងបទបញ្ញត្តិណាមួយដែលមានចែងក្នុងច្បាប់ស្តីពីរបបសារព័ត៌មាននេះផងដែរ។

### ១.២.២.៣. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ ២០០៩ និងត្រូវបានព្រះមហាក្សត្រឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៩។

ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើបាតុកម្មដោយសន្តិវិធីនៅក្នុងប្រទេសកម្ពុជា[29] និងក្នុងគោលបំណង ធានាការពារសេរីភាពខាងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋខ្មែរតាមរយៈការធ្វើបាតុកម្មដោយសន្តិវិធី ដោយមិនមានការប៉ះពាល់ដល់សិទ្ធិអ្នកដទៃ ទំនៀមទម្លាប់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិ[30]។

បញ្ញត្តិសំខាន់ៗដែលមានចែងក្នុងច្បាប់នេះ រួមការកំណត់អំពីវិសាលភាពនៃដែនអនុវត្តរបស់ច្បាប់នេះ[31] និយមន័យនៃការធ្វើបាតុកម្មដោយសន្តិវិធី[32] នីតិវិធីក្នុងការធ្វើបាតុកម្មដោយសន្តិវិធី[33] ការទទួលខុសត្រូវរបស់អ្នកដឹកនាំធ្វើបាតុកម្មនិងអាជ្ញាធរមានសមត្ថកិច្ច[34] និងនីតិវិធីនៃការដោះស្រាយបទល្មើសនិងទោសបញ្ញត្តិ[35]។

[28] ដូច២៣, មាត្រា៧
[29] ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី, មាត្រា១
[30] ដូច២៩, មាត្រា២
[31] ដូច២៩, មាត្រា៣
[32] ដូច២៩, មាត្រា៤
[33] ដូច២៩, ជំពូកទី២

### ១.២.២.៤. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាន៦៧២មាត្រា។ យោងតាមមាត្រា ៦៧២នៃក្រមព្រហ្មទណ្ឌ គន្ថីទី១នៃក្រមព្រហ្មទណ្ឌត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រម ឯបទបញ្ញត្តិផ្សេងទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល១ឆ្នាំក្រោយចូលជាធរមាននៃក្រម។

ពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាន៥ផ្នែកៗធំ។

- *ការបរិហារកេរ្តិ៍ និងការជេរប្រមាថ*

ស្ថិតក្នុងគន្ថីទី២ "បទល្មើសប្រឆាំងនឹងបុគ្គល" មាតិកាទី២ ជំពូកទី៦ ផ្នែកទី២ នៃក្រមព្រហ្មទណ្ឌ ការបរិហារកេរ្តិ៍ និងការជេរប្រមាថ មានចែកចេញជា បទបរិហារកេរ្តិ៍ជាសាធារណៈ(មាត្រា៣០៥) អំពើបរិហារកេរ្តិ៍តាមសារព័ត៌មាន(មាត្រា៣០៦) បទជេរប្រមាថជាសាធារណៈ(មាត្រា៣០៧) អំពើជេរប្រមាថតាមសារព័ត៌មាន(មាត្រា៣០៨) នីតិវិធីបណ្ដឹងចំពោះបទបរិហារកេរ្តិ៍ និងបទជេរប្រមាថ(មាត្រា៣០៩) និងទោសបន្ថែម(មាត្រា៣១០)។

- *ការគំរាមកំហែងថានឹងធ្វើការបំផ្លិចបំផ្លាញ ធ្វើឱ្យទ្រុឌទ្រោម ឬធ្វើឱ្យខូចខាត*

ស្ថិតក្នុងគន្ថីទី៣ "បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ" មាតិកាទី២ ជំពូកទី១ ផ្នែកទី២នៃក្រមព្រហ្មទណ្ឌ ការគំរាមកំហែងថានឹងធ្វើការបំផ្លិចបំផ្លាញធ្វើឱ្យទ្រុឌទ្រោមឬធ្វើឱ្យខូចខាត មានចែកចេញជា បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាត(មាត្រា៤២៣) បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នឹងបញ្ជាអ្វីមួយ(មាត្រា៤២៤) បទក្លែងព័ត៌មាន(មាត្រា៤២៥) និងទោសបន្ថែម(មាត្រា៤២៦)។

- *ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស*

ស្ថិតក្នុងគន្ថីទី៤ "បទល្មើសប្រឆាំងនឹងជាតិ" មាតិកាទី១ ជំពូកទី៣ ផ្នែកទី៣នៃក្រមព្រហ្មទណ្ឌ ការញុះញង់ឱ្យប្រព្រឹត្តបទល្មើស មានចែកចេញជា លក្ខខណ្ឌអត្ថិភាពនៃការញុះញង់ (មាត្រា៤៩៤) បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍(មាត្រា៤៩៥) បទញុះញង់ឱ្យមានការរើសអើង

[34] ដូច២៩, ជំពូកទី៣

[35] ដូច២៩, ជំពូកទី៤

(មាត្រា៤៩៦) អំពើញុះញង់ប្រព្រឹត្តតាមផ្លូវសារព័ត៌មាន(មាត្រា៤៩៧) និងទោសបន្ថែម(មាត្រា៤៩៨)។

- *ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ:*

ស្ថិតក្នុងគន្ថីទី៤ "បទល្មើសប្រឆាំងនឹងជាតិ" មាតិកាទី១ ជំពូកទី១ ផ្នែកទោលនៃក្រមព្រហ្មទណ្ឌ ការប្រមាថ និងការប្រឆាំងនឹងអ្នករាជការសាធារណៈ មានចែកចេញជា បទប្រមាថ(មាត្រា៥០២) បទប្រឆាំងនឹងអ្នករាជការសាធារណៈ(មាត្រា៥០៣) ស្ថានទម្ងន់ទោសនៃបទប្រឆាំងនឹងអ្នករាជការសាធារណៈ(មាត្រា៥០៤) បទញុះញង់ឱ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ(មាត្រា៥០៥) បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ(មាត្រា៥០៦) និងទោសបន្ថែម(មាត្រា៥០៧)។

- *ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ*

ស្ថិតក្នុងគន្ថីទី៤ "បទល្មើសប្រឆាំងនឹងជាតិ" មាតិកាទី២ ជំពូកទី១ ផ្នែកទី២នៃក្រមព្រហ្មទណ្ឌ ការប៉ះពាល់ដល់សេចក្តីសម្រេចរបស់តុលាការ មានចែកចេញជា បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ(មាត្រា៥២០) បទផ្តល់ដោយខុសច្បាប់នូវបញ្ជាឱ្យឃុំ ឬដោះលែង(មាត្រា៥២១) បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយ ដើម្បីធ្វើសម្ពាធលើយុត្តាធិការ(មាត្រា៥២២) បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ(មាត្រា៥២៣) បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ(មាត្រា៥២៤) ការប៉ុនប៉ង(មាត្រា៥២៥) និងទោសបន្ថែម(មាត្រា៥២៦)។

#### ១.២.២.៥. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

ដើម្បីធានា អភិវឌ្ឍលើវិស័យព័ត៌មាន ជាពិសេសសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋកម្ពុជាឱ្យកាន់តែទូលំទូលាយ និងដោយសេរីស្របតាមច្បាប់ ក្រសួងព័ត៌មានដោយបានសហការជាមួយអង្គការយូណេស្កូ និងប្រទេសស៊ុយអែត[36] បានរៀបចំនូវសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ ដែលគិតមកដល់ពេលនេះ(ខែមិថុនា ឆ្នាំ២០១៧) សេចក្តីព្រាងនេះកំពុងស្ថិតក្នុងការព្រាងនៅឡើយ។ ក្នុងដំណាក់កាលនៃសេចក្តីព្រាងនេះ ដោយមានការចូលរួមពីអន្តរក្រសួង រួមជាមួយដៃគូសហការ លើសពីនេះគឺមានការដាក់ឱ្យមានការបញ្ចេញមតិយោបល់ ការយល់ឃើញ

[36] គេហទំព័រក្រសួងព័ត៌មាន សេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន <http://a2i.info.gov.kh/>

របស់សាធារណជនទៅលើសេចក្តីព្រាងច្បាប់មួយនេះ តាមរយៈគេហទំព័ររបស់ក្រសួងព័ត៌មានផងដែរ។

យោងតាមមាត្រា១ នៃសេចក្តីព្រាងបឋមនៃច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដូចខាងក្រោម :

" ច្បាប់នេះមានគោលបំណងធានាឱ្យសាធារណជនគ្រប់រូបនូវសិទ្ធិ និងសេរីភាពក្នុងការទទួលព័ត៌មាន។

ច្បាប់នេះចែងពីភារកិច្ចដែលស្ថាប័នសាធារណៈនានាត្រូវផ្តល់ និងធ្វើការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៩នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ "

ក្រៅពីមាត្រានេះ នៅមានមាត្រាផ្សេងទៀតដែលបង្ហាញឱ្យឃើញពីចេតនាក្នុងការកែប្រែ និងធ្វើឱ្យមានល្អប្រសើរជាងមុន លើការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋខ្មែរស្របតាមគោលការណ៍រដ្ឋធម្មនុញ្ញ[37] ក៏ដូចជាការកំណត់នូវនិយមន័យពាក្យពេចន៍សំខាន់ៗដូចជាពាក្យព័ត៌មានប៉ះពាល់សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈជាដើម[38] ការកំណត់ពីសិទ្ធិនិងកាតព្វកិច្ចក្នុងការផ្តល់ព័ត៌មាន[39] នីតិវិធីស្នើសុំព័ត៌មាន[40] ការកំណត់វិសាលភាពទទួលបានព័ត៌មាន[41] និងការបង្រួមនូវការទទួលទោសព្រហ្មទណ្ឌឱ្យស្ថិតក្នុងទំហំតូចជាងមុន[42]ជាដើម ។

## ១.៣. បញ្ហាប្រឈម និងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា

ការសិក្សាទៅលើប្រវត្តិនៃសេរីភាពបញ្ចេញមតិ ដែលមានក្នុងរដ្ឋធម្មនុញ្ញទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ការសិក្សាទៅលើបទដ្ឋានគតិយុត្តជាតិនិងអន្តរជាតិដែលមានពាក់ព័ន្ធនឹង

[37] សេចក្តីព្រាងបឋមនៃច្បាប់ស្តីសិទ្ធិទទួលព័ត៌មាន, មាត្រា២ (សូមមើលឧបសម្ព័ន្ធទី១)

[38] ដូច៣៧, មាត្រា៤

[39] ដូច៣៧, ជំពូកទី២

[40] ដូច៣៧, ជំពូកទី៣

[41] ដូច៣៧, ជំពូកទី៤

[42] ដូច៣៧, ជំពូកទី៥

សេរីភាពបញ្ចេញមតិ បានបង្ហាញឱ្យឃើញអំពីអ្វីដែលប្រទេសកម្ពុជាបានមាន និងអ្វីដែលកម្ពុជាកំពុងតែមានក្នុងផ្លូវច្បាប់។ ក៏ប៉ុន្តែ ការសិក្សាតែទៅលើផ្លូវច្បាប់នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ពោលគឺត្រូវធ្វើការសិក្សាទៅលើការអនុវត្តជាក់ស្តែងផងដែរ។ ហេតុនេះ ក្នុងចំណុចនេះនឹងធ្វើការសិក្សាទៅលើការអនុវត្តជាក់ស្តែងតាមរយៈការលើកពីបញ្ហាប្រឈមដែលកំពុងកើតមាន និងអាចនឹងកើតមាននាថ្ងៃអនាគត(១.៣.១) រួមជាមួយនឹង ដំណោះស្រាយទៅលើបញ្ហាទាំងនោះ (១.៣.២.)។

### ១.៣.១. បញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិ

ការទទួលស្គាល់នូវលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ ការគោរពសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជាដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ សបញ្ជាក់ឱ្យឃើញថាកម្ពុជាបានទទួលយកនូវការអនុវត្តតាមគោលការណ៍ទាំងអស់នោះ។ ជាក់ស្តែង ក្នុងការធានានូវការគោរពសិទ្ធិមនុស្សជាមូលដ្ឋាននៃសេរីភាពបញ្ចេញមតិ ប្រទេសកម្ពុជាមាននូវការរៀបចំជាលិខិតបទដ្ឋានគតិយុត្តជាតិដូចបានសិក្សានៅចំណុចខាងលើ ដែលធ្វើយ៉ាងណាឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញជាច្បាប់កំពូលរបស់ជាតិ និងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិ។ និងការអនុវត្តជាក់ស្តែង ទៅលើការធានាការប្រើប្រាស់នូវសេរីភាពមួយនេះរបស់ប្រជាពលរដ្ឋឱ្យស្របតាមច្បាប់ដែលមានជាធរមាន។ ទោះជាយ៉ាងណាក៏ដោយ ទាំងច្បាប់ និងការអនុវត្តនូវសេរីភាពបញ្ចេញមតិនេះ គឺតែងតែមាននូវកង្វះខ្វះខាត បញ្ហាប្រឈមផ្សេងៗដែលមិនអាចជៀសបាន។

មុននឹងចូលទៅក្នុងបញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិរបស់ប្រទេសកម្ពុជា សូមក្រឡេកមើលនូវការវិវត្តរបស់សេរីភាពនេះក្នុងប្រទេសកម្ពុជាជាមុនសិន។ ក្រោយពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឬក្រោយពីការកសាងប្រទេសសារជាថ្មី សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជាបានវិវត្តខ្លួនពីមួយដំណាក់កាលទៅមួយដំណាក់កាល។ ការវិវត្តខ្លួននេះ គឺចាប់ពីចំណុចដែលប្រទេសកម្ពុជា ស្ថិតនៅទីតាំងដ៏គួរឱ្យកត់សម្គាល់មួយនៃការរំលោភបំពានលើសេរីភាពបញ្ចេញមតិប្រែក្លាយមកកាន់កម្រិតល្អមួយមាននូវការផ្តល់សិទ្ធិសេរីភាពបានទូលំទូលាយជាងកាលពីមុន។ ដំណើរវិវត្តខ្លួននៃសេរីភាពបញ្ចេញមតិរបស់ប្រទេសកម្ពុជា មិនមែនមានតែការអង្កេតមើលតែពីសំណាក់ជាតិ ដែលមានដូចជាអង្គការក្រៅរដ្ឋាភិបាល(NGO) អ្នកឃ្លាំមើលស្ថានភាពសិទ្ធិមនុស្ស អ្នកវិភាគឯករាជ្យជាដើមប៉ុណ្ណោះទេ ក៏មានផងដែរនូវការអង្កេតនិងតាមដានពីសំណាក់អន្តរជាតិមកលើស្ថានភាពនៃការគោរពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។ ការសង្កេតពីសំណាក់អន្តរជាតិមកកាន់កម្ពុជា រួមមានអង្គការសហប្រជាជាតិ ដែលជាប្រចាំតែងតែមាននូវវត្តមាននៃការធ្វើទស្សនកិច្ច

របស់អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិមកកាន់ប្រទេសកម្ពុជាក្នុងការតាមដាន ពិនិត្យមើលដោយផ្ទាល់លើស្ថានភាពជាក់ស្តែងដែលកម្ពុជាកំពុងស្ថិតនៅ ក៏ដើម្បីសិក្សាពីបញ្ហា និងផ្តល់ជាអនុសាសន៍ក្នុងការដោះស្រាយនូវបញ្ហានោះផងដែរ។ ក្រៅពីអ្នកនាំពាក្យពិសេសរបស់អង្គការសហប្រជាជាតិ ក៏មានផងដែរនូវការឃ្លាំមើលសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា ជាពិសេសលើសេរីភាពបញ្ចេញមតិ ក៏ដូចជាសេរីភាពសារព័ត៌មានរបស់ប្រទេសកម្ពុជា គឺអង្គការអ្នកសារព័ត៌មានគ្មានព្រំដែន[43]។ អង្គការនេះបង្កើតឡើងដើម្បីការពារអ្នកសារព័ត៌មាន និងតាមដានដោយផ្តោតសំខាន់ទៅលើស្ថានភាពសេរីភាពសារព័ត៌មាន ក៏ដូចជាសេរីភាពបញ្ចេញមតិរបស់ប្រទេសនានាទូទាំងពិភពលោក ដែលក្នុងនោះក៏មានប្រទេសកម្ពុជាមួយផងដែរ។

ការពិនិត្យតាមដាន អង្កេតលើស្ថានភាពនៃសិទ្ធិមនុស្សរបស់តួអង្គទាំងអស់នេះ អាចបង្ហាញឱ្យឃើញពីបញ្ហាប្រឈមមួយចំនួនដែលប្រទេសកម្ពុជាកំពុងជួបប្រទះ និងដើម្បីរកនូវដំណោះស្រាយល្អប្រសើរ ទៅលើបញ្ហាទាំងនោះ ធានាឱ្យបាននូវការគោរពសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធិភាពស្របតាមច្បាប់។ គួរបញ្ជាក់ផងដែរថា ការត្រួតពិនិត្យតាមដាននេះមិនមែនមានតែក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ពោលគឺមានទៅលើប្រទេសដទៃផ្សេងទៀតមិនថាជាប្រទេសអភិវឌ្ឍ ឬកំពុងអភិវឌ្ឍនោះទេ។

តាមរយៈការអង្កេតរបស់អង្គការទាំងនោះ ដោយមាននូវការដាក់ចេញជារបាយការណ៍ផ្សេងៗ រួមផ្សំនឹងការសិក្សាវិភាគទៅលើគោលការណ៍ដែលមាន ប្រទេសកម្ពុជាមាននូវបញ្ហាប្រឈមមួយចំនួន មានទាំងបញ្ហាគតិយុត្ត និងបញ្ហាអនុវត្តជាក់ស្តែងនៃសេរីភាពបញ្ចេញមតិ។

#### ១.៣.១.១. បញ្ហាគតិយុត្តនៃកង្វះស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការកាត់ក្តីបញ្ហារំលោភសេរីភាពបញ្ចេញមតិ

បញ្ហានេះ អាចនិយាយបានថាជាបញ្ហាថ្មីដែលមិនធ្លាប់មាន ឬក៏ត្រូវបានយកមកពិភាក្សាពីមុនក្នុងការសិក្សាផ្នែកច្បាប់ ជាពិសេសផ្នែកនីតិរដ្ឋធម្មនុញ្ញក្នុងប្រទេសកម្ពុជានោះទេ។ ក៏ប៉ុន្តែសម្រាប់ប្រទេសដែលមានការរីកចម្រើនផ្នែកសិទ្ធិមនុស្ស ដែលមានដូចជាប្រទេសបារាំង សហរដ្ឋអាមេរិក ប្រទេសជប៉ុនជាដើម គឺសុទ្ធតែមាននូវស្តង់ដារគតិយុត្តដោយឡែកពិសេសក្នុងការទុកសម្រាប់កាត់ក្តីលើបញ្ហារំលោភបំពានសេរីភាពបញ្ចេញមតិនេះ។ ដោយឡែក សម្រាប់ប្រទេស

[43] អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Sans Frontières、Reporters Without Borders) គឺជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិដែលត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងឆ្នាំ១៩៨៥។ (កាលបរិច្ឆេទចូលទស្សនាចុងក្រោយថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៧) <https://rsf.org/en/cambodia>

កម្ពុជាវិញ នៅមិនទាន់មានសូម្បីតែការពិភាក្សាក្នុងការពិចារណាយកនូវស្តង់ដារនេះមកអនុវត្តនៅឡើយទេ។

មុននឹងធ្វើការពិភាក្សាស៊ីជម្រៅ លើបញ្ហានៃកង្វះស្តង់ដារគតិយុត្តិមួយនេះក្នុងប្រទេសកម្ពុជា សូមធ្វើការសិក្សា អំពីស្តង់ដារគតិយុត្តក្នុងការកាត់ក្តីបញ្ហាសេរីភាពបញ្ចេញមតិនេះជាមុនសិន។ ស្តង់ដារគតិយុត្តនេះ ត្រូវបានបង្កើតឡើង និងប្រើប្រាស់នៅក្នុងប្រព័ន្ធយុត្តាធិការរបស់ប្រទេសដែលយកចិត្តទុកដាក់ខ្លាំងលើបញ្ហាសិទ្ធិមនុស្ស។ ស្តង់ដារនេះ ត្រូវបានបង្កើតឡើងដោយផ្តោតជាសំខាន់ទៅលើបញ្ហារំលោភបំពានសេរីភាពបញ្ចេញមតិផ្ទាល់តែម្តង។ នៅពេលដែលមាននូវការរំលោភបំពានលើសេរីភាពបញ្ចេញមតិ ដែលត្រូវធ្វើការជំនុំជម្រះក្តី តុលាការនៃបណ្តាប្រទេសទាំងនោះនឹងយកស្តង់ដារដែលមានចែងទុកនោះមកធ្វើជាមូលដ្ឋានក្នុងការពិចារណាក្តី។ ស្តង់ដារក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពនៃការរំលោភបំពានសេរីភាពបញ្ចេញមតិនេះ ត្រូវបានអនុវត្តផ្សេងគ្នាទៅតាមប្រព័ន្ធច្បាប់នៃប្រទេសនីមួយៗ។ ក្នុងប្រទេសបារាំង ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព មិនមែនជាតុលាការនោះទេ តែគឺជាតុលាការធម្មនុញ្ញ។ ដូច្នេះ តុលាការធម្មនុញ្ញ នៅពេលដែលមានបណ្តឹងស្តីពីការការរំលោភសេរីភាពបញ្ចេញមតិ តុលាការធម្មនុញ្ញបារាំងនឹងយក ស្តង់ដារដែលមាននោះមកពិចារណា។ ដោយឡែក នៅសហរដ្ឋអាមេរិក ប្រទេសជប៉ុនឯណោះវិញ ប្រទេសទាំងពីរនេះ មិនមាននូវតុលាការធម្មនុញ្ញនោះទេ ពោលគឺអ្នកដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យធម្មនុញ្ញភាពគឺតុលាការតែម្តង។

ដោយឡែក ក្រឡេកមកមើលករណីប្រទេសកម្ពុជាវិញម្តង។ អ្វីដែលដឹងគ្រប់គ្នា គឺបើនិយាយពីសមត្ថកិច្ចត្រួតពិនិត្យធម្មនុញ្ញភាព គឺជារបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ហើយសមត្ថកិច្ចនេះទៀតសោត គឺជាការបកស្រាយនូវធម្មនុញ្ញភាពរបស់ច្បាប់ និងការដោះស្រាយនូវវិវាទកើតឡើងនៅពេលបោះឆ្នោត។ នេះជាសមត្ថកិច្ចដែលក្រុមប្រឹក្សាធម្មនុញ្ញមាន ហើយដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ បែបនេះ ឃើញថាការដោះស្រាយនូវបញ្ហានៃការរំលោភសិទ្ធិមនុស្សទូទៅ មិនថាតែលើបញ្ហាសេរីភាពបញ្ចេញមតិ គឺមិនមែនជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនោះទេ។ ត្រង់ចំនុចនេះមាននូវរឿងពីរដែលត្រូវពិចារណា។ ទីមួយ គឺប្រទេសបារាំងដែលមាននូវតុលាការធម្មនុញ្ញដូចនឹងប្រទេសកម្ពុជាដែរ ហើយដែលរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបានទទួលឥទ្ធិពលពីប្រទេសបារាំង នៅប្រទេសបារាំងមាននូវស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពនេះ ប៉ុន្តែនៅប្រទេសកម្ពុជាមិនមាននូវស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពនេះទេ។ ទីពីរ គឺការនៅតែបន្តមាននូវបញ្ហានៃការរំលោភសិទ្ធិមនុស្សកើតមានក្នុងប្រទេសកម្ពុជា។ បញ្ហាសិទ្ធិមនុស្ស

នៅតែបន្តកើតមាន ក៏ប៉ុន្តែដំណោះស្រាយដែលជនរងគ្រោះអាចប្រើប្រាស់និងអាចជឿជាក់បាន មិនមាន ហេតុនេះ គឺរាល់រឿងក្តីដែលកើតមានឡើងបានត្រឹមតែបញ្ចប់ទៅទាំងគ្មានដំណោះស្រាយត្រឹមត្រូវ និង ច្បាស់លាស់។

### ១.៣.១.២. បញ្ញាតតិយុត្តមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាន

ដូចដែលបានដឹងហើយថា សេរីភាពសារព័ត៌មានជាសេរីភាពមួយដែលសំខាន់ ហើយទូលំទូលាយសម្រាប់មនុស្ស។ សេរីភាពសារព័ត៌មាន គឺជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិ។ បន្ថែមពីការធានានូវការគោរពសេរីភាពសារព័ត៌មាន ក៏ដូចជាសេរីភាពបោះពុម្ពផ្សាយ តាមរយៈមាត្រា៤១នៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាមាននូវលិខិតបទដ្ឋានគតិយុត្តដែលជាច្បាប់ស្តីពីរបបសារព័ត៌មាន។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងធានាការពារនូវសេរីភាពសារព័ត៌មានឱ្យស្របទៅនឹងមាត្រា៣១ និងមាត្រា៤១នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា។ ថ្វីត្បិតតែមាននូវការចែងឱ្យឃើញពីការការពារលើសេរីភាពនេះយ៉ាងណាក្តី ច្បាប់ស្តីពីរបបសារព័ត៌មាននេះ មាននូវបញ្ញាតតិយុត្តមួយចំនួន។ បញ្ញាតតិយុត្តនោះ គឺស្ថិតក្នុងមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

មុននឹងសិក្សាលើបញ្ញាតតិតយុត្តនៃមាត្រា១២នេះ សូមលើកយកនូវមាត្រា១២នេះជាមុនសិន។ មាត្រា១២ វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មានចែងថា :

" សារព័ត៌មានមិនត្រូវបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថេរភាពនយោបាយ" ។

#### ក. និយមន័យពាក្យ "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ"

បញ្ញាតតិយុត្តដែលមានក្នុងមាត្រានេះ គឺនិយមន័យនៃវាក្យសព្ទ "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ" ។ គួរបញ្ជាក់ដែរថា បញ្ហានេះត្រូវបានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដាក់នៅក្នុងរបាយការណ៍របស់ខ្លួនស្តីពីបញ្ហាសិទ្ធិមនុស្ស។

ក្នុងច្បាប់ស្តីពីរបបសារព័ត៌មាននេះ មិនមាននូវមាត្រាណាមួយចែងផ្តល់និយមន័យវាក្យសព្ទនេះទេ។ នៅពេលដែលមិនមាននូវនិយមន័យលើវាក្យសព្ទទាំងពីរនេះបែបនេះ បញ្ហាដែលមិនអាចជៀសបាននោះគឺ ការរំលោភលើសេរីភាពសារព័ត៌មានរបស់អ្នកសារព័ត៌មាន។ មាននូវការរំលោភសេរីភាពនេះ ព្រោះថាអវត្តមាននៃនិយមន័យវាក្យសព្ទទាំងពីរនេះនឹងក្លាយជាប្រយោជន៍ ឬនិយាយដោយងាយស្រួលថាជាលេសសម្រាប់បុគ្គលមួយចំនួនការពារខ្លួន។

នៅពេលដឹងថាមាននូវការបោះពុម្ពផ្សាយ ឬផ្សាយនូវព័ត៌មានណាមួយដែលអាចនឹងមាននូវការទម្លាយអាថ៌កំបាំង រឿងផ្ទៃក្នុងណាមួយដែលមិនចង់ឱ្យដឹងរបស់បុគ្គលដែលមានឋានៈខ្ពស់

មន្ត្រីថ្នាក់ធំ ឬរាជរដ្ឋាភិបាលណាមួយនោះ បុគ្គលទាំងអស់នោះនឹងលើកអំណះអំណាងថាមានការប៉ះពាល់ដល់សន្តិសុខជាតិ ឬស្ថេរភាពនយោបាយ ដូច្នេះមិនអាចធ្វើការបោះពុម្ពផ្សាយ ឬផ្សាយព័ត៌មាននោះបានទេ។ នៅពេលនោះនឹងមានសំនួរសួរថា ហេតុអ្វីបានជាប៉ះពាល់ដល់សន្តិសុខជាតិ ឬស្ថេរភាពនយោបាយបែបនេះ? សំនួរនេះអាចឆ្លើយបានតាមរយៈនិយមន័យវាក្យសព្ទទាំងពីរនេះ តែដោយសារតែគ្មាននូវការកំណត់និយមន័យក្នុងច្បាប់ នោះនឹងធ្វើឱ្យមានចម្ងល់ទៅលើនិយមន័យនៃវាក្យសព្ទទាំងពីរ ថាអ្វីទៅជាសន្តិសុខជាតិ និងអ្វីទៅជាស្ថេរភាពនយោបាយ។ ដោយសារមិនមាននូវការកំណត់នូវនិយមន័យវាក្យសព្ទនេះ នោះនឹងជាឱកាសឱ្យមាននូវការបកស្រាយនិយមន័យនៃវាក្យសព្ទនេះដោយសេរី មិនមានកំណត់ និងបកស្រាយសម្រាប់ការពារខ្លួនគេបាន។ យ៉ាងនេះហើយ ដែលធ្វើឱ្យមាននូវការរំលោភបំពានមកលើសេរីភាពសារព័ត៌មានដោយសារភាពខ្វះចន្លោះនៃច្បាប់បែបនេះ។

**ខ. ធម្មនុញ្ញភាពនៃមាត្រា១២ច្បាប់ស្តីពីរបបសារព័ត៌មាន**

ក្នុងមាត្រា១២វាក្យខណ្ឌទី១នេះដដែល មាននូវបញ្ហាគតិយុត្តមួយទៀតដែលទាក់ទិនទៅនឹងធម្មនុញ្ញភាពរបស់មាត្រានេះ ជាមួយនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន។ និយាយម៉្យាងទៀតថា មាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាននេះស្របទៅនឹងរដ្ឋធម្មនុញ្ញដែរឬទេ។ ចំពោះបញ្ហានេះ ត្រូវបានលើកឡើងដោយអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាផងដែរ ។

សំនួរសួរថា តើអ្វីទៅជាបញ្ហាធ្វើឱ្យមាននូវការពិភាក្សាលើធម្មនុញ្ញភាពនៃមាត្រា២១វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាននេះ? បញ្ហានោះ គឺស្ថិតនៅត្រង់វាក្យសព្ទ "ស្ថេរភាពនយោបាយ" ដែលមានក្នុងមាត្រានេះ។

ដូចដែលបានរៀបរាប់មកជាបន្តបន្ទាប់ហើយថា ច្បាប់ស្តីពីរបបសារព័ត៌មាននេះបង្កើតឡើងក្នុងគោលបំណងធានាការពារសេរីភាពសារព័ត៌មាន សេរីភាពបោះពុម្ពផ្សាយក្នុងប្រទេសកម្ពុជាឱ្យស្របទៅនឹងមាត្រា៣១ និងមាត្រា៤១នៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន។ ខ្លឹមសារនេះមានកំណត់ក្នុងមាត្រា១នៃច្បាប់ស្តីពីរបបសារព័ត៌មាន។ ជាថ្មីម្តងទៀត មាត្រា៣១នៃរដ្ឋធម្មនុញ្ញចែងអំពីការទទួលស្គាល់របស់ប្រទេសកម្ពុជាក្នុងការគោរពសិទ្ធិមនុស្ស ស្របទៅតាមលិខិតបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្សដែលកម្ពុជាបានទទួលស្គាល់ ដោយគ្មានការរើសអើងអ្វីឡើយ។ រីឯ មាត្រា៤១នៃរដ្ឋធម្មនុញ្ញ បានចែងអំពីការគោរពចំពោះការមានសិទ្ធិរបស់ប្រជាពលរដ្ឋលើសេរីភាព

បញ្ចេញមតិ សេរីភាពសារព័ត៌មានជាដើម លើកលែងតែមានការប៉ះពាល់ទៅដល់កិត្តិយសរបស់អ្នកដទៃ ទំនៀមទំលាប់ល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិ។

តាមការលើកឡើងត្រួសៗសារជាថ្មីនូវមាត្រា៣១ និងមាត្រា៤១នៃរដ្ឋធម្មនុញ្ញរួចមក សូមធ្វើការប្រៀបធៀបរវាងមាត្រា៤១នៃរដ្ឋធម្មនុញ្ញ និងមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាន ដោយទុកមាត្រា៣១នៃរដ្ឋធម្មនុញ្ញមួយឡែកសិន។ នៅពេលដែលធ្វើការប្រៀបធៀបមាត្រាទាំងពីរនេះ នឹងឃើញមាននូវចំណុចខុសគ្នានៃមាត្រាទាំងពីរនេះ។ ចំណុចខុសគ្នានោះ គឺត្រង់ក្នុងមាត្រា៤១នៃរដ្ឋធម្មនុញ្ញ មិនមាននូវវាក្យសព្ទ "ស្ថេរភាពនយោបាយ" ដូចក្នុងមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាននោះទេ។ វាក្យសព្ទ "ស្ថេរភាពនយោបាយ" នេះត្រូវបានប្រើក្នុងមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាន ក្នុងការកំណត់នូវវិសាលភាពដែលអាចបោះពុម្ពផ្សាយ ឬផ្សាយនូវសារព័ត៌មានបាន។ មានន័យថា នៅពេលដែលសារព័ត៌មានមួយត្រូវបានចង្អុលថាប៉ះពាល់ដល់ស្ថេរភាពនយោបាយ សារព័ត៌មាននោះមិនអាចផ្សាយចេញបានឡើយ។ ពិតប្រាកដណាស់ ក្នុងការដាក់ឱ្យអនុវត្តនូវសិទ្ធិអ្វីក៏ដោយ គឺមិនអាចមិនកំណត់ព្រំដែនវិសាលភាពនៃសិទ្ធិសេរីភាពនោះបានទេ ត្រូវតែមាននូវការកម្រិតមួយត្រឹមត្រូវតាមច្បាប់។ មាត្រា៤១នៃរដ្ឋធម្មនុញ្ញក៏មានដែរនូវការកំណត់វិសាលភាពនៃសេរីភាពបញ្ចេញមតិនេះ ដូចបានរៀបរាប់ខាងលើ តែមិនមាននូវការហាមមិនឱ្យប៉ះពាល់ដល់ "ស្ថេរភាពនយោបាយ" នោះទេ។

បញ្ហាដែលត្រូវពិចារណាមានពីរ ទីមួយគឺនិយមន័យនៃវាក្យសព្ទ "ស្ថេរភាពនយោបាយ" មុននឹងចូលទៅដល់បញ្ហាទីពីរដែលជាបញ្ហានៃធម្មនុញ្ញភាពមាត្រា១២វាក្យខណ្ឌទី១នេះ។ ទាក់ទិននឹងបញ្ហាធម្មនុញ្ញភាពនេះ ចាំបាច់ត្រូវលើកយកនូវបញ្ហានិយមន័យនៃវាក្យសព្ទនេះមកម្តងទៀត មូលហេតុគឺ ដើម្បីដឹងពីគោលបំណងដែលនីតិនិពន្ធបានយកវាក្យសព្ទនេះមកដាក់ក្នុងមាត្រានេះ។ ប៉ុន្តែ ដោយសារតែមិនមាននូវការកំណត់និយមន័យវាក្យសព្ទនេះ ហេតុនេះបញ្ហានៃអវត្តមាននិយមន័យ "ស្ថេរភាពនយោបាយ"នេះ បានក្លាយជាផ្នែកមួយធ្វើឱ្យមាននូវបញ្ហាធម្មនុញ្ញភាពនៃមាត្រានេះកើតឡើង។

ចូលដល់បញ្ហាទីពីរតែម្តងដែលជាបញ្ហាត្រូវពិភាក្សាក្នុងចំណុចនេះ មានការលើកឡើងអំពីអធម្មនុញ្ញភាពនៃមាត្រា១២វាក្យខណ្ឌទី១នេះ ការលើកឡើងនេះ មានន័យថាមាត្រា១២វាក្យខណ្ឌទី១នេះមិនស្របទៅនឹងរដ្ឋធម្មនុញ្ញបច្ចុប្បន្ននោះទេ។ មិនស្របព្រោះថា ក្នុងមាត្រា១២វាក្យខណ្ឌទី ១ នៃច្បាប់ស្តីពីរបបសារព័ត៌មានមានបន្ថែមវាក្យសព្ទគតិយុត្ត "ស្ថេរភាពនយោបាយ" ដែលក្នុងមាត្រា៤១នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្នមិនមាន។ ដោយគិតថា ការបន្ថែមនូវវាក្យសព្ទនេះ ជាចេតនារបស់

អ្នកបង្កើតច្បាប់នេះដើម្បីទុកចន្លោះដល់អ្នកអនុវត្តផ្ទាល់ ជាពិសេសអ្នកនយោបាយនៅពេលដែលមាននូវអាថិកំបាំងខាងនយោបាយ ឬប៉ះពាល់ដល់ផ្ទៃក្នុងរបស់ពួកគេ អ្នកសារព័ត៌មានមិនអាចធ្វើការផ្សាយបានឡើយដោយមូលហេតុប៉ះពាល់ដល់ស្ថេរភាពនយោបាយ។ ប៉ុន្តែ សួរថាអ្វីទៅជាស្ថេរភាពនយោបាយ គឺមិនមានមាត្រាណាមួយនៃច្បាប់ស្តីពីរបបសារព័ត៌មានចែងពីនិយមន័យនេះទេ គឺធ្វើឱ្យមានការបកស្រាយបានដោយសេរី និងសម្រាប់ប្រយោជន៍ពួកគេ។ មកដល់ត្រឹមនេះ ជាការប្រៀបធៀបគ្នារវាងមាត្រា៤១នៃរដ្ឋធម្មនុញ្ញ និងមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

ជាបន្តសូមក្រឡេកមើលទៅមាត្រា៣១នៃរដ្ឋធម្មនុញ្ញវិញម្តង មាត្រា៣១ក៏ជាមាត្រាដែលច្បាប់ស្តីពីរបបសារព័ត៌មានត្រូវគោរពតាម (មាត្រា១នៃច្បាប់ស្តីពីរបបសារព័ត៌មាន)។ យោងតាមមាត្រា៣១នៃរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាត្រូវគោរពសិទ្ធិមនុស្សឱ្យស្របទៅនឹងលិខិតបទដ្ឋានគតិយុត្តអន្តរជាតិស្តីពីសិទ្ធិមនុស្សនានាដែលខ្លួនបានទទួលស្គាល់។ ដូចបានរៀបរាប់នៅចំណុចស្តីពីបទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិខាងលើ បទដ្ឋានគតិយុត្តអន្តរជាតិស្តីពីសិទ្ធិមនុស្សនៃសេរីភាពបញ្ចេញមតិដែលកម្ពុជាបានទទួលស្គាល់នោះ គឺមានដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយជាដើម។ ក្នុងបទដ្ឋានគតិយុត្តអន្តរជាតិទាំងពីរ មាត្រាស្តីពីសេរីភាពបញ្ចេញមតិ ក៏មិនមាននូវវាក្យសព្ទដូច ឬមានអត្ថន័យស្រដៀងនឹងវាក្យសព្ទ "ស្ថេរភាពនយោបាយ" ដែលមានក្នុងមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មានឡើយ។ តាមអំណះអំណាងទាំងអស់នេះហើយ ទើបមានការលើកឡើងនូវបញ្ហាអធម្មនុញ្ញភាពនៃមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្តីពីរបបសារព័ត៌មាន។ គួរបន្ថែមផងដែរថា ការលើកឡើងនេះមិនមែនមានតែអង្គការក្រៅរដ្ឋាភិបាលមួយប៉ុណ្ណោះទេ គឺមានតាំងពីនៅពេលដែលតំណាងរាស្ត្រធ្វើការប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីរបបសារព័ត៌មានឯណោះ[44] ក៏មានការលើកឡើងពីការដាក់វាក្យសព្ទនេះដែលធ្វើឱ្យប៉ះពាល់ដល់សេរីភាពសារព័ត៌មាន ពោលគឺធ្វើឱ្យអ្នកសារព័ត៌មានមិនហ៊ានក្នុងការផ្សព្វផ្សាយ បើផ្សាយក៏ផ្សាយបានតែព័ត៌មានខ្លះៗ ដោយលាក់បាំងមិនគ្រប់ជ្រុងជ្រោយ ឬដល់ថ្នាក់ផ្សាយនូវព័ត៌មានដែលមានទំនោរលំអៀងទៅម្ខាងៗ។

ផ្ទុយទៅនឹងការលើកឡើងពីអធម្មនុញ្ញភាពនៃមាត្រា១២វាក្យខណ្ឌទី១នេះ ក៏មាននូវមតិលើកឡើងពីធម្មនុញ្ញភាពនៃមាត្រាដដែលនេះថាមិនមានភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញអ្វីនោះទេ។ មូលហេតុមកពី ការតាក់តែងរដ្ឋធម្មនុញ្ញដែលជាច្បាប់គ្រឹះរបស់ប្រទេសនោះ គឺត្រូវតាក់តែងនូវខ្លឹមសារ

[44] កំណត់ហេតុពិស្តារច្បាប់ស្តីពីរបបសារព័ត៌មាន

គោលៗ មិនអាចចែងលម្អិតបាននោះទេ ការចែងលម្អិតត្រូវទុកឱ្យច្បាប់ដោយឡែក។ ដូច្នេះ ច្បាប់ដោយឡែក ដែលក្នុងករណីនេះ គឺច្បាប់ស្ដីពីរបបសារព័ត៌មានអាចចែងលម្អិតពីលើរដ្ឋធម្មនុញ្ញបាន។ ជាសរុបមក គឺមិនមានភាពផ្ទុយគ្នាទៅនឹងរដ្ឋធម្មនុញ្ញនោះទេ[45]។

ទោះជាមានការលើកឡើងនូវគំនិតពីរផ្ទុយគ្នាបែបនេះក៏ដោយ ប៉ុន្តែអ្វីដែលចោទជាបញ្ហានោះ គឺមិនទាន់មាននូវចម្លើយមួយពិតប្រាកដដែលត្រូវបានទទួលស្គាល់តាមច្បាប់នៅឡើយទេ។ ពោលគឺ គ្មាននរណាម្នាក់អាចបកស្រាយពីធម្មនុញ្ញភាពរបស់ច្បាប់ក្រៅពីក្រុមប្រឹក្សាធម្មនុញ្ញបាននោះទេ។ អាចនិយាយម៉្យាងទៀតបានថា ដោយសារតែមកដល់ពេលនេះ មិនទាន់មាននូវបណ្ដឹងបែបនេះដាក់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញក៏មិនអាចចេញនូវសេចក្ដីសម្រេចណាមួយស្ដីពីភាពមាន ឬគ្មានធម្មនុញ្ញភាពនៃមាត្រា១២វាក្យខណ្ឌទី១នៃច្បាប់ស្ដីពីរបបសារព័ត៌មាននេះបានដែរ។

### ១.៣.១.៣. បញ្ហាអនុវត្តជាក់ស្ដែងនៃអ្នកសារព័ត៌មាន

យោងតាមរបាយការណ៍នានាដែល ចេញដោយអង្គការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា បានបង្ហាញនូវការព្រួយបារម្ភណ៍ ចំពោះការរឹតត្បិតនូវសេរីភាពបញ្ចេញមតិ ក៏ដូចជាសេរីភាពសារព័ត៌មានមួយចំនួន។ តាមរយៈរបាយការណ៍មុនៗរបស់អង្គការទាំងអស់នោះ មាននូវការបង្ហាញពីការចាប់ខ្លួន ការធ្វើឃាតអ្នកកាសែតមួយចំនួន។ តែនាពេលបច្ចុប្បន្ននេះ សង្កេតឃើញថាបញ្ហាសង្គមទាំងអស់នេះ មាននូវការកាត់បន្ថយបានមួយកម្រិតធំដែរ ដោយមាននូវការផ្ដល់សិទ្ធិសេរីភាពទូលំទូលាយ ដល់អ្នកកាសែតក្នុងការយកព័ត៌មាន។

តែទោះជាយ៉ាងណាក៏ដោយ ក៏សង្កេតឃើញមាននូវបញ្ហាមួយចំនួននៅបន្តកើតឡើងលើវិស័យសារព័ត៌មាននេះ។ បញ្ហាដែលមាននោះ គឺប្រទាក់ក្រឡាទៅនឹងបញ្ហាគតិយុត្តដែលបានលើកឡើងខាងលើស្ដីពីកង្វះនិយមន័យវាក្យសព្ទ និងការដាក់បន្ថែមវាក្យសព្ទ "ស្ថេរភាពនយោបាយ" ដែលមានតែក្នុងច្បាប់ស្ដីពីរបបសារព័ត៌មាននេះឯង។ សង្គមមួយមានច្បាប់ តែនៅពេលដែលច្បាប់នោះមានបញ្ហា នឹងបង្កឱ្យកើតជាបញ្ហាសង្គម។ ដូចគ្នាដែរ ដោយសារតែច្បាប់ស្ដីពីរបបសារព័ត៌មានមាននូវបញ្ហាមួយចំនួនដូចដែលបានលើកឡើងខាងលើ បញ្ហាជាក់ស្ដែងក៏ត្រូវកើតមានចំពោះអ្នកសារព័ត៌មានទៅតាមនោះដែរ។

[45] ការធ្វើបទសម្ភាសន៍សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមួយរូប។

បញ្ហាជាក់ស្តែងដែលមាននោះគឺ ឯករាជភាពនៃអ្នកសារព័ត៌មាន ការប្រព្រឹត្តខុសនឹងវិជ្ជាជីវៈអ្នកសារព័ត៌មានជាដើម។

**ក. បញ្ហាឯករាជភាពនៃអ្នកសារព័ត៌មាន**

បញ្ហាដែលទាក់ទងនឹងឯករាជភាពនៃអ្នកសារព័ត៌មាននោះគឺ អ្នកសារព័ត៌មាន បណ្តាញផ្សព្វផ្សាយសារព័ត៌មានដែលមានទូរទស្សន៍ វិទ្យុ សារព័ត៌មានតាមគេហទំព័រផ្សេងៗ នៅមិនទាន់មាននូវឯករាជភាពពេញលេញនៅឡើយ។ អ្នកសារព័ត៌មានទាំងនោះ ធ្វើការផ្សព្វផ្សាយព័ត៌មានណាដែលត្រូវបានអនុញ្ញាតឱ្យផ្សាយតែប៉ុណ្ណោះ ទោះជាព័ត៌មាននោះពិត ឬមិនពិតយ៉ាងណាក៏ដោយ។ អ្នកសារព័ត៌មាន គឺជាអ្នកមាននូវភារកិច្ចក្នុងការបំពេញការងារសម្រាប់ផ្សព្វផ្សាយព័ត៌មានក្នុងសង្គមជូនដល់ប្រជាពលរដ្ឋ ដើម្បីឱ្យពួកគេអាចដឹងពីព្រឹត្តិការណ៍ ដំណើរវិវត្តក្នុងសង្គមផ្សេងៗ។ ប៉ុន្តែ នៅពេលដែលអ្នកសារព័ត៌មាន ផ្សព្វផ្សាយនូវព័ត៌មានដែលមិនពិត មិនច្បាស់លាស់បែបណាមួយ ប្រជាពលរដ្ឋក៏នឹងទទួលបានព័ត៌មានបែបនោះដែរ។ គួរលើកឡើងផងដែរថា ភ្ជាប់ជាមួយនឹងសេរីភាពបញ្ចេញមតិដែលជាសេរីភាពមូលដ្ឋាន សំខាន់ចាំបាច់និងមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋ ប្រជាពលរដ្ឋមាននូវសិទ្ធិក្នុងការទទួលបានព័ត៌មាន។ សិទ្ធិទទួលបានព័ត៌មាន គឺជាសិទ្ធិដ៏សំខាន់និងមិនអាចខ្វះបានរបស់ប្រជាពលរដ្ឋក្នុងសង្គមមួយ ហើយព័ត៌មាននោះត្រូវតែជាព័ត៌មានដែលពិត។ ពីព្រោះថា តាមរយៈការទទួលបាននូវព័ត៌មាន ប្រជាពលរដ្ឋអាចបំពេញកាតព្វកិច្ច ក្នុងការកំណត់នូវជោគវាសនារបស់ប្រទេសជាតិខ្លួន[46] បានដោយត្រឹមត្រូវពិតប្រាកដ។ និយាយដោយសម្រាយ ប្រជាពលរដ្ឋត្រូវទទួលបានព័ត៌មាន ជាពិសេសព័ត៌មានដែលទាក់ទងទៅនឹងសេវា សាធារណៈ រាជរដ្ឋាភិបាល ការអភិវឌ្ឍប្រទេស ដំណើរការរៀបចំប្រទេស បញ្ហាដែលប្រទេសខ្លួនកំពុងប្រឈមសព្វគ្រប់បែបយ៉ាង ដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តបានដោយត្រឹមត្រូវនៅពេលធ្វើការបោះឆ្នោត។ បែបនេះ បញ្ហានៃឯករាជភាពរបស់អ្នកសារព័ត៌មានដែលកំពុងបន្តមានសព្វថ្ងៃនេះ ជាបញ្ហាដែលតែត្រូវរកដំណោះស្រាយ ដើម្បីធានាឱ្យនូវការប្រព្រឹត្តិទៅបានដោយត្រឹមត្រូវនូវសេរីភាពសារព័ត៌មាន និងជាការធានាឱ្យបានប្រាកដថាសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋពិតជាមានពេញលេញប្រាកដមែន។

[46] មាត្រា៥១ថ្មីវាក្យខណ្ឌទី២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា " ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន" ។

**ខ. បញ្ហាវិជ្ជាជីវៈអ្នកសារព័ត៌មាន**

បញ្ហាមួយទៀត ដែលទាក់ទងនឹងវិជ្ជាជីវៈអ្នកសារព័ត៌មាន។ ស្ថានភាពសារព័ត៌មាននៅកម្ពុជាពេលបច្ចុប្បន្ននេះ មាននូវការរីកចម្រើនបានច្រើនដែលគួរឱ្យកត់សម្គាល់។ សង្កេតឃើញមាននូវការរៀបចំដំណើរការផ្សព្វផ្សាយព័ត៌មាន ទៅតាមបច្ចេកទេសទំនើបដូចនឹងសារព័ត៌មាននៅបណ្ដាប្រទេសរីកចម្រើនជាដើម ក៏មានដូចជាការបង្កើតនូវសមាគមអ្នកសារព័ត៌មានកម្ពុជា ។

ប៉ុន្តែ ទន្ទឹមនឹងនេះដែរ សង្កេតឃើញការប្រព្រឹត្តខុសទៅនឹងវិជ្ជាជីវៈអ្នកសារព័ត៌មានរបស់អ្នកសារព័ត៌មានមួយចំនួន។ ជាក់ស្តែង ក្នុងការបិទបញ្ចប់សិក្ខាសាលាស្តីពីការបណ្តុះបណ្តាលអ្នកសារព័ត៌មាន លោក ប៉ែន បូណា ប្រធានអ្នកកាសែតកម្ពុជា បានលើកឡើងថា សព្វថ្ងៃប្រទេសកម្ពុជាមានអ្នកសារព័ត៌មានច្រើន ប៉ុន្តែអ្នកព័ត៌មានដែលមានវិជ្ជាជីវៈនៅមិនទាន់មានច្រើននៅឡើយ។ អ្នកសារព័ត៌មានទាំងនោះ ខ្លះបំពេញការងារជាអ្នកសារព័ត៌មានដោយខ្វះវិជ្ជាជីវៈ ដោយការប្រើប្រាស់នូវពាក្យពេចន៍ផ្តាំផ្តង ការរៀបចំតវិយាបថមិនទាន់បានត្រឹមត្រូវជាដើម។ ឯខ្លះទៀតបំពេញការងារលើសពីវិជ្ជាជីវៈរបស់ខ្លួន ដោយលើសពីការផ្សាយព័ត៌មាន អ្នកសារព័ត៌មានមួយចំនួនធ្វើការវិភាគដោយគំនិតជ្រុលនិយម ដែលធ្វើឱ្យក្លាយជាមានការភាន់ច្រឡំជាដើម។ មួយចំនួនទៀត ធ្វើការផ្សាយនូវព័ត៌មានដែលមិនពិត ឬបំផ្លើស ឬបំប៉ោងព័ត៌មានហួសពីការពិតក៏មាន។ បញ្ហាទាំងអស់នេះ ដែលជាកត្តាធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមិនទាន់មាននូវការជឿជាក់ទុកចិត្តទៅលើសារព័ត៌មានខ្មែរនាពេលបច្ចុប្បន្នបានទាំងស្រុងនៅឡើយ។

### ១.៣.២. ដំណោះស្រាយបញ្ហាសេរីភាពបញ្ចេញមតិ

#### ១.៣.២.១. ការពិចារណាលើស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការកាត់ក្តីបញ្ហាសេរីភាពបញ្ចេញមតិ

នៅមិនទាន់មានការលើកឡើង ឬក៏ពិភាក្សាលើការសិក្សានាំយកនូវស្តង់ដារត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការកាត់ក្តីនៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ ដើម្បីដោះស្រាយលើកង្វល់នៃបញ្ហាសិទ្ធិមនុស្សដែលនៅតែបន្តកើតមានឡើងជារឿយៗ ដំណោះស្រាយដែលមានស្រាប់ត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវ និងខ្ជាប់ខ្ជួន តែទន្ទឹមនឹងនេះ ការសិក្សាក្នុងការជ្រើសរើសយកវិធីថ្មីក៏គួរតែត្រូវពិចារណា។ ហេតុនេះ ដើម្បីធានាឱ្យបាននូវការគោរពសិទ្ធិមនុស្ស ការធានាឱ្យបាននូវនីតិរដ្ឋមួយដ៏ល្អ និងពេញលេញ ការពិភាក្សាក្នុងការនាំយកនូវស្តង់ដារនៃការត្រួតពិនិត្យធម្មនុញ្ញភាពក្នុងការដោះស្រាយលើបញ្ហារំលោភសិទ្ធិមនុស្ស ពិសេសបញ្ហាសេរីភាពបញ្ចេញមតិគប្បីលើកយកមកពិភាក្សា និងពិចារណា។

### ១.៣.២.២. មាត្រា១២ច្បាប់ស្តីពីរបបសារព័ត៌មាន

#### ក. និយមន័យពាក្យសព្ទគតិយុត្ត "សន្តិសុខជាតិ" និង "ស្ថេរភាពនយោបាយ"

ទាក់ទិនងនឹងបញ្ហានិយមន័យនៃវាក្យសព្ទគតិយុត្ត ដែលមានក្នុងមាត្រា១២វាក្យខណ្ឌទី១ នៃច្បាប់ស្តីពីរបបសារព័ត៌មាននេះ តំណាងរាស្ត្រនៅពេលធ្វើសេចក្តីព្រាងច្បាប់ស្តីពីរបបសារព័ត៌មាន ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលដែលមានក្នុងប្រទេសកម្ពុជាបច្ចុប្បន្នបានធ្វើការលើកឡើង និង ផ្តល់ជាអនុសាសន៍ចំពោះបញ្ហានេះ។

នៅពេលធ្វើការប្រជុំក្នុងវិមានរដ្ឋសភាលើសេចក្តីព្រាងច្បាប់ស្តីពីរបបសារព័ត៌មាន មានតំណាងរាស្ត្រមកពីគណបក្សហ្វុន ស៊ិនប៉ិច បានលើកឡើងនូវសំណួរស្រដៀងគ្នាទាក់ទងទៅនឹងនិយមយ័យនៃវាក្យសព្ទទាំងពីរនេះទៅកាន់រដ្ឋមន្ត្រីក្រសួងព័ត៌មាន។ ឆ្លើយតបទៅនឹងសំណួររបស់តំណាងរាស្ត្រទាំងពីររូប រដ្ឋមន្ត្រីក្រសួងព័ត៌មានបានធ្វើការពន្យល់ពីអត្ថន័យនៃពាក្យទាំងពីរ។ ក៏ប៉ុន្តែ នៅតែមាននូវការមិនពេញចិត្ត ដោយតំណាងរាស្ត្រដដែល រួមនឹងតំណាងរាស្ត្រផ្សេងទៀតបានធ្វើការស្នើឱ្យមាននូវការកំណត់នូវនិយមន័យមួយច្បាស់លាស់ដាក់ចូលទៅក្នុងច្បាប់ ដោយមិនមែនគ្រាន់តែជាការពន្យល់តែមាត់។ ដោយតំណាងរាស្ត្រទាំងនោះ បានលើកឡើងថា ត្រូវតែមាននូវការកំណត់និយមន័យឱ្យបានច្បាស់លាស់ បើមិនដូច្នេះទេ នឹងធ្វើឱ្យអ្នកកាសែតមិនហ៊ានយកព័ត៌មានព្រោះតែខ្លាចត្រូវមានទោសដោយប្រការណាមួយ។ ជាងនេះទៀត ការមិនកំណត់និយមន័យបែបនេះ គឺងាយស្រួលឱ្យជនដែលមានប្រយោជន៍ណាមួយ បកស្រាយន័យនៃវាក្យសព្ទនេះបានដោយសេរី និងទៅតាមប្រយោជន៍របស់ពួកគេ។ ដែលជាហេតុធ្វើឱ្យមាននូវការរំលោភបំពានលើសេរីភាពសារព័ត៌មានក្នុងប្រទេសកម្ពុជា។ មួយវិញទៀត មាននូវការលើកឡើងពីតំណាងរាស្ត្រថា ច្បាប់ស្តីពីរបបសារព័ត៌មាន គឺជាច្បាប់ដោយឡែកដែលត្រូវបានចង្អុលបង្ហាញដោយរដ្ឋធម្មនុញ្ញ។ ដូចនេះ ច្បាប់នេះ ត្រូវតែមាននូវការកំណត់ឱ្យបានច្បាស់លាស់។ ក្នុងនោះដែរ មាននូវការលើកឡើងរបស់តំណាងរាស្ត្រមួយរូប ដោយបានស្នើឱ្យធ្វើការលុបចោលនូវវាក្យសព្ទ "ស្ថេរភាពនយោបាយ" ចេញ។ ការស្នើនេះ ដោយសារតែយល់ឃើញថា ការដាក់នូវវាក្យសព្ទនេះជាការបង្កឱ្យមានការភ័យខ្លាចដល់អ្នកសារព័ត៌មាន។ អ្នកសារព័ត៌មាននឹងមិនហ៊ានផ្សាយ ឬទៅប្រមូលនូវព័ត៌មានណាដែលទាក់ទងនឹងរឿងនយោបាយនោះទេ។ ព្រោះថា អាចនឹងត្រូវមានទោសទៅតាមមាត្រា១២នេះ ហើយមួយទៀត មិនប្រាកដច្បាស់ថាអ្វីដែលប៉ះពាល់ និងអ្វីដែលមិនប៉ះពាល់ទៅនឹងស្ថេរភាពនយោបាយដែលគេបានហាមឃាត់ក្នុងច្បាប់នេះ។

ចំណែកឯការលើកឡើងរបស់អង្គការមិនមែនរដ្ឋាភិបាលវិញ ក៏មានលក្ខណៈស្រដៀងគ្នាដែរ។ ទន្ទឹមនឹងការមើលឃើញនូវបញ្ហាដែលកើតមានឡើងចំពោះអ្នកសារព័ត៌មាន សង្គមស៊ីវិលមួយចំនួន បានលើកឡើងពីបញ្ហានៃមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាននេះ។ ហើយឆ្លើយតបទៅនឹងបញ្ហានេះ ពួកគេបានស្នើឱ្យមាននូវការវិសោធនកម្មច្បាប់នេះ ដោយធ្វើការកំណត់នូវនិយមន័យនៃវាក្យសព្ទ "សន្តិសុខជាតិ" តែត្រូវធ្វើការលុបចោលវាក្យសព្ទ "ស្ថេរភាពនយោបាយ"។

**ខ. ធម្មនុញ្ញភាពនៃមាត្រា១២នៃច្បាប់ស្តីពីរបបសារព័ត៌មាន**

ទាក់ទិននឹងបញ្ហានៃធម្មនុញ្ញភាពនៃមាត្រា១២ ច្បាប់ស្តីពីរបបសារព័ត៌មាននេះ មាននូវការលើកឡើងនូវការយល់ឃើញពីរផ្សេងគ្នា គឺមាត្រានេះស្របទៅនឹងរដ្ឋធម្មនុញ្ញ និងការយល់ថាមាត្រានេះមិនស្របទៅនឹងរដ្ឋធម្មនុញ្ញ។ ទោះបីជាមាននូវការយល់ឃើញខុសគ្នាបែបនេះក៏ដោយ មកដល់ពេលនេះ នៅមិនទាន់មាននូវការផ្តល់នូវការសន្និដ្ឋានចុងក្រោយ និងផ្លូវការនៅឡើយនោះទេ។ ការដែលមិនទាន់មាននូវដំណោះស្រាយលើបញ្ហានេះ ឬចម្លើយលើបញ្ហានេះ អាចបណ្តាលមកពីការយល់ឃើញនូវទស្សនៈពីរផ្សេងគ្នា ឬម៉្យាងទៀត ការគិតគូរលើបញ្ហានេះពីសំណាក់អ្នកច្បាប់កម្ពុជានៅមិនទាន់មានច្រើននៅឡើយ។ យ៉ាងនេះហើយ ចម្លើយរួមមួយចុងក្រោយគឺនៅមិនទាន់មានសម្រាប់បញ្ហានេះទេ។

សង្កេតឃើញជារួម ចំពោះបញ្ហាដែលបានលើកឡើងទាក់ទងទៅនឹងច្បាប់ស្តីពីរបបសារព័ត៌មាន ដែលជាច្បាប់សំខាន់ពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មានថា មាននូវបញ្ហាជាច្រើនដែលមានចេញពីច្បាប់មួយនេះ។ គួរបញ្ជាក់ផងដែរថា បញ្ហាដែលកើតមាននេះ មិនមែនមានត្រឹមតែបញ្ហាដែលបានលើកឡើងខាងលើតែប៉ុណ្ណោះទេ គឺនៅមានបញ្ហាជាច្រើនទៀតផងដែរ រួមផ្សំនឹងបញ្ហានៃការអនុវត្តជាក់ស្តែងដទៃទៀត។ ទោះជាយ៉ាងនេះក្តី គិតចាប់តាំងពីច្បាប់នេះត្រូវបានអនុវត្តរហូតមកដល់បច្ចុប្បន្ន បានឆ្លងកាត់រយៈពេលជាច្រើនឆ្នាំមកហើយ បញ្ហាដែលមានគឺត្រូវបានលើកឡើងជាបន្តបន្ទាប់ និងម្តងហើយម្តងទៀត ក៏ប៉ុន្តែនៅមិនមាននូវចំណាត់ការដោះស្រាយទៅលើបញ្ហាទាំងនោះនោះទេ។

### ១.៣.២.៣. បញ្ហាអនុវត្តជាក់ស្តែងនៃអ្នកសារព័ត៌មាន

#### ក. ឯករាជភាពនៃអ្នកសារព័ត៌មាន

ជុំវិញដំណោះស្រាយនៃឯករាជភាពនៃអ្នកសារព័ត៌មាននេះ ត្រូវបានមើលឃើញថានៅមានកម្រិតនៅឡើយ។ បញ្ហានៃឯករាជភាពនៃអ្នកសារព័ត៌មានត្រូវបានទទួលស្គាល់ ប៉ុន្តែចំណាត់ការដោះស្រាយទៅលើបញ្ហានេះ ហាក់ដូចជាមិនទាន់មានអ្វីគួរឱ្យកត់សម្គាល់នោះទេ។

ទោះបែបនេះក៏ដោយ ក្នុងស្ថានភាពបច្ចុប្បន្នជាក់ស្តែង ប្រព័ន្ធផ្សព្វផ្សាយរបស់ក្រុមហ៊ុនឯកជនមួយចំនួន កំពុងតែដំណើរការ ប្រតិបត្តិការផ្សាយរបស់ខ្លួន ដោយឯករាជពីឥទ្ធិពលផ្សេងៗ។ ថ្វីត្បិតតែ មិនអាចនិយាយបានថាមានឯករាជ្យទាំងស្រុងក៏ដោយ តែក៏សង្កេតឃើញថាដំណើររបស់ក្រុមហ៊ុនឯកជនទាំងនោះ បានបំពេញការងារជាអ្នកសារព័ត៌មានស្របទៅតាមវិជ្ជាជីវៈ និងដោយឯករាជ្យ។ ជាមួយគ្នានេះដែរ គឺមាននូវអ្នកសារព័ត៌មានដែលបង្ហាញចំហរឯករាជ្យ ដោយផ្សាយនូវព័ត៌មានពិត មិនមានភាពលំអៀងទៅខាងណាមួយ។ នេះជាសញ្ញាណវិជ្ជមានមួយនៃវិស័យសារព័ត៌មាននៅប្រទេសកម្ពុជា។ តែពាក់ព័ន្ធនឹងដំណោះស្រាយដែលមានប្រសិទ្ធិភាពជុំវិញបញ្ហានេះ គឺនៅជាចំណោទបញ្ហានៅឡើយ។

#### ខ. វិជ្ជាជីវៈអ្នកសារព័ត៌មាន

នាពេលបច្ចុប្បន្ននេះ មាននូវការបង្កើតនូវសមាគមអ្នកសារព័ត៌មាន ក៏ដូចជាវត្តមាននៃក្លឹបអ្នកកាសែតកម្ពុជាដែលមានតាំងពីយូរមកហើយ។ វត្តមាននៃស្ថាប័នទាំងអស់នេះ អាចនិយាយបានថាជាមុខមាត់ថ្មីមួយនៃប្រព័ន្ធព័ត៌មានរបស់ប្រទេសកម្ពុជា។ ក្លឹបអ្នកកាសែតកម្ពុជា ដែលបង្កើតឡើង និងកំពុងដំណើរការសព្វថ្ងៃក្នុងគោលបំណងរក្សាឱ្យបាននូវវិជ្ជាជីវៈអ្នកកាសែតកម្ពុជាឱ្យមានស្តង់ដារ និងសមស្របត្រឹមត្រូវទៅតាមវិជ្ជាជីវៈអ្នកកាសែតពិតប្រាកដ។ នៅពេលថ្មីៗនេះ មាននូវការបង្កើតឱ្យមាននូវសមាគមអ្នកសារព័ត៌មានកម្ពុជា ដែលធ្វើការប្រមូលផ្តុំនូវអ្នកសារព័ត៌មានដែលមានក្នុងប្រទេសកម្ពុជា។ សមាគមនេះ ក៏កំពុងតែខិតខំក្នុងការណែនាំដល់អ្នកសារព័ត៌មានក្នុងការបំពេញការងាររបស់ខ្លួនទៅតាមវិជ្ជាជីវៈអ្នកសារព័ត៌មានពិតប្រាកដ។

ការរួមសហការគ្នា មិនថាក្លឹបអ្នកកាសែតកម្ពុជា ឬក៏សមាគមអ្នកសារព័ត៌មានកម្ពុជានោះទេ គឺសុទ្ធតែកំពុងខិតខំ កែលម្អនូវបញ្ហាដែលជាចំណុចខ្វះខាតនៃវិជ្ជាជីវៈអ្នកសារព័ត៌មាន ធ្វើយ៉ាងណាឱ្យអ្នកសារព័ត៌មានប្រកបរបរនេះទៅតាមវិជ្ជាជីវៈមួយត្រឹមត្រូវ និងទទួលបាននូវជំនឿចិត្តពីប្រជាពលរដ្ឋ។

ជាសរុបមក បញ្ហានៃការអនុវត្តជាក់ស្តែងនៃអ្នកសារព័ត៌មានកម្ពុជា ជាបញ្ហាមួយដ៏សំខាន់ ដែលគួរតែមានការគិតគូររកនូវដំណោះស្រាយសមស្របមួយ។ ដោយហេតុថា វិស័យសារព័ត៌មាន ក្នុងប្រទេសកម្ពុជាសព្វថ្ងៃ បញ្ហាទាក់ទងនឹងវិជ្ជាជីវៈអ្នកសារព័ត៌មាន បញ្ហាឯករាជភាពនៃអ្នកសារព័ត៌មានដែលជាបញ្ហាចម្បងធំៗ កំពុងតែចោទជាបញ្ហានៅឡើយ ដែលមិនទាន់មានដំណោះស្រាយ។ ការដោះស្រាយបញ្ហាចម្បងទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះប្រទេសសេរីដែលគោរពសិទ្ធិមនុស្សជាធំ។ ម្តងហើយម្តងទៀត ព្រោះថា ព័ត៌មានមានសារៈសំខាន់ចាំបាច់ ដោយមិនមែនសម្រាប់តែអ្នកសារព័ត៌មានក្នុងការប្រកបរបររបស់គាត់ប៉ុណ្ណោះទេ តែរឹតតែសំខាន់ជាងនេះទៀតនោះ គឺសិទ្ធិក្នុងការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋក្នុងប្រទេសមួយ មានសិទ្ធិដឹងឮ ទទួលបាននូវរាល់ព័ត៌មានទាំងឡាយដែលកើតមានក្នុងប្រទេសរបស់ពួកគេ។ ហេតុនេះហើយ ដំណោះស្រាយចំពោះបញ្ហានៃអ្នកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជាត្រូវតែមាន។

# ជំពូកទី២
# អំពី
# សេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

# ជំពូកទី ២ អំពី សេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

## ២.១. ប្រវត្តិ និងសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

### ២.១.១. ប្រវត្តិនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

ដូចគ្នាទៅនឹងករណីនៃប្រទេសកម្ពុជាដែរ ដើម្បីសិក្សាទៅលើសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន ជាដំបូងនឹងសិក្សាអំពីប្រវត្តិនៃសេរីភាពនេះ។ ដោយការសិក្សាប្រវត្តិនៃសេរីភាពនេះគឺតាមរយៈការសិក្សាទៅលើរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះតែម្តង។ ក្នុងប្រវត្តិសាស្ត្រប្រទេសជប៉ុនមានបែងចែកជាសម័យបុរាណ សម័យកណ្តាល និងសម័យទំនើប។ ហើយចំណោមសម័យទាំង៣នេះ សម័យបុរាណ និងសម័យកណ្តាលជាសម័យកាលដែលស្ថិតក្នុងសម័យកាលបុរាណ ត្រូវគ្រប់គ្រងដោយអធិរាជ សម័យកាលខ្លះគ្រប់គ្រងដោយពួកសាមុរ៉ៃ ដូចនេះការចងក្រងជាច្បាប់តាមបែបសម័យទំនើបមិនទាន់មាននោះទេ។ តាមរយៈនេះ រដ្ឋធម្មនុញ្ញដែលមានក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសជប៉ុនគឺរដ្ឋធម្មនុញ្ញដែលមានក្នុងសម័យទំនើប។ ដែលរួមមាន រដ្ឋធម្មនុញ្ញដែលមានក្នុងសម័យទំនើប ឈ្មោះថារដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន (大日本帝国憲法) (២.១.១.១) និងរដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យបច្ចុប្បន្ន (២.១.១.២)។

#### ២.១.១.១. រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន

រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន (大日本帝国憲法) ឬអាចហៅម៉្យាងទៀតបានថារដ្ឋធម្មនុញ្ញសម័យមេជិ (明治憲法) គឺជារដ្ឋធម្មនុញ្ញដែលត្រូវបានប្រកាសឱ្យប្រើនៅក្នុងឆ្នាំ១៨៨៩ ក្នុងសម័យមេជិ (明治維新) បន្ទាប់ពីមាននូវការធ្វើចលនាដើម្បីសិទ្ធិសេរីភាព (自由民権運動) របស់ប្រជាជនជប៉ុន[47]។ គួរបញ្ជាក់ផងដែរថា សម័យមេជិជាសម័យដែលអំណាចត្រូវស្ថិតនៅក្នុងដៃរបស់អធិរាជជប៉ុនស្ទើរទាំងស្រុង។ ប៉ុន្តែ ដោយសារការធ្វើចលនាដើម្បីសិទ្ធិសេរីភាពរបស់ប្រជាជនជប៉ុន អំណាច ឬក៏សិទ្ធិមួយចំនួនបានប្រគល់មកឱ្យមន្ត្រី និងប្រជាពលរដ្ឋ ទោះជាយ៉ាងណាក្តីព្រះចៅអធិរាជនៅតែមាននូវអំណាចធំដដែល[48]។

[47] 名古屋大学日本法教育研究センター『日本法を学ぶための日本の法システム—3 年生用教材—（カンボジア版）』（2014 年 9 月）、62 頁
មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, ប្រព័ន្ធច្បាប់ប្រទេសជប៉ុនដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន សៀវភៅសិក្សាសម្រាប់ឆ្នាំទី៣ (ភាសាខ្មែរ), (ខែកញ្ញា ឆ្នាំ២០១៤), ទំព័រ៦២
[48] ដូច៤៧, ទំព័រ៧៥

សិទ្ធិមួយចំនួនដែលត្រូវបានផ្តល់មកឱ្យប្រជាពលរដ្ឋជប៉ុននាសម័យមេជិ តាមរយៈរដ្ឋធម្មនុញ្ញអាណាចក្រជប៉ុននេះ មានដូចជាសិទ្ធិកម្មសិទ្ធិលើដី[49] សិទ្ធិក្នុងការជឿ[50] និងសេរីភាពក្នុងការបញ្ចេញមតិ[51]ផងដែរ។

មាត្រា២៩ នៃរដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន[52] បានចែងថា :

> " ប្រជាពលរដ្ឋជប៉ុន មានសិទ្ធិនិយាយស្តី សិទ្ធិនិពន្ធ សិទ្ធិបោះពុម្ពផ្សាយ និងសិទ្ធិក្នុងការជួបជុំក្នុងវិសាលភាពកំណត់ដោយច្បាប់ "[53] ។

តាមបញ្ញត្តិនៃមាត្រា២៩នេះ ប្រជាពលរដ្ឋជប៉ុននាសម័យមេជិ មានសិទ្ធិសេរីភាពបញ្ចេញមតិ ហើយសេរីភាពដែលបានផ្តល់ឱ្យនោះរួមមាន សិទ្ធិក្នុងការនិយាយស្តី ការបោះពុម្ពផ្សាយ ការនិពន្ធ ការជួបប្រជុំ ទៅតាមការកំណត់របស់ច្បាប់។

ប៉ុន្តែ ទោះបីជារដ្ឋធម្មនុញ្ញនេះបានចែងអំពីសេរីភាពបញ្ចេញមតិដែលប្រជាពលរដ្ឋជប៉ុនមានក៏ដោយ ក៏សេរីភាពនេះត្រូវបានកម្រិតដោយច្បាប់ （法律の留保）ដែលធ្វើឱ្យច្បាប់អាចកម្រិតនូវសេរីភាពនេះយ៉ាងណាក៏បាន[54]។ ហើយការចែងបែបនេះ ក៏ជាទុកចន្លោះឱ្យអំណាចរដ្ឋក្នុងការគាបសង្កត់លើសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋជប៉ុនបានដែរ។ ដោយសារសម័យមេជិជាសម័យដែលព្រះចៅអធិរាជមាននូវអំណាចខ្លាំងនៅឡើយ សេរីភាពបញ្ចេញមតិនាសម័យនោះពិតជាអាចធានាបានថាមិនមានបញ្ហារំលោភបំពាននោះទេ។ ច្បាស់ណាស់ថា ការរំលោភបំពាន ការបំបិទនូវសិទ្ធិសេរីភាព មិនឱ្យមានការនិយាយស្តី ការអនុវត្តនូវសិទ្ធិរបស់ប្រជាពលរដ្ឋដោយសេរីប្រាកដជាមាន។

---

[49] រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន, មាត្រា២៧ វាក្យខណ្ឌទី១

[50] រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន, មាត្រា២៨

[51] រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន, មាត្រា២៩

[52] 大日本帝国憲法第 29 条には、「日本臣民ハ法律ノ範囲内ニ於て言論著作印行集会及結社ノ自由ヲ有ス」と定めている。

[53] ការបកប្រែក្រៅផ្លូវការ

[54] 渋谷秀樹、赤坂正浩『憲法 1 人権〔第 4 版〕』、（有斐閣、2010 年）、136 頁
ស៊ីប៊ីថានី ហ៊ីដិគី, អាកាសាកា ម៉ាសាហ៊ីរ៉ូ, រដ្ឋធម្មនុញ្ញ១ សិទ្ធិមនុស្ស〔បោះពុម្ពលើកទី៤〕, (រោងពុមយ៉ឺហ៊ីកាគឹ, ២០១០), ទំព័រ១៣៦

### ២.១.១.២. រដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្ន

រដ្ឋធម្មនុញ្ញសម័យបច្ចុប្បន្នរបស់ប្រទេសជប៉ុន គឺជារដ្ឋធម្មនុញ្ញថ្មីដែលត្រូវបានបង្កើតឡើងក្រោយពីប្រទេសជប៉ុនចាញ់សង្គ្រាមលោកលើកទី២។

នៅខែសីហា ឆ្នាំ១៩៤៥ ប្រទេសជប៉ុនបានទទួលស្គាល់នូវសេចក្តីថ្លែងការណ៍ផុសដាម (Potsdam Declaration、ポツダム宣言) ដែលជាសេចក្តីថ្លែងការណ៍ធ្វើឡើងដោយសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងប្រទេសចិនស្នើបង្គាប់ឱ្យជប៉ុនចុះចាញ់សង្គ្រាមគ្មានលក្ខខណ្ឌ ធ្វើថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៤៥[55]។

យោងតាមសេចក្តីថ្លែងការណ៍ផុសដាម សហរដ្ឋអាមេរិកបានធ្វើនូវកំណែទម្រង់ក្រោយសង្គ្រាមដើម្បីធ្វើឱ្យមាននូវប្រជាធិបតេយ្យក្នុងប្រទេសជប៉ុន។ ក្នុងឆ្នាំ១៩៤៥ដដែលនេះ សហរដ្ឋអាមេរិកបានចង្អុលបង្ហាញឱ្យរដ្ឋាភិបាលជប៉ុនធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញសម័យមេជិ។ រដ្ឋាភិបាលជប៉ុននាពេលនោះ បានធ្វើវិសោធនកម្មតាមការបញ្ជារបស់សហរដ្ឋអាមេរិក ប៉ុន្តែរដ្ឋធម្មនុញ្ញដែលបានធ្វើវិសោធនកម្មនោះ មិនមានអ្វីខុសប្លែកពីរដ្ឋធម្មនុញ្ញសម័យមេជិនោះទេ។ ដូចនេះ សហរដ្ឋអាមរិកមិនបានយល់ស្របទទួលយករដ្ឋធម្មនុញ្ញនោះទេ ក៏បានរៀបចំបង្កើតនូវសេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញដោយខ្លួនឯងតែម្តង។ ហេតុនេះហើយ រដ្ឋធម្មនុញ្ញដែលប្រទេសជប៉ុនកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះ គឺជារដ្ឋធម្មនុញ្ញដែលត្រូវបានបង្កើតឡើងតាមគំរូរបស់សេចក្តីព្រាងច្បាប់រដ្ឋធម្មនុញ្ញ ដែលបង្កើតឡើងដោយអគ្គទីបញ្ជាការសហរដ្ឋអាមេរិក (General Headquarter, the Supreme Commander for the Allied Powers) ហៅកាត់ថា GHQ ។

រដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យបច្ចុប្បន្ន ត្រូវបានអនុម័តដោយរដ្ឋសភា និងត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៤៦ និងត្រូវដាក់ឱ្យប្រើនៅឆ្នាំបន្ទាប់ គឺនៅថ្ងៃទី៣ ខែឧសភា ឆ្នាំ១៩៤៧។

រដ្ឋធម្មនុញ្ញដែលត្រូវបានបង្កើតឡើង ដោយស្ថិតក្រោមការចង្អុលបង្ហាញរបស់សហរដ្ឋអាមេរិកនេះ អាចបង្ហាញឱ្យឃើញពីលទ្ធិប្រជាធិបតេយ្យដែលប្រទេសជប៉ុនមាន។ ព្រោះថា រដ្ឋធម្មនុញ្ញនេះបានរៀបចំបង្កើតឡើងដោយសហរដ្ឋអាមេរិក ដែលជាប្រទេសត្រូវបានគេទទួលស្គាល់ថាជាប្រទេសនៃលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្សយ៉ាងទូលំទូលាយ យ៉ាងនេះហើយប្រាកដ

[55] 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民—２年生用教材—（カンボジア版）』、2010 年、39 頁
មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, ប្រវត្តិសាស្ត្រ និងពលរដ្ឋវិទ្យាប្រទេសជប៉ុនដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន សៀវភៅសិក្សាសម្រាប់ឆ្នាំទី៣ (ភាសាខ្មែរ), (២០១០) ទំព័រ៣៩

ណាស់ថា ឥទ្ធិពលលទ្ធិប្រជាធិបតេយ្យរបស់សហរដ្ឋអាមេរិកនឹងមានមកលើប្រទេសជប៉ុនដោយមិនអាចប្រកែកបាន។

ជាការពិតណាស់ បើធ្វើការក្រឡេកមើលរដ្ឋធម្មនុញ្ញប្រទេសជប៉ុនបច្ចុប្បន្នផ្ទាល់ នឹងឃើញមាននូវការចែងជាច្រើនអំពីសិទ្ធិ កាតព្វកិច្ចរបស់ប្រជាពលរដ្ឋជប៉ុន ព្រមជាមួយគ្នានឹងការបែងចែកអំណាចផ្សេងៗ។

បើនិយាយអំពីសិទ្ធិរបស់ប្រជាពលរដ្ឋជប៉ុន ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញប្រទេសជប៉ុន សង្កេតឃើញមាននូវសិទ្ធិជាច្រើន ដែលក្នុងនោះដែរ សេរីភាពបញ្ចេញមតិត្រូវបានធានានៅក្នុងមាត្រា២១នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន។

មាត្រា២១នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន[56]ចែងថា :

> " ធានានូវសេរីភាពបញ្ចេញមតិទាំងអស់ សិទ្ធិក្នុងការបោះពុម្ពផ្សាយ សិទ្ធិក្នុងការជួបជុំ សិទ្ធិក្នុងការបង្កើតសមាគម និងសិទ្ធិក្នុងការនិយាយស្តីផ្សេងៗ។
> ការត្រួតពិនិត្យមុន មិនត្រូវអនុញ្ញាតទេ។ អាថ៌កំបាំងនៃការទាក់ទង មិនអាចត្រូវរំលោភបំពានឡើយ។[57] "

ការប្រើប្រាស់ពាក្យពេចន៍ក្នុងរដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យបច្ចុប្បន្ន ក៏មិនខុសពីរដ្ឋធម្មនុញ្ញសម័យមេជិប៉ុន្មានទេលើការផ្តល់នូវសេរីភាពបញ្ចេញមតិដល់ប្រជាពលរដ្ឋជប៉ុន ។ ប៉ុន្តែ មិនមែនមានន័យថា រដ្ឋធម្មនុញ្ញបច្ចុប្បន្នរបស់ប្រទេសជប៉ុននៅតែយកគម្រូតាមរដ្ឋធម្មនុញ្ញចាស់នោះទេ។ តាមការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជប៉ុនដោយសហរដ្ឋអាមេរិក មាត្រា២១នៃរដ្ឋធម្មនុញ្ញជប៉ុនបច្ចុប្បន្ន ធ្វើឱ្យមាននូវភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងរដ្ឋធម្មនុញ្ញសម័យមេជិ គ្រង់ការលុបចោលនូវការកម្រិតសេរីភាពបញ្ចេញមតិដោយច្បាប់ ដោយធ្វើការដាក់នូវមកវិញនូវពាក្យថា " ធានានូវសេរីភាពបញ្ចេញមតិទាំងអស់ "[58] ។

ការចែងបែបនេះ បង្ហាញបានថាប្រទេសជប៉ុនធានាការពារ ក៏ដូចជាផ្តល់នូវសេរីភាពបញ្ចេញមតិដល់ប្រជាពលរដ្ឋជប៉ុនយ៉ាងទូលំទូលាយដោយមិនមានការកម្រិតសិទ្ធិណាមួយ ទោះ

[56] 日本国憲法第 21 条には、「①集会、結社及び言論、出版その一切の表現の自由は、これを保障する。②検閲は、これをしてはならない。通信の秘密は、これを侵してはならない。」と定めている。
[57] ការបកប្រែក្រៅផ្លូវការ
[58] ដូច៥៥

តាមរយៈច្បាប់ ឬការទុកចន្លោះរបស់ច្បាប់ដែលធ្វើឱ្យអំណាចរដ្ឋណាមួយអាចគាបសង្កត់ប្រជាពលរដ្ឋបាននោះទេ។

### ២.១.២. សញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

អំពីសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុនមាននូវការស្រាវជ្រាវ ការសរសេរនិពន្ធរបស់បណ្ឌិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ ក៏ដូចជាយុត្តិសាស្ត្ររបស់តុលាការជាច្រើនដែលសំបូរគ្រប់គ្រាន់សម្រាប់ការសិក្សាស្រាវជ្រាវ។ ទន្ទឹមនឹងភាពសម្បូរបែបនៃការស្រាវជ្រាវនេះ ក៏ធ្វើឱ្យមាននូវការយល់ឃើញជាទស្សនៈមួយចំនួនផ្សេងគ្នារវាងអ្នកស្រាវជ្រាវទាំងអស់នោះ។ យ៉ាងនេះក្តី ក៏នៅតែមាននូវសញ្ញាណទូទៅរួមគ្នាមួយដែលអាចយកមកធ្វើការសិក្សាស្វែងយល់ និងប្រៀបធៀបរវាងសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជា និងប្រទេសជប៉ុន។

#### ២.១.២.១. និយមន័យ

នៅប្រទេសជប៉ុន សេរីភាពបញ្ចេញមតិ ត្រូវឱ្យនិយមន័យថា ជាសេរីភាពមួយដែលមនុស្សបង្ហាញនូវគំនិត ទស្សនៈ អារម្មណ៍របស់ខ្លួនទៅកាន់មនុស្សដទៃទៀត មិនថាដោយផ្ទាល់មាត់ តាមការបោះពុម្ពផ្សាយ សារទូរគមនាគមន៍ ឬដោយមធ្យោបាយណាមួយនោះទេ[59]។

#### ២.១.២.២. អត្ថន័យ

សេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន គឺជាសិទ្ធិមួយដ៏សំខាន់បំផុតក្នុងចំណោមសិទ្ធិខាងផ្លូវចិត្តរបស់ប្រជាពលរដ្ឋជប៉ុន ហើយត្រូវបានការពារយ៉ាងទូលំទូលាយ។ សេរីភាពមួយនេះ គឺជាសេរីភាពដែលមនុស្សអាចធ្វើការបង្ហាញចេញនូវការគិត ការយល់ ការជឿដែលមាននៅក្នុងចិត្តរបស់ខ្លួន ទៅខាងក្រៅ ឬទៅឱ្យមនុស្សដទៃផ្សេងទៀតក្រៅពីខ្លួនឯងបានដឹង ដែលបង្កើតឱ្យបាននូវការទំនាក់ទំនង ប្រាស្រ័យទាក់ទងក្នុងសង្គមកើតឡើង[60]។

មានការឱ្យតម្លៃ២សំខាន់ៗ[61]ទៅលើសេរីភាពបញ្ចេញមតិនេះ។

---

[59] 小林伸一、（大沢秀介、大林啓吾「編集」）『確認憲法用語』（成文堂、2014 年）、37-38 頁
ខុបាយ៉ាស៊ី ស៊ីនអ៊ីឆី, (អូហ្សាវ៉ា ហ៊ីដិយ៉ឹគី, អូប៉ាយ៉ាស៊ី ខេហ្គុ [កែសម្រួល] ), វាក្យសព្ទនីតិរដ្ឋធម្មនុញ្ញ, (រោងពុម្ពសេប៊ឹនដូរ, ២០១៤), ទំព័រ៣៧-៣៨

[60] 芦部信善（高橋和之補訂）『憲法 第六版』（岩波書店、2015 年）、175 頁
អាស៊ីបេ ណុប៊ឹយុស៊ី (កែសម្រួលដោយថាកាហាស៊ី ខាហ្សឹយ៉ឹគី) , រដ្ឋធម្មនុញ្ញ បោះពុម្ពលើកទី៦, (រោងពុម្ពអ៊ីវ៉ាណាមិ, ២០១៥), ទំព័រ១៧៥

[61] ដូច៦០

- ទស្សនៈទី១៖ ការដែលធ្វើឱ្យអភិវឌ្ឍលើចរិតលក្ខណៈខ្លួនឯងតាមរយៈការសម្តែងចេញមកក្រៅនូវគំនិតរបស់ខ្លួន និងការទទួលបាននូវគំនិតអ្នកដទៃ ដែលហៅថាតម្លៃនៃការអភិវឌ្ឍខ្លួន（Self-fulfillment、自己実現の価値）។
- ទស្សនៈទី២៖ ការចូលរួមក្នុងសកម្មភាពនយោបាយដែលជាសង្គមប្រជាធិបតេយ្យរបស់ប្រជាពលរដ្ឋតាមរយៈសកម្មភាពបញ្ចេញមតិរបស់ខ្លួន និងការទទួលបាននូវព័ត៌មានទាក់ទងនឹងនយោបាយរបស់ប្រទេសជាតិ ដែលហៅថាតម្លៃនៃការចូលរួម（Self-government、自己統治の価値）។

តាមឯកសារស្រាវជ្រាវ ក៏ដូចជាសេចក្តីសម្រេចរបស់តុលាការប្រទេសជប៉ុន សេរីភាពបញ្ចេញមតិត្រូវបានឱ្យតម្លៃខ្ពស់និងជាអាទិភាពបើប្រៀបធៀបនឹងសិទ្ធិសេរីភាពដទៃទៀត។ ជាក់ស្តែង សេរីភាពបញ្ចេញមតិនេះ ត្រូវបានគេចាត់ជាសិទ្ធិអាទិភាពលើសិទ្ធិសេដ្ឋកិច្ច។

### ២.១.២.៣. ប្រភេទ

សេរីភាពបញ្ចេញមតិ ត្រូវបែងចែកជាប្រភេទផ្សេងៗទៅតាមទំនាក់ទំនងរបស់វា។ មានន័យថា តាមរយៈសេរីភាពបញ្ចេញមតិ គេអាចបញ្ចេញមតិយោបល់របស់ខ្លួន ហើយគេក៏អាចទទួលបានព័ត៌មានពីការបញ្ចេញមតិរបស់អ្នកដទៃ គេអាចដឹងឮ ឬទទួលបានការផ្សព្វផ្សាយព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ និងក្រៅពីនេះគេអាចធ្វើការប្រមូលផ្តុំគ្នាជាក្រុម សមាគម ដើម្បីធ្វើការ សម្តែងមតិរបស់ខ្លួនទៅតាមរូបភាពផ្សេងៗដូចជាការធ្វើបាតុកម្មជាដើម។ ការមានទំនាក់ទំនងបែបនេះហើយ ដែលធ្វើឱ្យសេរីភាពបញ្ចេញមតិមានសារៈសំខាន់ជាសិទ្ធិមូលដ្ឋានខាងផ្លូវចិត្តរបស់មនុស្ស ជាពិសេសមានវិសាលភាពធំ និងត្រូវបែងចែកជាប្រភេទផ្សេងៗ។

សេរីភាពបញ្ចេញមតិ មានវិសាលភាពគ្របដណ្តប់លើការបញ្ចេញមតិទាំងអស់។ ការសម្តែងសុន្ទរកថា ការបោះពុម្ពផ្សាយជាកាសែត ទស្សនាវដ្តីនិងការបោះពុម្ពផ្សេងៗ ការផ្សាយតាមវិទ្យុ ទូរទស្សន៍ គំនូរ រូបថត ខ្សែភាពយន្ត តន្ត្រី ការសម្តែងផ្សេងៗ សុទ្ធតែត្រូវបានធានាដោយសេរីភាពបញ្ចេញមតិ។ សេរីភាពក្នុងការជួបជុំ ប្រមូលផ្តុំក៏ត្រូវបានធានាថាជាសេរីភាពបញ្ចេញមតិផងដែរ។ ដោយហេតុថា ការជួបជុំ ការប្រមូលផ្តុំគ្នា គឺជាមធ្យោបាយមួយដើម្បីឱ្យមនុស្សមួយក្រុមនោះអាចពិភាក្សា ផ្លាស់ប្តូរយោបល់ នូវគំនិតផ្សេងៗរបស់គេបានដែរ។ ដោយឡែក នៅប្រទេសអឺរ៉ុបមួយចំនួន សេរីភាពក្នុងការជួបជុំ ត្រូវបានបញ្ញត្តិដោយឡែកពីសេរីភាពបញ្ចេញមតិ ដូចជាប្រទេស

អាឡឺម៉ង់ជាដើម។ ប៉ុន្តែ ប្រទេសជប៉ុនដោយយកគម្រូតាមសហរដ្ឋអាមេរិក សេរីភាពបញ្ចេញមតិត្រូវបានកំណត់ក្នុងវិសាលភាពធំទូលាយ[62]។

យោងស្មារតីនៃមាត្រា២១រដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យបច្ចុប្បន្ន សេរីភាពបញ្ចេញមតិត្រូវបានបែងចែកជា៦ផ្នែកធំៗ គឺ សិទ្ធិទទួលបានព័ត៌មាន សេរីភាពខាងសារព័ត៌មាន សេរីភាពបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត សេរីភាពបញ្ចេញមតិទាក់ទងនឹងសិទ្ធិបុគ្គល សេរីភាពបញ្ចេញមតិលើ វិស័យជំនួញ និងសេរីភាពខាងការជួបជុំ បង្កើតសមាគម។

### ក. សិទ្ធិទទួលបានព័ត៌មាន

សេរីភាពបញ្ចេញមតិ ជាសេរីភាពមួយរបស់មនុស្សក្នុងការបញ្ជូនព័ត៌មានចេញទៅ និងជាសេរីភាពទំនាក់ទំនងនូវព័ត៌មាន ដែលត្រូវមានអ្នកផ្សាយព័ត៌មាន និងអ្នកទទួលបានព័ត៌មាន។ ដូច្នេះ អ្នកទទួលព័ត៌មានដែលជាប្រជាពលរដ្ឋក៏ត្រូវបានការពារសិទ្ធិរបស់ពួកគេផងដែរ ដែលសិទ្ធិនោះគឺសិទ្ធិទទួលបានព័ត៌មាន។

សិទ្ធិទទួលបានព័ត៌មាន គឺជាសិទ្ធិរបស់អ្នកទទួលព័ត៌មាន(ប្រជាពលរដ្ឋ) ក្នុងការទទួលបានព័ត៌មាននៃព្រឹត្តិការណ៍ទាំងឡាយដែលកើតមានឡើងក្នុងសង្គម[63]។ អាចនិយាយម៉្យាងទៀតថា គឺជាសិទ្ធិដែលប្រជាពលរដ្ឋត្រូវមាន ក្នុងការដឹងពីសង្គមដើម្បីកុំឱ្យមានការរំលោភបំពានសិទ្ធិរបស់ពួកគេពីសំណាក់រដ្ឋ។

សិទ្ធិក្នុងការទទួលបានព័ត៌មាននេះ គឺជាសេរីភាពដែលបានពីរដ្ឋ (国家からの自由) និងជាសេរីភាពដែលផ្តល់ទៅរដ្ឋ (国家への自由)[64]។ ជាសេរីភាពដែលបានពីរដ្ឋ ព្រោះថាប្រជាពលរដ្ឋអាចមានសិទ្ធិនេះបាន លុះត្រាតែរដ្ឋផ្តល់ឱ្យ បើកទូលាយនូវរាល់ព័ត៌មានទាំងអស់ដែលមានក្នុងសង្គម រួមទាំងព័ត៌មានក្រៅប្រទេស ដែលទាក់ទង ឬមិនទាក់ទងនឹងប្រទេសខ្លួនយ៉ាងណាក៏ដោយ។ ហើយការផ្តល់ព័ត៌មាននេះរដ្ឋត្រូវតែធានាថាជាការផ្តល់នូវព័ត៌មានពិត ត្រឹមត្រូវជាព័ត៌មានដែលប្រជាពលរដ្ឋត្រូវដឹង និងគួរតែដឹងឱ្យបានគ្រប់ជ្រុងជ្រោយ។

តាមរយៈការទទួលបានព័ត៌មានដែលរដ្ឋផ្តល់ឱ្យ ប្រជាពលរដ្ឋធ្វើការពិចារណាគិតគូរចំពោះនយោបាយ ការដឹកនាំរបស់រដ្ឋាភិបាល ហើយធ្វើការជ្រើសរើសអ្នកដឹកនាំប្រទេស ពោលគឺការបោះឆ្នោត បែបនេះហើយទើបគេផ្តល់ឈ្មោះថាជាសេរីភាពផ្តល់ទៅរដ្ឋ។ ដូច្នេះហើយ រដ្ឋមាន

[62] ដូច៦០, ទំព័រ ១៨០

[63] ដូច៥៩, ទំព័រ១៩៨

[64] ដូច៦០, ទំព័រ១៧៦

តួនាទីយ៉ាងសំខាន់ក្នុងការបំពេញឱ្យបាននូវការគោរព ការពារសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ដោយតាមរយៈការធានានូវការផ្តល់នូវព័ត៌មានជូនប្រជាពលរដ្ឋបានត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងពិតប្រាកដ។

### ខ. សេរីភាពខាងសារព័ត៌មាន

សេរីភាពខាងសារព័ត៌មាន ជាសេរីភាពមួយមានសារៈសំខាន់មិនមែនត្រឹមតែសម្រាប់អ្នកសារព័ត៌មានប៉ុណ្ណោះទេ តែគឺសំខាន់សម្រាប់ការទទួលបាននូវព័ត៌មានរបស់ប្រជាពលរដ្ឋ។

សាលដីការបស់តុលាការកំពូលប្រទេសជប៉ុនលើរឿងក្តីស្ថានីយហាខាតា [65] បានចេញសេចក្តីសម្រេចថា សារព័ត៌មានរបស់ស្ថាប័នសារព័ត៌មាន ក្នុងសង្គមប្រជាធិបតេយ្យ មានសារៈសំខាន់ក្នុងទំនាក់ទំនងជាមួយនឹងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ក្នុងការស្វែងយល់ពីនយោបាយរបស់រដ្ឋាភិបាល និងផ្តល់ឯកសារសម្រាប់ការវិនិច្ឆ័យចាំបាច់ដល់ប្រជាពលរដ្ឋ។ ដូច្នេះសេរីភាពសារព័ត៌មាន ត្រូវទទួលបានការការពារ និងធានាពីរដ្ឋ។

សេរីភាពសារព័ត៌មាន មានសារៈសំខាន់ចំពោះសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ តែអ្វីដែលអាចធ្វើឱ្យសេរីភាពសារព័ត៌មានកើតឡើងបាននោះ គឺសេរីភាពក្នុងការប្រមូលព័ត៌មាន។ ដើម្បីអាចផ្សាយព័ត៌មានចេញទៅប្រជាពលរដ្ឋបាន អ្នកសារព័ត៌មានត្រូវស្វែងរក ប្រមូលព័ត៌មានទៅតាមទីកន្លែង ឬប្រភពផ្សេងៗដែលព័ត៌មាននោះមាន។ ហេតុនេះ រដ្ឋាភិបាលចាំបាច់ត្រូវការពារនូវសេរីភាពប្រមូលព័ត៌មាននេះ។ ព្រោះថា ប្រសិនបើមាននូវការបំបិទសិទ្ធិ ការលាក់កំបាំង មិនផ្តល់ព័ត៌មានដោយហេតុផលមិនសមរម្យ នោះព័ត៌មាននឹងមិនត្រូវបានទៅដល់ប្រជាពលរដ្ឋនោះទេ ឬទៅដល់តែជាព័ត៌មានខុសពីការពិត។ យ៉ាងនេះ នឹងធ្វើឱ្យមាននូវការរំលោភបំពានទៅលើសេរីភាពសារព័ត៌មានក្នុងការប្រមូលព័ត៌មាន និងជាពិសេសគឺសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។ មាត្រា២១ វាក្យខណ្ឌទី២នៃរដ្ឋធម្មនុញ្ញប្រទេសជប៉ុនបច្ចុប្បន្ន បានហាមមិនឱ្យមាននូវការត្រួតពិនិត្យជាមុននោះទេ។ ការត្រួតពិនិត្យនេះ សម្តៅលើការដែលស្ថាប័នរដ្ឋពិនិត្យមើលខ្លឹមសារព័ត៌មាន ឬការបោះពុម្ពផ្សាយផ្សេងៗរបស់អ្នកសារព័ត៌មានមុនអនុញ្ញាតឱ្យចេញផ្សាយ។ ការត្រួតពិនិត្យបែបនេះ ត្រូវបានហាមឃាត់ ព្រោះថាជាការគាបសង្កត់ ឬ ការកម្រិតនូវសេរីភាពសារព័ត៌មាន។

[65] 「報道機関の報道は、民主主義社会において、国民が国政に関与するにつき、重要な判断の資料を提供し、国民の『国民の知る権利』に奉仕する」という博多駅（テレビフィルム提出命令）事件での指摘である。

### គ. សេរីភាពបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត

ដោយមានការវិវត្តនូវបច្ចេកវិទ្យា ការរីកចម្រើនលើប្រព័ន្ធផ្សព្វផ្សាយជាច្រើន ក្រៅពីកាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ជាដើមនោះ ប្រព័ន្ធអ៊ីនធើណេត ត្រូវបានបង្កើតឡើង ហើយត្រូវបានក្លាយជាមធ្យោបាយដ៏សំខាន់ក្នុងការទំនាក់ទំនង ផ្សព្វផ្សាយ ដែលមានការពេញនិយមសម្រាប់មនុស្សសម័យថ្មី។ តាមរយៈនេះ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណេតសម្រាប់ផ្សព្វផ្សាយ ទាំងការផ្សាយជាព័ត៌មាន ការបញ្ចេញមតិយោបល់យល់ឃើញផ្ទាល់ខ្លួនចំពោះបញ្ហាសង្គម នយោបាយជាដើម ឬក៏រឿងរ៉ាវផ្ទាល់ខ្លួនណាមួយនោះ ត្រូវបានចាត់ទុកថាជា ការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធើណេត។ ដោយសង្កេតឃើញថា ការបញ្ចេញមតិតាមមធ្យោបាយមួយនេះ មានសារៈសំខាន់មិនអាចខ្វះបានស្របតាមសម័យថ្មី គេក៏បានចាត់ទុកថាជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិ និងត្រូវបានការពារដោយរដ្ឋធម្មនុញ្ញប្រទេសជប៉ុនផងដែរ។

### ឃ. សេរីភាពបញ្ចេញមតិទាក់ទងនឹងសិទ្ធិបុគ្គល និងរូបភាពអាសអាភាស

ការបញ្ចេញមតិទាក់ទងនឹងសិទ្ធិបុគ្គល និងរូបភាពអាសអាភាស គឺសម្តៅលើការនិយាយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គល ឬសេចក្តីថ្លៃថ្នូរ កិត្តិយសអ្នកដទៃ និងការចែកចាយ បោះពុម្ព ឬលក់នូវសៀវភៅអាសអាភាស។ ការបញ្ចេញមតិនេះ ត្រូវបានចាត់ទុកចូលក្នុងវិសាលភាពនៃការការពារសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋជប៉ុន តាមរយៈមាត្រា២១នៃរដ្ឋធម្មនុញ្ញប្រទេសជប៉ុន[66]។

គួរបញ្ជាក់ផងដែរថា មុននឹងមានការសម្រេចថាសេរីភាពនេះត្រូវបានចាត់ជាសេរីភាពដែលត្រូវបានការការពារដោយមាត្រា២១នៃរដ្ឋធម្មនុញ្ញ ឬត្រូវបានការពារជាសេរីភាពបញ្ចេញមតិមួយ គឺមាននូវការបដិសេធនូវសេរីភាពបញ្ចេញមតិប្រភេទមួយនេះ។ ដោយបដិសេធថា ការបញ្ចេញមតិទាក់ទងនឹងសិទ្ធិបុគ្គល និងរូបភាពអាសអាភាសនេះ ជាបទល្មើសដែលត្រូវស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌ មិនមែនរដ្ឋធម្មនុញ្ញនោះទេ ព្រោះវាជាប្រភេទមួយនៃបទល្មើស។ ដូច្នេះ សេរីភាពទាំងពីរនេះត្រូវស្ថិតក្រៅវិសាលភាពនៃការការពាររបស់សេរីភាពបញ្ចេញមតិតាមស្មារតីនៃរដ្ឋធម្មនុញ្ញ។ ប៉ុន្តែនៅពេលដែលមានការពិភាក្សា ពិចារណាដល់ការសម្រេចពីសារតានៃការបញ្ចេញមតិទាំងពីរប្រភេទនេះ ធ្វើឱ្យមាននូវការសម្រេចសារឡើងវិញ។ ការសម្រេចសារឡើងវិញនេះ គឺការសិក្សាទៅលើសារតាដែលជាប្រភពដើមនៃការបញ្ចេញមតិទាំងពីរនេះ តាមទ្រឹស្តីរដ្ឋធម្មនុញ្ញ។ ពេលនោះហើយទើបធ្វើឱ្យមានការសម្រេចដាក់សេរីភាពបញ្ចេញមតិទាំងពីរនេះ ស្ថិតក្រោមការពារតាមរយៈរដ្ឋធម្មនុញ្ញដែរ។ ការការពារនេះត្រូវបានការពារយ៉ាងម៉ត់ចត់បំផុត ដោយមាននូវការបង្កើតជាច្បាប់

[66] ដូច៦០, ទំព័រ១៨៩

ដោយឡែក ក្នុងការកំណត់កាន់តែច្បាស់ពីទំហំនៃការការពារសេរីភាពនេះ។ ទាក់ទងនឹងច្បាប់នេះនឹងសិក្សានៅចំណុចបន្ទាប់(២.២.២)។

### ខ. សេរីភាពបញ្ចេញមតិលើវិស័យជំនួញ

សេរីភាពបញ្ចេញមតិលើវិស័យជំនួញ （Commercial Speech 、営利的言論の自由）[67] ក៏ជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិដែរ។ សេរីភាពនេះសម្តៅដល់ការផ្សព្វផ្សាយលើការធ្វើជំនួញអាជីវកម្ម។ មូលហេតុដែលការធ្វើជំនួញត្រូវបានចាត់ជាផ្នែកមួយនៃសេរីភាពបញ្ចេញមតិ ពីព្រោះថាក្នុងការធ្វើជំនួញដែលអាជីករ ធ្វើការផ្សព្វផ្សាយ ឃោសនា ពីទំនិញ ផលិតផលរបស់ខ្លួន ដែលសកម្មភាពទាំងនេះ ត្រូវបានចាត់ទុកជាការនិយាយចេញទៅក្រៅ ពោលគឺជាការបញ្ចេញមតិ ឯម្ខាងទៀតគឺជាអតិថិជនដែលជាអ្នកត្រូវទទួលព័ត៌មានពីអាជីវករទាំងនោះ។ ដោយមានភាពស៊ីសង្វាក់គ្នារវាងការឃោសនារបស់អ្នកលក់ និងការទទួលបានព័ត៌មានរបស់អ្នកទិញ ដែលប្រៀបទៅនឹងការផ្សាយព័ត៌មានដែលមានអ្នកផ្សាយ និងអ្នកទទួលព័ត៌មាន ទើបធ្វើឱ្យអ្នកស្រាវជ្រាវនីតិរដ្ឋធម្មនុញ្ញនៅប្រទេសជប៉ុន បានចាត់ទុកវាជាសេរីភាពបញ្ចេញមតិមួយ។

### ច. សេរីភាពក្នុងការជួបជុំ ការបង្កើតសមាគម

សេរីភាពក្នុងការជួបជុំ ត្រូវបានចាត់ទុកជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិ។

ការជួបជុំ សម្តៅលើការដែលមនុស្សច្រើននាក់ ធ្វើការប្រមូលផ្តុំគ្នានៅទីកន្លែងមួយមានគោលបំណងច្បាស់លាស់ដែលទាក់ទងទៅនឹងបញ្ហានយោបាយ សេដ្ឋកិច្ច ការអប់រំ សិល្បៈ សាសនាជាដើម[68]។ ឯទីកន្លែងក្នុងការជួបជុំនោះ គឺសម្តៅលើទីកន្លែងសាធារណៈដែលមានដូចជាសួនច្បារ ទីធ្លាសាធារណៈណាមួយ។ ប៉ុន្តែ ក៏មិនកម្រិតត្រឹមទីកន្លែងកំណត់មួយនោះទេ ការធ្វើបំលាស់ប្តូរទីកន្លែងពីកន្លែងមួយទៅទីកន្លែងមួយជាក្រុម ដែលហៅថាការធ្វើបាតុកម្មនោះក៏ត្រូវបានរាប់បញ្ចូលដែរ។

ចំណែកឯ សេរីភាពក្នុងការបង្កើតសមាគម ក៏ត្រូវបានចាត់ទុកជាសេរីភាពមួយក្នុងចំណោមសេរីភាពដទៃទៀតនៃសេរីភាពបញ្ចេញមតិដែរ។ សេរីភាពក្នុងការបង្កើតសមាគម គឺសម្តៅទៅលើមនុស្សមួយក្រុមដែលមានគោលបំណងណាមួយក្នុងការរួមជាសមាគមដែលមាននិរន្តភាព ឬជាក្រុមសមាគមដែលរួមគ្នាបង្កើតឡើង[69]។

---

[67] ដូច៦០, ទំព័រ១៩៣

[68] ដូច៦០, ទំព័រ២១៣

[69] ដូច២, ទំព័រ២២០

## ២.២. បទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

បន្ទាប់ពីបានសិក្សាពីសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិរបស់ប្រទេសជប៉ុន សង្កេតឃើញមាននូវការកំណត់ បែងចែក ការផ្តល់និយមន័យ អត្ថន័យ ទស្សនៈជាច្រើនដែលកើតចេញពីការស្រាវជ្រាវទៅលើនីតិរដ្ឋធម្មនុញ្ញយ៉ាងទូលំទូលាយ និងម៉ត់ចត់ពីសំណាក់អ្នកស្រាវជ្រាវ អ្នកជំនាញខាងនីតិរដ្ឋធម្មនុញ្ញ ក៏ដូចជាតាមរយៈការសិក្សាទៅលើយុត្តិសាស្ត្ររបស់តុលាការប្រទេសជប៉ុន។ ដើម្បីសិក្សាឱ្យកាន់តែស៊ីជម្រៅទៀត នឹងធ្វើការលើកយកនូវបទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិដែលប្រទេសជប៉ុនមាននាពេលបច្ចុប្បន្ន។ ដូចនឹងករណីប្រទេសកម្ពុជាដែរ គឺនឹងលើកយកនូវបទដ្ឋានគតិយុត្តអន្តរជាតិ និងបទដ្ឋានគតិយុត្តជាតិមកធ្វើការសិក្សា។

### ២.២.១. បទដ្ឋានគតិយុត្តអន្តរជាតិនៃសេរីភាពបញ្ចេញមតិ

មិនខុសគ្នានឹងប្រទេសកម្ពុជាដែរ ប្រទេសជប៉ុនជាប្រទេសលទ្ធិប្រជាធិបតេយ្យ និងជាសមាជិកនៃអង្គការសហប្រជាជាតិ ដើម្បីបំពេញឱ្យបាននូវការគោរពសិទ្ធិមនុស្សយ៉ាងពិតប្រាកដ ប្រទេសជប៉ុនក៏បានទទួលស្គាល់នូវលិខិតបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិមនុស្សផងដែរ។ ការទទួលស្គាល់នូវលិខិតបទដ្ឋានអន្តរជាតិនេះ ជាការធានាថាការគោរពសិទ្ធិមនុស្សក្នុងប្រទេសស្របទៅតាមការគោរពសិទ្ធិមនុស្សអន្តរជាតិ ដោយធ្វើការប្រៀបធៀបនិងអនុវត្តចូលក្នុងលិខិតបទដ្ឋានជាតិ។ អ្វីដែលគួរឱ្យកត់សម្គាល់ លិខិតបទដ្ឋានអន្តរជាតិទាក់ទងនឹងសេរីភាពបញ្ចេញមតិដែលប្រទេសជប៉ុនបានទទួលស្គាល់គឺដូចគ្នាទៅនឹងប្រទេសកម្ពុជាដែរ ពោលគឺមានដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

### ២.២.២. បទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

តាមរយៈការសិក្សាអំពីសញ្ញាណទូទៅនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន បង្ហាញឱ្យឃើញថាក្នុងប្រទេសជប៉ុន សេរីភាពបញ្ចេញមតិមាននូវការបែងចែកជាច្រើន និងមាននូវវិសាលភាពធំទូលាយយ៉ាងខ្លាំង។ ពោលគឺ ស្ទើរគ្រប់ផ្នែកក្នុងការរស់នៅក្នុងសង្គមសម្រាប់តម្រូវការសិទ្ធិសេរីភាព ត្រូវមានទំនាក់ទំនងជាមួយនឹងសេរីភាពបញ្ចេញមតិ។ ហេតុនេះហើយ ការបង្កើតច្បាប់គ្រប់គ្រងទៅលើប្រភេទនីមួយៗនៃសេរីភាពបញ្ចេញមតិនោះក៏មានច្រើនទៅតាមនោះដែរ។

ដូចដែលបានសិក្សានៅចំណុចនៃប្រវត្តិសេរីភាពបញ្ចេញមតិ តាមរយៈការលើកឡើងនូវរដ្ឋធម្មនុញ្ញ ដែលក្នុងនោះមាននូវរដ្ឋធម្មនុញ្ញដែលប្រទេសជប៉ុនអនុវត្តសព្វថ្ងៃ ពោលគឺ រដ្ឋធម្មនុញ្ញ

ប្រទេសជប៉ុនសម័យបច្ចុប្បន្ន។ រដ្ឋធម្មនុញ្ញប្រទេសជប៉ុនសម័យបច្ចុប្បន្ន ដែលត្រូវបានទទួលស្គាល់ថាជាច្បាប់កំពូលរបស់ប្រទេស មានចែងអំពីការធានានូវសេរីភាពបញ្ចេញមតិក្នុងមាត្រា២១។ ទាក់ទងនឹងខ្លឹមសារនៃមាត្រានេះ បានលើកមកសិក្សានៅចំណុចប្រវត្តិសាស្ត្ររួចហើយ ដូច្នេះ ក្នុងចំណុចបទដ្ឋានគតិយុត្តជាតិនេះ នឹងសិក្សាលើច្បាប់ដោយឡែកដែលមាន។

### ២.២.២.១. ច្បាប់ស្តីការបើកចំហរព័ត៌មាននៃស្ថាប័នរដ្ឋបាល[70]

ច្បាប់នេះ ជាច្បាប់មួយដែលត្រូវបានគេស្គាល់ច្រើន ប្រសិនបើនិយាយពីសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន ជាពិសេសពាក់ព័ន្ធទៅនឹងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាជនជប៉ុន។ មុននឹងបង្កើតច្បាប់នេះ[71] មាននូវការបង្កើតនូវសេចក្តីប្រកាសស្តីពីការបើកចំហរព័ត៌មាននៅតាមអាជ្ញាធរមូលដ្ឋានជាច្រើនក្នុងប្រទេសជប៉ុន។ បន្ទាប់មក នៅខែវិច្ឆិកា ឆ្នាំ១៩៩៦ មានការប្រកាសនូវសេចក្តីព្រាងច្បាប់ស្តីពីការបើកចំហរព័ត៌មាន ដោយគណកម្មាការបើកចំហរព័ត៌មានរដ្ឋបាលនៃគណកម្មាធិការកំណែទម្រង់រដ្ឋបាល។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានដាក់ទៅរដ្ឋសភាជប៉ុន នាខែមិនា ឆ្នាំ១៩៩៨ ហើយត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៩ និងត្រូវបានអនុវត្តចាប់ពីខែមេសា ឆ្នាំ២០០១។

យោងតាមមាត្រា១នៃច្បាប់នេះ ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ធានាការពារនូវសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋជប៉ុន។ ដោយប្រជាពលរដ្ឋជប៉ុនមានសិទ្ធិក្នុងការស្នើសុំការបង្ហាញនូវលិខិតរដ្ឋបាលដែលអាចបើកចំហរបាន ហើយស្ថាប័នរដ្ឋបាលត្រូវមានបង្ហាញនូវព័ត៌មានទាំងឡាយណាដែលប្រជាពលរដ្ឋត្រូវដឹងទាក់ទងនឹងស្ថាប័នរដ្ឋបាល និងមានកាតព្វកិច្ចពន្យល់ដល់ប្រជាពលរដ្ឋនូវរាល់សកម្មភាពដែលរដ្ឋាភិបាលបានធ្វើ ព្រមទាំងធ្វើការជម្រុញនូវដំណើរការរដ្ឋបាលស្របតាមលទ្ធិប្រជាធិបតេយ្យនិងប្រកបដោយយុត្តិធម៌ ក្រោមការស្វែងយល់និងការរិះគន់របស់ប្រជាពលរដ្ឋ។

### ២.២.២.២. ច្បាប់ស្តីពីការផ្សព្វផ្សាយ[72]

ច្បាប់ស្តីពីការផ្សព្វផ្សាយ ត្រូវបានបង្កើតឡើងនៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៥០។ យោងតាមមាត្រា១ ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណង ពង្រីកវិសាលភាពនៃការផ្សព្វផ្សាយដ៏សំបូរបែបដោយរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈល្អក្នុងសង្គម ជូនទៅប្រជាពលរដ្ឋ រួមទាំងការផ្សព្វផ្សាយព័ត៌មានដោយមិនមានភាពលម្អៀង អយុត្តិធម៌ ការប្រកាន់បក្សពួក និយមទៅខាង

[70] 行政機関の保有する情報の公開に関する法律という。
[71] ដូច៦០, ទំព័រ១៧៧
[72] 放送法という。

គណបក្សនយោបាយណាមួយនោះទេ។ ពោលគឺ ការផ្សព្វផ្សាយត្រូវប្រព្រឹត្តទៅដោយសុក្រឹត្យភាព ភាពត្រឹមត្រូវ ស្មើភាពគ្នា និងគោរពទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ។

ច្បាប់នេះមានតួនាទី និងមានវិសាលភាពអនុវត្តទៅលើរាល់គ្រប់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសជប៉ុន។ ប្រព័ន្ធផ្សព្វផ្សាយទាំងនោះមានវិសាលភាពធំទូលាយ ដែលមានដូចជា ការផ្សព្វផ្សាយតាមទូរទស្សន៍ ការផ្សាយផ្ទាល់ក្នុងប្រទេស ការផ្សាយបន្តផ្ទាល់ទៅក្រៅប្រទេស ឬការផ្សាយបន្តផ្ទាល់មកពីបរទេសផ្សេងៗ។ គ្រប់ប្រព័ន្ធផ្សព្វផ្សាយដែលកំពុងដំណើរការទាំងអស់ ត្រូវគោរពទៅតាមបទបញ្ញតិដែលមានចែងក្នុងច្បាប់នេះ បើមិនដូច្នោះទេនឹងមានការពិន័យផ្សេងៗដូចជា ការពិន័យជាប្រាក់ ឬការពិន័យឱ្យផ្អាកការផ្សាយជាដើម។ ព្រមជាមួយគ្នានោះដែរ តាមរយៈច្បាប់នេះ គឺគេអនុញ្ញាតឱ្យមានបង្កើតជាសមាគមប្រព័ន្ធផ្សព្វផ្សាយ (មាត្រា២០) ដែលសមាគមនោះត្រូវបង្កើតឡើងក្នុងគោលបំណងជួយជម្រុញនូវការរីកចម្រើន និងភាពសំបូរបែបនៃប្រព័ន្ធផ្សព្វផ្សាយឱ្យមានភាពរីកចម្រើនទៅតាមស្តង់ដារអន្តរជាតិ។ សមាគមនៃប្រព័ន្ធផ្សព្វផ្សាយនេះ ត្រូវអនុវត្តទៅតាមបទបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធផ្សព្វផ្សាយនេះ។

### ២.២.២.៣. ក្រមព្រហ្មទណ្ឌ

សេរីភាពបញ្ចេញមតិ ដែលទាក់ទងនឹងសិទ្ធិ កិត្តិយសបុគ្គលឯកជន ការបរិហារកេរ្តិ៍ជាសាធារណៈ ដែលត្រូវបានគេស្គាល់ថាជាបទល្មើសមួយនោះ ក្រមព្រហ្មទណ្ឌរបស់ប្រទេសជប៉ុនក៏មានចែងអំពីប្រការទាំងនេះដែរ។ ក្រមព្រហ្មទណ្ឌប្រទេសជប៉ុន ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៧។ ក្នុងក្រមនេះ មានចែងទាក់ទងនឹងបទល្មើសដែលប្រព្រឹត្តឡើងដោយសេរីភាពបញ្ចេញមតិដូចបានរៀបរាប់ខាងលើ។ រួមមានដូចជា បទការបោះពុម្ពរូបភាពអាសអាភាស បទបរិហារកេរ្តិ៍ជាសាធារណៈ បទជេរប្រមាថជាដើម។

ការបោះពុម្ពនូវសៀវភៅ ជាសេរីភាពមួយនៃសេរីភាពបញ្ចេញមតិក្នុងការបញ្ចេញគំនិតយោបល់ ការយល់ឃើញរបស់ខ្លួនតាមរយៈការបោះពុម្ពសៀវភៅ។ ក៏ប៉ុន្តែ ការបោះពុម្ពសៀវភៅដែលទាក់ទងនឹងរូបភាពអាសអាភាសដែលខុសពីក្រមសីលធម៌ ត្រូវបានហាមឃាត់ និងត្រូវបានកំណត់ជាបទល្មើសព្រហ្មទណ្ឌមួយ។ មាត្រា១៧៥នៃក្រមព្រហ្មទណ្ឌ បានចែងអំពីការចែកចាយអត្ថបទអាសអាភាស។ ការចែកចាយអត្ថបទអាសអាភាសនេះ អាចមានច្រើនរូបភាពដែលរួមមានជា អត្ថបទសៀវភៅ វីដេអូ ការផ្ញើសារតាមប្រព័ន្ធអេឡិចត្រូនិចជាដើម។ ការប្រព្រឹត្តបទល្មើសដែលប្រឆាំងនឹងបញ្ញត្តិនេះ មានន័យថានៅពេលដែលមានការផ្សាយ ឬចែកចាយនូវរូបភាពអាសអាភាសដែលត្រូវបានហាមឃាត់ ត្រូវទទួលពិន័យជាប្រាក់ក្រោម២៥០ម៉ឺនយ៉េន (ស្មើនឹង

២៥០០០ដុល្លារ) ឬត្រូវពិន័យជាប់ពន្ធនាគាររហូតក្រោមពីរឆ្នាំ។ ជាក់ស្តែង ចំពោះការចែកចាយ ឬបោះពុម្ពផ្សាយអត្ថបទ សៀវភៅដែលមានរូបភាពអាសអាភាសនោះគឺត្រូវបានចរាចរណ៍នាពេលសព្វថ្ងៃនេះ។ មិនមែនមានន័យថា ឱ្យតែទាក់ទងនឹងរូបភាពអាសអាភាសគឺត្រូវហាមឃាត់នោះទេ។ ទាក់ទងនឹងរូបភាពអាសអាភាសដែលត្រូវហាមឃាត់នោះ គឺកន្លងមកគេបានយោងទៅតាមការបកស្រាយដែលមានក្នុងសាលដីការបស់តុលាការជប៉ុនពីមុនៗមក។ បានសេចក្តីថា ការចែកចាយនូវអត្ថបទអាសអាភាសផ្សេងៗដែលខុសនឹងច្បាប់នោះ គឺជាប្រភេទនៃរូបភាពអាសអាភាសដែលខុសទៅនឹងសីលធម៌ល្អ សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទន្លាប់សង្គមល្អធ្ងន់ធ្ងរខ្លាំង រីឯអត្ថន័យពិស្តារនៃការបកស្រាយនោះ គឺអាស្រ័យលើការបកស្រាយរបស់តុលាការទៅតាមរឿងក្តីនីមួយៗ។

បន្ថែមពីនេះទៅទៀត ការបញ្ចេញមតិដែលធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គលឯកជន ដែលហៅថាការបរិហារកេរ្តិ៍ជាសាធារណៈ។ មាត្រា២៣០ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌបានចែងថា ចំពោះជនទាំងឡាយណាដែលបានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គល ដោយការបរិហារកេរ្តិ៍ ទោះបីជាការពិតឬមិនពិតក៏ដោយ ជននោះត្រូវពិន័យជាប្រាក់ក្រោម៥០ម៉ឺនយ៉េន (ស្មើនឹង៥០០០ដុល្លារ) ឬត្រូវជាប់ពន្ធនាគារក្រោមបីឆ្នាំ។ ភ្ជាប់នឹងបទល្មើសនេះដែរ ការជេរប្រមាថក៏ត្រូវចាត់ទុកថាជាបទល្មើសមួយដែរ ដែលមានចែងក្នុងមាត្រា២៣១នៃក្រមព្រហ្មទណ្ឌ។ ការបរិហារកេរ្តិ៍ជាសាធារណៈនេះ ក្នុងសង្គមជាក់ស្តែងគឺមានទំនាក់ទំនងទៅនឹងរឿងនយោបាយ។ និយាយមួយបែបទៀត ការបរិហារកេរ្តិ៍ជាសាធារណៈគឺមានសារៈសំខាន់មិនអាចខ្វះបានក្នុងសង្គមប្រជាធិបតេយ្យ សម្រាប់ការបញ្ចេញនូវការយល់ស្រប ឬមិនយល់ស្រប ការគាំទ្រ ឬប្រឆាំងទៅនឹងនយោបាយណាមួយ។ មាត្រា២៣០ ផ្នែកទី២ វាក្យខណ្ឌទី១ ចែងថា នៅពេលដែលការបរិហារកេរ្តិ៍ជាសាធារណៈនោះ ត្រូវបានទទួលស្គាល់ថាត្រូវប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ហើយត្រូវបានបង្ហាញពីការពិតនៃរឿងដែលបរិហារនោះ ជនដែលប្រព្រឹត្តត្រូវទទួលទោសបញ្ញត្តិដូចមានចែង។

### ២.២.២.៤. ច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំខាន់ពិសេសរបស់រដ្ឋ[73]

ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៣ និងត្រូវអនុវត្តនៅឆ្នាំបន្ទាប់គឺថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងរក្សានូវព័ត៌មានដែលរដ្ឋគិតថាជាងអាថ៌កំបាំងសំងាត់ និងពិសេស។ ដោយសង្កេតឃើញមាននូវការវិវត្តនៃការរីករាលដាលនៃការ

[73] 特定秘密保護法という。

ធ្វើភេរវកម្ម ក៏ដូចជាសន្តិសុខពិភពលោកកំពុងតែជួបប្រទះនូវបញ្ហាជាច្រើន រដ្ឋាភិបាលជប៉ុនបានពិភាក្សាក្នុងការបង្កើតនូវច្បាប់នេះឡើង។ យោងតាមមាត្រា១នៃច្បាប់នេះ ការរក្សានូវព័ត៌មានសំងាត់នេះ គឺដើម្បីធានាឱ្យបាននូវសន្តិសុខ សុវត្ថិភាព នៃការរស់នៅរបស់ប្រជាពលរដ្ឋជប៉ុនជៀសវាងមាននូវការបំបះបំបោរដោយសារព័ត៌មានមិនច្បាស់ការ ជាពិសេសព័ត៌មានដែលពាក់ព័ន្ធនឹងការធ្វើភេរវកម្ម។

### ២.២.២.៥. ច្បាប់ស្ដីពីការការពារសកម្មភាពដែលបង្កឱ្យមានការបំផ្លាញ

ដើម្បីរក្សាការពារសណ្ដាប់ធ្នាប់ក្នុងការធ្វើជួបជុំ ការបង្កើតសមាគម ការធ្វើបាតុកម្ម ឬសកម្មភាពណាមួយដែលមានលក្ខណៈជាក្រុម ក្នុងគោលបំណងទាមទារអ្វីមួយនោះ ច្បាប់ស្ដីពីការការពារសកម្មភាពដែលបង្កឱ្យមានការបំផ្លាញត្រូវបានបង្កើតឡើង។ ច្បាប់នេះត្រូវបានដាក់អនុវត្តឱ្យប្រើនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩២៥។

យោងតាមសេចក្ដីចែងនៃមាត្រា១[74] ក្នុងច្បាប់នេះ ច្បាប់នេះត្រូវបានបង្កើតឡើងក្នុងគោលបំណងគ្រប់គ្រង ក៏ដូចជាពិនិត្យលើបទបញ្ញត្តិនៃការធ្វើបាតុកម្ម ឬសកម្មភាពជាក្រុមដែលមានលក្ខណៈអាចបង្កឱ្យមាននូវការបំផ្លាញ ឬអំពើហិង្សាណាមួយ។ បន្ថែមពីនេះទៀត ច្បាប់នេះក៏មានចែងពីទោសបញ្ញត្តិដែលត្រូវដាក់ចំពោះអ្នកដែលបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃច្បាប់នេះ។ រួមជាមួយនឹង ការធានារក្សាឱ្យបាននូវសណ្ដាប់ធ្នាប់សាធារណៈសម្រាប់ប្រជាពលរដ្ឋ។ ថ្វីត្បិតតែច្បាប់នេះចែងដោយដាក់កម្រិតថាត្រូវគ្រប់គ្រងការប្រមូលផ្ដុំជាក្រុម ពោលគឺសិទ្ធិជួបជុំ ឬបង្កើតសមាគមរបស់ប្រជាពលរដ្ឋក៏ដោយ ក៏ច្បាប់នេះត្រូវធានាឱ្យបានថាការគ្រប់គ្រងលើសិទ្ធិនេះ ត្រូវស្ថិតក្នុងកម្រិតអប្បបរមា។ មាត្រា២[75]នៃច្បាប់នេះចែងថា ដោយទាក់ទងទៅនឹងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋដ៏សំខាន់បំផុត នោះការរក្សានូវសណ្ដាប់ធ្នាប់សាធារណៈចាំបាច់ត្រូវតែស្ថិតក្នុងកម្រិតអប្បបរមា។ មានន័យថា សេរីភាពក្នុងការជួបជុំ ឬប្រមូលផ្ដុំ ជាសេរីភាពមូលដ្ឋានមួយដែលមានសារៈសំខាន់ចាំបាច់ និងត្រូវការពារពីរដ្ឋ ទន្ទឹមនឹងនេះ ការការពារនូវសណ្ដាប់ធ្នាប់សាធារណៈសង្គម ការហាមប្រាមមិនឱ្យធ្វើសកម្មភាពណាមួយដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈក៏ត្រូវតែធ្វើមិនអាចជៀសបានឡើយ។ តែទោះជាយ៉ាងណាក្ដី ដោយឈរលើគោល

[74] 破壊活動防止法第 1 条には、「この法律は、団体の活動として暴力主義的破壊活動を行った団体に対する必要な規制措置を定めるとともに、暴力主義的破壊活動に関する刑罰規定を補整し、もって、公共の安全の確保に寄与することを目的とする。」と定めている。

[75] 破壊活動防止法第 2 条には、「この法律は、国民の基本的人権に重大な関係を有する者であるから、公共の安全の確保のために必要な最小限度においてのみ適用すべきであって、いやしくもこれを拡張して解釈するようなことがあってはならない。」と定めている。

ការណ៍នៃការគោរព និងផ្តល់តម្លៃដល់សេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋធំជាង ដូច្នេះ ការហាមឃាត់សកម្មភាពនៃការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋ ត្រូវតែជាការហាមឃាត់ក្នុងចន្លោះមួយតូចបំផុត ដោយទុកឱកាស ឬវិសាលភាពធំសម្រាប់ការប្រើប្រាស់សិទ្ធិរបស់ប្រជាពលរដ្ឋ។

**២.២.២.៦. ច្បាប់ស្តីពីការលុបបំបាត់សកម្មភាពរើសអើងទៅនឹងជនជាតិបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន**

ច្បាប់នេះត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦។ ច្បាប់នេះបង្កើតឡើងក្នុងគោលបំណងធានាឱ្យបាននូវការលុបបំបាត់ការធ្វើសកម្មភាពមិនត្រឹមត្រូវផ្សេងៗ ក្នុងន័យរើសអើង បែងចែកពូជសាសន៍ ពណ៌សម្បុរទៅនឹងជនជាតិបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន។ ដោយមានកំនត់ពីគោលគំនិតសំខាន់ៗ ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋជប៉ុនដែលមានគំនិតរើសអើងជ្រុល ឬ ធ្លាប់ធ្វើសកម្មភាពរើសអើងណាមួយទៅលើជនជាតិបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន មានការកែប្រែការយល់ឃើញរបស់ពួកគេ ដើម្បីរក្សាឱ្យបាននូវសង្គមមួយដែលមិនមានការរើសអើង និងមាននូវសន្តិសុខ និងរក្សាបាននូវសណ្តាប់ធ្នាប់សង្គមមួយល្អ។ គួររំលឹកផងដែរថា ហេតុដែលធ្វើឱ្យមាននូវការបង្កើតច្បាប់នេះឡើង គឺដោយសារតែក្នុងប្រទេសជប៉ុនមាននូវបញ្ហានៃការរើសអើងជនជាតិបរទេសដែលរស់នៅក្នុងប្រទេសជប៉ុន។ ជនជាតិបរទេសរស់នៅប្រទេសជប៉ុនដែលត្រូវប្រឈមនឹងបញ្ហារើសអើងនេះ គឺភាគច្រើនជាជនជាតិកូរ៉េ។ ហើយការរើសអើងនេះ មានទៅតាមរូបភាព ផ្សេងៗគ្នាដូចជាការដង្ហែក្បួនបាតុកម្មស្រែកទាមទារ លើកបដាដោយមានសរសេរអក្សរជេរប្រមាថផ្សេងៗដូចជាការបណ្តេញពួកគេចេញពីប្រទេសជប៉ុន ការដុតទង់ជាតិឬរូបភាពជាដើម។

ហេតុនេះហើយ ទើបធ្វើឱ្យមានការឈានទៅដល់ការបង្កើតនូវច្បាប់នេះឡើងមក ដើម្បីកុំឱ្យមាននូវការបន្តនូវរូបភាពនៃការរើសអើងពូជសាសន៍ តាមរយៈការប្រើប្រាស់សេរីភាពជ្រុលលើសពីទំហំដែលបានកំណត់ និងរក្សាឱ្យបាននូវសង្គមដែលមាននូវសណ្តាប់ធ្នាប់ល្អ។

## ២.៣. បញ្ហាប្រឈម និងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន

សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសជប៉ុន ហាក់ដូចជាមាននូវការការពារពីរដ្ឋបានល្អច្រើនតាមរយៈការកំណត់បែងចែកនូវប្រភេទនៃសេរីភាពបញ្ចេញមតិ និងវត្តមាននៃច្បាប់ជាធរមានដែលសុទ្ធសឹងតែចែងកំណត់អំពីសេរីភាពយ៉ាងទូលំទូលាយ ។ ត្បិតបែបនេះក្តី មិនមែនមានន័យថាប្រទេសជប៉ុនមិនមានជួបនូវបញ្ហាប្រឈមទាក់ទងទៅនឹងសេរីភាពបញ្ចេញមតិនោះទេ។ មាន

ន័យថា សេរីភាពបញ្ចេញមតិក្នុងប្រទេសជប៉ុនក៏ធ្លាប់មានជួប និងកំពុងជួបនូវបញ្ហាប្រឈមមិនថា បញ្ហាគតិយុត្ត ឬក៏បញ្ហាអនុវត្តជាក់ស្តែងនោះទេ។

ក្នុងចំណុចនេះ នឹងធ្វើការសិក្សាទៅលើបញ្ហាប្រឈម(២.៣.១) និងដំណោះស្រាយ (២.៣.២)នៃសេរីភាពបញ្ចេញមតិនៅប្រទេសជប៉ុន ដើម្បីធ្វើការស្វែងយល់ឱ្យបានមួយកម្រិតទៀត ទៅលើសេរីភាពបញ្ចេញមតិនេះ។ ជាពិសេស គឺសិក្សាទៅលើចំណុចខ្សោយ និងការរកវិធីដោះស្រាយទៅនឹងបញ្ហាទាំងនោះរបស់ប្រទេសជប៉ុន។

### ២.៣.១. បញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិ

#### ២.៣.១.១. បញ្ហាគតិយុត្តនៃច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំខាន់ពិសេសរបស់រដ្ឋ

ដើម្បីរក្សានូវសន្តិសុខ ក៏ដូចជាសុវត្ថិភាពរបស់ប្រជាពលរដ្ឋជប៉ុន រដ្ឋាភិបាលប្រទេសជប៉ុនបានបង្កើតនូវច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋឡើង។ ច្បាប់នេះត្រូវបានបង្កើតឡើង និងត្រូវបានអនុវត្តមកដល់សព្វថ្ងៃ។ ក៏ប៉ុន្តែ នៅមុនពេលដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើ មាននូវការប្រឆាំងរិះគន់យ៉ាងខ្លាំងពីសំណាក់គណៈមេធាវី អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ដែលក្នុងនោះក៏មានអង្គការសហប្រជាជាតិផងដែរ។ ការប្រឆាំងមិនពេញចិត្តទៅនឹងច្បាប់នេះ គឺដោយសារតែយល់ឃើញថា ច្បាប់នេះបង្កើតឡើងក្នុងការកម្រិតនូវសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ការបិទនូវការប្រមូលព័ត៌មានរបស់អ្នកសារព័ត៌មាន ដោយយកលេសថាជាព័ត៌មានដែលទាក់ទងនឹងអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋ។ ក៏ប៉ុន្តែ មានសំនួរលើកឡើងថាតើអ្វីទៅជាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋនោះ គឺមិនមាននូវការបកស្រាយច្បាស់លាស់អំពីនិយមន័យនៃពាក្យនេះទេ។ ដែលជាហេតុធ្វើឱ្យមាននូវការលើកឡើងថា នេះជាចេតនាមួយដែលរដ្ឋាភិបាល ជប៉ុនអាចប្រើប្រាស់សម្រាប់លាក់ទុកនូវព័ត៌មានណាមួយដែលគេមិនចង់ឱ្យប្រជាពលរដ្ឋដឹង។ តាមពិត ក្នុងច្បាប់នេះដដែល ព័ត៌មានដែលត្រូវបានចាត់ទុកថាជាអាថ៌កំបាំងសំងាត់ពិសេសនោះ មាននូវអាជ្ញាយុកាលកំណត់មួយ។ មានន័យថា ព័ត៌មាននោះអាចរក្សាជាព័ត៌មានសំងាត់បានក្នុងរយៈពេលកំណត់មួយតែប៉ុណ្ណោះ។ យ៉ាងនេះក្តី ក្នុងច្បាប់ដដែលនេះ បានចែងដោយមានការអនុញ្ញាតឱ្យរក្សាព័ត៌មានអាថ៌កំបាំងនោះរហូត ដោយគ្មានអាជ្ញាយុកាលកំណត់ក៏បាន។

យ៉ាងនេះហើយ ធ្វើឱ្យមាននូវការរិះគន់យ៉ាងខ្លាំងទៅលើច្បាប់មួយនេះ រហូតដល់វត្តមានរបស់អ្នកនាំពាក្យពិសេសរបស់អង្គការសហប្រជាជាតិលោក ដេវីដ ខេ (David Kaye) ដែលបានធ្វើទស្សនកិច្ចនៅប្រទេសជប៉ុនកាលពីឆ្នាំ២០១៦ បានធ្វើការវាយតម្លៃពីភាពចុះខ្សោយនូវសេរីភាព

បញ្ចេញមតិក្នុងប្រទេសជប៉ុនដោយសារការបង្កើតនូវច្បាប់នេះឡើង។ ដោយមានការលើកឡើងថា សេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន ឯករាជភាពនៃប្រព័ន្ធផ្សព្វផ្សាយទទួលរងនូវការគាបសង្កត់ពីសំណាក់រដ្ឋាភិបាល ហើយលោកបានស្នើឱ្យមាននូវការធ្វើវិសោធនកម្មនូវច្បាប់ស្តីពីការរក្សាអាថិកំបាំងសំងាត់ពិសេសរបស់រដ្ឋនេះចេញផងដែរ[76]។ ពីព្រោះថា ដោយសារតែច្បាប់នេះ ធ្វើឱ្យអ្នកសារព័ត៌មានមានភាពភ័យខ្លាចក្នុងការយកព័ត៌មាន ដោយខ្លាចយកចំព័ត៌មានដែលត្រូវបានហាមឃាត់ដែលគេមិនអនុញ្ញាតឱ្យចុះផ្សាយជាដើម ជៀសវាងត្រូវទទួលទោសពិន័យដែលមានចែងក្នុងច្បាប់នេះ។

គួរបញ្ជាក់បន្ថែមផងដែរថា ចាប់តាំងពីពេលដែលមានវត្តមាននៃច្បាប់នេះមក សញ្ញាណដែលគួរឱ្យកត់សម្គាល់គឺការវាយតម្លៃពីកម្រិតនៃសេរីភាពបញ្ចេញមតិរបស់ប្រទេសជប៉ុន ជាពិសេសសេរីភាពសារព័ត៌មាន មានការធ្លាក់ចុះជាលំដាប់។ យោងតាមរបាយការណ៍របស់អង្គការអ្នកកាសែតគ្មានព្រំដែន បានចេញនូវការវាយតម្លៃពីកម្រិតនៃសេរីភាពបញ្ចេញមតិក្នុងប្រទេសជប៉ុន ដោយក្នុងឆ្នាំ២០១០ស្ថិតក្នុងលេខរៀងទី១១ ឆ្នាំ២០១១ដល់ឆ្នាំ២០១២ស្ថិតក្នុងលេខរៀងទី២២ ឆ្នាំ២០១៣ស្ថិតក្នុងលេខរៀងទី៥៣ ឆ្នាំ២០១៤ស្ថិតក្នុងលេខរៀងទី៥៩ ឆ្នាំ២០១៥ស្ថិតក្នុងលេខរៀងទី៦១ ឆ្នាំ២០១៦ស្ថិតក្នុងលេខរៀងទី៧២[77]។ នេះជាការវាយតម្លៃមួយដែលបង្ហាញពីការធ្លាក់ចុះជាបន្តបន្ទាប់នៃស្ថានភាពសេរីភាពសារព័ត៌មានរបស់ប្រទេសជប៉ុន។

### **២.៣.១.២. បញ្ហាគតិយុត្ត និងបញ្ហាជាក់ស្តែងនៃឯករាជភាពស្ថាប័នសារព័ត៌មាន**

មានការលើកឡើងពីបញ្ហានៃភាពឯករាជរបស់ស្ថាប័នសារព័ត៌មានក្នុងប្រទេសជប៉ុន។ បញ្ហានេះត្រូវបានលើកឡើងដោយ សមាគមអ្នកសារព័ត៌មានប្រទេសជប៉ុន សមាគមអ្នកច្បាប់មេធាវីជាដើម។ ហេតុដែលបណ្តាលឱ្យមានការលើកឡើងនេះ គឺមាននូវបញ្ហាចំបងពីរ ដែលបញ្ហាទី១គឺ បញ្ហាគតិយុត្តនៃច្បាប់ស្តីពីការផ្សព្វផ្សាយ និងបញ្ហាទី២ គឺបញ្ហានៃការអនុវត្តជាក់ស្តែង។

---

[76] 「特定秘密保護法の改正　国連特別報告者が政府に勧告」(最終アクセス日：2017 年 6 月 31 日) <http://www.tokyo-np.co.jp/article/world/list/201705/CK2017053102000127.html>
「អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិវាយការណ៍ទៅរដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ស្តីពីការរក្សាអាថិកំបាំងសំងាត់ពិសេសរបស់រដ្ឋ」(កាលបរិច្ឆេទចូលទស្សនាចុងក្រោយថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៧) <http://www.tokyo-np.co.jp/article/world/list/201705/CK2017053102000127.html>

[77] 明日の自由を守る若手弁護士の会『これでわかった！超訳　特定秘密保護法』（岩波書店、2014 年）、1 頁、国境なき記者団のホームページ（最終アクセス日：2017 年 6 月 26 日）<https://rsf.org/en/ranking>　を参照。
សមាគមមេធាវីវ័យក្មេងការពារសេរីភាពថ្ងៃស្អែក, យល់ទេ! ការបកស្រាយ ច្បាប់ស្តីពីការរក្សាអាថិកំបាំងសំងាត់ពិសេសរបស់រដ្ឋ, (រោងពុម្ពអ៊ីវ៉ាណាមិ, ២០១៤), ទំព័រ១ និង គេហទំព័រអង្គការអ្នកកាសែតគ្មានព្រំដែន (កាលបរិច្ឆេទចូលទស្សនាចុងក្រោយថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧) <https://rsf.org/en/ranking>

បញ្ហាទី១ បញ្ហាគតិយុត្តនៃច្បាប់ស្តីពីការផ្សព្វផ្សាយ។ បញ្ហាគតិយុត្តនៃច្បាប់នេះ គឺពាក់ព័ន្ធនឹងមាត្រា៩។ មាត្រា៩នៃច្បាប់នេះបានចែងថា "សារព័ត៌មានមិនត្រូវធ្វើការប៉ះពាល់ទៅដល់ទំនៀមទន្លាប់ល្អរបស់សង្គម និងសណ្តាប់ធ្នាប់សាធារណៈទេ"។ ត្រង់នេះ មានបញ្ហាទាក់ទងទៅនឹងនិយមន័យនៃពាក្យពេចន៍ទំនៀមទន្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ។ មានន័យថា គេមិនមានចែងច្បាស់ពីនិយមន័យនៃពាក្យពេចន៍ទាំងអស់នេះទេ។ បញ្ហានេះ ត្រូវបានគេមើលឃើញថាជាការទុកចន្លោះមួយអាចឱ្យអ្នកអនុវត្ត ឬអ្នកដែលមានប្រយោជន៍ពីការផ្សព្វផ្សាយ និយាយឱ្យចំគឺសម្តៅលើរដ្ឋាភិបាល អាចប្រើប្រាស់មាត្រានេះ ក្នុងការហាមមិនឱ្យផ្សាយព័ត៌មានណាមួយដែលគេមិនចង់ឱ្យផ្សាយ។

បញ្ហាទី២ បញ្ហានៃការអនុវត្តជាក់ស្តែង។ តាមរយៈបញ្ហាគតិយុត្តដែលមានក្នុងមាត្រា៩ នៃច្បាប់ស្តីពីការផ្សព្វផ្សាយខាងលើនេះ បានជាប្រយោជន៍ដល់រដ្ឋាភិបាលក្នុងការលូកដៃ ជ្រៀតជ្រែកចូលក្នុងការប្រកបវិជ្ជាជីវៈសារព័ត៌មានរបស់អ្នកសារព័ត៌មាន។ បញ្ហានេះត្រូវបានលើកឡើងដោយអ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិលោក ដេវីដ ខេ (David Kaye) ដែលលោកបានដាក់ក្នុងរបាយការណ៍បណ្តោះអាសន្ន មុននឹងដាក់ជូនទៅការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[78]។ ក្នុងរបាយការណ៍បណ្តោះអាសន្ននោះ លោកបានលើកឡើងពីការបាត់បង់នូវឯករាជភាពនៃស្ថាប័នសារព័ត៌មានក្នុងប្រទេសជប៉ុន ដែលត្រូវបាត់បង់បន្តិចម្តងៗ ដោយសារការជ្រៀតជ្រែកពីរដ្ឋាភិបាល។ នៅប្រទេសជប៉ុនសព្វថ្ងៃ ត្រូវបានគេមើលឃើញថា ប្រព័ន្ធផ្សព្វផ្សាយមួយចំនួនមានការលំអៀង ទៅតាមបក្សនយោបាយមួយចំនួន ឬ ត្រូវបានគ្រប់គ្រងដោយបក្សនយោបាយមួយចំនួនដោយប្រយោល។ តាមរយៈការសង្កេតបែបនេះ អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិរូបនេះ បានលើកឡើងពីការបាត់បង់នូវការការពារសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។ ព្រោះថា នៅពេលដែលស្ថាប័នសារព័ត៌មានមិនមានភាពឯករាជ្យក្នុងការប្រកបវិជ្ជាជីវៈរបស់ខ្លួន ជាពិសេសគឺក្នុងការបំពេញការងារដើម្បីបម្រើជាប្រយោជន៍ផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ នោះធ្វើឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ជោគវាសនានៃអនាគតប្រទេសជាតិខ្លួន មិនអាចទទួលបានព័ត៌មានពិត។ ការដែលមានអាចទទួលបាននូវព័ត៌មានពិតប្រាកដ និងច្បាស់លាស់មួយដែលមានស្ថាប័នសារព័ត៌មានបំពេញការងារដើម្បីតែបម្រើប្រយោជន៍ផ្ទាល់ខ្លួននិងបក្សនយោបាយ

[78] 「国連の人権専門家、報道の独立性に対する重大な脅威を警告」（最終アクセス日：2017年6月31日）<http://www.unic.or.jp/news_press/info/18693/>
「អ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ប្រមានចំពោះការភ័យខ្លាចធ្ងន់ធ្ងរនៃឯករាជភាពសារព័ត៌មាន 」(កាលបរិច្ឆេទចូលទស្សនាចុងក្រោយថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១៧), <http://www.unic.or.jp/news_press/info/18693/>

នោះនឹងធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿចិត្តចំពោះស្ថាប័នសារព័ត៌មាន ពេលនោះគុណភាព និង ការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយក៏ត្រូវជួបបញ្ហាទៅតាមនោះដែរ។ និយាយមួយបែបទៀត ការផ្សព្វផ្សាយមិនមានការរីកចម្រើន អភិវឌ្ឍទៅមុខឡើយ។

### ២.៣.១.៣. បញ្ហាជាក់ស្ដែងនៃការប្រើពាក្យរិះគន់ក្នុងន័យរើសអើងពូជសាសន៍

ការប្រើប្រាស់ពាក្យពេចន៍ ជេរប្រមាថ មើលងាយ ក្នុងន័យរើសអើងពូជសាសន៍ (Hate Speech , ヘイトスピーチ) ត្រូវបានចាត់ជាបញ្ហាប្រឈមដ៏គួរឱ្យកត់សម្គាល់មួយក្នុងប្រទេសជប៉ុន។ ដោយធ្លាប់ជួបប្រទះនឹងបញ្ហាសង្គ្រាមដូចកាលក្នុងប្រវត្តិសាស្ត្រជាមួយនឹងប្រទេសកូរ៉េ ចិន ជាដើមនោះ មកទល់នឹងសព្វថ្ងៃនេះ ក្នុងផ្នត់គំនិតរបស់ប្រជាពលរដ្ឋជប៉ុនមួយចំនួននៅមាននូវកំហឹង ការស្អប់ ការបែងចែកពូជសាសន៍នេះនៅឡើយ។ ជាក់ស្ដែង ក្នុងប្រទេសជប៉ុននៅតាមតំបន់មួយចំនួន ជាពិសេសតំបន់ដែលមានជនជាតិកូរ៉េរស់នៅ ប្រជាពលរដ្ឋជប៉ុននាំគ្នាធ្វើបាតុកម្មប្រឆាំងនឹងការរស់នៅរបស់ជនជាតិកូរ៉េទាំងនោះ។ ការធ្វើបាតុកម្មនោះ ប្រជាពលរដ្ឋជប៉ុនតែងតែប្រើនូវពាក្យពេចន៍អសុរស ពាក្យពេចន៍បង្កឱ្យមានជម្លោះ ឬក៏ពាក្យពេចន៍ក្នុងន័យបែងចែកពូជសាសន៍ជាដើម ដែលធ្វើយ៉ាងណាមិនចង់ឱ្យពួកគេរស់នៅលើទឹកដីប្រទេសជប៉ុនបន្តទៀតនោះទេ។ ដែលពាក្យទាំងនោះ មានដូចជា "ឯងចេញពីប្រទេសយើងទៅ" "ទៅស្លាប់ទៅ" ជាដើម។ ការធ្វើការជេរប្រមាថនេះទៀតសោត ស្ដែងឡើងក្រោមរូបភាពផ្សេងៗគ្នាដូចជា តាមរយៈការធ្វើបាតុកម្មតាមដងផ្លូវ ការបង្ហោះតាមប្រព័ន្ធអ៊ីនធើណេតជាដើម។

ទាំងអស់នេះ ត្រូវបានចោទជាបញ្ហាមួយក្នុងប្រទេសជប៉ុន ដែលធ្វើឱ្យមានការពិភាក្សាអំពីភាពស្របច្បាប់ ជាពិសេសធម្មនុញ្ញភាពនៃការប្រើសេរីភាពបញ្ចេញមតិមួយនេះរបស់ប្រជាពលរដ្ឋជប៉ុន។ ប្រជាពលរដ្ឋជប៉ុនដែលចូលរួមក្នុងសកម្មភាពនេះ យល់ឃើញថាគឺជាសិទ្ធិសេរីភាពរបស់ពួកគេក្នុងការបញ្ចេញមតិ ការយល់ឃើញ ការទាមទារនូវអ្វីដែលពួកគេចង់បាន ពោលគឺជាសិទ្ធិរបស់ពួកគេ។ក៏ប៉ុន្តែ ការប្រើប្រាស់សិទ្ធិមួយនេះហាក់ដូចជាហួសពីទំហំវិសាលភាពដែលសិទ្ធិពួកគេមាន ដែលបែរជាបង្កឱ្យមាននូវការរើសអើង រូបភាពអសកម្ម ធ្វើឱ្យមាននូវអស្ថេរភាពក្នុងសង្គម និងបង្កឱ្យមានភាពភ័យខ្លាចទាំងផ្លូវកាយ និងផ្លូវចិត្តដល់ប្រជាជនកូរ៉េដែលរស់នៅក្នុងប្រទេសជប៉ុនទៀតផង។ ហេតុនេះហើយ ទើបធ្វើឱ្យមាននូវការពិភាក្សាអំពីការប្រើប្រាស់នូវសេរីភាពមួយនេះ តើស្របនិងត្រឹមត្រូវទៅនឹងរដ្ឋធម្មនុញ្ញដែរឬយ៉ាងណា។ ជាពិសេស តើគួរឱ្យមាននូវការបង្កើតច្បាប់ក្នុងការកម្រិត និងគ្រប់គ្រងលើសកម្មភាពនេះដែរឬយ៉ាងណា។ មាននូវការពិភាក្សាពីសំណាក់អ្នកជំនាញសិទ្ធិមនុស្ស ដែលទន្ទឹមនឹងនោះដែរ ក៏មាននូវការប្រឆាំងមិនយល់ស្របឱ្យមាន

នូវការបង្កើតច្បាប់ទាក់ទងនឹងបញ្ហានេះឡើង ដោយលើកឡើងថាជាការកម្រិតសិទ្ធិប្រជាពលរដ្ឋជាដើម។ គួរបន្ថែមដែរថា នៅបណ្តាប្រទេសធំមួយចំនួនក៏មានប្រឈមនឹងបញ្ហានេះផងដែរ តួយ៉ាងដូចជាសហរដ្ឋអាមេរិក អង់គ្លេស កាណាដា និងបណ្តាប្រទេសអឺរ៉ុបមួយចំនួនទៀត។ ក៏ប៉ុន្តែ ចំពោះសហរដ្ឋអាមេរិក បានចាត់ទុកថាការធ្វើបាតុកម្មបែបនេះ ជាសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ហើយមិនត្រូវបានកម្រិត ឬហាមឃាត់ដោយច្បាប់អ្វីនោះទេ។

**២.៣.១.៤. បញ្ហាជាក់ស្តែងនៃការកម្រិតសេរីភាពក្នុងការធ្វើបាតុកម្ម**

ការធានានូវការប្រើប្រាស់សេរីភាពបញ្ចេញមតិ តាមរយៈការធ្វើបាតុកម្មក្នុងប្រទេសជប៉ុនត្រូវបានទទួលស្គាល់ថាប្រព្រឹត្តិទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ។ ក៏ប៉ុន្តែ ការផ្តល់ឱ្យប្រជាពលរដ្ឋនូវសេរីភាពនេះហាក់ដូចជាមាននូវបញ្ហាប្រឈម ឬនិយាយម៉្យាងទៀតថាមាននូវការរិះគន់មិនពេញចិត្តចំពោះការផ្តល់ឱ្យដូចសព្វថ្ងៃនេះ។ ប្រជាពលរដ្ឋជប៉ុនមានសិទ្ធិក្នុងការដង្ហែរក្បួនធ្វើបាតុកម្មក្នុងការប្រឆាំង តវ៉ា ទាមទារនូវសំណូមពរណាមួយដែលខ្លួនត្រូវការស្របទៅតាមច្បាប់។ នេះជាការផ្តល់ឱ្យ និងការពារដោយរដ្ឋធម្មនុញ្ញប្រទេសជប៉ុនមាត្រា២១។ យ៉ាងនេះក្តីចំពោះការអនុវត្តជាក់ស្តែង មានការលើកឡើងថា ការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋជប៉ុនមាននូវការកម្រិតនូវសិទ្ធិ ឬមាននូវការប៉ះពាល់សិទ្ធិធ្វើបាតុកម្មរបស់ពួកគេ។ នៅពេលធ្វើបាតុកម្ម ប្រជាពលរដ្ឋត្រូវស្ថិតក្នុងក្បួនដង្ហែរមួយត្រឹមត្រូវ ដោយមានអមដោយប៉ូលីសការពារសន្តិសុខ តែក្នុងការស្រែកតវ៉ា ពួកគេមិនអាចធ្វើបានដោយសេរីនោះទេ។ មានន័យថា ពួកគេមិនអាចស្រែកខ្លាំងៗដែលអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដទៃ ដោយពួកគេត្រូវធ្វើការដង្ហែរក្បួនក្នុងសភាពស្ងៀមស្ងាត់ អាចស្រែកទាមទារបានក្នុងកម្រិតមួយដែលបានកំណត់។ ស្ថានភាពបែបនេះ ដែលធ្វើឱ្យមាននូវការលើកឡើងថា ជាការដែលកម្រិតនូវសិទ្ធិសេរីភាពបញ្ចេញមតិរបស់ពួកគេ ដោយមិនបានបើកទូលាយដោយសេរីសម្រាប់ពួកគេក្នុងការនិយាយស្តី បញ្ចេញការយល់ឃើញរបស់ពួកគេឱ្យអស់ពីចិត្ត។ ហើយនៅពេលដែល ពួកគេធ្វើបាតុកម្ម ត្រូវសមត្ថកិច្ចដែលការពារសណ្តាប់ធ្នាប់ ធ្វើការកត់សម្គាល់អត្តសញ្ញាណរបស់ពួកគេ ដែលនេះធ្វើឱ្យមានការប៉ះពាល់នូវសេរីភាពក្នុងការធ្វើបាតុកម្មហើយ ប៉ះពាល់ដល់សិទ្ធិបុគ្គលរបស់ពួកគេថែមទៀតដោយត្រូវមានការត្រួតពិនិត្យបែបនេះ។

**២.៣.១.៥. បញ្ហាជាក់ស្តែងនៃការបង្កើតសមាគម**

ការបង្កើតសមាគម គឺជាសេរីភាពរបស់ប្រជាពលរដ្ឋ។ ទោះជាអ្នកណាចង់បង្កើតសមាគមជាមួយអ្នកណា ហើយទោះជាគេចង់ធ្វើការកំណត់បែងចែកពីលក្ខខណ្ឌដើម្បីចូលក្នុងសមាគមក៏

ដោយ ក៏មិនមានអ្វីខុសដែរ ព្រោះជាសេរីភាពរបស់ពួកគេ ហើយក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។ ក៏ប៉ុន្តែ នៅពេលដែលមាននូវការកំណត់នូវលក្ខខណ្ឌក្នុងការចូលក្នុងសមាគម ពេលនោះនឹងធ្វើឱ្យមាននូវបញ្ហានៃការរើសអើងកើតឡើង។ ឧទាហរណ៍ជាក់ស្តែង នៅពេលដែលមាននូវការបង្កើតសមាគមមួយដែលលក្ខខណ្ឌនៃសមាគមនោះតម្រូវឱ្យ អ្នកចូលរួមជាសមាជិកនោះត្រូវតែជាបុរសទើបអាចចូលរួមបាន។ ការបង្កើតឱ្យមាននូវលក្ខខណ្ឌបែបនេះ ធ្វើឱ្យមាននូវការរើសអើងចំពោះស្ត្រីភេទមិនឱ្យចូលរួមក្នុងសមាគមនោះ។ ដែលនេះ ទន្ទឹមនឹងការផ្តល់នូវសេរីភាពក្នុងការបង្កើតសមាគម ក៏មាននូវបញ្ហានៃការរើសអើងកើតឡើង។

### ២.៣.២. ដំណោះស្រាយបញ្ហាសេរីភាពបញ្ចេញមតិ

#### ២.៣.២.១. ច្បាប់ស្តីពីការរក្សាអាថ៌កំបាំងពិសេសរបស់រដ្ឋ

ទោះបីជាច្បាប់នេះត្រូវទទួលបានការរិះគន់ មិនពេញចិត្តពីសំណាក់អ្នករិះគន់ប្រឆាំងមួយចំនួននៅប្រទេសជប៉ុនក៏ដោយ តែនៅទីបំផុតច្បាប់នេះនៅតែត្រូវបានអនុម័តនិងត្រូវបានដាក់ឱ្យប្រើប្រាស់ដដែល។ យ៉ាងនេះក្តី ទាក់ទងនឹងបញ្ហាដែលក្រុមអ្នកប្រឆាំងបានលើកឡើងមកនោះឃើញថានៅមិនទាន់មានកើតឡើងជាក់ស្តែងនៅឡើយទេ។ មានន័យថា បញ្ហាទាំងនោះគឺជាបញ្ហាដែលគេមានការភ័យខ្លាច និងទស្សន៍ទាយទុកមុន។ ហេតុនេះ រដ្ឋាភិបាលប្រទេសជប៉ុនមិនបានចាត់ទុកថាបញ្ហាទាំងអស់នោះគឺជាបញ្ហានោះទេ ទើបធ្វើឱ្យគេមិនមានគិតគូរអំពីដំណោះស្រាយអ្វីទាំងអស់។

ក៏ប៉ុន្តែ បើយោងតាមអ្នកនាំពាក្យពិសេសរបស់អង្គការសហប្រជាជាតិដែលបានបំពេញទស្សនកិច្ចនៅក្នុងប្រទេសជប៉ុនដោយផ្ទាល់វិញ លោកបានលើកឡើងថាការបង្កើតច្បាប់នេះជាបញ្ហាគម្រាមកំហែងដល់សេរីភាពបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលប្រទេសជប៉ុនត្រូវគិតគូរពិចារណាលើការវិសោធនកម្មច្បាប់នេះ។ ព្រោះថា បើមិនដូច្នោះទេប្រទេសជប៉ុនដែលត្រូវបានគេទទួលស្គាល់ថាបានការពារនូវសេរីភាពបញ្ចេមតិរបស់ប្រជាពលរដ្ឋខ្លួនយ៉ាងច្បាស់ៗ នៅក្នុងមាត្រា២១នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ន ក្លាយជាប្រទេសដែលមិនមាននូវការគោរពសិទ្ធិជាមូលដ្ឋានដ៏សំខាន់មួយនេះរបស់ប្រជាពលរដ្ឋជាមិនខាន។

#### ២.៣.២.២. ឯករាជភាពស្ថាប័នសារព័ត៌មាន

ឆ្លើយតបទៅនឹងបញ្ហានៃឯករាជភាពស្ថាប័នសារព័ត៌មានរបស់ប្រទេសជប៉ុន ដែលមកពីមូលហេតុនៃមាត្រា៤ច្បាប់ស្តីពីការផ្សព្វផ្សាយ អ្នកនាំពិសេសរបស់អង្គការសហប្រជាជាតិបានស្នើ

ឱ្យធ្វើការលុបមាត្រា៩នេះចោល និងបង្កើតនូវច្បាប់គ្រប់គ្រងអ្នកសារព័ត៌មានដោយឯករាជពីរដ្ឋាភិបាល។ លោកដេវីដ ខេ ដែលជាអ្នកនាំពាក្យពិសេសនេះ បានលើកឡើងចំៗថា មាត្រា៩នៃច្បាប់ស្តីពីការផ្សព្វផ្សាយនេះ គឺជាចេតនារបស់រដ្ឋាភិបាលជប៉ុនដែលមានបំណងធ្វើឱ្យស្ថាប័នសារព័ត៌មានជប៉ុនមិនមានឯករាជភាព។ តាមរយៈមាត្រា៩នៃច្បាប់ស្តីពីការផ្សព្វផ្សាយនេះ ធ្វើឱ្យអ្នកសារព័ត៌មានមានភាពភ័យខ្លាច មិនមានសេរីភាពក្នុងការបំពេញវិជ្ជាជីវៈជាអ្នកសារព័ត៌មានបានពេញលេញ។ នៅពេលដែលអ្នកសារព័ត៌មានមិនអាចបំពេញវិជ្ជាជីវៈដោយឯករាជ្យបាននោះ នឹងធ្វើឱ្យប៉ះពាល់ទៅលើសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ ដែលជាសិទ្ធិដ៏សំខាន់បំផុតមិនអាចខ្វះបាន។ ដូចនេះ ជាដំណោះស្រាយចំពោះមុខ ការលុបមាត្រានេះចេញពីក្នុងច្បាប់ស្តីពីការផ្សព្វផ្សាយ គឺជាវិធីដែលរដ្ឋាភិបាលគួរធ្វើ។

### ២.៣.២.៣. ការប្រើពាក្យរិះគន់ក្នុងន័យរើសអើងពូជសាសន៍

បញ្ហាដែលកើតចេញពីការប្រើប្រាស់សេរីភាពបញ្ចេញមតិ តាមរយៈការបង្ហោះលើអ៊ីនធើណេត ឬក៏តាមរយៈការដង្ហែរក្បួនបាតុកម្មរបស់ប្រជាពលរដ្ឋជប៉ុន ក្នុងការស្រែកតវ៉ាមិនឱ្យជនជាតិកូរ៉េរស់នៅក្នុងប្រទេសជប៉ុននោះ ត្រូវបានគេមើលឃើញថាមានភាពហួសហេតុ។ បញ្ហានេះ ត្រូវបានគេមើលឃើញថាបានបង្កឱ្យមាននូវការរើសអើងពូជសាសន៍ ហើយបានធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ជនបរទេសទាំងនោះ។ ដើម្បីទប់ស្កាត់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហានេះ ប្រទេសជប៉ុនបានសម្រេចបង្កើតឱ្យមាននូវច្បាប់មួយឡើង។ ច្បាប់នោះបកប្រែជាភាសាខ្មែរថា "ច្បាប់ស្តីពីការទប់ស្កាត់សកម្មភាពរើសអើង"។ ការបង្កើតច្បាប់នេះត្រូវបានគេមើលឃើញថា ជាដំណោះស្រាយមួយ ដែលរដ្ឋាភិបាលជប៉ុនជ្រើសរើសក្នុងការដោះស្រាយបញ្ហាការរើសអើងពូជសាសន៍នេះ។ ទោះបីជាមាននូវការមិនពេញចិត្ត និងចោទប្រកាន់រដ្ឋាភិបាលថា បង្កើតច្បាប់នេះធ្វើឱ្យមាននូវការកម្រិតសិទ្ធិសេរីភាពរបស់ពួកគេ តាមរយៈការកំណត់ឱ្យមានទោសទណ្ឌផ្សេងៗក៏ដោយ។

### ២.៣.២.៤. ការធ្វើបាតុកម្ម និងការបង្កើតសមាគម

ទាក់ទិននឹងបញ្ហាក្នុងការត្រួតពិនិត្យលើការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋជប៉ុន ក៏នៅមិនទាន់មាននូវដំណោះស្រាយណាមួយពិតប្រាកដពីរដ្ឋាភិបាលជប៉ុននៅឡើយទេ។ ដោយសារមូលហេតុថា បញ្ហាទាំងអស់នេះត្រូវបានគេមើលឃើញជាការទទូចចង់បានរបស់ក្រុមប្រឆាំង ធ្វើការរិះគន់ទៅលើរដ្ឋាភិបាលជប៉ុនតែប៉ុណ្ណោះ។ ខាងរដ្ឋាភិបាលបានចាត់ទុកថា ការត្រួតពិនិត្យនេះ គឺធ្វើឡើងដើម្បីរក្សាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈល្អ ផ្តល់នូវការការពារដល់សុវត្ថិភាពបាតុករ ក៏ដូចជាសុវត្ថិភាពរបស់អ្នកដទៃទៀតដែលអ្នកជុំវិញបរិវេណធ្វើបាតុកម្មនោះ។ ឯការដែលសមត្ថកិច្ច

ធ្វើការកត់សម្គាល់អត្តសញ្ញាណរបស់បាតុករនោះ គឺដោយសារតែក្នុងគោលបំណងកំណត់ឱ្យបានច្បាស់នូវវត្តមានបាតុករ ជៀសវាងការបន្លំចូលដោយមិនត្រឹមត្រូវ ហើយធ្វើឱ្យកើតមានអំពើអសន្តិសុខណាមួយកើតឡើង។ ទោះជាយ៉ាងណា បញ្ហានៃការធ្វើការកត់សម្គាល់អត្តសញ្ញាណរបស់បាតុករនេះ បានក្លាយជាបញ្ហាមួយដែលពាក់ព័ន្ធនឹងសេរីភាពក្នុងការធ្វើបាតុកម្មរបស់គេ ព្រោះថាត្រូវមានការត្រួតពិនិត្យបែបនេះ។ ចំពោះបញ្ហានេះដែរ ក្រុមអ្នកការពារសិទ្ធិសេរីភាពមួយរបស់ជប៉ុន បានលើកឡើងថានឹង ព្យាយាមស្វែងរកនូវដំណោះស្រាយដាក់ស្នើទៅរដ្ឋាភិបាលជប៉ុននាពេលខាងមុខ[79]។

### ២.៣.២.៥. ការបង្កើតសមាគម

ដោយឡែក ចំពោះបញ្ហានៃការបង្កើតសមាគមដែលធ្វើឱ្យមាននូវការរើសអើងវិញ ប្រសិនបើជា ការបង្កើតសមាគមនោះ ត្រូវបានគេរកឃើញពិតជាបានធ្វើដោយមានចេតនារើសអើងបែងចែកក្រុមពិតប្រាកដមែននោះ នោះការបង្កើតសមាគមនោះនឹងត្រូវចាត់ទុកថាខុសនឹងច្បាប់។ ការចាត់ទុកថាខុសនឹងច្បាប់នេះ គឺដោយសារមូលហេតុដែលខុសទៅនឹងសិទ្ធិរបស់មនុស្សដូចគ្នា យោងទៅតាមអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើង ដែលជាលិខិតុបករណ៍អន្តរជាតិក្នុងការការពារសិទ្ធិមនុស្ស។ មួយវិញទៀត ក្នុងប្រទេសជប៉ុនផ្ទាល់ សកម្មភាពដែលបង្កឱ្យមានការរើសអើងដោយការបង្កើតសមាគមបែបនេះ ត្រូវបានចាត់ទុកថាខុសទៅនឹងគោលការណ៍នៃការប្រើប្រាស់សិទ្ធិឯកជនរបស់សិទ្ធិមនុស្ស ព្រមជាមួយនឹងការលើកឡើងនូវការធ្វើឱ្យមាននូវការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏អំពើអនីត្យានុកូល ទៅតាមការសម្រេចរបស់តុលាការ[80]។

[79] 秘密保護法対策弁護団、「表現の自由と知る権利の危機をどのようにして克服するのか」（最終アクセス日：2017年7月1日）<http://nohimituho.exblog.jp/25869014/>
ក្រុមដាក់គោលការណ៍ច្បាប់ស្តីពីការរក្សាអាថិកំបាំងសំងាត់របស់រដ្ឋ, តើគ្រោះថ្នាក់នៃសេរីភាពបញ្ចេញមតិនិងសិទ្ធិទទួលបានព័ត៌មានត្រូវជំនះដូចម្តេច? (កាលបរិច្ឆេទចូលទស្សនាចុងក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៧)
<http://nohimituho.exblog.jp/25869014/>
[80] ដូច២, ទំព័រ២២១

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការបកស្រាយនូវប្រធានបទនេះរួចមក បានបង្ហាញកាន់តែច្បាស់អំពីអត្ថន័យ និងសារៈសំខាន់នៃសេរីភាពបញ្ចេញមតិ។ មិនថាតែចំពោះប្រទេសកម្ពុជា ឬប្រទេសជប៉ុន ពោលគឺគ្រប់ប្រទេសដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យសេរី និង គោរពនូវគោលការណ៍សិទ្ធិមនុស្ស សុទ្ធតែបានទទួលស្គាល់នូវតម្លៃនៃសេរីភាពមួយនេះ។ សេរីភាពមួយនេះ ជាសេរីភាពមួយដែលសំខាន់មិនអាចខ្វះបាន មិនថាតែចំពោះតែសេរីភាពបញ្ចេញមតិតែមួយមុខទេ គេសេរីភាពនេះនឹងធ្វើឱ្យមាននូវសិទ្ធមនុស្សជាមូលដ្ឋានដទៃផ្សេងទៀត។ ប្រសិនបើ មិនមានការផ្តល់នូវសេរីភាពនេះទេ សិទ្ធិក៏ដូចជាសេរីភាពផ្សេងៗទៀតក៏មិនអាចកើតមានដែរ។ តាមរយៈប្រធានបទនេះ សញ្ញាណដែលមានក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន អាចបង្ហាញជាការសន្និដ្ឋានមួយបានថា សេរីភាពបញ្ចេញមតិដែលមាននូវវិសាលភាពគ្របដណ្តប់ធំទូលាយ ត្រូវបានបែងចែកចេញជាសេរីភាពដទៃទៀតជាច្រើន។ ក្នុងនោះមានដូចជា សេរីភាពព័ត៌មាន សេរីភាពប្រមូលព័ត៌មាន សិទ្ធិទទួលបានព័ត៌មាន សិទ្ធិក្នុងការធ្វើបាតុកម្ម សិទ្ធិក្នុងការជួបជុំ សិទ្ធិក្នុងការបង្កើតសមាគម។ សិទ្ធនិងសេរីភាពទាំងអស់នេះ មាននូវទំនាក់ទំនងគ្នាជាមួយនឹងសេរីភាពបញ្ចេញមតិ និងបំពេញគ្នាទៅវិញទៅមក។ មុននឹងអាចធ្វើការបញ្ចេញមតិ ការគាំទ្រ ការប្រឆាំងផ្សេងៗ ប្រជាពលរដ្ឋត្រូវទទួលបានព័ត៌មានដែលនេះបង្កើតឱ្យមាននូវសេរីភាពព័ត៌មាន។ សេរីភាពព័ត៌មានត្រូវបានផ្តល់ទៅឱ្យស្ថាប័នព័ត៌មានដែលមានអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មានជាអ្នកធ្វើការផ្សាយបន្តទៅប្រជាពលរដ្ឋ។ ក្នុងការប្រកបវិជ្ជាជីវៈសារព័ត៌មាន អ្នកសារព័ត៌មានក៏ត្រូវមាននូវសិទ្ធិសេរីភាពរបស់ខ្លួនដែរ ដែលសិទ្ធិនោះត្រូវបានគេស្គាល់ថាជាសិទ្ធិប្រមូលព័ត៌មាន។ បើមិនមាននូវការការពារសិទ្ធិនោះទេ អ្នកសារព័ត៌មាននឹងមិនអាចទទួលបានព័ត៌មានយកទៅផ្សព្វផ្សាយទៅកាន់ប្រជាពលរដ្ឋបានឡើយ។ ទន្ទឹមនឹងការដែលមាននូវការការពារសេរីភាពរបស់អ្នកសារព័ត៌មានដែលជាផ្សាយ អ្នកដែលទទួលព័ត៌មានពោលគឺប្រជាពលរដ្ឋក៏ត្រូវទទួលបាននូវការការពារសិទ្ធិសេរីភាពរបស់ពួកគេដូចគ្នា ហើយសិទ្ធិនោះត្រូវបានគេហៅថា សិទ្ធិទទួលបានព័ត៌មាន។ សិទ្ធិទទួលបានព័ត៌មាននេះ មានសារៈសំខាន់ចាំបាច់ណាស់សម្រាប់ប្រជាពលរដ្ឋ ព្រោះថាតាមរយៈការទទួលបានព័ត៌មានអំពីសង្គមជាតិនយោបាយដឹកនាំប្រទេស និងបញ្ហាដទៃផ្សេងទៀត ប្រជាពលរដ្ឋដែលជាអ្នកសម្រេចលើជោគវាសនាប្រទេសជាតិខ្លួន ពោលគឺការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ អ្នកដឹកនាំប្រទេសដូចនេះការសម្រេចចិត្តក្នុងការជ្រើសរើសនេះ គឺអាស្រ័យទៅលើអ្វីដែលគេយល់ឃើញ និងយោងតាមអ្វីដែលគេបានដឹងពីប្រទេសជាតិ ពីព័ត៌មាននេះឯង។ បន្ថែមទៅទៀតដែរ ប្រជាពលរដ្ឋតែងតែ

មានការពេញចិត្ត មិនពេញចិត្តផ្សេងៗទៅតាមការយល់របស់បុគ្គលរៀងៗខ្លួន ម៉្យាងទៀតពួកគេអាចចង់សំណូមពរ ឬធ្វើការទាមទារមិនសុខចិត្តទៅនឹងអ្វីមួយ ពួកគេនឹងធ្វើការបញ្ចេញមតិរបស់ពួកគេដោយធ្វើការប្រមូលផ្តុំជាក្រុម។ ពេលនោះសេរីភាពក្នុងការធ្វើបាតុកម្ម ការជួបប្រជុំ ការបង្កើតសមាគមជាដើមក៏ក្លាយជាសេរីភាពដែលសំខាន់មួយជាមួយនឹងសេរីភាពបញ្ចេញមតិ។ នេះជាការសរុបរួមនៃសញ្ញាណទូទៅទាក់ទងនឹងសេរីភាពបញ្ចេញមតិដែលមានក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុន។ ក៏ប៉ុន្តែ ប្រសិនបើធ្វើការសិក្សាដោយធ្វើការបែងចែករវាងសេរីភាពបញ្ចេញមតិនៅក្នុងប្រទេសទាំងពីរ នឹងឃើញមាននូវចំណុចដូចគ្នា និងខុសគ្នា រួមនឹងចំណុចវិជ្ជមាន និងអវិជ្ជមាន។

ករណីប្រទេសកម្ពុជា ដោយសូមធ្វើការបែងចែកជាបីចំណុចធំៗ ទី១ គឺអំពីសញ្ញាណនៃសេរីភាពបញ្ចេញមតិ។ ទាក់ទងនឹងសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា តាមពិតនៅមិនទាន់មាននូវសញ្ញាណរួមមួយច្បាស់លាស់ដែលធ្វើការបកស្រាយពីប្រភេទនៃសេរីភាពបញ្ចេញមតិ និងទំនាក់ទំនងនៃសិទ្ធិនេះនៅឡើយទេ។ ដោយភាគច្រើននៃការស្រាវជ្រាវអំពីសេរីភាពបញ្ចេញមតិនេះ មានតែការសិក្សាបង្ហាញពីអត្ថន័យ សារៈសំខាន់តែប៉ុណ្ណោះ ក៏ប៉ុន្តែបែរជាមិនមាននូវការបង្ហាញឱ្យបានច្បាស់លាស់ពីប្រភេទ និងទំនាក់ទំនងនៃសេរីភាពនេះ។ ព្រោះថា សេរីភាពបញ្ចេញមតិនេះ មិនមែនតែជាសេរីភាពតែមួយទេ គឺមានវិសាលភាព ទំនាក់ទំនងទៅនឹងសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សជាច្រើនទៀត។ ទី២ គឺអំពីបទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិ។ មានទាំងបទដ្ឋានគតិយុត្តអន្តរជាតិ និងបទដ្ឋានគតិយុត្តជាតិដែលទាក់ទងនឹងសេរីភាពបញ្ចេញមតិ។ ចំពោះបទដ្ឋានគតិយុត្តអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ គឺមានភាពគ្រប់គ្រាន់ដែលអាចនិយាយបានថា ទទួលស្គាល់បានគ្រប់នូវរាល់បទដ្ឋានគតិយុត្តអន្តរជាតិដែលទាក់ទងនឹងសិទ្ធិមនុស្សទាំងអស់។ រីឯបទដ្ឋានគតិយុត្តជាតិក៏ដូចគ្នាដែរ បើនិយាយពីចំនួននៃបទដ្ឋានគតិយុត្តទាំងនោះ ត្បិតមិនទាន់គ្រប់គ្រាន់ទាំងស្រុង តែអាចនិយាយបានថាអាចទទួលយកបាន ក៏ប៉ុន្តែបើនិយាយពីគុណភាព ដែលចង់សម្តៅទៅលើបញ្ញត្តិដែលមានចែងក្នុងបទដ្ឋានទាំងនោះវិញហាក់ដូចជាមិនទាន់អាចនិយាយបានថាគ្រប់គ្រាន់នៅឡើយទេ។ ដូចបានបង្ហាញតាមរយៈបញ្ហាប្រឈមនៃសេរីភាពបញ្ចេញមតិដែលមានក្នុងប្រទេសកម្ពុជា គឺមាននូវបញ្ហាគតិយុត្តដែលពាក់ព័ន្ធនឹងសេរីភាពសារព័ត៌មាន សិទ្ធិទទួលបានព័ត៌មានជាដើម។ ទី៣ គឺអំពីបញ្ហាប្រឈមនិងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិ។ ភ្ជាប់គ្នាទៅនឹងបញ្ហាគតិយុត្ត បញ្ហាដែលកើតមានក្នុងការអនុវត្តជាក់ស្តែងក្នុងសង្គមកម្ពុជាជាក់ស្តែង ត្រូវបានបន្តមានជាបន្តបន្ទាប់ ដែលមិនទាន់ឃើញមាននូវដំណោះ

ស្រាយសមស្របទៅនឹងបញ្ហាទាំងនោះនៅឡើយ។ ចំណុចនេះ ជាអ្វីដែលគួរតែមាននូវការគិតគូរពិចារណា និងយកចិត្តទុកដាក់បំផុត។

ដោយឡែក ករណីប្រទេសជប៉ុន ទី១ទាក់ទងនឹងសញ្ញាណនៃសេរីភាពបញ្ចេញមតិ។ ដោយការយកចិត្តទុកដាក់លើការគោរពសិទ្ធិរបស់ប្រជាពលរដ្ឋខ្លាំង សេរីភាពបញ្ចេញមតិក្នុងប្រទេសជប៉ុន ត្រូវបានមើលឃើញថាមានភាពល្អប្រសើរជាងប្រទេសកម្ពុជា។ ភាពល្អប្រសើរនេះ មកពីការដើរមុន ក៏ដូចជាការឆ្លងកាត់ ទទួលបាននូវបទពិសោធន៍មុនប្រទេសកម្ពុជាទាក់ទងនឹងការគោរពសិទ្ធិមនុស្ស។ មួយវិញទៀត ដោយភាពសម្បូរបែបនៃការស្រាវជ្រាវលើនីតិរដ្ឋធម្មនុញ្ញ នីតិសិទ្ធិមនុស្ស ដែលអាចនិយាយម៉្យាងទៀតបានថាប្រទេសជប៉ុនមាននូវការបើកទូលាយលើការស្រាវជ្រាវនេះ ទើបធ្វើឱ្យមាននូវការសិក្សា ការបែងចែក ទៅលើទ្រឹស្តីពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិនេះបានទូលំទូលាយ។ ទី២ គឺអំពីបទដ្ឋានគតិយុត្តនៃសេរីភាពបញ្ចេញមតិ។ មិនខុសពីប្រទេសកម្ពុជា លើការទទួលស្គាល់នូវបទដ្ឋានគតិយុត្តអន្តរជាតិស្តីពីសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិ ប្រទេសជប៉ុនគឺដូចគ្នា។ អ្វីដែលខុសគ្នា គឺបទដ្ឋានគតិយុត្តជាតិនៃសេរីភាពបញ្ចេញមតិ។ ប្រទេសជប៉ុនមាននូវបទដ្ឋានគតិយុត្តជាតិដែលពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិច្រើន។ ការដែលប្រទេសជប៉ុនមាននូវបទដ្ឋានគតិយុត្តច្រើនបែបនេះ អាចនិយាយបានថាមកពីការបែងចែកទៅលើប្រភេទ ក៏ដូចជាទំនាក់ទំនងនៃសេរីភាពបញ្ចេញមតិនេះមានច្រើនប្រភេទ ដូច្នេះតម្រូវឱ្យមានបទដ្ឋានគតិយុត្តទៅតាមចំនួននោះដែរ។ គួរបញ្ជាក់ផងដែរថា ប្រសិនបើធ្វើការសិក្សាឱ្យលម្អិត និងស៊ីជម្រៅបំផុត បទដ្ឋានគតិយុត្តដែលមានពាក់ព័ន្ធនឹងសេរីភាពបញ្ចេញមតិក្នុងប្រទេសជប៉ុន គឺមានច្រើនណាស់ ដោយមានភាពប្រទាក់ក្រឡាគ្នាពីច្បាប់មួយទៅច្បាប់មួយ។ ប៉ុន្តែ អាស្រ័យដោយទំហំនៃការស្រាវជ្រាវមានកំណត់ ពាក់ព័ន្ធនឹងចំណុចនេះនឹងលើកទៅការស្រាវជ្រាវក្រោយទៀត។ ទី៣ គឺបញ្ហាប្រឈម និងដំណោះស្រាយនៃសេរីភាពបញ្ចេញមតិ។ ទោះជាមាននូវភាពល្អប្រសើរច្រើនជាងប្រទេសកម្ពុជា តែប្រទេសជប៉ុនក៏មាននូវបញ្ហានៃការប៉ះពាល់សេរីភាពបញ្ចេញមតិដែរ។ ទាក់ទិននឹងបញ្ហាប្រឈមនេះដែរ សង្កេតឃើញមាននូវបញ្ហាមួយចំនួនដែលស្រដៀងទៅនឹងប្រទេសកម្ពុជាដែរ ដូចជាបញ្ហានៃមាត្រា៩ច្បាប់ស្តីពីការផ្សព្វផ្សាយ បញ្ហានៃឯករាជភាពស្ថាប័នព័ត៌មានជាដើម។ តែក៏មាននូវបញ្ហាមួយចំនួនដែលប្រទេសកម្ពុជាមិនមាន ឬមិនទាន់មានធ្ងន់ធ្ងរដូចប្រទេសជប៉ុន។ បញ្ហានោះគឺពាក់ព័ន្ធនឹងការប្រើប្រាស់សេរីភាពបញ្ចេញមតិ សិទ្ធិក្នុងការធ្វើបាតុកម្មជ្រុលហួសហេតុរហូតដល់មានការរើសអើង បែងចែកពូជសាសន៍ជនជាតិបរទេសរស់នៅក្នុងប្រទេសជប៉ុនបច្ចុប្បន្ន។

# អនុសាសន៍

## អនុសាសន៍

ឆ្លងកាត់តាមការបកស្រាយលើប្រធានបទនេះរួចមក បានបង្ហាញឱ្យឃើញថា សេរីភាពបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា និងប្រទេសជប៉ុនមាននូវចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួន។ ជាទុនក្នុងការផ្តល់ជាដំណោះស្រាយទៅនឹងបញ្ហាដែលបានកើតមាន នាងខ្ញុំសូមបង្ហាញនូវការយល់ឃើញជាអនុសាសន៍ដូចខាងក្រោម ៖

**ករណីប្រទេសកម្ពុជា ៖**

ដោយសង្កេតឃើញទិដ្ឋភាពជារួម ស្ថានភាពនៃសេរីភាពបញ្ចេញមតិសព្វថ្ងៃហាក់មានការវិវត្តបានល្អប្រសើរជាងមុន ប៉ុន្តែទន្ទឹមគ្នានេះដែរ រូបភាពនៃបញ្ហាដែលកើតចេញពីការរំលោភបំពានលើសេរីភាពបញ្ចេញមតិនៅតែបន្តកើតមានដដែល។ ដូចបានរៀបរាប់បង្ហាញក្នុងសារណានេះ ទាំងបញ្ហាគតិយុត្ត និងបញ្ហាអនុវត្តនៅបន្តរួមគ្នា ជាហេតុបង្កឱ្យមាននូវការរំលោភបំពានកើតឡើង។

បញ្ហាដែលបានលើកឡើងទាក់ទងនឹង កង្វះស្តង់ដារនៃការត្រួតពិនិត្យធម្មនុញ្ញភាពលើបញ្ហារំលោភសិទ្ធិមនុស្ស ជាពិសេសបញ្ហាសេរីភាពបញ្ចេញមតិនេះតែម្តង បញ្ហានេះជាបញ្ហាថ្មីស្រឡាងមួយ ឬអាចនិយាយបានថាជាវិធីដោះស្រាយថ្មីមួយក្នុងការដោះស្រាយបញ្ហារំលោភលើសេរីភាពបញ្ចេញមតិ ហេតុនេះក្នុងការស្វែងរកនូវដំណោះស្រាយដ៏ល្អប្រសើរ និងប្រែក្លាយមុខមាត់ប្រទេសកម្ពុជាទៅជាប្រទេសដែលមាននូវដំណើរការល្អនៃការការពារសិទ្ធិមនុស្ស ពិសេសសេរីភាពបញ្ចេញមតិនេះ ប្រទេសកម្ពុជា គប្បីធ្វើការពិចារណាក្នុងការជ្រើសយកដំណោះស្រាយមួយនេះ។ ដោយសារស្តង់ដារនេះជាស្តង់ដារថ្មី ហើយមានច្រើនប្រភេទ និងត្រូវមាននូវអ្នកជំនាញខាងនីតិរដ្ឋធម្មនុញ្ញ ឬអាចនិយាយបានថានីតិវិធីរដ្ឋធម្មនុញ្ញក្នុងការកាត់ក្តីរឿងដែលពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញ ដូចនេះការសម្រេចយកនូវស្តង់ដារនេះឬយ៉ាងណា ត្រូវមាននូវការសិក្សាស្រាវជ្រាវមួយច្បាស់លាស់ ហើយប្រសិនបើជ្រើសយកតើត្រូវប្រើប្រាស់នូវស្តង់ដារណាខ្លះ? ដោយអនុវត្តទៅនឹងរឿងអ្វីខ្លះ? ព្រោះថា ដើម្បីអនុវត្តឱ្យត្រូវទៅនឹងស្ថានភាពដែលមានក្នុងប្រទេសកម្ពុជាប៉ុន្តែសមស្របនិងត្រឹមត្រូវទៅតាមគោលការណ៍សិទ្ធិមនុស្សពិតប្រាកដ។

មួយវិញទៀត អំពីបញ្ហាដែលកើតមានក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន។ បញ្ហាគតិយុត្តដែលមានក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ត្រូវបានក្លាយជារឿងមួយចាស់ទៅហើយ មានន័យថាការដែលច្បាប់នេះមានបញ្ហា វាមិនមែនជារឿងថ្មីអ្វីនោះទេ មានការដឹងឮរួចមកហើយ។ បញ្ហាដែល

មានក្នុងច្បាប់នេះ ត្រូវបានចង្អុលបង្ហាញតាំងពីការប្រជុំនៅវិមានរដ្ឋសភាលើសេចក្តីព្រាងច្បាប់នេះមកម្ល៉េះ។បញ្ហានេះបានបន្តរហូតដល់ក្លាយជាបញ្ហាចាស់ រហូតដល់គេលែងគិតគូររកដំណោះស្រាយឱ្យវាទៅហើយ។ មិនអាចទុកបញ្ហានេះចោលបាន ដោយបន្តអនុវត្តច្បាប់នេះទាំងមានបញ្ហាបែបនេះទៀតនោះទេ។ ក្រសួងព័ត៌មាន និងក្រសួងពាក់ព័ន្ធ រួមសហការជាមួយនឹងអ្នកជំនាញខាងសិទ្ធិមនុស្សអន្តរជាតិ គួរតែមាននូវការចាត់វិធានការណ៍ដោះស្រាយលើបញ្ហាទាំងអស់ដែលមានដោយធ្វើការបង្កើតនូវគណកម្មាការក្នុងការពិភាក្សាឡើងវិញ ក្នុងកាដោះស្រាយនូវបញ្ហាទាំងអស់នេះ។ បញ្ហាដែលបានលើកឡើងទាក់ទងនឹងនិយមន័យវាក្យសព្ទ "សន្តិសុខជាតិ" "ស្ថេរភាពនយោបាយ" ត្រូវមានការពន្យល់ និងកំណត់និយមន័យឱ្យបានច្បាស់ ព្រមទាំងការវិសោធនកម្មច្បាប់នេះ ដោយកំណត់និយមន័យក្នុងច្បាប់ស្តីពីរបបសារព័ត៌មានតែម្តង។ នេះជាសំណូមពរដែលមានរួចមកហើយ តែមិនទាន់មានការពិចារណាលើសំណូមពរនេះទេ ដូចនេះក្រសួងគួរងាកមកចាប់អារម្មណ៍ចំពោះរឿងនេះ ទោះបីជាមិនជ្រើសរើសយកជាដំណោះស្រាយ តែគួរតែចាប់ផ្តើមពិភាក្សាដោះស្រាយលើបញ្ហានេះ។ ដោយឡែក ពាក់ព័ន្ធនឹងបញ្ហានៃធម្មនុញ្ញភាពមាត្រា១២ច្បាប់ស្តីពីរបបសារព័ត៌មានវិញ នៅមិនទាន់មាននូវការបកស្រាយផ្លូវការនៅឡើយទេ។ ដោយសម្ថកិច្ចក្នុងការបកស្រាយធម្មនុញ្ញភាពនៃច្បាប់ជារបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយដើម្បីអាចស្នើសុំឱ្យមានការបកស្រាយបាន គឺអ្នកតំណាងប្រជាពលរដ្ឋ ដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញដែលមានដូចជាតំណាងរាស្ត្រ នាយករដ្ឋមន្ត្រីជាដើម ដូច្នេះក្នុងនាមជាអ្នកតំណាងឱ្យប្រជាពលរដ្ឋ ក្នុងនាមជាអ្នកដែលប្រជាពលរដ្ឋបានផ្តល់នូវសេចក្តីទុកចិត្តទៅហើយនោះ តំណាងរាស្ត្រគួរតែពិចារណាអំពីចំណុចនេះក្នុងការដាក់ស្នើទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យធ្វើការបកស្រាយធម្មនុញ្ញភាពនៃច្បាប់នេះ។ ឯក្រុមប្រឹក្សា ធម្មនុញ្ញផ្ទាល់ ក៏ត្រូវធ្វើការសម្រេចសេចក្តីឱ្យបានត្រឹមត្រូវ ប្រកបដោយអព្យាក្រឹត្យក្នុងនាមផលប្រយោជន៍ប្រជាពលរដ្ឋកម្ពុជា។

ចំណែកឯ ជុំវិញបញ្ហានៃការអនុវត្តជាក់ស្តែងនៃអ្នកសារព័ត៌មានកម្ពុជា ទាំងបញ្ហានៃវិជ្ជាជីវៈ បញ្ហានៃឯករាជភាពរបស់អ្នកសារព័ត៌មាន។ ដំណោះស្រាយចំពោះបញ្ហាវិជ្ជាជីវៈ គឺត្រូវមានការចូលរួមពីរាជរដ្ឋាភិបាល ពិសេសក្រសួងព័ត៌មានដែលជាក្រសួងសាម៉ីក្នុងការជួយជ្រោមជ្រែង និងពង្រឹង ក៏ដូចជា ផ្តល់ឱ្យនូវការបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវជាអ្នកសារព័ត៌មានដល់អ្នកសារព័ត៌មានកម្ពុជា។ ព្រមជាមួយគ្នានេះដែរ ក្រសួងគួររៀបចំឱ្យមាននូវបទដ្ឋានគតិយុត្តច្បាស់លាស់មួយនិងជាសាធារណៈអំពីលក្ខខណ្ឌក្នុងការអាចក្លាយជាអ្នកសារព័ត៌មាន ក្នុងការកំណត់ឱ្យបាននូវវិជ្ជាជីវៈមួយត្រឹមត្រូវ និងស្របតាមច្បាប់។ អំពីបញ្ហានៃឯករាជភាពអ្នកសារ

ព័ត៌មានវិញ អ្នកដែលត្រូវចូលរួមក្នុងការដោះស្រាយនេះ ក៏ត្រូវមានរាជរដ្ឋាភិបាល និងក្រសួងព័ត៌មានដែរ ប៉ុន្តែជាការចូលរួមមួយដែលគិតពីផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំ តាមរយៈការប្តេជ្ញាចិត្តជានាក្នុងការស្ថិតនៅជាអព្យាក្រឹត្យ មិនចូលពាក់ព័ន្ធនឹងសារព័ត៌មានណាមួយ។ ភ្ជាប់គ្នានេះដែរ បញ្ហាទាក់ទងនឹងសេដ្ឋកិច្ចរបស់អ្នកសារព័ត៌មានក៏ជាបញ្ហាប្រឈមមួយដែរ ប្រការនេះក៏ត្រូវមានការគិតគូររកដំណោះស្រាយក្នុងការផ្តល់តម្លៃ និងប្រាក់បៀវត្សមួយសមរម្យសម្រាប់អ្នកសារព័ត៌មានផងដែរ។ ដោយឡែក ក្នុងការដោះស្រាយនូវបញ្ហានេះ អ្នកសារព័ត៌មានដែលជាសាមីខ្លួនឯងផ្ទាល់ក៏ត្រូវពិចារណា និងមាននូវជំហរអព្យាក្រឹត្យមួយ ប្រកបរបរជាអ្នកសារព័ត៌មានទៅតាមវិជ្ជាជីវៈ ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋបានត្រឹមត្រូវនិងច្បាស់លាស់ ដើម្បីទទួលបានមកវិញនូវសេចក្តីទុកចិត្តពីប្រជាពលរដ្ឋ។

ជាមួយគ្នានេះដែរ ការផ្តល់នូវសេរីភាពក្នុងការធ្វើបាតុកម្ម សេរីភាពក្នុងការជួបប្រជុំ ឬបង្កើតសមាគម ត្រូវមាននូវការផ្តល់នូវសេរីភាពមួយ ដោយមិនមានការគម្រាមកំហែងក្នុងរូបភាពនៃការប្រើប្រាស់អំពើហិង្សានោះទេ។ ត្រូវធ្វើការណែនាំដល់សមត្ថកិច្ចការពារសណ្តាប់ធ្នាប់នៅពេលធ្វើបាតុកម្ម ឬការជួបជុំណាមួយ ឱ្យបំពេញកាតព្វកិច្ចក្នុងការការពារសណ្តាប់ធ្នាប់ពិតប្រាកដមានភាពអំណត់អត់ធ្មត់ខ្លាំង បំពេញការងារឱ្យចំគោលដៅ ជៀសឱ្យបាននូវកម្រិតអតិបរមាលើការតបតទៅកាន់ប្រជាពលរដ្ឋដោយអំពើហិង្សា។ ឯប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ ត្រូវយល់ច្បាស់ពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន យល់ពីភាពខុសនិងត្រូវ ដោយមិនត្រូវស្តាប់តាមការញុះញង់ពីជនទុច្ចរិតណាមួយទៅធ្វើបាតុកម្មដោយមិនដឹងហេតុផលច្បាស់លាស់ឡើយ។ ហើយត្រូវប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនដោយត្រឹមត្រូវ មិនត្រូវធ្វើបាតុកម្មដោយមានការប្រើអំពើហិង្សា មិនត្រូវអាងថាជាសិទ្ធិរបស់ខ្លួនធ្វើការទាមទារហួសល្មើសច្បាប់នោះទេ។

**ករណីប្រទេសជប៉ុន ៖**

បញ្ហាដែលកើតមានក្នុងប្រទេសជប៉ុន បណ្តាលមកពីមូលហេតុច្រើន ដែលក្នុងនោះមូលហេតុប្រវត្តិសាស្ត្រ មូលហេតុនៃចំណេះដឹង មូលហេតុនៃការផ្តល់នូវសេរីភាពទូលំទូលាយជាដើម។ ប្រជាពលរដ្ឋជប៉ុនទាំងអស់សុទ្ធតែជាអក្ខរជន ពួកគេទទួលបាននូវការអប់រំគ្រប់ៗគ្នា ប៉ុន្តែទន្ទឹមនឹងនោះ ប្រវត្តិសាស្ត្រដែលជាស្លាកស្នាមដក់ជាប់ក្នុងចិត្តរបស់ប្រជាពលរដ្ឋជប៉ុនមួយចំនួន បង្កើតឱ្យមាននូវការស្អប់ រើសអើងជាតិសាសន៍ដទៃក្រៅពីជាតិសាសន៍ខ្លួនឯង ទើបធ្វើឱ្យប្រជាពលរដ្ឋជប៉ុនមួយចំនួននៅបន្តគំនិតបែបនេះ ដោយប្រើប្រាស់នូវសេរីភាពបញ្ចេញមតិ សេរីភាពក្នុងការធ្វើ

បាតុកម្ម ស្រែកជេរ បណ្តេញជនជាតិកូរ៉េចេញពីប្រទេសជប៉ុន។ ចំពោះបញ្ហានេះ ឃើញថាមានដំណោះស្រាយពីរដ្ឋាភិបាលក្នុងការបង្កើតនូវច្បាប់ទប់ស្កាត់សកម្មភាពទាំងនោះ។ នេះជាវិធានការណ៍មួយសមស្រប ដោយឡែកអ្វីដែលជាបញ្ហាគឺនៅតែផ្នត់គំនិតរបស់ប្រជាពលរដ្ឋជប៉ុនមួយចំនួននោះតែប៉ុណ្ណោះ។ ហេតុនេះ ប្រជាពលរដ្ឋជប៉ុនមួយចំនួននោះ គួរតែធ្វើការផ្លាស់ប្តូរនូវផ្នត់គំនិតនៃការរើសអើងនេះចេញ ដោយធ្វើការបើកចិត្តទូលាយ ក្នុងការរាប់អានគ្នាជាភាតរៈ ដោយមិនមែនគិតពីរឿងប្រវត្តិសាស្ត្រ ជាពិសេសមិនមាននូវការបែងចែក ប្រកាន់រើសអើងពូជសាសន៍នោះឡើយ។

មួយវិញទៀត ទាក់ទងនឹងបញ្ហានៃឯករាជភាពសារព័ត៌មានជប៉ុនវិញ រដ្ឋាភិបាលជប៉ុនគួរគោរពគោលការណ៍ទាំងឡាយ ជាពិសេសគោលការណ៍នៃសិទ្ធិមនុស្សដែលមានចែងក្នុងរដ្ឋធម្មនុញ្ញជប៉ុន ក៏ដូចជាតួនាទីរបស់ខ្លួនក្នុងជំហរអព្យាក្រឹត្យ មិនមានការលូកដៃចូលក្នុងការងារសារព័ត៌មាន។ ជាមួយនឹងបញ្ហានេះដែរ បញ្ហាដែលបានលើកឡើងដោយអ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិ ទាក់ទងនឹងច្បាប់ស្តីពីការរក្សាអាថ៌កំបាំងសំងាត់របស់រដ្ឋ ក៏ដូចជាច្បាប់ស្តីពីការផ្សព្វផ្សាយ គួរមានការពន្យល់ជាផ្លូវការឱ្យបានច្បាស់ និងដោយងាយស្រួលយល់លើខ្លឹមសារពាក្យពេចន៍ ក៏ដូចជាវត្ថុបំណងទាំងនោះ ជៀសវាងការដាក់នូវពាក្យពេចន៍ដែលពិបាកយល់ ធ្វើឱ្យមានការយល់ច្រឡំ ឬការបកស្រាយផ្សេងគ្នា ដែលបង្កទៅជាបញ្ហាប្រឆាំងគ្នាទៅវិញទៅមក។ ការដោះស្រាយទៅលើបញ្ហានេះ នឹងធ្វើឱ្យការវាយតម្លៃលើស្ថានភាពសេរីភាពបញ្ចេញមតិក្នុងប្រទេសជប៉ុនដែលបានធ្លាក់ចុះអាចនឹងប្រែក្លាយមកជាល្អប្រសើរវិញបាន។

# ឯកសារយោង

## ឯកសារយោង

### ក. ច្បាប់ និងបទដ្ឋានគតិយុត្តជាតិ ៖

1. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ ប្រទានដោយសម្តេច នរោត្តម សីហនុ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧
2. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋកម្ពុជា ឆ្នាំ១៩៧២ ដាក់ជូនប្រជាពលរដ្ឋធ្វើប្រជាមតិ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៧២
3. រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យ ប្រកាសឱ្យប្រើជាផ្លូវការ នៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦
4. រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប្រកាសឱ្យប្រើដោយប្រធានក្រុមប្រឹក្សារដ្ឋ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១
5. រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ប្រកាសឱ្យប្រើដោយប្រធានក្រុមរដ្ឋ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៨៩
6. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
7. ច្បាប់ស្តីពីរបបសារព័ត៌មាន ប្រកាសឱ្យប្រើថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ១៩៩៥
8. ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ប្រកាសឱ្យប្រើថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៩
9. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
10. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។

### ខ. ច្បាប់ និងបទដ្ឋានគតិយុត្តអន្តរជាតិ ៖

1. ធម្មនុញ្ញអង្គការសហប្រជាជាតិ ដោយសន្និបាតអង្គការសហប្រជាជាតិ សាន់ហ្វ្រាន់ស៊ីស្កូ សហរដ្ឋអាមេរិក ឆ្នាំ១៩៤៥
2. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដោយមហាសន្និបាតអង្គការសហប្រជាជាតិ លេខ២១៧ A(III) នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
3. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
4. រដ្ឋធម្មនុញ្ញអាណាចក្រជប៉ុន ឆ្នាំ១៨៨៩
5. រដ្ឋធម្មនុញ្ញជប៉ុនបច្ចុប្បន្ន ប្រកាសឱ្យប្រើនៅថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ១៩៤៦
6. ក្រមព្រហ្មទណ្ឌប្រទេសជប៉ុន ប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩០៧

7. ច្បាប់ស្ដីពីការការពារសកម្មភាពដែលបង្កឱ្យមានការបំផ្លាញឆ្នាំ១៩២៥
8. ច្បាប់ស្ដីពីការផ្សព្វផ្សាយ ឆ្នាំ១៩៥០
9. ច្បាប់ស្ដីពីការបើកចំហរព័ត៌មាននៃស្ថាប័នរដ្ឋបាល ឆ្នាំ២០០១
10. ច្បាប់ស្ដីពីការរក្សាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋ ប្រកាសឱ្យប្រើនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣
11. ច្បាប់ស្ដីពីការលុបបំបាត់សកម្មភាពរើសអើងទៅនឹងជនជាតិបរទេសដែលរស់នៅប្រទេសជប៉ុន ប្រកាសឱ្យប្រើនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦។

**គ. ឯកសារស្រាវជ្រាវជាភាសាខ្មែរ៖**

1. បណ្ឌិត ឈុន ណារ៉េត, សេចក្ដីផ្ដើមនីតិរដ្ឋធម្មនុញ្ញ, ឆ្នាំ២០១២
2. សាស្ត្រាចារ្យ ម៉ុក ដារ៉ា, នីតិរដ្ឋធម្មនុញ្ញ, ឆ្នាំ២០១០
3. ឈន សុភាព និងផ្សេងទៀត, រដ្ឋធម្មនុញ្ញកម្ពុជា, (ភ្នំពេញ, ហ្វូឈាន, បោះពុម្ពលើកទី២), ឆ្នាំ២០០៥ បន្ថែម និងកែសម្រួលចេញពីសៀវភៅដែលបោះពុម្ពលើកទីមួយ របស់លោកសាស្ត្រាចារ្យ Maurice GAILLARD, "ប្រជាធិបតេយ្យកម្ពុជា រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣" រោងពុម្ពL' Harmattan, ឆ្នាំ១៩៩៤
4. កៅ មុយថង កែសម្រួលដោយ មុី វិចិត្រ, រដ្ឋធម្មនុញ្ញកម្ពុជា, (បណ្ណាគារអង្គរ បោះពុម្ពលើកទី១), ឆ្នាំ២០០៦
5. សុខ យ៉ាន, សុខ ចិន្តា, នីតិរដ្ឋធម្មនុញ្ញ, ឆ្នាំ២០១៤
6. អ៊ិន បូជា, ទ្រឹស្ដីនីតិរដ្ឋធម្មនុញ្ញ, ឆ្នាំ២០០៣
7. ពេជ្រ សីហា, នីតិសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន
8. Dr. Wilhelm Treiber/ Andrea Behm/ Hout Sotheary, ការពិចារណាពិស្ដារផ្នែកគតិយុត្តិ សៀវភៅសិក្សាផ្នែកទី១ សិទ្ធិមនុស្ស, វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ
9. ច្បាប់សិទ្ធិមនុស្សកម្ពុជា, ចងក្រងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, ខែកញ្ញា ឆ្នាំ២០១២
10. វចនានុក្រមខ្មែរ ភាគទី១, ភាគទី២ (ពុទ្ធសាសនិកបណ្ឌិត, ១៩៦៨)។

**ឃ. ឯកសារស្រាវជ្រាវជាភាសាជប៉ុន**

1. 四本健二『カンボジア憲法論』（勁草書房、1999 年）
   យុស៊ីមូតុ ខេនជី, ទ្រឹស្ដីរដ្ឋធម្មនុញ្ញកម្ពុជា, (រោងពុម្ពខេសូ, ១៩៩៩)
2. 芦部信善（高橋和之補訂）『憲法 第六版』（岩波書店、2015 年）

អាស៊ីបេ ណុបឹយុស៊ី (កែសម្រួលដោយថាកាហាស៊ី ខាហ្សឺយឹគី) , រដ្ឋធម្មនុញ្ញ បោះពុម្ពលើកទី៦, (រោងពុម្ពអ៊ីវ៉ាណាមិ, ២០១៥)

3. 高橋和之『立憲主義と日本国憲法　第 2 版』（有斐閣、2010 年）
ថាកាហាស៊ី កាហ្សឺយឹគី, របបអាស្រ័យរដ្ឋធម្មនុញ្ញនិងរដ្ឋធម្មនុញ្ញប្រទេសជប៉ុន បោះពុម្ពលើកទី២, (រោងពុម្ពយឺហ៊ីកាគឹ,២០១០)

4. 渋谷秀樹、赤坂正浩『憲法 1 人権〔第 4 版〕』（有斐閣、2010 年）
ស៊ីបឹថានី ហ៊ីដិគី, អាកាសាកា ម៉ាសាហ៊ីរុ, រដ្ឋធម្មនុញ្ញ១ សិទ្ធិមនុស្ស〔បោះពុម្ពលើកទី៤〕, (រោងពុមយឺហ៊ីកាគឹ, ២០១០)

5. 野中俊彦ほか『憲法 I （第 4 版）』（有斐閣、2006 年）
ណុណាកា តុស៊ីហ៊ីកុ, នីតិរដ្ឋធម្មនុញ្ញ១ បោះពុម្ពលើកទី៤, (រោងពុម្ពយឺហ៊ីកាកឹ,២០០៦ )

6. 長谷部恭男『憲法 第 5 版』（新世社、2011 年）
ហាសិបិ យ៉ាសឹអុ, នីតិរដ្ឋធម្មនុញ្ញ បោះពុម្ពលើកទី៥, (រោងពុម្ពស៊ីនសិ, ២០១១)

7. 松井茂記、『インターネットの憲法学　新版』（岩波書店、2014 年）
ម៉ាហ្សឺអ៊ីស៊ីហ្គិណុរី, សិក្សានីតិរដ្ឋធម្មនុញ្ញនៃប្រព័ន្ធអ៊ីនធើណេត, (រោងពុម្ពអ៊ីវ៉ាណាមិ, ២០១៤)

8. 明日の自由を守る若手弁護士の会『これでわかった！超訳　特定秘密保護法』（岩波書店、2014 年）
សមាគមមេធាវីវ័យក្មេងការពារសេរីភាពថ្ងៃស្អែក, យល់ទេ! ការបកស្រាយ ច្បាប់ស្តីពីការរក្សាអាថិកំបាំងសំងាត់ពិសេសរបស់រដ្ឋ, (រោងពុម្ពអ៊ីវ៉ាណាមិ, ២០១៤)

9. 小林伸一、（大沢秀介、大林啓吾「編集」）『確認憲法用語』（成文堂、2014 年）
ខុប៉ាយ៉ាស៊ី ស៊ីនអ៊ីឆី, (អូហ្សាវ៉ា ហ៊ីដិយឹគី, អូប៉ាយ៉ាស៊ី ខេហ្គុ [កែសម្រួល] ), វាក្យសព្ទនីតិរដ្ឋធម្មនុញ្ញ, (រោងពុម្ពសេប៊ឹនដូរ, ២០១៤)

10. 名古屋大学日本法教育研究センター『日本法を学ぶための日本史・公民―２年生用教材―（カンボジア版）』、2010 年
មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, ប្រវត្តិសាស្រ្ត និងពលរដ្ឋវិទ្យាប្រទេសជប៉ុនដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន សៀវភៅសិក្សាសម្រាប់ឆ្នាំទី៣ (ភាសាខ្មែរ), (២០១០)

11. 名古屋大学日本法教育研究センター『日本法を学ぶための日本の法システム―3 年生用教材―（カンボジア版）』（2014 年 9 月）

មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវអំពីច្បាប់ជប៉ុននៃសាកលវិទ្យាល័យណាហ្គោយ៉ា, ប្រព័ន្ធច្បាប់ប្រទេសជប៉ុនដើម្បីសិក្សាច្បាប់ប្រទេសជប៉ុន សៀវភៅសិក្សាសម្រាប់ឆ្នាំទី៣ (ភាសាខ្មែរ), (ខែកញ្ញា ឆ្នាំ២០១៤)

12. 木村光豪、「カンボジアにおける表現の自由に関する規制立法―刑法の名誉毀損と扇動を中心に―」、（関西大学、第 65 巻第 4 号、2015 年）

គីមឺរ៉ា ហ៊ីការ៉ុហ្គូ, ការបង្កើតច្បាប់ទាក់ទងទៅនឹងសេរីភាពបញ្ចេញមតិនៅប្រទេសកម្ពុជាផ្ដោតសំខាន់លើបទបរិហារកេរ្តិ៍ជាសាធារណៈនិងបទញុះញង់ក្នុងក្រមព្រហ្មទណ្ឌ, (សាកលវិទ្យាល័យកាន់សៃ, ភាគទី៦៥លេខ៤, ២០១៥)

## ខ. គេហទំព័រផ្សេងៗ

1. គេហទំព័រក្រសួងព័ត៌មាន សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន <http://a2i.info.gov.kh/>
2. អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Sans Frontières、Reporters Without Borders) <https://rsf.org/en/cambodia>
3. អ្នកនាំពាក្យពិសេសអង្គការសហប្រជាជាតិរាយការណ៍ទៅរដ្ឋាភិបាលធ្វើវិសោធនកម្មច្បាប់ស្ដីពីការរក្សាអាថ៌កំបាំងសំងាត់ពិសេសរបស់រដ្ឋ,「特定秘密保護法の改正 国連特別報告者が政府に勧告」 <http://www.tokyo-np.co.jp/article/world/list/201705/CK2017053102000127.html>
4. អ្នកជំនាញសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ប្រមានចំពោះការភ័យខ្លាចធ្ងន់ធ្ងរនៃឯករាជភាពសារព័ត៌មាន,「国連の人権専門家、報道の独立性に対する重大な脅威を警告」 <http://www.unic.or.jp/news_press/info/18693/>
5. ក្រុមដាក់គោលការណ៍ច្បាប់ស្ដីពីការរក្សាអាថ៌កំបាំងសំងាត់របស់រដ្ឋ, តើគ្រោះថ្នាក់នៃសេរីភាពបញ្ចេញមតិនិងសិទ្ធិទទួលបានព័ត៌មានត្រូវជំនះដូចម្ដេច?
秘密保護法対策弁護団、「表現の自由と知る権利の危機をどのようにして克服するのか」<http://nohimituho.exblog.jp/25869014/>

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី ១
# សេចក្តីព្រាងបឋមច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្ដីព្រាងបឋម

ក្រសួងព័ត៌មាន

# ច្បាប់
# ស្ដីពី
# សិទ្ធិទទួលព័ត៌មាន

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា ១**.

ច្បាប់នេះមានគោលបំណងធានាឲ្យសាធារណជនគ្រប់រូបនូវសិទ្ធិ និងសេរីភាពក្នុងការទទួលព័ត៌មាន។

ច្បាប់នេះចែងពីភារកិច្ចដែលស្ថាប័នសាធារណៈនានាត្រូវផ្ដល់ និងធ្វើការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា១៩ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស។

**មាត្រា ២**.

ច្បាប់នេះមានគោលដៅដូចតទៅៈ

ក- ជម្រុញ និងធានាឲ្យស្ថាប័នសាធារណៈបំពេញកាតព្វកិច្ចផ្សព្វផ្សាយ និងផ្ដល់ព័ត៌មានជូនសាធារណជន ឲ្យបានទូលំទូលាយ។

ខ- ធានាឲ្យមានការចូលរួមពី សាធារណជន ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងកិច្ចការវប្បធម៌របស់ជាតិដូចមានចែងក្នុងមាត្រា៣៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គ- ផ្ដល់ព័ត៌មានជូនដល់សាធារណជនឲ្យមានការយល់ដឹងអំពីតួនាទី សកម្មភាពប្រតិបត្តិការនិងសេចក្ដីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនទំនុកចិត្ត និងការជឿជាក់ពីសាធារណជន។

ឃ- ជួយសាធារណជនក្នុងការតាមដានសកម្មភាពការងាររបស់ស្ថាប័នសាធារណៈ ដើម្បីធានាថា មូលនិធិសាធារណៈត្រូវបានចំណាយតាមផែនការដែលបានគ្រោងទុក។

ង- ជម្រុញការគ្រប់គ្រងឯកសារនិងទិន្នន័យផ្សេងៗរបស់ស្ថាប័នសាធារណៈឲ្យបានល្អប្រសើរ ដើម្បីកសាងគោលនយោបាយក្នុងការផ្តល់សេវាជូន សាធារណជន ។

ច- ជួយជម្រុញឲ្យស្ថាប័នសាធារណៈបំពេញភារកិច្ចប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ឆ- កាត់បន្ថយព័ត៌មានសម្ងាត់ឲ្យមានកម្រិតទាបបំផុត។

**មាត្រា ៣**.

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះព័ត៌មានគ្រប់ប្រភេទ ដែលត្រូវផ្តល់ដោយស្ថាប័នសាធារណៈទាំងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែព័ត៌មានសម្ងាត់មួយចំនួន ដែលកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ៤**.

វាក្យសព្ទដែលប្រើប្រាស់នៅក្នុងច្បាប់នេះមាននិយមន័យដូចតទៅ៖

-**ព័ត៌មាន សំដៅដល់** ឯកសារផ្លូវការគ្រប់ប្រភេទដែលកាន់កាប់ដោយស្ថាប័ន សាធារណៈ។

-**ព័ត៌មានសាធារណៈ សំដៅដល់** ព័ត៌មានដែលស្ថាប័នសាធារណៈត្រូវតែធ្វើការផ្សព្វផ្សាយឲ្យសាធារណជនបានដឹងឮយ៉ាងទូលំទូលាយដោយមិនចាំបាច់មានការស្នើសុំ។

*-ព័ត៌មានសម្ងាត់ឯកជនបុគ្គល*

*-ព័ត៌មានសម្ងាត់វិជ្ជាជីវៈ*

-**ព័ត៌មានបុគ្គល សំដៅដល់** ព័ត៌មានអំពីបុគ្គលណាម្នាក់ (រួមមានព័ត៌មានដែលបង្កើតជាបញ្ជីទិន្នន័យ) ទោះបីជាពិត ឬមិនពិតនិងទោះបីជាបានកត់ត្រា ឬមិនកត់ត្រាទុកនៅក្នុងឯកសារ ជាទម្រង់ដើមក៏ដោយ។

-**ព័ត៌មានសម្ងាត់** សំដៅដល់ ព័ត៌មានដែលស្ថាប័នសាធារណៈមិនអាចផ្តល់ជូនអ្នកស្នើសុំបាន។

-**មន្ត្រី** សំដៅដល់ បុគ្គលដែលបំពេញតួនាទីក្នុងស្ថាប័នសាធារណៈមិនថាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន និងធ្វើការពេញម៉ោង ឬមិនពេញម៉ោងក៏ដោយ។

-**មន្ត្រីទទួលបន្ទុកព័ត៌មាន សំដៅដល់** មន្ត្រីដែលត្រូវបានតែងតាំងដោយស្ថាប័នសាធារណៈ មានភារកិច្ចគ្រប់គ្រងឯកសារនិងផ្តល់សេវាព័ត៌មានជូនសាធារណជន។

-**ការិយាល័យព័ត៌មាន សំដៅដល់** កន្លែងផ្តល់ព័ត៌មានដល់អ្នកស្នើសុំហើយត្រូវបានបង្កើតឡើងដោយស្ថាប័នសាធារណៈ។

-**ស្ថាប័នសាធារណៈ** សំដៅដល់ ក្រសួង រដ្ឋលេខាធិការដ្ឋាន ឬអង្គភាពរដ្ឋដទៃទៀតរួមទាំងរដ្ឋបាលមូលដ្ឋានក្រោមឱវាទនិងរដ្ឋបាលរាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ-ឃុំ-សង្កាត់ ដែលបង្កើតឡើងដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬលិខិតបទដ្ឋានដទៃទៀតស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

-**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលបានធ្វើសំណើសុំព័ត៌មាន។

-**រដ្ឋបាលថ្នាក់ជាតិ** សំដៅដល់ ក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈប្រហាក់ប្រហែល និងមន្ទីរជំនាញក្រោមឱវាទ។

-**រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់ រាជធានី -ខេត្ត-ក្រុង-ស្រុក-ខណ្ឌ-ឃុំ- សង្កាត់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

-**ព័ត៌មានប៉ះពាល់សន្តិសុខជាតិ**

ក- សំដៅដល់ព័ត៌មានសម្ងាត់ទាំងឡាយណា ដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់បូរណភាពទឹកដី និងនិរន្តរភាពដែលជាអាយុជីវិតរបស់ព្រះរាជាណាចក្រកម្ពុជា។

ខ- សំដៅដល់ព័ត៌មានសម្ងាត់ទាំងឡាយរបស់កងយោធពលខេមរភូមិន្ទ ឬកងកម្លាំងនគរបាលជាតិដែលការបែកធ្លាយនាំឲ្យមានគ្រោះថ្នាក់ដល់ការបំពេញបេសកកម្ម ឬប្រតិបត្តិការសឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

-**មន្ត្រីសាធារណៈ** សំដៅដល់បុគ្គលទាំងឡាយដែលបំរើការងារនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

-**សណ្តាប់ធ្នាប់សាធារណៈ** សំដៅដល់ព័ត៌មានសម្ងាត់ទាំងឡាយដែលការបែកធ្លាយ បង្កឲ្យកើតមានភាពច្របូកច្របល់ ចលាចល អំពើហឹង្សាធ្វើឲ្យបាត់បង់ស្ថេរភាពរបៀបរៀបរយសង្គម។

## ជំពូកទី២
## សិទ្ធិនិងភាតព្វកិច្ចនៃការផ្តល់ព័ត៌មាន

**មាត្រា ៥.**

បុគ្គល គ្រប់រូប មានសិទ្ធិនិងសេរីភាពក្នុងការទទួលបានព័ត៌មានពីស្ថាប័នសាធារណៈ ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់នេះ។

**មាត្រា ៦.**

គ្រប់ស្ថាប័នសាធារណៈ ទាំងអស់ត្រូវគោរពគោលការណ៍នៃការលាតត្រដាងព័ត៌មានជាអតិបរមា។ ដើម្បីសម្រេចគោលដៅនេះស្ថាប័នទាំងនោះត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំនិង ផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំ

ទូលាយ អំពីផែនការសកម្មភាពការងារ ផែនការថវិកា ការបំពេញភារកិច្ច ការទទួលខុសត្រូវ និងសេចក្តីសម្រេចនានាដែលពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិ ផលប្រយោជន៍របស់សាធារណជនដូចជា៖

ក- ការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថាប័នសាធារណៈនានា រួមទាំងសកម្មភាពការងារព្រមទាំងសមិទ្ធផលទាំងឡាយដែលសម្រេចបាន។

ខ- ផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផែនការអភិវឌ្ឍលើគ្រប់វិស័យរបស់ស្ថាប័នសា-ធារណៈ។

គ- ព័ត៌មានលម្អិតអំពីយន្តការសេវា រួមទាំងតារាងតម្លៃសេវាសាធារណៈនានា ដែលស្ថាប័នសាធារណៈត្រូវផ្តល់ជូនសាធារណជន។

ឃ- ច្បាប់ បទដ្ឋានគតិយុត្ត គោលនយោបាយ សេចក្តីសម្រេចនានា និងភារកិច្ចរបស់ស្ថាប័នសាធារណៈដែលទាក់ទងនឹងសិទ្ធិ សេរីភាព កាតព្វកិច្ច និងផលប្រយោជន៍របស់សាធារណជន។

ង- គ្រប់ទិដ្ឋភាពនៃដំណើរការ និងនីតិវិធីទាំងឡាយរបស់តុលាការ រួមទាំងកិច្ចការរដ្ឋបាលដែលមានផលប្រយោជន៍និងទំនាក់ទំនងផ្ទាល់ជាមួយសាធារណជន លើកលែងតែបទបញ្ញត្តិមួយចំនួនដែលហាមឃាត់។

ច- គម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដែលភ្ជាប់ជាមួយនឹងសេចក្តីលម្អិតព័ត៌មានអំពីថវិកាដែលត្រូវចំណាយក្នុងឆ្នាំហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងគណនីសវនកម្មនៃហិរញ្ញវត្ថុឆ្នាំមុន។

ឆ- សំណើផ្លូវការ ឬយន្តការបណ្តឹងសម្រាប់សាធារណជនដែលមានទំនាក់ទំនងជាមួយសកម្មភាព ឬខកខានមិនធ្វើសកម្មភាពដោយស្ថាប័នសាធារណៈនោះរួមជាមួយនឹងសេចក្តីសង្ខេបនៃសំណើពាក្យបណ្តឹង ឬសកម្មភាពផ្ទាល់ដទៃទៀតរបស់សមាជិកនៃស្ថាប័នសាធារណៈ និងការឆ្លើយតបរបស់ស្ថាប័ននោះ។

**មាត្រា ៧**.

គ្រប់ស្ថាប័នសាធារណៈត្រូវបង្កលក្ខណៈងាយស្រួល ព្រមទាំងបើកទូលាយក្នុងការផ្តល់ព័ត៌មានគ្រប់ប្រភេទដល់សាធារណជនតាមការស្នើសុំដោយគ្មានការរើសអើងតាមបែបបទ ដែលងាយយល់ក្នុងពេលវេលា និងតម្លៃសមស្រប លើកលែងតែព័ត៌មានសម្ងាត់ ដែលស្ថិត ក្នុងបទបញ្ញត្តិ ហាមឃាត់។

**មាត្រា ៨**.

ស្ថាប័នសាធារណៈត្រូវបំពេញកាតព្វកិច្ចដូចតទៅ៖

ក- បង្កើតការិយាល័យព័ត៌មាននៅតាមស្ថាប័ននីមួយៗទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយគាំទ្រផ្នែកហិរញ្ញវត្ថុ សម្ភារៈ និងមធ្យោបាយសមស្របដល់មន្ត្រីទទួលបន្ទុកព័ត៌មានដើម្បី សម្រួលដល់ការផ្តល់ព័ត៌មានជូនសាធារណជនដោយប្រសិទ្ធភាព។

ខ- ការិយាល័យព័ត៌មាននីមួយៗ ត្រូវដឹកនាំដោយអនុប្រធានស្ថាប័នមួយរូប ដែលមានជំនាញ និងបទពិសោធន៍លើវិស័យព័ត៌មានដែលស្ថាប័នខ្លួនទទួលខុសត្រូវព្រមទាំងមន្ត្រីទទួលបន្ទុកព័ត៌មានក្រោមឱវាទតាមតម្រូវការជាក់ស្តែង។

គ- ការតែងតាំងមន្ត្រីទទួលបន្ទុកព័ត៌មានត្រូវកំណត់ដោយ សេចក្តីសម្រេចរបស់ស្ថាប័នសាធារណៈ ។

ឃ- បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកព័ត៌មានឲ្យមានសមត្ថភាពជំនាញ អំពីសិទ្ធិទទួលព័ត៌មានដើម្បីអនុវត្តច្បាប់នេះឲ្យមានប្រសិទ្ធភាព។

ង- ជំរុញអង្គភាពជំនាញចំណុះឲ្យស្ថាប័នសាមី ត្រូវសហការទទួលខុសត្រូវក្នុងការស្រាវជ្រាវរកព័ត៌មានដែលជាកម្មវត្ថុសំណើសុំរបស់ប្រធានការិយាល័យទទួលបន្ទុកព័ត៌មាន ដើម្បីផ្តល់ជូនសាធារណជន។

**មាត្រា ៩.**

មន្ត្រីទទួលបន្ទុកព័ត៌មាន មានភារកិច្ចដូចតទៅ៖

ក- ជាអ្នកនាំពាក្យឲ្យស្ថាប័នដែលសាមីខ្លួនកំពុងបំពេញភារកិច្ច ដើម្បីឆ្លើយតបទៅសាធារណជន។

ខ- ជាអ្នកទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័ន ក្នុងការផ្តល់ព័ត៌មានគ្រប់ប្រភេទជូនសាធារណជន។

គ-ជាអ្នកសម្របសម្រួលកណ្តាលនៅក្នុងស្ថាប័នរបស់ខ្លួន និងទំនាក់ទំនងជាមួយសាធារណជនសម្រាប់ទទួលសំណើសុំព័ត៌មានពីសាធារណជន។

ឃ-សហការយ៉ាងជិតស្និទ្ធជាមួយគ្រប់អង្គភាពជំនាញចំណុះឲ្យស្ថាប័នរបស់ខ្លួន ដើម្បីស្រាវជ្រាវប្រមូលចងក្រងឯកសាររក្សាទុកនិងជួយរកឯកសារកំណត់ត្រាដែលជាកម្មវត្ថុរបស់អ្នកស្នើសុំ។

ង-ជួយសម្រួលដល់បុគ្គលគ្រប់រូប ដែលស្នើសុំព័ត៌មានរាប់បញ្ចូល ទាំងជំនួយក្នុងការរៀបចំបែបបទស្នើសុំព័ត៌មានព្រមទាំងនីតិវិធីផ្សេងទៀតដែលកំណត់ក្នុងច្បាប់នេះ។

ច-សហការជាមួយអង្គភាពជំនាញពាក់ព័ន្ធផ្សេងទៀតនៅក្នុងស្ថាប័នរបស់ខ្លួន ដើម្បីកំណត់ថាព័ត៌មានណាស្ថិតក្នុងក្របខណ្ឌព័ត៌មានសម្ងាត់ឬសំណៅឯកសារណាទទួលឬមិនទទួលអញ្ញត្រកម្ម។

ឆ-ជាអ្នករៀបចំផែនការទំនាក់ទំនងព័ត៌មាននិងផ្សព្វផ្សាយជាសាធារណៈអំពីការអនុវត្ត តួនាទីភារកិច្ច និងលទ្ធផលការងារដែលស្ថាប័នសាធារណៈសម្រេចបាន។

# ជំពូកទី៣
# នីតិវិធីស្នើសុំនិងផ្តល់ព័ត៌មាន

**មាត្រា ១០**.

បុគ្គលគ្រប់រូបទោះជារូបវន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិស្នើសុំព័ត៌មានគ្រប់ប្រភេទពីស្ថាប័នសាធារណៈដោយគ្មានការរើសអើង។

**មាត្រា ១១**.

ការស្នើសុំព័ត៌មាន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លម្អិតឲ្យបានច្បាស់លាស់អំពីព័ត៌មាន និងទម្រង់ព័ត៌មានដែលត្រូវស្នើសុំទៅស្ថាប័នសាធារណៈ។

នីតិវិធីនិងទម្រង់បែបបទនៃការស្នើសុំព័ត៌មានត្រូវបានកំណត់ដូចតទៅ៖

១- ទម្រង់បែបបទស្នើសុំព័ត៌មាន៖

- ឈ្មោះ ភេទ អាយុ សញ្ជាតិ មុខរបរ
- អាសយដ្ឋានស្នាក់នៅបច្ចុប្បន្ន និងអាសយដ្ឋានអេឡិចត្រូនិក (ប្រសិនបើមាន)
- បញ្ជីឈ្មោះព័ត៌មានលម្អិតដែលត្រូវស្នើសុំ។

២- អ្នកស្នើសុំដែលគ្មានលទ្ធភាពបំពេញទម្រង់បែបបទខ្លួនឯងដោយសារអនក្ខរភាព ឬពិការភាពសាមីខ្លួនអាចធ្វើការស្នើសុំព័ត៌មានដោយផ្ទាល់មាត់។ មន្ត្រីទទួលបន្ទុកព័ត៌មាន ដែលបានទទួលសំណើសុំហើយ ត្រូវជួយបំពេញបែបបទព័ត៌មានជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវតាម ការស្នើសុំដោយឥតគិតថ្លៃ ហើយត្រូវដាក់ឈ្មោះមន្ត្រីដែលបានបំពេញកាតព្វកិច្ចនេះនៅក្នុងសេចក្តីថតចម្លងនិងបង្កាន់ដៃរបស់អ្នកស្នើសុំ។

៣- អ្នកស្នើសុំអាចប្រគល់សំណើសុំព័ត៌មានជាលាយលក្ខណ៍អក្សរដោយផ្ទាល់ដៃ ឬតាមរយៈតំណាងស្របច្បាប់ទៅមន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មាន ឬអាចផ្ញើតាមរយៈ ប្រៃសណីយ៍ ឬសារអេឡិចត្រូនិចទៅកាន់ស្ថាប័នសាធារណៈដែលកាន់កាប់ព័ត៌មាននោះ។

៤- មន្ត្រីនៃស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មាន ដែលបានទទួលការស្នើសុំព័ត៌មានត្រូវចុះបញ្ជី និងចេញនូវបង្កាន់ដៃបញ្ជាក់ឱ្យអ្នកដែលបានស្នើសុំនោះ។

៥- អ្នកស្នើសុំត្រូវទទួលយកបង្កាន់ដៃសំអាងពីមន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មានបន្ទាប់ពីបានប្រគល់សំណើរួច។ ចំពោះអ្នកស្នើសុំតាមរយៈប្រៃសណីយ៍ ឬសារអេឡិចត្រូនិច បង្កាន់ដៃសំអាងត្រូវផ្តល់ជូនតាមប្រភេទមធ្យោបាយដែលស្នើសុំ។

៦- មន្ត្រីស្ថាប័នសាធារណៈដែលទទួលបានសំណើសុំព័ត៌មានហើយ ត្រូវបញ្ជូនសំណើនោះទៅកាន់មន្ត្រីទទួលបន្ទុកព័ត៌មានក្នុងរយៈពេល ២៤(ម្ភៃបួន)ម៉ោងនៃថ្ងៃធ្វើការ។

៧- ប្រសិនបើសំណើសុំព័ត៌មានមិនចំស្ថាប័នមានសមត្ថកិច្ចកាន់កាប់ព័ត៌មាន មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវបញ្ជូនសំណើនោះត្រឡប់ទៅអ្នកស្នើសុំវិញឱ្យបានឆាប់រហ័សបំផុត និងត្រូវផ្តល់ព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើបានអំពីស្ថាប័នដែលកំពុងកាន់កាប់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងសំណើនោះ ។

**មាត្រា ១២.**

ស្ថាប័នសាធារណៈត្រូវផ្តល់ព័ត៌មានច្បាស់លាស់ទៅតាមប្រភេទ និងទម្រង់ព័ត៌មានរបស់អ្នកស្នើសុំជាអាទិ៍៖

១- ច្បាប់ថតចម្លងសំណៅព័ត៌មានត្រឹមត្រូវតាមច្បាប់ដើម។

២- ការថតចម្លងសំណៅព័ត៌មានអាចជាអក្សរ សំឡេង រូបភាព កាសែ្សតវីដេអូ ថាស ឬជាទម្រង់ផ្សេងៗទៀត។

៣- សំណៅជាទម្រង់លេខកូដ អក្សរកាត់ អក្សរស្ទាប ឬទម្រង់ជាសញ្ញាផ្សេងៗទៀត។

៤- ក្នុងករណីការស្នើសុំព័ត៌មានច្រើនភាសា ស្ថាប័នសាធារណៈអាចផ្តល់ជូនអ្នកស្នើសុំជាភាសាខ្មែរ ឬភាសាតាមទម្រង់ដើមនៃព័ត៌មាននោះ។

**មាត្រា ១៣.**

មន្ត្រីទទួលបន្ទុកព័ត៌មាន ត្រូវពិនិត្យសំណើសុំព័ត៌មានឲ្យបានឆាប់បំផុត ហើយត្រូវធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំថាមានឬគ្មានព័ត៌មាននោះ ឬជាប្រភេទព័ត៌មានសម្ងាត់ដែលត្រូវបានហាមឃាត់ការលាតត្រដាងជាសាធារណៈដោយបញ្ញត្តិច្បាប់។ ការឆ្លើយតបនេះត្រូវធ្វើឡើងក្នុងរយៈពេលមិនឲ្យលើសពី ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានសំណើសុំ។

ការឆ្លើយតបជាវិជ្ជមាន ត្រូវបញ្ជាក់អំពីតម្លៃសេវាដែលត្រូវចំណាយ សម្រាប់ទទួលបានព័ត៌មាននៅក្នុងលិខិតនោះ។

**មាត្រា ១៤.**

ស្ថាប័នសាធារណៈត្រូវផ្តល់ព័ត៌មានដល់អ្នកស្នើសុំដូចតទៅ៖

១- ផ្តល់ព័ត៌មានជូនអ្នកស្នើសុំក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលបានការឆ្លើយតបជាផ្លូវការពីអ្នកស្នើសុំថាឯកភាពទទួលយកតម្លៃសេវាដូចបានបញ្ជាក់ក្នុងមាត្រា១៣ នៃច្បាប់នេះ ។

២- ប្រសិនបើការផ្តល់ព័ត៌មាន មិនអាចធ្វើទៅបានក្នុងអំឡុងពេលដែលបានកំណត់នៅចំណុចទី១ ស្ថាប័នសាធារណៈអាចធ្វើការពន្យារពេលបន្តទៀតមិនឲ្យលើសពីរយៈពេល ៤០ (សែសិប) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានសំណើសុំ ដោយបញ្ជាក់ពីមូលហេតុនៃការពន្យារពេលនេះជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំព័ត៌មានវិញ។

**ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦**

**មាត្រា ១៥.**

ស្ថាប័នសាធារណៈ អាចបដិសេធផ្តល់ព័ត៌មានជូនអ្នកស្នើសុំក្នុងលក្ខខណ្ឌដែលបានកំណត់ដូចតទៅ៖

១- ព័ត៌មានដែលស្ថិតក្នុងបទបញ្ញត្តិហាមឃាត់ដូចមានចែងក្នុងមាត្រា២០ នៃច្បាប់នេះ។

២- អ្នកស្នើសុំមិនព្រមបំពេញបែបបទស្នើសុំឲ្យបានពេញលេញ ដូចមានចែងក្នុងមាត្រា១១ នៃច្បាប់នេះ។

៣- អ្នកស្នើសុំប្រឆាំងដល់ប្រតិបត្តិការរបស់ស្ថាប័នសាធារណៈ។

៤- ស្ថាប័នសាធារណៈទើបបានផ្តល់ព័ត៌មានឲ្យអ្នកស្នើសុំរួចហើយ ក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃ។

៥- សំណៅឯកសារស្នើសុំដែលកំពុងរក្សាទុកដោយស្ថាប័នសាធារណៈ មានលក្ខណៈផុយស្រួយ ឬងាយខូចខាត ដែលពុំមានមធ្យោបាយណាមួយផ្តល់ជូនបាន។

**មាត្រា ១៦**.

អ្នកស្នើសុំដែលមានបំណងចង់បានព័ត៌មានពិតប្រាកដ ហើយត្រូវបានស្ថាប័នសាធារណៈបដិសេធ ដោយមូលហេតុច្បាស់លាស់ដូចមានចែងក្នុងមាត្រា១១ និងមាត្រា១៥ នៃច្បាប់នេះអាចស្នើសុំឡើងវិញ ដោយជ្រើសរើសព័ត៌មានដែលត្រូវការចាំបាច់ពិតប្រាកដឲ្យមានចំនួនសមស្រប ងាយស្រួលដល់មន្ត្រីទទួលបន្ទុកព័ត៌មានបំពេញភារកិច្ចតាមពេលកំណត់ដូចមានចែងក្នុងមាត្រា១៤ នៃច្បាប់នេះ។

ប្រសិនបើស្ថាប័នសាធារណៈមិនបានផ្តល់ព័ត៌មានក្នុងរយៈពេល ៤០ (សែសិប)ថ្ងៃ នៃថ្ងៃធ្វើការ ដោយពុំបានបញ្ជាក់មូលហេតុច្បាស់លាស់ អ្នកស្នើសុំអាចប្តឹងតវ៉ាទៅស្ថាប័នមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ។

**មាត្រា ១៧**.

មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវពិនិត្យសំណើសុំព័ត៌មានដែលស្ថិតក្នុងដែនអញ្ញត្រកម្ម រួចធ្វើការបែងចែកផ្នែកព័ត៌មានដែលស្ថិតក្នុងបទបញ្ញត្តិហាមឃាត់និងផ្នែកដែលមិនស្ថិតក្នុងបទបញ្ញត្តិហាមឃាត់។

មន្ត្រីទទួលបន្ទុកព័ត៌មានត្រូវសម្រេចផ្តល់ជូនអ្នកស្នើសុំដូចខាងក្រោម៖

១- ព័ត៌មានដែលបានផ្សព្វផ្សាយជាសាធារណៈរួចហើយដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ឬថតចម្លងផ្នែកព័ត៌មានដែលមិនមែនជាព័ត៌មានសម្ងាត់។

២- ព័ត៌មានអំពីការកាត់ចោលកំណត់ត្រាមួយផ្នែកដែលជាព័ត៌មានសម្ងាត់ ដោយបញ្ជាក់ហេតុផលនៃការកាត់ចោលផ្នែកព័ត៌មានសម្ងាត់ និងបទបញ្ញត្តិហាមឃាត់។

៣- ព័ត៌មានរបស់មន្ត្រីនយោបាយនៃស្ថាប័នសាធារណៈ និងមន្ត្រីក្របខណ្ឌរដ្ឋបាលសាធារណៈ ទាក់ទងទៅនឹងតួនាទី ភារកិច្ច។

៤- ព័ត៌មានពាក់ព័ន្ធផ្នែកពាណិជ្ជកម្មដែលម្ចាស់កម្មសិទ្ធិបានបោះបង់ចោល ឬបានយល់ព្រមផ្តល់ឲ្យស្ថាប័នសាធារណៈប្រើប្រាស់ជាប្រយោជន៍សាធារណៈ ។

**មាត្រា ១៨.**

មន្ត្រីទទួលបន្ទុកព័ត៌មាននៅគ្រប់ស្ថាប័នសាធារណៈ មិនត្រូវគេចវេះពីការទទួលខុសត្រូវក្នុងការបំពេញកាតព្វកិច្ចផ្ដល់ព័ត៌មានជូនសាធារណជនដោយមូលហេតុព័ត៌មានស្ថិតក្នុងដែនអញ្ញត្រកម្ម ដូចមានចែងក្នុងមាត្រា ៦ និងមាត្រា១៧ នៃច្បាប់នេះ ។

ប្រសិនបើសំណើសុំព័ត៌មានស្ថិតក្នុងដែនអញ្ញត្រកម្ម ត្រូវអនុវត្តតាមមាត្រា ១៧ នៃច្បាប់នេះ។

**មាត្រា ១៩.**

ស្ថាប័នសាធារណៈត្រូវ~~បំពេញកាតព្វកិច្ចផ្ដល់ព័ត៌មានឲ្យសាធារណជន ដោយកំណត់តម្លៃសេវា សមស្របដូចតទៅ~~កំណត់តម្លៃសេវាក្នុងការផ្ដល់ព័ត៌មានជូនសាធារណជនឱ្យបានសមស្របដូចតទៅ៖

១- ផ្ដល់សេវាក្នុងការរៀបចំទម្រង់បែបបទស្នើសុំព័ត៌មានដោយពុំគិតថ្លៃ។

២- ផ្ដល់កំណត់ត្រាព័ត៌មានថតចម្លងជាលាយលក្ខណ៍អក្សរ សំឡេង រូបភាព ~~កាសែត វីដេអូ ម៉ាស ឬជា~~តាមទម្រង់ផ្សេងៗ~~ទៀត~~ត្រូវកំណត់យកតម្លៃសេវាដោយប្រកាសអន្តរក្រសួងរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយស្ថាប័នពាក់ព័ន្ធ។

# ជំពូកទី ៤
# ព័ត៌មានសម្ងាត់

**មាត្រា ២០.**

ស្ថាប័នសាធារណៈអាចបដិសេធផ្ដល់ជូនព័ត៌មានដល់សាធារណជន ប្រសិនបើការបញ្ចេញព័ត៌មាននោះបណ្ដាលឲ្យ៖

១- អន្តរាយដល់សន្តិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ។

២- អន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ។

៣- អន្តរាយដល់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈជាតិ។

៤- ប៉ះពាល់ដល់សំណុំរឿង *ក្ដីរបស់តុលាការ* ~~*ស៊ើបអង្កេតឬដំណើរការជំនុំជម្រះក្ដី*~~ ឬការសម្ងាត់របស់តុលាការ។

៥- ប៉ះពាល់ដល់អាថ៌កំបាំងឯកជនបុគ្គល ដោយរួមបញ្ចូលទាំងសំណុំរឿងរបស់មន្ត្រី រាជការ សំណុំរឿងពាក់ព័ន្ធបញ្ហាសុខភាព សំណុំរឿងវិវាទ~~*ពាណិជ្ជកម្ម*~~ *នីតិឯកជន* ។

៦- គ្រោះថ្នាក់ដល់មន្ត្រីដែលអនុវត្តច្បាប់ ឬបំពេញបេសកកម្ម។

៧- ប៉ះពាល់ដល់លិខិតបទដ្ឋានគតិយុត្ត និងបទបញ្ញត្តិហាមឃាត់ស្ដីពី ព័ត៌មានសម្ងាត់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៥
## កិច្ចការពារនៃការផ្តល់ព័ត៌មាន

**មាត្រា ២១.**

បុគ្គលគ្រប់រូបមិនត្រូវទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ឬវិន័យរដ្ឋបាលណាមួយពីការប្តឹងបរិហារដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលខ្លួនបានដឹងនៅក្នុងក្របខណ្ឌនៃមុខងារ ឬក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន។

**មាត្រា ២២.**

មន្ត្រីទទួលបន្ទុកព័ត៌មានមិនត្រូវទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ឬ វិន័យរដ្ឋបាលណាមួយចំពោះការសំរេចផ្តល់ព័ត៌មានជូនសាធារណជន ដែលបានធ្វើក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនក្នុងឋានៈជាមន្ត្រីទទួលបន្ទុកព័ត៌មាន។ គោលការណ៍នេះ មិនត្រូវបានយកមកអនុវត្តឡើយក្នុងករណីមន្ត្រីទទួលបន្ទុកព័ត៌មានបំពេញភារកិច្ចរបស់ខ្លួន ដោយបំពានក្នុងចេតនាទុច្ចរិតលើសមត្ថកិច្ច និងមុខងារដែលច្បាប់បានប្រគល់ឲ្យ។

## ជំពូកទី ៦
## ការប្តឹងតវ៉ានិងការអនុវត្តសេចក្តីសម្រេច

**មាត្រា ២៣.**

អ្នកស្នើសុំអាចប្តឹងតវ៉ាទៅប្រធានស្ថាប័នដែលខ្លួនបានស្នើសុំព័ត៌មាន ប្រសិនបើសំណើសុំព័ត៌មាននោះពុំត្រូវបានផ្តល់ជូនតាមការស្នើសុំដូចមានចែងក្នុងមាត្រា១៤ ឬត្រូវបានបដិសេធពីស្ថាប័នសាធារណៈដោយពុំមានការបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់លាស់ដូចមានចែង ក្នុងមាត្រា១៥ និងមាត្រា ១៧ នៃច្បាប់នេះ។

ស្ថាប័នសាធារណៈត្រូវឆ្លើយតបទៅនឹងបណ្តឹងក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ករណីអ្នកស្នើសុំមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ប្រធានស្ថាប័នសាធារណៈដែលខ្លួនបានប្តឹង អ្នកស្នើសុំអាចប្តឹងបដិសេធសេចក្តីសំរេចនេះទៅសាលាដំបូងរាជធានី ឬខេត្ត និងអាចប្តឹងជំទាស់សេចក្តីសម្រេចរបស់សាលាដំបូងរាជធានី ឬខេត្តទៅតាមនីតិវិធីច្បាប់ ។

**មាត្រា ២៤.**

បើសាលាជម្រះក្តីជាន់ទាប ឬសាលាជម្រះក្តីជាន់ខ្ពស់សម្រេចឲ្យស្ថាប័នសាធារណៈផ្តល់ព័ត៌មានតាមការស្នើសុំ នីតិវិធីនៃការផ្តល់ព័ត៌មានត្រូវអនុវត្តតាមមាត្រា១៣ និងមាត្រា១៤ នៃច្បាប់នេះ។

# ជំពូកទី ៧

# ទោសបញ្ញត្តិ

**មាត្រា ២៥.**

មន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មានដែលពុំបានបំពេញកាតព្វកិច្ចតាមបទបញ្ញត្តិ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៧ មាត្រា១៨ និងមាត្រា២៣ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាង~~និ័យ~~វិន័យរដ្ឋបាល ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌ ។

**មាត្រា ២៦.**

បុគ្គលណាប្រព្រឹត្តអំពើធាផៅរំខាន រារាំងឬប្រើប្រាស់មធ្យោបាយណាមួយដើម្បីជាឧបសគ្គដល់ប្រតិបត្តិការរបស់មន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មានក្នុងការបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ)ថ្ងៃ ទៅ១ (មួយ)ខែ និងពិន័យជាប្រាក់ពី១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ។

ក្នុងករណីប្រព្រឹត្តអំពើហឹង្សាប្រឆាំងនឹងមន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុកព័ត៌មានដែលបំពេញមុខងារដូចមានចែងក្នុងកថាខណ្ឌទី១ មាត្រា២៦នៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមបទ បញ្ញត្តិមាត្រា ៥០៦ (បទប្រឆាំងនឹងការអនុវត្តការងារសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ២៧.**

អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តអំពើធាផៅរំខាន រារាំង ឬប្រើប្រាស់មធ្យោបាយណាមួយ ដើម្បីជាឧបសគ្គដល់ប្រតិបត្តិការបំពេញភារកិច្ចរបស់មន្ត្រីស្ថាប័នសាធារណៈ ឬមន្ត្រីទទួលបន្ទុក ព័ត៌មាន ដូចមានចែងក្នុងមាត្រា១៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិមាត្រា ៥០៥ (បទញុះញង់ឲ្យប្រព្រឹត្តអំពើប្រឆាំងនឹងអ្នករាជការសាធារណៈ) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ២៨.**

បុគ្គលណាដែលប្តឹងបរិហារដោយកូតកុហកដល់ស្ថាប័នសាធារណៈ ឬអាជ្ញាធរតុលាការនូវអំពើជាបទល្មើស កាលបើការប្តឹងបរិហារនេះនាំឲ្យធ្វើការស្រាវជ្រាវដោយឥតប្រយោជន៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីអំពើផ្តល់ព័ត៌មានមិនពិតដល់អាជ្ញាធរស៊ីវិល ឬយោធាខ្មែរ ដែលអាចឲ្យអន្តរាយដល់ការការពារជាតិដើម្បីបម្រើផលប្រយោជន៍រដ្ឋបរទេស ត្រូវផ្តន្ទាទោសតាមបទបញ្ញត្តិមាត្រា៤៤៨ (បទផ្តល់ព័ត៌មានមិនពិត) នៃក្រមព្រហ្មទណ្ឌ។

**មាត្រា ២៩**.

បុគ្គលណាដែលមានភារកិច្ចផ្ដល់ព័ត៌មាន ឬកាន់កាប់ព័ត៌មានរបស់ស្ថាប័នសាធារណៈហើយ យល់ព្រមបង្ហាញព័ត៌មានសម្ងាត់ដល់បុគ្គលគ្មានសមត្ថកិច្ចឲ្យដឹងដើម្បីទទួលអំណោយ ជំនូន ការសន្យា ឬផលប្រយោជន៍ណាមួយត្រូវផ្ដន្ទាទោសតាមបទបញ្ញត្តិមាត្រា៣២(បទល្មើសពុករលួយ) នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ។

**មាត្រា ៣០**.

បុគ្គលណាដែលមានភារកិច្ចផ្ដល់ព័ត៌មាន ឬកាន់កាប់ព័ត៌មានសម្ងាត់ដោយមូលហេតុនៃស្ថាន ភាពរបស់ខ្លួន មុខរបរ មុខងារ ឬបេសកកម្មរបស់ខ្លួន ហើយបានបង្ហាញ ឬធ្វើឲ្យបែកធ្លាយព័ត៌មានសម្ងាត់ដល់បុគ្គលគ្មានសមត្ថកិច្ចដឹងពីការសម្ងាត់របស់ស្ថាប័នសាធារណៈត្រូវផ្ដន្ទាទោសដាក់ពន្ធ នាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវផ្ដន្ទាទោសដោយទោសបន្ថែមដូចមានចែងក្នុងមាត្រា ៤៨៣ (ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

ក្នុងករណីការបែកធ្លាយព័ត៌មានសម្ងាត់ដោយអចេតនា ឬការមិនគោរពបទបញ្ជា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែទៅ ទៅ ២(ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។

**មាត្រា ៣១**.

បុគ្គលណាដែលមានភារកិច្ចផ្ដល់ព័ត៌មាន ឬកាន់កាប់ព័ត៌មានហើយបានប្រគល់ឬធ្វើឲ្យងាយស្រួលធ្លាក់ដល់ដៃរដ្ឋបរទេស ឬភ្នាក់ងារបរទេសនូវព័ត៌មានសម្ងាត់ដែលធ្វើឲ្យអន្តរាយសន្តិសុខជាតិ សេដ្ឋកិច្ចជាតិ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ)ឆ្នាំ និងពិន័យជា ប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល និងត្រូវ ផ្ដន្ទាទោស ដោយទោសបន្ថែមដូចមានចែងក្នុងមាត្រា៤៥០ (ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣២**.

បុគ្គលណាដែលគ្មានសមត្ថកិច្ចកាន់កាប់ព័ត៌មាន ឬបុគ្គលដែលធ្លាប់បំពេញភារកិច្ចកាន់កាប់ព័ត៌មានរបស់ស្ថាប័នសាធារណៈហើយបានរក្សាទុក ឬកាន់កាប់ព័ត៌មានសម្ងាត់ជាឯកជនដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០០០០(បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល ។

**មាត្រា ៣៣**.

បុគ្គលណាដែលមានភារកិច្ចកាន់កាប់ព័ត៌មានសាធារណៈ ហើយបានធ្វើឲ្យខូចខាត ឬបំផ្លិចបំផ្លាញព័ត៌មាន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០ ០០០

(បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន) រៀល និងត្រូវផ្តន្ទាទោសដោយ ទោសបន្ថែមដូចមានចែងក្នុងមាត្រា ៤៨៣ (ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

ប្រសិនបើការខូចខាតព័ត៌មានដោយអចេតនាក្នុងពេលបំពេញភារកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី១.០០០.០០០ (មួយលាន)រៀល ទៅ ២.០០០.០០០ (ពីរលាន)រៀល ។

# ជំពូកទី ៨

# អន្តរបញ្ញត្តិ

**មាត្រា ៣៤**.

ច្បាប់ស្តីពីរបបសារព័ត៌មាន ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨៩៥/០៧ ចុះថ្ងៃទី០១ខែកញ្ញា ឆ្នាំ១៩៩៥ និងបទបញ្ញត្តិនៃច្បាប់ពាក់ព័ន្ធផ្សេងទៀត ព្រមទាំងបទដ្ឋានគតិយុត្តទាំងឡាយដែលគាំទ្រដល់ការអនុវត្តច្បាប់នេះមានសុពលភាពអនុវត្តរហូតដល់មានបទបញ្ញត្តិថ្មីមកជំនួស។

មន្ត្រីទទួលបន្ទុកព័ត៌មានរដ្ឋបាលរាជធានី - ខេត្ត ដែលបានបង្កើតឡើងដោយប្រកាសអន្តរ-ក្រសួងរវាងក្រសួងមហាផ្ទៃជាមួយក្រសួងព័ត៌មានតាមប្រកាសលេខ៣៥២៧ ប្រក ៤៥៣ ពម.ប្រក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១២ ត្រូវបន្តអនុវត្តរហូតដល់ការិយាល័យទទួលបន្ទុកព័ត៌មានថ្មីមកជំនួស ស្របតាមស្មារតីនៃច្បាប់នេះ។

# ជំពូកទី ៩

# អវសានបញ្ញត្តិ

**មាត្រា ៣៥**.

ច្បាប់នេះមានអាទិភាព ប្រសិនបើមានបទបញ្ញត្តិនៃច្បាប់ផ្សេងទៀតមិនស្របគ្នានឹងបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ។

**មាត្រា ៣៦**.

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

# ឧបសម្ព័ន្ធទី ២
# កំណត់ត្រាសង្ខេបរបស់
# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តី
# ពីសេរីភាពបញ្ចេញមតិ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក

ខែកុម្ភៈ ឆ្នាំ២០១៣

# សេរីភាពបញ្ចេញមតិ

## ខ្លឹមសារសង្ខេប

កំណត់ត្រាសង្ខេបនេះ បង្ហាញនូវទិដ្ឋភាពពីស្ថានភាពសេរីភាពបញ្ចេញមតិក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) និងផ្តល់អនុសាសន៍ជាក់លាក់សម្រាប់ការពារ និងលើកស្ទួយសិទ្ធិនេះឲ្យបានសមស្រប។ ផ្នែកទីមួយ បង្ហាញនូវទិដ្ឋភាពនៃសិទ្ធិសេរីភាពបញ្ចេញមតិ ដែលត្រូវបានការពារក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ និងគូសបញ្ជាក់យ៉ាងសង្ខេបពីវិធានការណ៍នានា ដែលអាជ្ញាធរកម្ពុជាបានអនុវត្តដើម្បីរឹតត្បិតសិទ្ធិ។ ផ្នែកបន្ទាប់ បកស្រាយលំអិតលើវិធានការណ៍ទាំងនេះ។ ផ្នែកទីពីរ ការបំបិទសំឡេងតាមរយៈការត្រួតពិនិត្យ ពិពណ៌នាការត្រួតពិនិត្យក្នុងប្រទេសកម្ពុជាដែលជ្រាបចូលគ្រប់មធ្យោបាយប្រព័ន្ធផ្សព្វផ្សាយនិងសង្គមជាពិសេសប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ដូចជា កាសែត វិទ្យុ ទូរទស្សន៍ ក៏ដូចជា ស្ថានភាពនៃសេរីភាពក្នុងការប្រើប្រាស់អ៊ីនធើណែតនាពេលបច្ចុប្បន្ន និងទៅពេលអនាគត។ ផ្នែកទីបី ពិពណ៌នា ពីការបំបិទសំឡេងតាមរយៈការគំរាមកំហែង និងតាមការប្រើអំពើហិង្សារបស់អាជ្ញាធរបំបិទសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល (អង្គការ) ហើយជាពិសេស គឺក្រុមបាតុករ។ ផ្នែកទីបួន ការបំបិទសំឡេងតាមរយៈច្បាប់ លើកយកនូវបទប្បញ្ញត្តិមួយចំនួនដែលគួរឲ្យព្រួយបារម្ភ និងបានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសិទ្ធិសេរីភាពបញ្ចេញមតិរបស់ប្រជាពលរដ្ឋ។ផ្នែកទីប្រាំ ពិពណ៌នា ពីការបំបិទសំឡេងតាមរយៈការប្រើប្រាស់ប្រព័ន្ធតុលាការដ៏ពុករលួយជាឧបករណ៍នយោបាយជាពិសេសនោះ ករណីពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្ស។

ការបង្ក្រាបលើសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា បានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ការវិវឌ្ឍន៍ និងអាយុជីវិតនៃលទ្ធិប្រជាធិបតេយ្យដ៏ក្មេងខ្ចីរបស់ប្រទេស ក៏ដូចជាបានគំរាមដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចដ៏យូរអង្វែង។ ដោយឃើញមានការកើនឡើងនាពេលថ្មីៗនេះ ចំពោះការរឹតត្បិតដ៏ធ្ងន់ធ្ងរលើសិទ្ធិសេរីភាពបញ្ចេញមតិ ព្រមជាមួយការបោះឆ្នោតរដ្ឋសភាជាតិនាខែកក្កដា ឆ្នាំ២០១៣ខាងមុខនេះ កំណត់ត្រាសង្ខេបនេះ បានផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. ប្រព័ន្ធផ្សព្វផ្សាយគួរតែអាចធ្វើសេចក្តីរាយការណ៍ដោយសេរី ឯករាជ្យ និងត្រូវបានលើកទឹកចិត្តឲ្យមានកិច្ចពិភាក្សាផ្នែកនយោបាយ ពុំមែនដាក់ទោសនោះទេ។

២. សេចក្តីព្រាងច្បាប់គ្រប់គ្រងអ៊ីនធើណែត ដែលមានគោលបំណងរឹតត្បិតសេរីភាពខាងការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែត ជាពិសេស សេរីភាពបញ្ចេញមតិគួរតែត្រូវបោះបង់។

៣. ទិដ្ឋភាពច្បាប់ដែលមានស្រាប់ដែលគំរាមកំហែងដល់សេរីភាពបញ្ចេញមតិ ត្រូវតែធ្វើវិសោធនកម្ម ឬ លុបចោល និង

៤. ធ្វើកំណែទម្រង់ប្រព័ន្ធតុលាការ រួមទាំងធានាផ្តល់ការអប់រំ វិជ្ជាជីវៈផ្នែកច្បាប់ ឲ្យបានប្រសើរឡើងទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ និងការផ្តន្ទាទោសចំពោះការប្រព្រឹត្តអំពើពុករលួយ។

កំណត់ត្រាសង្ខេបនេះ តាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។

## សិទ្ធិសេរីភាពបញ្ចេញមត

សេរីភាពបញ្ចេញមតិ គឺជាសិទ្ធិមនុស្សមូលដ្ឋានមួយដែលបង្កើតបានជាសសរស្តម្ភសម្រាប់សិទ្ធិមនុស្សផ្សេងៗទៀត។ គណៈកម្មាធិការសិទ្ធិមនុស្ស("គ.ស.ម")ជាអ្នកឃ្លាំមើល កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ("ក.អ.ស.ព.ន")ថ្លែងថា "សេរីភាពបញ្ចេញមតិ គឺជាលក្ខខណ្ឌចាំបាច់មួយសម្រាប់ការទទួលស្គាល់ពីគោលនយោបាយតម្លាភាព និងគណនេយ្យភាព ដែលជាលទ្ធផលមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស"។[1]

សិទ្ធិសេរីភាពបញ្ចេញមតិត្រូវបានធានាក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិសេរីភាពបញ្ចេញមតិ។ មាត្រា៣១ ទទួលស្គាល់ និងគោរពតាមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស("ស.ស.ស.ម")និងកតិកាសញ្ញា អនុសញ្ញានានាដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។ ប្រទេសកម្ពុជាបានផ្តល់បត្យាប័ន ក.អ.ស.ព.ន នាឆ្នាំ១៩៩២ ដែលបង្កើតឲ្យមានកាតព្វកិច្ចគតិយុត្តលើប្រទេសកម្ពុជា។ ដោយហេតុថា ក.អ.ស.ព.ន ត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់កម្ពុជាបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលធ្វើឡើងកាលពីថ្ងៃទី១០កក្កដា ឆ្នាំ២០០៧ ដែលចែងថា "*សន្ធិសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ហើយ*" បង្កើតបានជាផ្នែកនៃច្បាប់កម្ពុជា។[2] មាត្រា១៩ នៃ ស.ស.ស.ម និង ក.អ.ស.ព.ន ធានានូវសិទ្ធិសេរីភាពបញ្ចេញមតិ។ មាត្រា៣៥ នៃរដ្ឋធម្មនុញ្ញ ចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ ដែលរួមមានទាំងសិទ្ធិសេរីភាពបញ្ចេញមតិផងដែរ។ ថ្វីបើមានច្បាប់បញ្ញត្តពីការការពារសិទ្ធិជាច្រើនក៏ដោយ ក៏ស្ថានភាពសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជា មានសភាពធ្ងន់ធ្ងរ។ រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បន្តបំបិទសេរីភាពបញ្ចេញមតិ និងគាបសង្កត់លើអ្នកប្រឆាំង។ វិធានការណ៍ហួសហេតុ (ពិពណ៌នានៅខាងក្រោម) ញុាំងឲ្យមានភាពភ័យខ្លាចចំពោះប្រជាពលរដ្ឋ និងបង្កើតនូវបរិយាកាសនៃការត្រួតពិនិត្យខ្លួនឯង។ សកម្មជនសិទ្ធិមនុស្ស បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកសារព័ត៌មាន អ្នកសរសេរប្លុក និងសមាជិករដ្ឋសភារបស់គណបក្សប្រឆាំង ជារឿយៗ គឺត្រូវបានអាជ្ញាធរដៅជាមុខសញ្ញា ។

---

[1] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីពន្យល់ទូទៅ លេខ ៣៤ កិច្ចប្រជុំលើក១០២ ក្រុងហ្សឺណែវ ១១-២៩ ខែកក្កដា ឆ្នាំ២០១១(គ.គ.ផ.រ/គ/ង.គ/៣៤ សេចក្តីអត្ថាធិប្បាយទូទៅ លេខ៣ <http://www2.ohchr.org/english/bodies/hrc/docs/gc34.pdf>

[2] ក្រុមប្រឹក្សាធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧/ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

## ការបំបិទសំឡេងតាមរយៈការត្រួតពិនិត្យ

### ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី

"ប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី" មានដូចជាសារព័ត៌មានក្នុងទម្រង់បោះពុម្ព វិទ្យុ និងទូរទស្សន៍ គឺជាទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយដែលបង្កើតឡើងជាយូរមកហើយ ប៉ុន្តែនេះក៏ជាទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយ ដែលទទួលរងការគ្រប់គ្រង និងត្រួតពិនិត្យយ៉ាងតឹងរឹងបំផុតនៅប្រទេសកម្ពុជា។ ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩២ កម្ពុជាបានធ្វើឲ្យប្រសើរឡើងនូវទិដ្ឋភាពនៃប្រព័ន្ធផ្សព្វផ្សាយបែបពហុចម្រុះ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាល មានឥទ្ធិពលយ៉ាងខ្លាំងទៅលើបណ្ដាញផ្សព្វផ្សាយនានាស្ទើតែទាំងអស់។ អង្គការ ហ្វ្រីដឹមហៅស៍ បានវាយតម្លៃក្នុងការស្ទង់មតិរបស់ខ្លួនមួយកាលពីឆ្នាំ២០១២ថា សេរីភាពសារព័ត៌មានក្នុងប្រទេសកម្ពុជា គឺ "មិនសេរី"[3] ខណៈដែលអង្គការ អ្នករាយការណ៍គ្មានព្រំដែនចាត់ចំណាត់ថ្នាក់លេខទី១៤៣ ឲ្យកម្ពុជាក្នុងចំណោម ១៧៩ប្រទេស នៅលើសន្ទស្សន៍សេរីភាពសារព័ត៌មាននាពេលថ្មីៗនេះ[4]។

គ្រប់ស្ថានីយទូរទស្សន៍ ស្ថានីយវិទ្យុ និង សារព័ត៌មានខ្មែរល្បីៗ ជាកម្មសិទ្ធិ ឬក៏គ្រប់គ្រងដោយគណបក្សប្រជាជនកម្ពុជា ដែលកំពុងកាន់អំណាច ("គ.ប.ក") ឬ បុគ្គលដែលមានសម្ពន្ធភាពជាមួយគណបក្សកាន់អំណាច[5] ហើយការធ្វើយ៉ាងដូច្នេះ ជាការធានាអំពីការគាបសង្កត់របស់ រដ្ឋាភិបាល លើការចែកចាយព័ត៌មាន ។[6] សារព័ត៌មានដើរតួនាទីយ៉ាងសំខាន់ក្នុងទិដ្ឋភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់ប្រទេសកម្ពុជា។ មានសារពត៌មានចំនួន៣០ ត្រូវបានបោះពុម្ពផ្សាយ ជាប្រចាំក្នុងប្រទេសកម្ពុជា ហើយភាគច្រើនអ្នកសារព័ត៌មាន ជាមុខសញ្ញានៃសកម្មភាពរបស់រដ្ឋាភិបាលដើម្បីដាក់ការត្រួតពិនិត្យ[7]។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារអាត្រាអក្ខរភាពមានចំនួនទាប[8] និងដែល ៨៥ ភាគរយនៃប្រជពលរដ្ឋកម្ពុជារស់នៅក្នុងតំបន់ជនបទ និងពុំមានឱកាសទិញសារព័ត៌មាន ដែលចែកចាយយ៉ាង

---

[3] ការិន ការឡិកា និងជេនីហ្វឺ ដាន់ហាម ' សេរីភាពសារព័ត៌មាន ក្នុងឆ្នាំ២០១១៖ ទម្លុះរបាំងការពារ និងរុញច្រាននៅមជ្ឈិមបូព៌ា' ហ្វ្រីដឹមហៅស៍ (២០១២) ៖ <http://www.freedomhouse.org/sites/default/files/booklet%20for%20Website.pdf>

[4] អ្នករាយការណ៍គ្មានព្រំដែន 'តារាងសេរីភាពសារព័ត៌មាន ឆ្នាំ២០១៣ ៖ សេចក្ដីសង្ឃឹមត្រូវកម្ទេចបន្ទាប់ពីរដូវរំហើយ' <http://en.rsf.org/spip.php?page=classement&id_rubrique=1054> ។

[5] គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា ("ខុមហ្វ្រែល") លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ការបោះឆ្នោត និងកំណែទម្រង់ ៖ ២០០៩ របាយការណ៍ (ខែកុម្ភ: ២០១០) <http://www.comfrel.org/images/others/1265785063Comfrel-Cambodia%20Democratic%20Reform%202009-En-Final.pdf>។

[6] ម.ស.ម.ក 'ប្រព័ន្ធផ្សព្វផ្សាយថ្មី និងការលើកស្ទួយសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា(របាយការណ៍)(ខែកក្កដា ឆ្នាំ២០១២) ៖ www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=79&id=5

[7] ម.ស.ម.ក និងប្រភពដទៃទៀត ៖ 'កម្ពុជា ព្យាយាមមិនឲ្យនិយាយ៖ លទ្ធិប្រជាធិបតេយ្យប្រឈមហានិភ័យ អាចស្វែងរកបានតាមរយៈ៖ www.article19.org/data/files/pdfs/publications/cambodia-gagged-democracy-at-risk-.pdf

[8] យោងតាមការស្រាវជ្រាវ ៧៣.៦% នៃប្រជាជនកម្ពុជាត្រូវបានវាយតម្លៃថា ចេះអក្ស ប៉ុន្តែ ភាពចេះអក្សរនេះ ត្រូវបានកំណត់ដោយចង្អៀតថា អាចមានលទ្ធភាពអាន និងសរសេរសោរលិខិតធម្មតា សូមមើល អង្គការសម្ព័ន្ធខ្មែរ ជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ)"អានរវាងបន្ទាត់ ៖ នយោបាយ ប្រាក់ ការភ័យខ្លាចគ្របសង្កត់កម្ពុជាដោយរបៀបណា" ខែ ឧសភា ឆ្នាំ២០០៨ អាចស្វែងរកបាន ៖ http://licadho-cambodia.org/reports/files/119LICADHOMediaReport2008.pdf.

លើសលុបតែនៅទីប្រជុំជន[9] នេះគឺជាការដាក់កំហិតក្នុងការទទួលបាន និងអត្រាអ្នកអាន សារព័ត៌មានក្នុងទម្រង់បោះពុម្ព។

ដូច្នេះ វិទ្យុមានសារៈសំខាន់ខ្លាំងណាស់ក្នុងប្រទេសកម្ពុជា ដោយសារតែវិទ្យុមានការគ្របដណ្តប់ទូលំទូលាយជាង។ មានស្ថានីយវិទ្យុចំនួន៧៤ បានចុះបញ្ជីជាផ្លូវការក្នុងប្រទេសកម្ពុជា[10] ហើយភាគច្រើននៃស្ថានីយទូរទស្សន៍ទាំងនោះ នៅក្រោមឥទ្ធិពលរបស់ គ.ប.ក។[11] មានស្ថានីយវិទ្យុឯករាជ្យចំនួន៤ ក្នុងប្រទេស[12]ហើយវិទ្យុមួយក្នុងចំណោមវិទ្យុ៣ទាំងនេះគឺវិទ្យុសំបុកឃ្មុំបានប្រឈមការរឹតត្បិតច្រើនលើកច្រើនសារ និងបានត្រូវបិទស្ថានីយមិនឲ្យចាក់ផ្សាយជាច្រើនដង។ លោកម៉ម សូណង់ដូ ម្ចាស់វិទ្យុនេះ ត្រូវបានអាជ្ញាធរចាប់ខ្លួនបីលើក ដែលក្នុងពេលថ្មីៗនេះ ទាក់ទងនឹងបទបង្កើតតំបន់អបគមន៍ និងញុះញង់ឲ្យកាន់អាវុធ ដែលជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លីមួយក្នុងខេត្តក្រចេះ។ គាត់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ កាលពីថ្ងៃទី០១ខែតុលា ឆ្នាំ២០១២។[13]

មានការប៉ុនប៉ងជាច្រើនលើក ដើម្បីដាក់កំហិតលើប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី ទាំងប្រើច្បាប់ព្រហ្មទណ្ឌ ការគំរាម និងការបំភិតបំភ័យដល់អ្នកសារព័តមាន អ្នកបោះពុម្ពផ្សាយ និងប្រព័ន្ធផ្សព្វផ្សាយនានា។ ពីចន្លោះឆ្នាំ២០០៧ និងឆ្នាំ២០១១ មានការយាយីរំខានលើប្រព័ន្ធផ្សព្វផ្សាយមានចំនួន១២៣ ករណី រួមទាំងការចាប់ខ្លួនអ្នកសារព័ត៌មាន ការរារាំងអ្នកយកព័ត៌មានមិនឲ្យចូលទៅយកព័ត៌មានក្នុងព្រឹត្តិការណ៍សំខាន់ៗ ការដកហូត ឬ កម្ទេចចោលនូវសម្ភារៈរបស់អ្នកសារព័ត៌មាន ចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងថែមទាំងមានអំពើហិង្សាទៀតផង។[14] ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មាន បានត្រូវរាំងខ្ទប់ដោយការបន្តរំខានពីសំណាក់រដ្ឋាភិបាល រួមទាំងបិទ ឬបានគំរាមបិទសារព័ត៌មានឯករាជ្យ។[15] ជាលទ្ធផលនៃការរំខានបែបនេះ តាមភស្តុតាងបង្ហាញថាបានញ៉ាំងឲ្យមានការត្រួតពិនិត្យ

---

9 ដូចខាងលើ

10 ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ "រំលឹកពីទំនាក់ទំនងកម្ពុជា ឆ្នាំ២០១០" (ខែធ្នូ ឆ្នាំ២០១០) ៖ <www.dmc-cci.edu.kh/userfiles/Cambodian%20Communication%20Review%202011.pdf>

11 ម.ស.ម.ក. និងអង្គការផ្សេងទៀត 'កម្ពុជា រឹតត្បិតប្រព័ន្ធផ្សព្វផ្សាយ ៖ លទ្ធិប្រជាធិបតេយ្យប្រឈមហានិភ័យឬ?' (របាយការណ៍) (ខែកញ្ញា ឆ្នាំ២០១០) ទំព័រ២០ ៖ <www.article19.org/data/files/pdfs/publications/cambodia-gagged-democracy-at-risk-.pdf>

12 ម.ស.ម.ក 'ប្រព័ន្ធផ្សព្វផ្សាយជំនាន់ថ្មី និងការលើកកម្ពស់ផ្នែកសិទ្ធិមនុស្ស' (របាយការណ៍) (ខែកក្កដា ឆ្នាំ២០១២)ទំព័រ៦ ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=report_detail.php&reid=79&id=5>

13 សម្រាប់ព័ត៌មានបន្ថែម លើករណីលោកម៉ម សូណង់ដូ សូមមើលកំណត់ហេតុសង្ខេបរបស់ ម.ស.ម.ក (ខែសីហា ឆ្នាំ២០១២)៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=20&id=5 ។

14 សូមមើល ផែនទី បង្ហាញពីការយាយីលើប្រព័ន្ធសារព័ត៌មានរបស់ ម.ស.ម.ក ៖ http://www.sithi.org/temp.php?url=jour_case.php&

15 ឧទាហរណ៍មួយ ដូចសារព័ត៌មានមនសិកាខ្មែរ(Khmer Conscience)ដែលគាំទ្រគណបក្សប្រឆាំង ជាសារព័ត៌មានប្រឆាំងដែលមានប្រជាប្រិយភាព មានវ័យចំណាស់ជាងគេមួយ។ និពន្ធនាយករបស់សារព័ត៌មាននេះគឺលោក ដាំ សិទ្ធ ត្រូវបានគេគំរាមបង្ខំឲ្យបិទសារព័ត៌មានក្នុងខែកក្កដា ឆ្នាំ២០០៩ ដើម្បីជៀសវាងការផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះបទរិះគន់ទៅលើមន្ត្រីរដ្ឋាភិបាល។ សារព័ត៌មានត្រូវបានបិទកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៩។ ការចោទប្រកាន់រូបលោកដាំ សិទ្ធ ទាក់ទងនឹងមាតិការឿងជាច្រើនបានចេញផ្សាយក្នុងខែកុម្ភៈ និងខែឧសភា។ ការស្នើឲ្យលោកបិទសារព័ត៌មាននេះ កើតមានបន្ទាប់ពីការគំរាមកំហែងនៃការផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះការរិះគន់លើមន្ត្រីរដ្ឋាភិបាល អស់រ

ខ្លួនឯងក្នុងចំណោមបុគ្គលិកអ្នកសារព័ត៌មាន ដែលចៀសវាងមិនបោះពុម្ពផ្សាយនូវព័ត៌មានដែលរដ្ឋាភិបាលចាត់ទុកថាមានលក្ខណៈប៉ះពាល់ ឬក៏ជារឿងនយោបាយ។[16] អ្នកអង្កេតការណ៍បានកត់សម្គាល់ឃើញថា មានគោលនយោបាយសកម្មមួយដែលជាផ្នែកមួយនៃអ្នកបោះពុម្ពផ្សាយ និងនិពន្ធនាយក ដែលផ្សាយព័ត៌មានដែលមានលក្ខណៈមិនសូវរសើប និងរឿងដែលមិនសូវមានការចាប់អារម្មណ៍ "ដើម្បីសុវត្ថិភាពរបស់គេ" ។[17]

## ប្រព័ន្ធអ៊ីនធើណែត

កម្ពុជា ជាប្រទេសមួយដែលមានអត្រាអ្នកប្រើប្រាស់អ៊ីនធើណែតទាបជាងគេបំផុតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ [18] ទោះជាយ៉ាងណាក្តី ការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែតក្នុងប្រទេសនេះ កំពុងតែកើនឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ និងមានការកើនឡើងយ៉ាងខ្លាំងក្នុងការប្រើប្រាស់តាមបណ្តាញ និងវេទិកាទំនាក់ទំនងសង្គមមានដូចជា ធ្វីតទ័រ ហ្វេសប៊ុក និងយូធ្យូប។ ស្ថានីយព័ត៌មានឯករាជ្យនានា ខ្លះកំពុងតែចែករំលែកព័ត៌មានលើប្រព័ន្ធអ៊ីនធើណែត ហើយ អ្នកសរសេរប្លុក កំពុងតែចែករំលែកគំនិត និងទស្សនៈនានា ហើយទស្សនៈទាំងនោះ ភាគច្រើនគឺរិះគន់ រដ្ឋាភិបាល។ អវត្តមាន នៃការរឹតត្បិតចំពោះខ្លឹមសារតាមប្រព័ន្ធអ៊ីនធើណែត នៅកម្ពុជា ដូចជាអ្វីដែលអ្នកសរសេរប្លុកជនជាតិខ្មែរដ៏ល្បីឈ្មោះ និងជានាយិកាគ្រប់គ្រងកម្មវិធីរបស់ ម.ស.ម.ក អ្នកស្រីចក់ សុភាព បានពិពណ៌នាថា អ៊ីនធើណែតដូចជា "លទ្ធិប្រជាធិបតេយ្យតាមបែបឌីជីថល" របស់កម្ពុជា"។[19]ប្រហែលដោយសារតែអាត្រាការប្រើប្រាស់នៅមានកម្រិតទាប អ៊ីនធើណែតនៅតែជាទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយដែលកម្រិតនៃការរឹតត្បិតគឺទាបបំផុតក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលបានព្យាយាមទប់ស្កាត់ការចូលអានវែបសាយដែលចុះផ្សាយព័ត៌មានដែលមានលក្ខណៈ"រសើប"។[20] កាលពីដើមខែកុម្ភៈ ឆ្នាំ២០១១ កម្ពុជាបានដកពិសោធន៍នូវការបញ្ចេញកំហឹងមួយ ដែលធ្វើឲ្យប៉ះពាល់ដល់គេហទំព័រ ខេអាយមេឌៀ ខេមរៈយាន្តកម្ម និងប្លុករបស់អ្នកគូររូបត្លុកបែបនយោបាយជនជាតិខ្មែរឈ្មោះថា សក្តិក្រវ៉ា ព្រមទាំងគេហទំព័រចំនួនប្រាំផ្សេងទៀត ។[21] បុគ្គលិកមិនស្គាល់ឈ្មោះមួយរូប របស់

---

យៈពេលជាច្រើនឆ្នាំមក។ សូមមើល សេចក្តីថ្លែងការណ៍ អង្គការឃ្លាំមើលការរំលោភបំពានសិទ្ធិមនុស្ស កម្ពុជា៖ បញ្ចប់ការវាយប្រហារលើអ្នករិះគន់ប្រឆាំង ចេញផ្សាយកាលពីថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០០៩។

16 កំណត់ហេតុទី៧

17 "ទាហាន សម្រាប់សេរីភាពនិយាយស្តី" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១០។ ៖ <www.phnompenhpost.com/2010010630643/LIFT/soldiers-for-free-speech.html>

18 សហភាពទូរគមនាគមន៍អន្តរជាតិ "សង្គមព័ត៌មាន ទម្រង់តាមស្ថិតិ ៖ អាស៊ី និង បាស៊ីភិច"(ឆ្នាំ២០០៩) ៖<www.itu.int/ITU-D/ict/material/ISSP09-AP_final.pdf> សម្រាប់ព័ត៌មានបន្ថែម សូមមើល របាយការណ៍របស់ ម.ស.ម.ក "ប្រព័ន្ធផ្សព្វផ្សាយថ្មី និងការលើកកម្ពស់ផ្នែកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា" (ខែកក្កដា ឆ្នាំ២០១២) ១១

19 លោកស្រីចក់ សុភាព 'លទ្ធិប្រជាធិបតេយ្យលើប្រព័ន្ធអ៊ីនធើណែត' (sopheapfocus, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១១) ៖ <sopheapfocus.com/index.php/2009/11/digital-democracy-emerging-in-cambodia/>

20 សម្រាប់ព័ត៌មានបន្ថែមសូមមើល សលាប័ត្រព័ត៌មានរបស់ ម.ស.ម.ក ស្តីពីការត្រួតពិនិត្យលើប្រព័ន្ធអ៊ីនធើណែត(ខែកក្កដា ឆ្នាំ២០១១) ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=2&id=5

21 មាននៅក្នុងកំណត់ទី៦ ទំព័រ៣២

ក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធើណែតមួយ ដែលទទួលផលប៉ះពាល់ បានប្រាប់សារព័ត៌មានថា ក្រសួងបានបញ្ជាក្រុមហ៊ុនឲ្យបិទខេអាយមេឌៀ ពីព្រោះវែបសាយ នេះ បានចុះផ្សាយព័ត៌មានដែល "ប៉ះពាល់ដល់រដ្ឋាភិបាល"។[22]

អ៊ីនធើណែតបានក្លាយជាវេទិកាកណ្ដាលមួយសម្រាប់ការពិភាក្សាសាធារណៈ សកម្មនិយមនិងការអភិវឌ្ឍន៍។ វាផ្ដល់ជាមធ្យោបាយសម្រាប់អ្នកសរសេរប្លុក ភ្នាក់ងារព័ត៌មាន អង្គការមិនមែនរដ្ឋាភិបាល ក្រុមប្រឆាំង និងគណបក្សនយោបាយនានា ដើម្បីអាចបញ្ជូនសាររបស់ពួកគេទៅកាន់សាធារណជន។ សូមចងចាំថា ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ បានអនុម័តសេចក្ដីប្រកាសមួយស្ដីពីការលើកកម្ពស់ ការពារ និងសិទ្ធិទទួលបានការប្រើប្រាស់អ៊ីនធើណែត (សេចក្ដីប្រកាស) នាថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១២។ សេចក្ដីប្រកាសនេះ អះអាងថា ការគោរពសិទ្ធិមនុស្ស ជាពិសេស សេរីភាពបញ្ចេញមតិ និងសេរីភាពទទួលព័ត៌មាននៅលើប្រព័ន្ធអ៊ីនធើណែត ដែលថ្មីៗនេះ រាជរដ្ឋាភិបាលបានចេញប្រកាសថា រដ្ឋាភិបាលកំពុងធ្វើសេចក្ដីព្រាងច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណែត ដើម្បីបញ្ញត្ត និងកម្រិតការប្រើប្រាស់អ៊ីនធើណែត។ ហេតុផលមួយ ក្នុងចំណោមហេតុផលនានា សម្រាប់ការអនុម័តច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណែតបែបនេះ គឺដើម្បីរារាំងមិនឲ្យ "ជនទុច្ចរិត ផ្សព្វផ្សាយនូវព័ត៌មានមិនពិត"។[23] ច្បាប់នេះកំពុងតែស្ថិតនៅដំណាក់កាលដំបូងនៃការធ្វើសេចក្ដីព្រាង ដោយមិនទាន់បានប្រកាសឲ្យប្រើជាសាធារណៈនៅឡើយទេ ប៉ុន្តែ មានការភ័យខ្លាចថាច្បាប់បែបនេះ អាចធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេរីភាពបញ្ចេញមតិតាមអ៊ីនធើណែតក្នុងប្រទេសកម្ពុជា។ ច្បាប់ស្ដីពីឧក្រិដ្ឋកម្មលើកុំព្យូទ័ររបស់ប្រទេសថៃ ដែលបានអនុម័តកាលពីឆ្នាំ២០០៧ បង្ហាញនូវគំរូឧទាហរណ៍ដ៏សមស្របមួយ ពីរបៀបអនុវត្តច្បាប់គ្រប់គ្រងអ៊ីនធើណែតស្រដៀងគ្នានេះ ក្នុងប្រទេសកម្ពុជា ដែលជំនួសឲ្យការពារនូវផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា ច្បាប់នេះបែរជាអាចផ្ដល់ផលប៉ះពាល់ដ៏គ្រោះថ្នាក់លើសេរីភាពផ្នែកនយោបាយ សេរីភាពបញ្ចេញមតិ និង "សិទ្ធិដឹង"។[24]

## ការបំពិនសិទ្ធិតាមរយៈការគំរាមកំហែង និងការប្រើប្រាស់អំពើហិង្សា

នៅក្នុងប្រទេសកម្ពុជា បុគ្គលទាំងឡាយណាដែលសម្ដែងឡើងនូវគំនិតដែលមាននិន្នាការប្រឆាំង បុគ្គលទាំងនោះជាញឹកញាប់ ត្រូវប្រឈមនឹងការសម្លុត គំរាមកំហែង និងអំពើហិង្សា។ បាតុកម្មដោយសន្តិវិធី ជាទូទៅបានក្លាយជាអំពើហិង្សាដោយកម្លាំងពុំសមាមាត្រប្រើប្រាស់ដោយអាជ្ញាធរ។ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១២ លោក

---

[22] "គេហទំព័រប្រឆាំងត្រូវបានបិទ" កាសែតភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ៖ <www.phnompenhpost.com/2011021446784/National/opposition-site-blocked.html>

[23] "បុគ្គលទុច្ចរិត 'ជំរុញ' ការបង្កើតច្បាប់គ្រប់គ្រងប្រព័ន្ធអ៊ីនធើណែត ៖ មន្ត្រី" ភ្នំពេញប៉ុស្ដិ៍ (ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២) ៖ www.phnompenhpost.com/2012052456372/National/the-ill-willed-spark-cyber-law-officials.html

[24] ម.ស.ម.ក 'សិទ្ធិប្រើប្រាស់ប្រព័ន្ធអ៊ីនធើណែត' (សលាកប័ត្រព័ត៌មាន) (កក្កដា ២០១២) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=51&id=5>

រ៉ុង បញ្ញា បុគ្គលិករបស់សហភាពសហជីពកម្ពុជា ត្រូវបានវាយដំ និងចាប់ខ្លួនដោយអាជ្ញាធរ ខណៈពេលដែលលោកកំពុងធ្វើការតវ៉ាដោយសន្តិវិធី ជាមួយនិងនិយោជិតមកពីរោងចក្រ តៃ ណាន ជាច្រើននាក់។[25]

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ ក្នុងអំឡុងពេលនៃការតវ៉ានៅ រោងចក្រមួយក្នុងខេត្តស្វាយរៀង អាជ្ញាធរមូលដ្ឋាន គឺលោក ឈូក បណ្ឌិត បានបើកការបាញ់ប្រហារលើក្រុមបាតុករ ដែលបាញ់ឲ្យរបួសកម្មការិនីរោងចក្រចំនួន៣រូប ហើយនៅថ្ងៃទី១៦ ខែឧសភា ក្មេងស្រីអាយុ១៤ឆ្នាំ ឈ្មោះ ហេង ចន្ថា ត្រូវបានបាញ់សម្លាប់នៅខេត្តក្រចេះនៅពេលដែលនគរបាលបានបាញ់ប្រហាលើក្រុមអ្នកភូមិកំឡុងពេលនៃការបង្ក្រាបលើបាតុកម្មទាមទាសិទ្ធិដីធ្លី។ លោក ឈុត វុទ្ធី ជាស្ថាបនិក និងជានាយកនៃអង្គការការពារធនធានធម្មជាតិ ត្រូវបានសម្លាប់ កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ នៅចំនុចវាលបី ខេត្តកោះកុង ខណៈពេលដែលលោកចុះទៅប្រមូលឯកសារកាប់ឈើខុសច្បាប់ជាមួយអ្នកកាសែតពីររូប។[26]

មានអ្នកសារព័ត៌មានចំនួន ១១រូប ត្រូវបានធ្វើឃាតក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤ ។ នាពេលថ្មីនេះៗ ករណីឃាតកម្មលើ លោក ហង្ស សិរីឧត្តម អ្នកសារព័ត៌មានរបស់កាសែត *វីជនខ្មែរ ដេលី* ក្នុងខេត្តរតនៈគិរីដែលសាកសពរបស់លោកត្រូវបានរកឃើញនៅក្នុងឃ្លុបក្រោយរថយន្តកាលពីថ្ងៃទី១១ខែកញ្ញា ឆ្នាំ២០១២។ លោក ហង្ស សិរីឧត្តម បានរាយការណ៍ពីករណីកាប់ឈើខុសច្បាប់ ហើយដែលក្នុងរយៈពេលបួនខែចុងក្រោយនេះបានលាតត្រដាងឡើងនូវករណីជាច្រើនដែលមានជាប់ព័ន្ធនឹងជនមានអំណាច និងក្រុមដែលមានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាល។[27] ទោះបី ជនសង្ស័យពីររូបត្រូវបានសមត្ថកិច្ចចាប់ខ្លួន និងបានចោទប្រកាន់ពីបទមនុស្សឃាត[28] ក៏ជាទូទៅនិទណ្ឌភាពរីករាលដាលក្នុងករណីប្រើអំពើហិង្សាទៅលើអ្នកសារព័ត៌មាន។ ឧទាហរណ៍ និទណ្ឌភាពក្នុងករណីលោក ឃឹម សំបូរ អ្នកយកព័ត៌មានឲ្យកាសែតជំទាស់ជាភាសាខ្មែរមួយ គាត់ត្រូវឃាតករបាញ់សម្លាប់ជាមួយនឹងកូនប្រុសអាយុ២១ឆ្នាំ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៨។[29] អាជ្ញាធរខេត្ត ជារឿយៗធ្វើការរារាំងអង្គការមិនមែនរដ្ឋាភិបាលមិនឲ្យបើកវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំនានា និងធ្វើការគំរាមកំហែងបុគ្គលិកអង្គការទាំងនោះ ដោយប្រើអំពើហិង្សា ដើម្បីរាំងមិនឲ្យមានទំនាក់ទំនងជាមួយសហគមន៍ប្រជាពលរដ្ឋតាមមូលដ្ឋាន។[30]

---

[25] ម.ស.ម.ក 'ប្រតិកម្មដោយហិង្សា ចំពោះការប្រឆាំងតវ៉ារបស់កម្មករ' (សលាកប័ត្រព័ត៌មាន)(ខែកក្កដា ឆ្នាំ២០១២) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=52&id=5>

[26] ម.ស.ម.ក "វរជន គឺលោកឈុត វុទ្ធី ត្រូវបានឃាតករបាញ់សម្លាប់នៅខេត្តកោះកុង(សេចក្តីប្រកាសព័ត៌មាន)(ថ្ងៃទី២៦ ខែមេសា ឆ្នាំ ២០១២) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=18&id=5>

[27] ម.ស.ម.ក 'ការស៊ើបអង្កេតសមស្របចាំបាច់ត្រូវធ្វើឡើងលើឃាតកម្មអ្នកសារព័ត៌មាន' (វិចារណកថាព័ត៌មាន) (១២ កញ្ញា ២០១២) <http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=287&id=5&lang=eng>

[28] "បុគ្គលពីរនាក់នៅ រតនៈគិរី រងការចោទប្រកាន់ចំពោះការស្លាប់អ្នកយកព័ត៌មាន" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ ៖ <www.phnompenhpost.com/index.php/2012091758733/National-news/ratanakkiri-duo-charged-in-death-of-reporter.html>

[29] អ្នកយកព័ត៌មានគ្មានព្រំដែន (ថ្ងៃទី១៥ ខែតុលាកា ឆ្នាំ២០០៨) ៖ http://en.rsf.org/cambodia-who-masterminded-journalist-khim-15-10-2008,28956.html>

[30] ម.ស.ម.ក ការប្រជុំ និងវគ្គបណ្តុះបណ្តាល (សលាកប័ត្រព័ត៌មាន)(ខែសីហា ឆ្នាំ២០១១)

ករណីប្រើអំពើហិង្សា និងសម្លុតគំរាមកំហែងប្រឆាំងនឹងបុគ្គលដែលអនុវត្តនូវប្រើសេរីភាពបញ្ចេញមតិ និង និទណ្ឌភាពដែលជាលទ្ធផលសម្រាប់បុគ្គលដែលបានរំលោភសិទ្ធិទាំងនេះ ជំរុញឲ្យមានវប្បធម៌ភ័យខ្លាច និងមាន ការត្រួតពិនិត្យលើខ្លួនឯង ដែលបច្ចុប្បន្ននេះ កើតមានឡើងចំពោះប្រជាពលរដ្ឋជាច្រើន។

## ការបំបិទសិទ្ធិដោយប្រើប្រាស់ច្បាប់

អាជ្ញាធរកម្ពុជា ជារឿយៗអនុវត្តច្បាប់មិនច្បាស់លាស់ ដែលមានលក្ខណៈរឹតត្បិត រារាំងចំពោះសេរីភាព បញ្ចេញមតិរបស់អ្នកការពារសិទ្ធិមនុស្ស បុគ្គលិករបស់ប្រព័ន្ធផ្សព្វផ្សាយ អ្នកនយោបាយដែលមាននិន្នាការប្រឆាំង និងប្រជាពលរដ្ឋកម្ពុជាជាទូទៅ។ ថ្វីបើមានការផ្តល់បត្យាប័នលើ ក.ស.អ.ស.ព.ន និងការធានានៅក្នុងរដ្ឋធម្មនុញ្ញ ក៏បទបញ្ញត្តិច្បាប់កម្ពុជាជាច្រើនពុំបានអនុលោមតាមសិទ្ធិមនុស្ស និងបទដ្ឋានសេរីភាពបញ្ចេញមតិអន្តរជាតិនានា នៅឡើយទេ។

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចូលជាធរមាន នាខែធ្នូ ឆ្នាំ២០១០ ដែលជំនួសច្បាប់អាជ្ញាធរអន្តរកាលនៃ អង្គការសហប្រជាជាតិនៅកម្ពុជា (ច្បាប់អ៊ុនតាក់) មានបទបញ្ញត្តិស្រពេចស្រពិលជាច្រើន ដែលរឹតត្បិតសេរីភាព បញ្ចេញមតិយ៉ាងធ្ងន់ធ្ងរក្នុងប្រទេសកម្ពុជា។[31] បទបញ្ញត្តិទាំងនេះ ពុំបានចែកឲ្យដាច់ស្រឡះរវាងបុគ្គលឯកជន និង បុគ្គលកាន់មុខងារសាធារណៈ ហើយថែមទាំងអនុញ្ញាត "ស្ថាប័ន" រដ្ឋាភិបាលអាចដាក់ពាក្យបណ្តឹងបរិហារកេរ្តិ៍ថែម ទៀត។ នេះគឺផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ដូចជាគោលការណ៍ ស៊ីរ៉ាឃ្យូសា (Siracusa) ស្តីពីការកំណត់ និងបដិ ប្បញ្ញត្តិនៃបទប្បញ្ញត្តិក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលចែងថា"ការដាក់កំហិតលើ សិទ្ធិមនុស្សដោយផ្អែកលើកិត្តិសព្ទរបស់បុគ្គលដទៃ នឹងមិនត្រូវបានប្រើប្រាស់ដើម្បីការពាររដ្ឋ និងមន្ត្រីរបស់ខ្លួន ពី គំនិតសាធារណៈ និងការរិះគន់នោះទេ"។[32]បន្ថែមលើសពីនេះ គ.ស.ម នាពេលថ្មីៗនេះបានណែនាំថា "*ក្នុងកាលៈ ទេសៈដែលមានការជជែកពិភាក្សាពីបុគ្គលសាធារណៈ នៅក្នុងវិស័យនយោបាយ និងនៅតាមបណ្តាស្ថាប័នសាធារ*

[31] តាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌ ការបង្ខូចកិត្តិយស កេរ្តិ៍ឈ្មោះរបស់បុគ្គលណាម្នាក់ឬស្ថាប័នណាមួយ ជាបទបរិហារកេរ្តិ៍។ មូលហេតុ នៃជនដែលត្រូវចោទប្រកាន ឬ ជនជាប់ចោទ ត្រូវរកឃើញនៅក្នុងយុត្តាធិការនានា ដូចជា ការពន្យល់ដ៏យុត្តិធម៌ ពុំមានការទទួលខុសត្រូវ ចំពោះបទល្មើស។ ជាងនេះទៅទៀត មាត្រា៣០៧ ធ្វើឲ្យការបញ្ចេញមតិបែបជេរប្រមាថ ពាក្យសម្តីមើលងាយ ឬការបំពារបំពានជនណាមួយ ឬស្ថានប័នទាំងឡាយដោយពាក្យសម្តី ជាបទល្មើសព្រហ្មទណ្ឌ។ ការឲ្យនិយមន័យពាក្យថា 'ជេរប្រមាថ' គឺពុំមានលក្ខណៈច្បាស់លាស់។ ពាក្យនេះមានឥទ្ធិពលអនុវត្តចំពោះការរិះគន់ផ្នែកនយោបាយ ឬការនិពន្ធតិះដៀល។ មាត្រា៣១១ ធ្វើការបរិហារបង្កាច់កេរ្តិ៍ ជាបទល្មើសព្រហ្ម ទណ្ឌ ដោយចាត់ទុកថា ជាការធ្វើចោទប្រកាន់លើអង្គហេតុ ដែលស្គាល់ថាការក្លែងបន្លំ ដែលអាចនាំឲ្យជាអំពើព្រហ្មហទណ្ឌឬ ជាការដាក់ការ ដាក់ពិន័យប្រឆាំងនិងបុគ្គលណាម្នាក់។ បុគ្គលទាំងឡាយ ថែមទាំងអាចត្រូវចោទប្រកាន់ពីបទបង្ខូចកិត្យានុភាពលើសេចក្តីរបស់តុលាការ ក្រោមច្បាប់៥២៣។

[32] គណៈកម្មាធិការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ជ គោលការណ៍ ស៊ីរ៉ាឃ្យូសា ស្តីពីការកំណត់ និងបដិប្បញ្ញត្តិនៃបទប្បញ្ញត្តិក្នុងក តិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ(ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៨៤) ឯកសាររបស់ អ.ស.ប ង/គ.ន/៤/១៩៨៤/៤ អាច រកបានតាម៖www.unhcr.org/refworld/docid/4672bc122.html

*ណៈ តម្លៃដែលបានកំណត់ដោយកតិកាសញ្ញាស្តីពីការកំហិតសិទ្ធិសេរីភាពបញ្ចេញមតិ គឺខ្ពស់ជាពិសេស...រដ្ឋភាគី មិនត្រូវហាមឃាត់ចំពោះការរិះគន់ទៅលើស្ថាប័ននោះទេ"* ។[33]

សរុបមក ច្បាប់ស្តីពីការជួប្រជុំដោយសន្តិវិធី គឺជាការបកស្រាយថ្មីមួយដែលបានអនុម័តក្នុង ឆ្នាំ២០០៩ ពុំបានរឹតត្បិតសេរីភាពទេ ប្រសិនជា អនុវត្តបានត្រឹមត្រូវ។ ទោះជាយ៉ាងនេះក្តី មានការព្រួយបារម្ភខ្លះ អំពីការអនុវត្តន៍ច្បាប់នេះ និងភាពជាក់លាក់នៃបទប្បញ្ញត្តិមួយចំនួន ដែលបន្ថយនូវសេរីភាពបញ្ចេញមតិតាមរយៈការជួបជុំគ្នា។[34] ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ ត្រូវបានអនុម័តរួចហើយ ដោយមានសម្ពាធពីម្ចាស់ជំនួយអន្តរជាតិក្នុងគោលបំណងដើម្បីជាក់ឲ្យប្រើជំនួសច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៧២ ដែលមានលក្ខណៈធ្ងន់ធ្ងរ។ ខណៈដែលច្បាប់ស្តីពីរបបសារពត៌មានឆ្នាំ១៩៩៥មានបទប្បញ្ញត្តិជាវិជ្ជមានដើម្បីលើកស្ទួយសេរីភាពបញ្ចេញមតិស្របតាមសិទ្ធិដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ[35]ទាំងអង្គការមិនមែនរដ្ឋាភិបាល និងសារព័ត៌មាននានា បានរិះគន់បន្ថែមលើច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥នេះ ដោយសំអាងថាជាការដាក់កំហិតបន្ថែមទៀតចំពោះសេរីភាពរបស់អ្នកសារព័ត៌មាន។[36] ឧទាហរណ៍ មាត្រា១២ ចែងថា អ្នកសារព័ត៌មានដែលបានរកឃើញពិរុទ្ធភាពពីបទបរិហាកេរ្តិ៍ និងការបង្ខូចកេរ្តិ៍រួមជាមួយនឹងការសរសេរអត្ថបទដែលអាចប៉ះពាល់ដល់ "សន្តិសុខជាតិ" ឬប៉ះពាល់ដល់ "ស្ថិរភាពនយោបាយ"[37] គឺជាបទប្បញ្ញត្តិមួយក្នុងចំណោមបទនានា ដែលពុំមានលក្ខណៈច្បាស់លាស់ បង្កគ្រោះថ្នាក់ដល់សេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន។[38]

បន្ថែមពីលើនេះទៅទៀត បុគ្គលទាំងឡាយ អាចប្រឈមមុខជាប់ពន្ធធានាគារពី៦ខែ ឬពិន័យជាប្រាក់ពី១លានរៀល រហូតដល់១០លានរៀល ស្របតាមច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០ ប្រសិនបើពួកគេ បង្កើត "សំណួរដែលគ្មានប្រយោជន៍" មកកាន់អង្គភាពប្រឆាំងអំពើពុករលួយ ឬទៅកាន់តុលាការ។ មាត្រា៤១ចែងថា នឹងជាបទល្មើសព្រហ្មទណ្ឌ ប្រសិនបើ "បណ្តឹងបរិហាកេរ្តិ៍ ឬការផ្សព្វផ្សាយព័ត៌មានមិនពិត ដែលនាំឲ្យមានសំណួរដែលគ្មានប្រយោជន៍"។ នេះជាបទប្បញ្ញត្តិដ៏គ្រោះថ្នាក់ និងមានភាពស្រពេចស្រពិល ដែលញុាំងឲ្យមានភាពភ័យខ្លាចចំពោះសាក្សីដែលរាយការណ៍ពីអំពើពុករលួយ។ មាត្រាមួយនេះ ធ្វើឲ្យមោឃៈនូវអនុភាពនៃច្បាប់ទាំងមូល។

---

[33] គណៈកម្មាធិការសិទ្ធិមនុស្ស, បទអត្ថាធិប្បាយទូទៅលេខ៣៤ កិច្ចប្រជុំលើកទី១០២ នៅទីក្រុងហ្សឺណែវ ថ្ងៃ ទី១១ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ (គគពរ/គ/ធក/៣៤) កថាខ័ណ្ឌទី៣៨ ។ ៖<http://www2.ohchr.org/english/bodies/hrc/docs/gc34.pdf>

[34] ម.ស.ម.ក 'ច្បាប់ស្តីពីការជួបជុំដោយសន្តិវិធី' សលាកប័ត្រព័ត៌មាន(ខែសីហា ឆ្នាំ២០១២) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=7&id=5>

[35] រួមទាំងការធានា "សេរីភាពសារព័ត៌មាន" និង "សេរីភាពនៃការបោះពុម្ពផ្សាយ"(មាត្រា១) ការធានា ដែលប្រភពត្រូវបានការពារ(មាត្រា២) ការធានា ប្រឆាំងនឹង "ការត្រួតពិនិត្យមុនការបោះពុម្ពផ្សាយ" (មាត្រា៣) និងធានាថា ការបោះពុម្ពផ្សាយព័ត៌មានផ្លូវការមិនអាចត្រូវបានពិន័យប្រសិនបើការបោះពុម្ពផ្សាយនោះពិតត្រឹមត្រូវ ឬអត្ថបទសង្ខេបនៃរឿងពិត (មាត្រា៤)។

[36] អង្គការមាត្រា១៩ ' អនុស្សរណៈ ស្តីពីច្បាប់សារព័ត៌មានកម្ពុជា(ខែតុលា ឆ្នាំ២០០៤)៥ ៖ <www.article19.org/data/files/pdfs/analysis/cambodia-press-law-oct-2004.pdf

[37] ដូចខាងលើ

[38] ម.ស.ម.ក ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥(ច្បាប់សារព័ត៌មាន)(សលាកប័ត្រ) (ខែកញ្ញា ឆ្នាំ២០១១) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=11&id=5

សេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ច.ស.អ.ម.រ) ដ៏ចម្រូងចម្រាស់បានបណ្តាលឲ្យមានការជំទាស់ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល (អ.ស.ស) អង្គការអន្តរជាតិ និងម្ចាស់ជំនួយផ្សេងៗ ក្នុងឆ្នាំ២០១១ ពេលដែលសេចក្តីព្រាងចំនួនបួនលើកត្រូវបានធ្វើឡើង ដែលសេចក្តីព្រាងទាំងនោះមិនបានយកនូវផ្នែកជាច្រើននៃអនុសាសន៍របស់អង្គការសង្គមស៊ីវិលមកពិចារណានោះទេ ។ សេចក្តីព្រាងច្បាប់នេះ បានគំរាមដើម្បីរឹតត្បិតដ៏ធ្ងន់ធ្ងរលើសេរីភាពបញ្ចេញមតិរបស់អង្គការសង្គមស៊ីវិល។ ការរិះគន់សំខាន់មកលើសេចក្តីព្រាងច្បាប់ទីបួន និងជាសេចក្តីព្រាងច្បាប់ដ៏ថ្មីបំផុត នៅត្រង់លក្ខខណ្ឌនៃការចុះបញ្ជីដែលមានលក្ខណៈស្មុគស្មាញ និងធ្ងន់ធ្ងរ និងការគ្រប់គ្រងដែល ច.ស.អ.ម.រ ផ្តល់ឲ្យទៅរដ្ឋាភិបាលលើអង្គការសង្គមស៊ីវិលតាមរយៈលទ្ធភាពដែលអាចរំលាយអង្គការទាំងនោះដោយសារតែការរំលោភបំពានជាក់លាក់ណាមួយ។ [39] ច.ស.អ.ម.រ បច្ចុប្បន្ននេះត្រូវបានពន្យារពេលពិនិត្យពិចារណា តែទោះជាយ៉ាងណាក្តី ឧទាហរណ៍ពីរបៀបដែលច្បាប់នេះអាចត្រូវបានប្រើប្រាស់ដើម្បីបំបិទសំឡេងអង្គការមិនមែនរដ្ឋាភិបាល បានកើតឡើងមុន ការអនុម័តលើច្បាប់នេះ ដូចមានបង្ហាញខាងក្រោមនេះ ៖

## បំបិទសំឡេងតាមរយៈប្រើប្រាស់ប្រព័ន្ធតុលាការពុករលួយ

ការរំលោភបំពានដែលកាន់តែខ្លាំងមកលើសេរីភាពបញ្ចេញមតិក្នុងប្រទេសកម្ពុជាគឺដោយសារតែច្បាប់នោះបានញាំញីជាមួយនឹងការរឹតត្បិតយ៉ាងខ្លាំងលើសិទ្ធិសេរីភាពបញ្ចេញមតិ និងមានបទប្បញ្ញត្តិស្រពេចស្រពិលមួយចំនួន ដែលបើកចំហឲ្យមានការរំលោភបំពានលើសិទ្ធសេរីភាព នៅពេលត្រូវបានអនុវត្តដោយតុលាការមួយដែលគេដឹងឮជាទូទៅថាស្ថិតនៅក្រោមឥទ្ធិពលអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល។[40]

ការឃាយី និងបំភិតបំភ័យតាមប្រព័ន្ធតុលាការ ត្រូវគេប្រើជាញឹកញាប់ក្នុងប្រទេសកម្ពុជា ដើម្បីបំបិទសេរីភាពបញ្ចេញមតិរបស់អ្នកសារព័ត៌មាន អ្នកនយោបាយបក្សប្រឆាំង សកម្មជនសិទ្ធិមនុស្ស បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលទាំងឡាយណាដែលមាននិន្នាការប្រឆាំង។ ករណីលោក ម៉ម សូណង់ដូ ដែលបានពិពណ៌នាយ៉ាងសង្ខេបនៅខាងលើនោះ លោកគឺជាអ្នកមានកិត្តិសព្ទល្បីល្បាញខាងផ្សាយព័ត៌មានឯករាជ្យ និង ការរិះគន់មិនញញើតលើគោលនយោបាយរបស់រដ្ឋាភិបាល ជាឧទាហរណ៍ច្បាស់មួយនៃមធ្យោបាយនេះ។[41] អ្នកនយោបាយបក្សប្រឆាំងជាច្រើនរូប បានត្រូវដកហូតអភ័យឯកសិទ្ធិសភាចំពោះការរិះគន់លើគណបក្សកាន់អំណាច។ លោកស្រី មូរ

---

[39] ម.ស.ម.ក 'ច.ស.អ.ម.រ' ការវិភាគលើសេចក្តីព្រាងច្បាប់លើកទី៤ (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១១) ៖ <http://sithi.org/temp.php?url=media_view2.php&mid=5081>

[40] គណៈកម្មាធិការសិទ្ធិមនុស្សអាស៊ាន ' កម្ពុជា៖ ឯករាជ្យភាពផ្នែកប្រព័ន្ធតុលាការ គឺជាគន្លឹះដើម្បីកាត់បន្ថយបណ្តឹងបរិហារប្រឆាំងការរិះគន់ និងប្រកាន់ភ្ជាប់នូវសេរីភាពបញ្ចេញមតិ' (ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ២០០៩)

[41] សម្រាប់ព័ត៌មានបន្ថែមលើសំណុំរឿងលោកម៉ម សូណង់ដូ, សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក (ខែសីហាឆ្នាំ២០១២) ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=20&id=5.

សុខហួរ សមាជិកសភាមកពីគណបក្សសម រង្ស៊ី ជាគណបក្សជំទាស់ធំជាងគេ ដែលថ្មីៗនេះបានរួមបញ្ចូលគ្នាជាមួយគណបក្សសិទ្ធិមនុស្ស ដើម្បីបង្កើតជា គណបក្សសង្គ្រោះជាតិកម្ពុជានោះ លោកស្រីបាននិយាយមិនសំចៃលើបញ្ហាសិទ្ធិមនុស្សនៅទូទាំងប្រទេសកម្ពុជា ជាលទ្ធផលលោកស្រីត្រូវបានដកហូតអភ័យឯកសិទ្ធិសភាក្នុងឆ្នាំ២០០៩ បន្ទាប់ពីលោកស្រីបានដាក់ពាក្យប្តឹងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីបទអត្ថាធិប្បាយមើលងាយទៅលើរូបលោកស្រី។ លោកស្រីចាញ់ក្តី ដោយលោកហ៊ុន សែនបានប្តឹងបកមកវិញ។ លោកស្រីមូរ សុខហួរ មានពិរុទ្ធពីបទបរិហាកេរ្តិ៍ និងដែលតម្រូវឲ្យលោកស្រីបង់ប្រាក់ពិន័យ។[42] ចុងបញ្ចប់ លោកស្រីត្រូវបានផ្តល់អភ័យឯកសិទ្ធិសភាមកវិញ បន្ទាប់ពីមានយុទ្ធនាការជាច្រើន ក៏ប៉ុន្តែ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ មានពាក្យបណ្តឹងមួយផ្សេងទៀតកំពុងតែព្យួរទុក លើករណីជាប់ទាក់ទងនឹងលោកស្រី ដោយចោទថា លោកស្រីមានការពាក់ព័ន្ធក្នុងការដោះលែងសកម្មជនដីធ្លី ពីមណ្ឌលឃុំឃាំងក្នុងទីក្រុងភ្នំពេញ ដែលសកម្មជនទាំងនោះកំពុងតែត្រូវបានឃុំឃាំងដោយពុំមានការចោទប្រកាន់។ ស្ត្រី និងកុមារចំនួន១៨រូប មកពីសហគមន៍បុរីកីឡា ត្រូវបានចាប់ខ្លួនខណៈពេលកំពុងធ្វើបាតុកម្មប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ ហើយបានឃុំខ្លួននៅមណ្ឌលកែប្រែព្រៃស្ពឺ ក្នុងទីក្រុងភ្នំពេញ។ ពួកគេ បានគេចខ្លួនតាមរបងមណ្ឌលឃុំឃាំងអំឡុងពេលទស្សនៈកិច្ចរបស់លោកស្រី មូរ សុខហួរ កាលពីខែមករា ឆ្នាំ២០១២ ក្នុងពេលដែលលោកស្រីកំពុងតែចរចាគ្នាពីការដោះលែងអ្នកទាំងនោះ។[43]

ស្ថានភាពសិទ្ធិដីធ្លីនៅកម្ពុជា គឺកាន់តែអស់សង្ឃឹមកាន់តែខ្លាំងឡើង ហើយជាលទ្ធផល ករណីសេរីភាពបញ្ចេញមតិជាច្រើន ទាក់ទិនការរំលោភសិទ្ធិរបស់សកម្មជន ដែលពួកគេធ្វើបាតុកម្មដោយសន្តិវិធីដោយគ្រាន់តែសម្តែងឡើងពីទស្សនៈរបស់ខ្លួន។ ឧទាហរណ៍ជាក់ស្តែងមួយនៃការឃាយីផ្នែកប្រព័ន្ធតុលាការលើសកម្មជនការពារសិទ្ធដីធ្លីទាក់ទងនឹងជម្លោះដីធ្លីដ៏អូសបន្លាយមួយក្នុងទីក្រុងភ្នំពេញរវាងអ្នកភូមិបឹងកក់ ជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍ–ន៍ស៊ូកាគុជាក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនកម្មសិទ្ធិរបស់សមាជិកព្រឹទ្ធសភាគណបក្សប្រជាជនគឺ លោក ឡៅ ម៉េងឃិន។ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ស្ត្រី១៣រូប តំណាងឲ្យសហគមន៍បឹងកក់ត្រូវបានចោទប្រកាន់ ធ្វើសវនាការ និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារក្នុងរយៈពេលតែមួយថ្ងៃ។ ទីបំផុត ពួកគាត់ត្រូវបានដោះលែងមកវិញ តាមសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ដោយបន្ថយរយៈពេលទទួលទោសពួកគាត់មកត្រឹមពេលដែលពួកគាត់បានជាប់ពន្ធនាគាររួចហើយ ប៉ុន្តែការចោទប្រកាន់ប្រឆាំងនិងពួកគាត់ត្រូវបានដម្កល់ទុក។[44]

---

[42] ម.ស.ម.ក ‘វិភាគលើយុត្តិធម៌នៃនីតិវិធីតុលាការ កើតចេញពីការផ្តន្ទាទោសលើអ្នកតំណាងរាស្ត្រគឺលោកស្រី មូរ សុខហួរ’ (ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០)៖<www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=10&id=5>

[43] ម.ស.ម.ក ‘ សមាជិកសភាគណបក្សប្រឆាំងនិយាយមិនសំចៃ ប្រឈមការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងញុះញង់’ (សេចក្តីប្រកាសព័ត៌មាន) (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២)៖
<www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=14&id=5>

[44] ម.ស.ម.ក ‘វិភាគផ្លូវច្បាប់លើការចោទប្រកាន់ និងផ្តន្ទាទោសលើស្ត្រីតំណាងសហគមន៍បឹងកក់១៣រូប កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២’(ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១២) អាចស្វែងរកតាម៖
<www.cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=19&id=5>

ការឃាយឃីតាមប្រព័ន្ធតុលាការជារឿយៗ បានត្រូវគេប្រើប្រាស់ដើម្បីបំភិតបំភ័យ និងបំបិទសំឡេងអ្នកធ្វើការផ្នែកសិទ្ធិមនុស្ស។ ទោះបីជាសេចក្តីព្រាង ច.ស.អ.ម.រ បានត្រូវពន្យារពេលពិនិត្យពិចារណាក៏ដោយ ក៏ចរិតរបស់ច្បាប់ និងបទប្បញ្ញត្តិនានារបស់ច្បាប់នេះ មានលក្ខណៈរឹតត្បិត ហើយនៅតែធ្វើឲ្យមានការភ័យខ្លាចដល់អង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលិករបស់អង្គការទាំងនោះ ដោយសារតែរដ្ឋាភិបាលប៉ុនប៉ងបំបិទសំឡេងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអាចគ្រប់គ្រងលើបុគ្គលិកអង្គការទាំងនោះ។ ឧទាហរណ៍មួយដែលបានកើតឡើងកាលពីឆ្នាំ២០១២ គឺករណីរបស់ លោក ចាន់ សុវ៉េត មន្រ្តីស៊ើបអង្កេតជាន់ខ្ពស់នៅសមាគមការពារសិទ្ធិមនុស្សអាដហុក ត្រូវបានសាលាដំបូងក្រុងភ្នំពេញកោះហៅឲ្យចូលខ្លួនឆ្លើយបំភ្លឺកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២ ជាប់ពាក់ព័ន្ធជំនួយផ្នែកមនុស្សធម៌ ដែលរូបលោកបានជួយដល់សកម្មជនការពារសិទ្ធិដីធ្លីដែលបានមកកាន់ការិយាល័យកណ្តាលរបស់សមាគមការពារសិទ្ធិមនុស្សអាដហុកនៅរាជធានីភ្នំពេញ។[45]សកម្មជនដីធ្លីដែលប៉ូលីសតាមចាប់ខ្លួននៅពេលនោះ គឺមិនស្គាល់គ្នាជាមួយលោកចាន់ សុវ៉េត នោះទេ។ ការសាកសួរលើរូបលោកចាន់ សុវ៉េត ត្រូវពន្យារពេល ហើយក្រោយមកលោកបានចូលខ្លួនឆ្លើយបំភ្លឺនៅចំពោះមុខចៅក្រមតុលាការក្រុងភ្នំពេញ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២។ លោកមិនត្រូវបានចាប់ខ្លួននោះទេ ហើយការចោទប្រកាន់លើរូបលោកត្រូវទម្លាក់ចោល នៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣។[46] មានការជឿជាក់ជាទូទៅថា តុលាការត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយក្នុងករណីនេះ ដើម្បីបំបិទសំឡេងលោកចាន់ សុវ៉េត និងរារាំងកិច្ចការផ្នែកសិទ្ធិមនុស្សរបស់លោក។ មានឧទាហរណ៍ដទៃទៀតចំពោះការប៉ុនប៉ងបំបិទសំឡេងអង្គការមិនមែនរដ្ឋាភិបាល និងបុគ្គលិកអង្គការទាំងនោះ រួមទាំងមានការផ្អាកសកម្មភាពរបស់អង្គការសមាគមធាងត្នោតកាលពីខែសីហា ឆ្នាំ២០១១ ដោយចោទប្រកាន់ថា មានការពាក់ព័ន្ធទៅនឹងការរិះគន់លើការចាប់យកដីធ្លី និងការបណ្តេញចេញដោយ បង្ខំ[47] ហើយនាពេលថ្មីៗនេះ ករណីរបស់លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក ត្រូវបានកោះហៅឲ្យចូលខ្លួនឆ្លើយបំភ្លឺនៅតុលាការខេត្តរតនៈគិរី ដើម្បីសាកសួរពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ។ នៅក្នុងករណីរបស់លោក អ៊ូ វីរៈ នេះ ពុំមានព័ត៌មានណាមួយជាក់លាក់ឡើយ គឺមានការសន្មត់ថា ពាក្យបណ្តឹងនោះ បានធ្វើឡើងដោយមេឃុំគណបក្សប្រជាជនកម្ពុជា ទាក់ទងទៅនឹងបាតុកម្មមួយកាលពីឆ្នាំ២០០៩ ដោយក្រុមអ្នកភូមិពាក់ព័ន្ធក្នុងជម្លោះដីធ្លីមួយ ជាមួយក្រុមហ៊ុនឯកជន ឌី.អ៊ឹម.គ្រុប រហូតបង្កឲ្យមានហិង្សា។ លោកប៉ែន ប៊ុណ្ណា លោកឆាយ ធី បុគ្គលិករបស់សមាគមអាដហុកប្រចាំខេត្តរតនៈគិរី និងអ្នកសារព័ត៌មាន គឺលោក រដ្ឋា វិសាល ក៏ត្រូវបានកោះហៅផងដែរ។ ការកោះហៅនេះ បង្ហាញឲ្យឃើញការប៉ុនប៉ងមួយចំពោះការបំបិទសេរីភាពបញ្ចេញមតិរបស់បុគ្គ

[45] សូមមើល ម.ស.ម.ក សេចក្តីប្រកាសសិទ្ធិមនុស្ស(ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២) អាចរកបានតាម៖ www.cchrcambodia.org/index_old.php?url=media/media.php&p=alert_detail.php&alid=24&id=5

[46] ‘តុលាការទម្លាក់ចោលការចោទប្រកាន់ចំពោះបុគ្គលិកសិទ្ធិមនុស្សដ៏លេចធ្លោ’ ដឹខេមបូឌាដេលី (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៣) អាចស្វែងរកបានតាម៖ <http://www.cambodiadaily.com/news/court-drops-charge-against-prominent-human-rights-worker-dropped-9806/>

[47] សូមមើល សលាកប័ត្រព័ត៌មាន ស្តីពីការបញ្ឈប់សមាគមធាងត្នោត(ខែកញ្ញា ឆ្នាំ២០១១)៖ www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=13&id=5

លិកសិទ្ធិមនុស្ស ដែលអង្គការរបស់ពួកគេបើកវគ្គបណ្តុះបណ្តាលស្តីសិទ្ធិដីធ្លីនិងការបំបិទសេរីភាពបញ្ចេញមតិមកលើអ្នកសារព័ត៌មានដែលរាយការណ៍ពីជម្លោះដីធ្លីនៅតាមតំបន់។[48] ករណីនេះ ត្រូវបានទម្លាក់ចោលហើយ។[49]

មានឧទាហរណ៍ជាច្រើនចំពោះការឃាយីផ្នែកប្រព័ន្ធតុលាការទៅលើប្រជាពលរដ្ឋកម្ពុជា ដោយសារតែការអនុវត្តន៍សិទ្ធិសេរីភាពនិយាយស្តីរបស់ពួកគាត់ ហើយការឃាយីតាមប្រព័ន្ធតុលាការនេះ ធ្វើឲ្យបុគ្គលដទៃលែងហ៊ាននិយាយ ដោយហេតុនេះ នឹងធ្វើឲ្យលំហសម្រាប់សេរីភាពបញ្ចេញមតិកាន់តែថយចុះ។ ការបង្ក្រាបលើការចែកចាយខិតប័ណ្ណដែលមានខ្លឹមសាររិះគន់លើរាជរដ្ឋាភិបាលកម្ពុជា គឺជាឧទាហរណ៍សំខាន់មួយ៖ ក្នុងអំឡុងឆ្នាំ ២០១១ មានប្រជាពលរដ្ឋកម្ពុជាមួយចំនួន ក្នុងនោះរួមមាន ប្រធានការពារពលករកម្ពុជា និងបុគ្គលបីរូបទៀត ត្រូវបានចាប់ខ្លួន និងបានឃុំខ្លួនពីបទចែកចាយខិត ប័ណ្ណ រិះគន់គោលនយោបាយរបស់រដ្ឋាភិបាលស្តីពីតម្លៃអាហារ និងជម្លោះព្រំដែនជាមួយប្រទេសវៀតណាម នៅក្នុងចំណោមបញ្ហាផ្សេងៗទៀត។ ។[50]

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ដើម្បីឲ្យលទ្ធិប្រជាធិបតេយ្យកើតមានពិតប្រាកដក្នុងប្រទេសកម្ពុជាការរឹតត្បិតដ៏តឹងរឹងលើសេរីភាពបញ្ចេញមតិ ចាំបាច់ត្រូវតែបំបាត់ចោល។ រដ្ឋាភិបាលប្រើប្រាស់មធ្យោបាយជាច្រើន ដូចដែលបានរៀបរាប់ខាងលើនេះ ដើម្បីឃាយីចំពោះបុគ្គលទាំងឡាយដែលហ៊ាននិយាយប្រឆាំង និងបង្អាក់ទឹកចិត្តមិនឲ្យបុគ្គលដទៃទៀតហ៊ាននិយាយ។ ចំពោះការរឹតត្បិតសេរីភាពបញ្ចេញមតិនិងធ្វើការគាបសង្កត់ចំពោះអ្នកដែលបង្ហាញពីនិន្នាការប្រឆាំងរដ្ឋាភិបាលបានធ្វើឲ្យប៉ះពាល់ដល់បទប្បញ្ញត្តិមួយចំនួនក្នុងរដ្ឋធម្មនុញ្ញ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលលើកកម្ពស់ និងការពារសិទ្ធិទាំងនេះ។

ការត្រួតពិនិត្យលើបណ្តាញផ្សព្វផ្សាយ៖ ប្រព័ន្ធផ្សព្វផ្សាយគឺជាអាយុជីវិតរបស់សេរីភាព បញ្ចេញមតិក្នុងរបបលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែបានត្រូវបំបិទ ដោយការផ្តន្ទាទោសលើអ្នកសារព័ត៌មាន អំពើហិង្សា ការបិទសារព័ត៌មាន ការរឹតត្បិតលើអាជ្ញាប័ណ្ណទូរទស្សន៍ វិទ្យុ និងបង្កឲ្យមានបរិយាកាសនៃការត្រួតពិនិត្យខ្លួនឯង។ ដូច្នេះ ម.ស.ម.ក ផ្តល់នូវអនុសាសន៍ដូចខាងក្រោម ៖

- **សារព័ត៌មាន ទូរទស្សន៍ និងវិទ្យុ គួរតែអាចរាយការណ៍ដោយសេរី មិនលម្អៀង នឹងជំរុញឲ្យមានកិច្ចពិភាក្សាប្រកបដោយផ្លែផ្កា។**

---

[48] ម.ស.ម.ក 'បុគ្គលិកសិទ្ធិមនុស្សពនាក់ និងអ្នកកាសែតមួយរូបត្រូវដីកាកោះឲ្យចូលខ្លួនឆ្លើយបំភ្លឺនៅតុលាការខេត្តរតនៈគិរី ពីបទញុះញង់' (សេចក្តីថ្លែងការណ៍) (ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២) ៖ www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=295&id=5&lang=eng

[49] 'ព្រះរាជអាជ្ញាប្រាប់តុលាការអោយទម្លាក់ចោលការចោទប្រកាន់លើសំណុំរឿងជម្លោះដីធ្លី' ភ្នំពេញប៉ុស្តិ៍(ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣) ៖ <http://www.phnompenhpost.com/2013012360922/National/prosecutors-tell-court-to-drop-charge-in-land-dispute-case.html>

[50] សូមមើល សលាកប័ត្រព័ត៌មានទី៣ "សេរីភាពជាមូលដ្ឋាន៖ ការចែកចាយខិត្តប័ណ្ណ" (សាលាកប័ត្រព័ត៌មាន) (ខែសីហា ឆ្នាំ២០១១) ៖ <www.cchrcambodia.org/index_old.php?url=media/media.php&p=factsheet_detail.php&fsid=8&id=5>

- ការរិះគន់លើរដ្ឋាភិបាល លើគោលនយោបាយ និងស្ថាប័ននានារបស់រដ្ឋាភិបាល មិនគួរជាបទល្មើស ចែងក្នុងច្បាប់ និងគួរត្រូវបានលើកទឹកចិត្ត ដើម្បីឲ្យមានភាពយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យដ៏មានប្រសិទ្ធិភាព និងរីកធំធាត់។

អ៊ីនធើណែតគួរតែត្រូវបានកំណត់ថា គឺជាទ្រង់ទ្រាយដ៏សេរីនៃប្រព័ន្ធផ្សព្វផ្សាយ ដូច្នេះហើយ សំណើអនុម័តច្បាប់គ្រប់គ្រងអ៊ីនធើណែតដែលមានចរិតរឹតត្បិតសេរីភាពនោះ គួរមិនត្រូវបានបន្តទៀតទេ។

អំពើហិង្សា និងនិទណ្ឌភាព៖ ការប្រើអំពើហិង្សា របស់កងកម្លាំងរដ្ឋាភិបាលមានការកើនឡើង ដើម្បីបង្ក្រាបបាតុកម្ម និងដើម្បីគំរាមកំហែងដល់បុគ្គលទាំងឡាយណាដែលហ៊ាននិយាយ។ លទ្ធផលគឺ ពុំមានគ្រឿងលើកទឹកចិត្តសម្រាប់ការបញ្ឈប់អំពើហិង្សា ហើយព្រមទាំងមានភាពភ័យខ្លាច ការត្រួតពិនិត្យខ្លួនឯង និងភាពអស់ជំនឿលើអាជ្ញាធរគឺកាន់តែផុសផុលឡើងពីសំណាក់ប្រជាពលរដ្ឋកម្ពុជា។ ដោយហេតុនេះ ម.ស.ម.ក ផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- មន្ត្រីអនុវត្តច្បាប់គួរតែត្រូវបានបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវស្តីពីសិទ្ធិមនុស្ស និងគោលការណ៍អន្តរជាតិអំពីសមាមាត្រចំពោះការប្រើប្រាស់កងកម្លាំង មុនពេលពួកគេត្រូវបានអនុញ្ញាតឲ្យ អនុវត្តទួនាទីរបស់ខ្លួន
- និទណ្ឌភាពត្រូវបានដោះស្រាយ ដូចជាករណីប្រើហិង្សាប្រឆាំងអ្នកការពារសិទ្ធិមនុស្ស សកម្មជនសិទ្ធិមនុស្ស អ្នកតវ៉ានានា។ល។ ត្រូវតែស៊ើបអង្កេតឲ្យបានគ្រប់គ្រាន់ និងឯករាជ្យហើយត្រូវផ្តន្ទាទោសចំពោះជនដៃដល់។

ការយាយីតាមផ្លូវច្បាប់ និងតាមប្រព័ន្ធតុលាការ៖ ប៉ុន្មានឆ្នាំចុងក្រោយនេះ ច្បាប់នៅតែបានបន្តក្នុងការរឹតត្បិតសេរីភាពបញ្ចេញមតិ។ បទប្បញ្ញត្តិគួរឲ្យព្រួយបារម្ភជាច្រើនដែលមាននៅក្នុងច្បាប់បច្ចុប្បន្ននេះ បណ្តាលឲ្យបុគ្គលដែលនិយាយប្រឆាំងងាយទទួលរងការចោទប្រកាន់នានាពីតុលាការ។ បំពាក់ដោយឧបករណ៍ច្បាប់ទាំងនេះ តុលាការពុករលួយ ត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយដើម្បីបំបិទសំឡេងប្រឆាំងកាន់តែច្រើនឡើង។ ដោយហេតុនេះ ម.ស.ម.ក ផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

- មាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ច្បាប់ស្តីពីការជួបជុំដោយសន្តិវិធី ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ និងច្បាប់ប្រឆាំងអំពើពុករលួយ ដូចគូសបញ្ជាក់ខាងលើ គួរតែត្រូវបានធ្វើវិសោធនកម្មដើម្បីធានាភាពស៊ីសង្វាក់គ្នាជាមួយកាតព្វកិច្ចរបស់រដ្ឋាភិបាល ក្នុងការការពារនិងលើកស្ទួយសេរីភាពបញ្ចេញមតិ
- មាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលចាត់ទុកថា ការរិះគន់លើស្ថាប័ននានារបស់រដ្ឋាភិបាល និងសេចក្តីសម្រេចតុលាការជាបទល្មើសព្រហ្មទណ្ឌ គឺកំពុងតែធ្វើឲ្យមានការព្រួយបារម្ភយ៉ាងពិសេស ហើយគួរតែត្រូវបានលុបចោល
- ការយាយីផ្នែកប្រព័ន្ធតុលាការគ្រប់រូបភាពទៅលើអ្នកការពារសិទ្ធិមនុស្ស បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកនយោបាយ មេធាវី និងបុគ្គលទូទៅដោយគ្រាន់តែអ្នកទាំងនោះបញ្ចេញទស្សនៈទិតៀនលើទង្វើរបស់រដ្ឋាភិបាលនិងគោលនយោបាយរដ្ឋាភិបាល ត្រូវតែបញ្ឈប់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ ប្រធាន ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥(០)១២ ៤០ ៤០ ៥១ ឬអ៊ីម៉េល ouvirak@cchrcambodia.org ឬលោក រ៉ូប៊ឺត ហ្វីនច៍ ទីប្រឹក្សាជាន់ខ្ពស់ តាមរយៈទូរសព្ទ +៨៥៥(០) ៧៨ ៨០ ៩៩ ៦០ ឬអ៊ីម៉េល robert.finch@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
BY NC SA

# ឧបសម្ព័ន្ធទី ៣
# របាយការណ៍របស់អ្នកនាំពាក្យ
# ពិសេសអង្គការសហប្រជាជាតិ
# ទាក់ទងនឹងការព្រួយបារម្ភចំពោះ
# បញ្ហាឯករាជភាពស្ថាប័ន
# សារព័ត៌មានប្រទេសជប៉ុន

## 日本：国連の人権専門家、報道の独立性に対する重大な脅威を警告

2016 年 04 月 19 日

東京／ジュネーブ（2016 年 4 月 19 日）― 「意見及び表現の自由」の調査を担当する国連特別報告者ディビッド・ケイ氏が火曜日（4 月 19 日）、日本政府に対し、メディアの独立性保護と国民の知る権利促進のための対策を緊急に講じるよう要請しました。

「日本は、報道の自由を明確に保護した憲法に、当然の誇りを持っています。それにもかかわらず、報道の独立性は重大な脅威に直面しています」と、1 週間の日本滞在を終えたケイ氏は述べました。

「脆弱な法的保護、新たに採択された『特定秘密保護法』、そして政府による『中立性』と『公平性』への絶え間ない圧力が、高いレベルの自己検閲を生み出しているように見えます」とケイ氏は言います。「こうした圧力は意図した効果をもたらします。それはメディア自体が、記者クラブ制度の排他性に依存し、独立の基本原則を擁護するはずの幅広い職業的な組合組織を欠いているからです」

「多くのジャーナリストが、自身の生活を守るために匿名を条件に私との面会に応じてくれましたが、国民的関心事の扱いの微妙な部分を避けなければならない圧力の存在を浮かび上がらせました。彼らの多くが、有力政治家からの間接的な圧力によって、仕事から外され、沈黙を強いられたと訴えています。これほどの強固な民主主義の基盤のある国では、そのような介入には抵抗して介入を防ぐべきです」

ケイ氏によれば、1950 年に制定され政府に放送メディアを規制する直接的な権限を与えた『放送法』は、4 条において、ジャーナリストの職業的義務と、放送免許の取り消しを行う政府権限を混同しています。「政府は放送法 4 条を廃止し、メディア規制から手を引くべきです」と同氏は述べました。

こうした環境下で『特定秘密保護法』は、実施の初期段階ながら、重大な社会的関心事のメディア報道を委縮させる効果を生んでいるとケイ氏は述べています。例えば、内部告発者を保護する体制が弱いことは、情報源の枯渇につながり、ジャーナリスト自身も情報入手によって処罰されることを恐れるようになるでしょう。こうした恐れを持つことで、特に影響を受ける可能性があるのは、原子力産業の未来、災害対応、政府の国家安全保障政策など、日本の今日的な公共の関心事についての報道だとしています。

ケイ氏によれば、政府による圧力はさらに、第二次世界大戦中の「従軍慰安婦」問題など、非常に重要性の高い問題の議論も妨げています。複数の国際的な人権メカニズムがこの問題への対処を繰り返し日本に要求していることに触れつつ、ケイ氏は、日本の過去についての議論を制限しようとする試みに対して不満を表明しました。

「従軍慰安婦への言及は、中学校で必修科目である日本史の教科書から削除されつつあります」と、このことを知ったケイ氏は述べました。「第二次世界大戦中に犯した罪の現実を教科書でどう扱うか

について政府が介入することは、国民の知る権利を脅かし、国民が日本の過去の問題に取り組み理解する力を低下させます」

ケイ氏は国会を訪れ、法務委員会の委員と面会し、ヘイトスピーチの法規制に関する継続中の議論への関心を示しました。「日本は、広範囲に適用できる差別禁止法を採択しなければなりません。ヘイトスピーチに対する答えは、まず、差別行為を禁止する法律を制定することです。そうした法律が整えば、憎しみに満ちた表現に対する政府の広範な対応が、憎悪に反対する教育的かつ公の声明などの形で、差別との闘いに真の影響をもたらすようになるでしょう」とケイ氏は述べています。

さらにケイ氏は「ネット上の自由の分野で、日本がいかに重要なモデルを示しているかについても強調したいと思います」と述べました。「デジタルの自由への政府の介入度合が極めて低いことは、表現の自由に対する政府のコミットメントの表れです。政府が盗聴に関する法律やサイバーセキュリティへの新たな取り組みを検討する際、こうした自由の精神、通信セキュリティ、オンライン上のイノベーションが規制の取り組みの最前線でも保たれることを願っています」

ディビッド・ケイ氏は、日本政府の招きにより 4 月 12 日から 19 日まで日本に滞在し、国のさまざまな当局者と会談しました。また、NGO、ジャーナリスト、民間メディアの団体、弁護士とも議論を交わしました。ケイ氏は特別報告者として、今回の訪日による主な調査結果に関する報告書を作成し、2017 年に国連人権理事会に提出する予定です。

## Japan: UN rights expert warns of serious threats to the independence of the press

2016.04.19

TOKYO / GENEVA (19 April 2016) – The United Nations Special Rapporteur on the right to freedom of opinion and expression, David Kaye, on Tuesday called upon the Japanese Government to take urgent steps to protect the independence of the media and promote the public's right of access to information.

"Japan has well-earned pride in a Constitution that expressly protects the freedom of the press. Yet the independence of the press is facing serious threats," said Kaye after a week-long visit to the country.

"Weak legal protection, the newly adopted Specially Designated Secrets Act, and persistent Government pressure for 'neutrality' and 'fairness' appear to be producing high levels of self-censorship," Kaye said. "Such pressure has its intended effect because the media itself depends upon the exclusivity of the press club system and lacks a broad professional union that could advocate for basic principles of independence."

"Numerous journalists, many agreeing to meet with me only on condition of anonymity to protect their livelihoods, highlighted the pressure to avoid sensitive areas of public interest. Many claimed to have been sidelined or silenced following indirect pressure from leading politicians. A country with such strong democratic foundations should resist and protect against such interference."

According to Mr. Kaye, the Broadcast Act, adopted in 1950 to give the Government direct authority to regulate the broadcast media, confuses the professional obligations of journalists, in Article 4, with the Government's power to suspend broadcasting licenses. "The Government should repeal Article 4 and get itself out of the media-regulation business," he said.

Mr. Kaye noted that, in this environment, the Specially Designated Secrets Act, still in its early stages of implementation, is likely to have a chilling effect on the media's coverage of matters of serious public concern. The weakness of whistleblower protection, for example, could lead to information sources drying up, while journalists themselves may fear punishment for their work to gain access to information. Such fears may have particular impact on areas of major contemporary public interest in Japan, such as the future of the

nuclear power industry, disaster response, and the national security policies adopted by the Government.

According to the Special Rapporteur, Government pressure also undermines debate on issues of crucial importance, such as the use of “comfort women” during the Second World War. While noting that international human rights mechanisms have repeatedly urged Japan to address the issue, Mr. Kaye voiced his frustration about the attempts to limit debate over the country’s past.

“References to ‘comfort women’ are being edited out of textbooks in junior high schools, where Japanese history is compulsory,” Kaye found. “Government interference with how textbooks treat the reality of the crimes committed during the Second World War undermines the public’s right to know and its ability to grapple with and understand its past.”

Mr. Kaye visited the Diet, where he met the Committee on Judicial Affairs and expressed his interest in ongoing discussions on hate speech and surveillance legislation. “Japan must adopt a broadly applicable anti-discrimination law,” he said. “The first answer to hate speech is to have a law that prohibits acts of discrimination. Once that is in place, broad Government action against hateful expression — such as educational and public statements against hatred — can have a real impact on the fight against discrimination.”

“I want to emphasize as well how important a model Japan presents in the area of freedom on the Internet,” Kaye added. “The very low level of Government interference with digital freedoms illustrates the Government’s commitment to freedom of expression. As the Government considers legislation related to wiretaps and new approaches to cybersecurity, I hope that this spirit of freedom, communication security and innovation online is kept at the forefront of regulatory efforts.”

David Kaye visited Japan at the invitation of the Government and met with various national authorities. He also held discussions with non-governmental organizations, journalists, private media associations and lawyers. The Special Rapporteur will prepare a report to be presented in 2017 at the Human Rights Council on the main findings of his visit.

(*) Check the Special Rapporteur’s full end-of-mission statement

ENDS

David Kaye (USA) was appointed as Special Rapporteur on the promotion and protection of the right to freedom of opinion and expression in August 2014 by the United Nations Human

Rights Council. Learn more, log on to:
http://www.ohchr.org/EN/Issues/FreedomOpinion/Pages/OpinionIndex.aspx

The Special Rapporteurs are part of what is known as the Special Procedures of the Human Rights Council. Special Procedures, the largest body of independent experts in the UN Human Rights system, is the general name of the Council's independent fact-finding and monitoring mechanisms. Special Procedures mandate-holders are independent human rights experts appointed by the Human Rights Council to address either specific country situations or thematic issues in all parts of the world. They are not UN staff and are independent from any government or organization. They serve in their individual capacity and do not receive a salary for their work.